ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ កម្មវិធីសិក្សាស្រាវជ្រាវ : ជនជាតិភាគតិច និងកេរដំណែលពីរបបខ្មែរក្រហម

◆ ការផ្ដល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ ៨៩ ខែឧសភា ឆ្នាំ២០០៧

# ស្វែងរកការពិត

លេខ៨៩ ខែឧសភា ឆ្នាំ២០០៧


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រ ៖ ជនជាតិភាគតិច និងកេរដំណែលពីរបបខ្មែរក្រហម ............ ១

**ផ្នែកឯកសារ**

◆ ភៀសខ្លួនពីមណ្ឌលគិរីទៅជ្រកកោននៅប្រទេសវៀតណាម .................... ៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម .................... ៩

◆ ដំណើរចុងក្រោយឆ្លងកាត់បឹងទន្លេសាប .................... ១៧

◆ រកឃើញផ្នូរសាកសពជនរងគ្រោះនៅភូមិស្រែលាវ .................... ១៩

◆ ជីវិតដូចនៅក្នុងឋាននរក .................... ២៣

◆ អតីតនារីពេទ្យព-១៧ និយាយអំពី អៀង ធីរិទ្ធ .................... ២៦

◆ មិនចង់រំឭក .................... ២៨

◆ ដំណើរចាកចេញពីក្រុងបាត់ដំបង .................... ៣២

◆ យុវជនស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម .................... ៣៤

◆ ធ្វើបដិវត្តន៍ទទួលបានតែការព្រាត់ប្រាស .................... ៣៦

**ផ្នែកច្បាប់**

◆ ការផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ....... ៣៨

**វេទិកាពិភាក្សាសាធារណៈ**

◆ ភាពតក់ស្លុត និងការប៉ះផ្លូវចិត្ត នៅក្នុងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ... ៤៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការអប់រំដែលម្តាយខ្ញុំផ្តល់ឲ្យ .................... ៥៦

◆ លិខិតពីមិត្តអ្នកអាន .................... ៥៨




ជនជាតិស្ទៀង ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម
ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៥



សូ ហ្វារីណា សម្ភាសន៍ជាមួយជនជាតិអ៊ិស្លាមដែលចូលរួមដំណើរ
ទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១៣ម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ** ៖ ដេង ពង្សរ៉ាស៊ី, ឌី ខាំបូលី, គង់ សុកគឿន, ឡុង ដានី, យិន ឆាយ, លី សុខឃាង, សោម ប៊ុនថន, អេឡែន អ៊ុយណាក, ស៊ីវ លាង, អាឡិចសេនដឺ ហ៊ីនតុន, តាត លក្ខិណា, តុង វ៉ា **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ លី សុផល, ណយ សុផារី **អ្នកបកប្រែ** ៖ ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ** ៖ គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ** ៖ រ័ត្ន តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# កម្មវិធីសិក្សាស្រាវជ្រាវ : ជនជាតិភាគតិចនិងកេរដំណែលពីរបបខ្មែរក្រហម

បច្ចុប្បន្នមានសៀវភៅនិងអត្ថបទជាច្រើនសរសេរអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងវាសនានៃក្រុមមនុស្សមួយចំនួនតូច ដែលប្រកាន់គោលជំហរនយោបាយ ជំនឿសាសនាផ្សេងៗគ្នា នៅក្នុងសង្គមកម្ពុជា (តួយ៉ាងដូចជាអាចារ្យ បញ្ញវន្ត ទាហាន និងមន្ត្រីរាជការពីសម័យ លន់ នល់) ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក្រុមជនជាតិភាគតិចទទួលបានការយកចិត្តទុកដាក់តិចតួចបំផុត លើកលែងតែជនជាតិវៀតណាមប៉ុណ្ណោះ ដែលទទួលបានការចាប់អារម្មណ៍គួរឲ្យកត់សម្គាល់ ។ ផ្នែកសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងស្រាយបំភ្លឺអំពីតួនាទីរបស់ជនជាតិភាគតិចនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ការប្រព្រឹត្តនិងឥទ្ធិពលរបស់ជនជាតិភាគតិចចំពោះរដ្ឋាភិបាលអាណត្តិបន្តបន្ទាប់ ។ ក្នុងកម្មវិធីនេះ យើងនឹងកំណត់ថាតើតួនាទីរបស់ជនជាតិភាគតិចក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានឥទ្ធិពលប៉ះពាល់ដល់ស្ថានភាពសង្គមកម្ពុជាបច្ចុប្បន្នដែរឬទេ?



គម្រោងនេះមានគោលបំណងជំរុញឲ្យមានការស្វែងយល់ និងការគោរពគ្នាទៅវិញទៅមកចំពោះជនជាតិភាគតិចដទៃទៀតនៅកម្ពុជា ដើម្បីឲ្យមានសង្គមប្រជាធិបតេយ្យដ៏ពេញលេញមួយ ។ តាមរយៈការបង្ហាញអំពីទស្សនៈមិនសមស្របចំពោះជនជាតិភាគតិច ពីការឈឺចាប់របស់ជនជាតិភាគតិចក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ (មិនខុសគ្នាពីជនជាតិខ្មែរ) និងពីមូលហេតុនាំឲ្យក្រុមជនជាតិភាគតិចមួយចំនួនត្រូវបានផ្តាច់ខ្លួនចេញដោយមូលហេតុវិសមភាពសេដ្ឋកិច្ច ហើយអាចឈានទៅដល់ការប៉ុនប៉ងផ្នែកនយោបាយ យើងសង្ឃឹមថា នឹងអាចលើកទឹកចិត្តទាំងសិស្សានុសិស្សនិងប្រជាជនទាំងឡាយផ្តល់ការគោរពចំពោះសមាសភាពដទៃដើម្បីទទួលបានសង្គមមួយដែលប្រជាជនគ្រប់ជាតិសាសន៍ទទួលបាននូវការគោរពស្មើៗគ្នាចំពោះមុខច្បាប់ ។

នៅក្នុងអំឡុងរបបសង្គមរាស្ត្រនិយម (ពីឆ្នាំ១៩៥៣ដល់១៩៧០) សម្តេច ព្រះនរោត្តម សីហនុ ស្នើសុំឲ្យហៅសហគមន៍អ៊ីស្លាមនៅកម្ពុជាថា "ខ្មែរអ៊ីស្លាម" ។ អ្នកខ្លះយល់ឃើញថា នេះជាការប៉ុនប៉ងចង់បញ្ចូលសហគមន៍អ៊ីស្លាមទៅក្នុងវប្បធម៌ជាតិរួមមួយ ។ រីឯក្នុងរបបលន់នល់ (១៩៧០-១៩៧៥) សម្តែងការអនុគ្រោះចំពោះជនជាតិចាម (សហគមន៍ចាម ជាសហគមន៍មានឈ្មោះតាំងពីបូរាណកាល) ប៉ុន្តែរបបនេះបែរជាសម្លាប់ និងបណ្តេញជនជាតិភាគតិចវៀតណាមដោយឥតធម៌មេត្តាទៅវិញ ។ មិនត្រឹមតែប៉ុណ្ណោះ ជនជាតិវៀតណាម ត្រូវបានចាត់ទុកជាសត្រូវរបស់រដ្ឋ ។

ជនជាតិវៀតណាមទទួលរងនូវការឈឺចាប់ពីការសងសឹកដ៏ឃោរឃៅក្នុងរបបខ្មែរក្រហម ដោយសារមូលហេតុនយោបាយជាកត្តាចម្បង ។ សមាជិកនៃក្រុមជនជាតិត្រូវបានដាក់ដោយឡែក ដោយមូលហេតុថាអ្នកទាំងនោះមានលក្ខណៈសម្គាល់ខុសពីជនជាតិខ្មែរ ដែលជាប្រជាជនខ្មែរជាទូទៅ ។ ឧទាហរណ៍ជាក់ស្តែង អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញភ័ស្តុតាងបង្ហាញថា ជនជាតិចាមត្រូវបានសម្លាប់ក្នុងអត្រាមួយខ្ពស់ជាងប្រជាជនខ្មែរ ។ ដោយឡែកជនជាតិចិនត្រូវបានដៅយកទៅសម្លាប់ដោយសារមានសម្បុរសជ្រះនិងទ្រព្យសម្បត្តិ ។

ក្រុមជនជាតិភាគតិចឯទៀត (ជនជាតិភាគតិចមានដើមកំណើតនៅកម្ពុជា) មានប្រវត្តិធ្លាប់គាំទ្ររបបខ្មែរក្រហម ដូច្នេះជាទូទៅប្រជាជនទាំងនេះមិនសូវឆ្លងកាត់ការលំបាកធ្ងន់ធ្ងរអ្វីទេ ។

រយៈពេលប៉ុន្មានឆ្នាំក្រោយរបបខ្មែរក្រហម សេរីភាពខាង

សាសនានិងជនជាតិភាគតិច មានពន្លឺសាជាថ្មី ។ តួយ៉ាងនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (ពីឆ្នាំ១៩៧៩-១៩៨៩ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ) ជនជាតិភាគតិចចិនរស់នៅក្នុងស្ថានភាពដែលងាយនឹងទទួលរងឥទ្ធិពលពីកត្តានយោបាយភូមិសាស្ត្រ ។ ម្យ៉ាងវិញទៀត ដោយសារវៀតណាមមានអំណាចលើប្រទេសក្នុងខណៈនោះជនជាតិភាគតិចវៀតណាមស្ថិតក្នុងស្ថានភាពវិជ្ជមានច្រើនជាងពេលមុនៗ ។

បច្ចុប្បន្ន ជនជាតិភាគតិចនៅប្រទេសកម្ពុជារស់នៅក្នុងបរិស្ថានមានស្ថិរភាពជាងមុន ទោះបីជាភាពតានតឹងទូទៅនៅតែមានជាពិសេសចំពោះជនជាតិវៀតណាម និងថៃ (ជនជាតិទាំងពីរនេះធ្លាប់មានប្រវត្តិជា "សត្រូវ" របស់កម្ពុជាអស់រយៈពេលជិត១ពាន់ឆ្នាំហើយ ។ ជាទូទៅ ជនអន្តោប្រវេសន៍វៀត-ណាមគឺជាប្រជាជនក្រីក្រ និងខំប្រឹងប្រជែងស្វែងរកចំណូលជាមួយប្រជាជនកម្ពុជាតាមរយៈការនេសាទនិងការងារសំណង់ ។ សព្វថ្ងៃភាពល្អក់កករផ្លូវចិត្តរបស់ជនជាតិភាគតិចបន្សល់ទុកពីរបបខ្មែរក្រហម និងសម័យរំដោះចំពោះជនជាតិភាគតិចនៅតែជិតដាម ។ ទោះបីជាជនជាតិកម្ពុជានិងថៃ មានភាសាវប្បធម៌ និងសាសនាប្រហាក់ប្រហែលគ្នាប្រជាជនខ្មែរមួយចំនួនមានអារម្មណ៍ស្អប់ចំពោះប្រទេសជឿនលឿនដែលនៅជិតខាង ។ កុបកម្មប្រឆាំងថៃ ឆ្នាំ២០០៣ បានជះកំហឹងដោយសារតែពាក្យសម្តីរបស់តារាភាពយន្តថៃ ដែលនិយាយពីរឿងប្រទេសជា "ម្ចាស់ប្រាសាទអង្គរវត្ត" ។ កុបកម្មនេះបណ្តាលឲ្យស្ថានទូតថៃ និងអគារពាណិជ្ជកម្មថៃទទួលរងនូវការខូចខាតដោយអន្ទើដែលសរុបជាទឹកប្រាក់មានតម្លៃប្រហែល៥០លានដុល្លារអាមេរិក ។ សកម្មភាពនេះ បង្ហាញពីការបែកបាក់នៃទំនាក់ទំនងជនជាតិភាគតិចនៅកម្ពុជា ។


កក ឡៃ ជនជាតិមិត្ទ្យ, ខេត្តក្រចេះ


ផាន វណ្ណឌី ជនជាតិលាវ ខេត្តមណ្ឌលគិរី


សៀង ណយ ជនជាតិព្រៅ ខេត្តរតនគិរី


ស៊ីង ម៉ិន ជនជាតិកូឡា ខេតបាត់ដំបង, ឆ្នាំ២០០៥

សាសនាគ្របដណ្តប់នៅប្រទេសកម្ពុជា (សាសនាព្រះពុទ្ធ អ៊ីស្លាម និងគ្រិស្ត) ប្រៀនប្រដៅឲ្យមនុស្សចេះអត់ឱនអធ្យាស្រ័យគ្នា ប៉ុន្តែក្នុងសង្គមកម្ពុជានៅតែបង្ហាញពីការមិនទុកចិត្តចំពោះប្រទេសជិតខាង ។ អ្នកទីក្រុងរស់នៅយ៉ាងចុះសម្រុងជាមួយជនជាតិភាគតិចឯទៀត ចំណែកការរស់នៅនៅតាមភូមិស្រុកវិញនៅតែមានការបែងចែកជនជាតិចាម ខ្មែរ និងវៀតណាម រស់នៅដាច់ដោយឡែកពីគ្នា ។ ជាងនេះទៅទៀត ភាពតានតឹងដ៏ស្មុគស្មាញកំពុងលេចឡើងនៅកម្ពុជាដោយសារមានការហូរចូលនៃសាសនាថ្មីៗ និងនិកាយសាសនាផ្សេងៗទៀតជាច្រើន (ដូចជា និកាយប្រូតេស្តង់ នៅតាមខេត្តដែលជាតំបន់សម្បូរដោយជនជាតិភាគតិច អ្នកស្រុកភ្នំ និងនិកាយតឹងរ៉ឹងនៃសាសនាអ៊ីស្លាម) ។ របាយការណ៍ឆ្នាំ២០០២ របស់ការិយាល័យសហរដ្ឋអាមេរិកបានគូសបញ្ជាក់ថា៦ភាគរយនៃចំនួនប្រជាជនសរុប មានន័យថា ជនជាតិអ៊ីស្លាមប្រមាណ៧០ម៉ឺននាក់កំពុងប្រតិបត្តិ និកាយវ៉ាហាប៊ី ដ៏ចំណាស់ ។ ដូច្នេះការយល់ដឹងអំពីបញ្ហាភាពតានតឹងរវាងជនជាតិភាគតិចមានសារសំខាន់ក្នុងការទប់ស្កាត់ ... ការផ្ទុះបញ្ហាំងគោលនយោបាយរដ្ឋពីដំបូងចំពោះក្រុមជនជាតិក៏ដូចជាផ្ទុះបញ្ហាំងពីទំនាក់ទំនងអតីតកាលនិងបច្ចុប្បន្នរវាងក្រុមជនជាតិនៅកម្ពុជា ។

ការឃោសនានយោបាយត្រូវបានធ្វើឡើងតាមរយៈការបញ្ចុះបញ្ចូលនិងការប្រកាន់ពូជសាសន៍ក្នុងសង្គម ។ ការបោះឆ្នោតឆ្នាំ២០០៣ អាលែន មេយើ បានកត់សម្គាល់ថា ÷

យុទ្ធនាការប្រឆាំងគ្នាទាំងពីរផ្តោតជាចម្បងទៅលើការញុះញង់ឲ្យស្អប់ និងការព្រួយបារម្ភចំពោះជនជាតិភាគតិចវៀតណាម ។ ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោតនៅដើមឆ្នាំ២០០៣ គណបក្សនយោបាយបានបន្តភាពរាំងស្ទះដោយលើកពីការជំទាស់ជាច្រើនដងប្រឆាំងនឹង«ជនអន្តោប្រវេសន៍ខុសច្បាប់»មកពីវៀតណាម ។ ប្រជាជនមួយចំនួនធំត្រូវបានបដិសេធមិនឲ្យចុះឈ្មោះបោះឆ្នោត ដោយគណៈកម្មការជាតិរៀបចំការបោះឆ្នោត ដោយគ្មានសំអាងលើអ្វីក្រៅពីថា អ្នកចុះឈ្មោះមានឈ្មោះស្រដៀងវៀតណាម ឬរូបរាងដូចវៀតណាម ។

តាមការប៉ាន់ស្មាន ការឃោសនាលក្ខណៈស្នេហាជាតិនិយមជ្រុលនេះ បានបង្កឲ្យមានឧបទ្ទវហេតុផ្សេងៗដែលប៉ុនប៉ងដោយក្រុមមនុស្សអនាចារ ហើយក្នុងនោះមានករណីពីរ-បីទទួលបានជោគជ័យក្នុងការរារាំងមិនឲ្យជនជាតិវៀតណាមចូលរួមបោះឆ្នោត ។

សហគមន៍អឺរ៉ុបមានការយល់ឃើញប្រហាក់ប្រហែលគ្នាដែរ ។ ខណៈពេលផ្តើមយុទ្ធនាការឃោសនាបោះឆ្នោតនៅខែមិថុនាកាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ មានរបាយការណ៍ស្តីពីការគំរាមកំហែងផ្នែកនយោបាយ និងគោលគំនិតប្រឆាំងយ៉ាងខ្លាំងនឹងជនជាតិវៀតណាមដែលស្តែងចេញដោយបេក្ខជនបោះឆ្នោត ។

ប្រព័ន្ធនយោបាយនៅកម្ពុជាប្រឈមនឹងកង្វះខាតការអនុគ្រោះ និងការមិនទុកចិត្តគ្នារវាងប្រជាជនភាគច្រើននិងជនជាតិភាគតិច ដែលតែងតែបង្កឧបសគ្គដល់ប្រសិទ្ធភាពការងារនៅក្នុងជួររដ្ឋាភិបាល (ជម្លោះផ្ទៃក្នុងនយោបាយបានរារាំងការបង្កើតរដ្ឋាភិបាល និងអូសបន្លាយពេលវេលាតាំងពីខែកក្កដា ឆ្នាំ២០០៣ រហូតដល់ខែមេសា ឆ្នាំ២០០៤) និងភាពលម្អៀងក្នុងការអនុវត្តយុត្តិធម៌ ។ បញ្ហាជនជាតិភាគច្រើននិងភាគតិចនៅកម្ពុជា រួមទាំងបញ្ហាអត្តសញ្ញាណទំនាក់ទំនងរវាងជនជាតិ និងការប្រព្រឹត្តតាមផ្លូវច្បាប់ និងនយោបាយ នឹងត្រូវយកមកពិចារណាក្នុងការសិក្សានេះដោយយោងតាមទំនាក់ទំនងរវាងរដ្ឋាភិបាលជាមួយក្រុមជនជាតិភាគតិចនីមួយៗ ។ ការសិក្សានេះនឹងផ្តល់ព័ត៌មានឲ្យប្រជាជនដែលជាកត្តាចាំបាច់ក្នុងការស្តាបនាលទ្ធិប្រជាធិបតេយ្យ ដើម្បីឲ្យប្រជាជនធ្វើការសម្រេចចិត្តប្រកបដោយការត្រិះរិះ និងបានចូលរួមកិច្ចការសាធារណៈដែលមានឥទ្ធិពលដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួន ។ ដរាបណា ប្រជាជនយល់ដឹងពីបញ្ហានេះទើបអ្នកទាំងអស់គ្នាអាចជួយជ្រោមជ្រែងក្នុងការបង្កើតនិងទ្រទ្រង់សង្គមប្រជាធិបតេយ្យដ៏រឹងមាំមួយដែលមានសមាជិកធ្លាប់បានឆ្លងកាត់ខបាយកលនយោបាយនេះ ។

គម្រោងស្រាវជ្រាវនេះនឹងបំពេញកង្វះចន្លោះការយល់ដឹងរបស់ប្រជាជនកម្ពុជាអំពីជនជាតិភាគតិចនៅកម្ពុជាដើម្បីលុបបំបាត់ការសង្ស័យចំពោះជនជាតិភាគតិចដែលមានអត្តសញ្ញាណខុសពីប្រជាជនភាគច្រើន ។

ប្រជាជនកម្ពុជាហាក់បីដូចជាមិនមានទស្សនៈច្បាស់លាស់មួយអំពីថាតើជនជាតិភាគតិចគំណាងឲ្យសង្គមទាំងមូលយ៉ាងដូចម្តេចនៅឡើយទេ ។ អ្នកប្រាជ្ញល្បីល្បាញដែលធ្វើការស្រាវជ្រាវករណីប្រទេសកម្ពុជាមួយចំនួនដូចជា ប៉ែន ឃៀវនិន, ដេវីដ ឆេនល័រ និង មីហ្សែល វីកឃើរី បានសិក្សាលើក្រុមជនជាតិភាគតិចក្នុងរបបខ្មែរក្រហម ។ ខណៈពេលការប្រកួតប្រជែងពានរង្វាន់ព្រះសីហនុរាជ ការស្រាវជ្រាវចូលរួមដោយសមាជិកជំនាញផ្សេងៗគ្នា បានធ្វើការសិក្សាទៅលើក្រុមជនជាតិចាម ចិន វៀតណាម ឡាវ ថៃ ភូមា និងជនជាតិភាគតិចតំបន់ខ្ពង់រាប ។ ការស្រាវជ្រាវនេះចាប់ផ្តើមនៅ ខែមិថុនា ឆ្នាំ១៩៩៥ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៩៦ ប៉ុន្តែជាលទ្ធផលស្រាវជ្រាវមិនទាន់បានបោះពុម្ពផ្សាយនៅឡើយទេដោយសារកង្វះខាតថវិកា ។

កិច្ចការស្រាវជ្រាវចំនួនពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើឡើងដើម្បីបំពេញចន្លោះព័ត៌មាន ។ កិច្ចការស្រាវជ្រាវទីមួយនិងទីពីរជាលទ្ធផលពិសោធន៍របស់លោក អ៊ីសា ឧស្មាន អំពីសហគមន៍ចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងស្តីពីការបះបោររបស់ចាមក្នុងរបបនោះ ។ កិច្ចការទីបី ដែលនឹងចេញផ្សាយក្នុងពេលឆាប់ៗនេះ ស្រាវជ្រាវដោយ ស៊ឹម សូរិយា នៃមជ្ឈមណ្ឌលឯកសារកម្ពុជា និង សារ៉ា ខម នៃអង្គការសិទ្ធិមនុស្ស ។ កិច្ចការស្រាវជ្រាវនេះផ្តោតទៅលើប្រវត្តិសាស្ត្រនៃជនជាតិភាគតិចតំបន់ភ្នំនិងតួនាទីរបស់អ្នកទាំងនោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ភៀសខ្លួនពីមណ្ឌលគិរីទៅជ្រកកោននៅប្រទេសវៀតណាម

ខេត្តមណ្ឌលគិរីគឺជាខេត្តមួយក្នុងចំណោមខេត្តបីនៅក្នុងភូមិភាគឦសាន ដែលជាតំបន់ដាច់ស្រយាលរបស់កម្ពុជា ។ ដើម្បីទៅដល់ខេត្តនេះយើងត្រូវដំណើរតាមផ្លូវចុះឡើងភ្នំដ៏វែងអន្លាយ ។ ខេត្តមណ្ឌលគិរីគឺជាទីស្ថានប្រជុំទៅដោយភ្នំនិងព្រៃឈើដែលមានសម្រស់ស្រស់ស្អាតប្រកបដោយលក្ខណៈធម្មជាតិ និងមានអាកាសធាតុត្រជាក់មនោរម្យស្ទើរពេញមួយឆ្នាំ ។ ខេត្តមណ្ឌលគិរីត្រូវបានបង្កើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ ខេត្តមណ្ឌលគិរីមានស្រុក៥គឺ សែនមនោរម្យ កែវសីមា ពេជ្រចិន្តា កោះញែក និងស្រុកអូររាំង ។

ចាប់តាំងពីឆ្នាំ១៩៦៨ ខេត្តមណ្ឌលគិរីបានក្លាយជាទីជម្រកដំបូងបង្អស់របស់ខ្មែរក្រហម ។ ខ្មែរក្រហមបានធ្វើការជ្រើសរើសនិងហ្វឹកហាត់ក្បួនទ័ពដល់បងប្អូនជនជាតិនៅទីនោះក្រោមការជួយទំនុកបម្រុងផ្នែកបច្ចេកទេសនិងសម្ភារពីប្រទេសវៀតណាមខាងជើង (ក្នុងដំណាក់កាលនោះប្រទេសវៀតណាមត្រូវបានបែងចែកជាពីរ គឺវៀតណាមខាងជើងនិងវៀតណាមខាងត្បូង) ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ភូមិភាគឦសានទាំងមូលរួមមានខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ និងស្ទឹងត្រែង និងខេត្តព្រះវិហារបានក្លាយទៅតំបន់រំដោះដំបូងបំផុតរបស់ខ្មែរក្រហម ។ ទោះជាយ៉ាងនេះក្ដី ខ្មែរក្រហមបានជ្រកក្រោមផ្លាកខ្មែររំដោះដែលជាកងកម្លាំងតំណាងឲ្យរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្ដេចព្រះនរោត្ដម សីហនុ ជាព្រះប្រធាន និងមានប្រទេសចិនកុម្មុយនីស្ដ និងវៀតណាមខាងជើងជាអ្នកជួយជ្រោមជ្រែង ។

នេះជាជំហានជោគជ័យដំបូងរបស់ខ្មែរក្រហម ។ ព្រឹត្ត-ការណ៍ក្នុងខេត្តមណ្ឌលគិរីមានលក្ខណៈចម្លែកជាងតំបន់ផ្សេងៗទៀត ។ តំបន់ភាគច្រើននៃខេត្តនេះជាតំបន់ភ្នំ ដែលមិនអាចធ្វើការបង្កបង្កើនផលបាន ។ ដូច្នេះខ្មែរក្រហមបានចាប់ផ្ដើមជម្លៀសប្រជាជនដែលរស់នៅជាយៗនិងពីស្រុកផ្សេងៗនៃខេត្តឲ្យមកផ្ដុំគ្នានៅក្នុងស្រុកកោះញែក ដែលជាតំបន់វាលទំនាបដើម្បីធ្វើស្រែចម្ការ ។ ប្រជាជនដែលរស់នៅនិងតស៊ូនៅក្នុងព្រៃត្រូវបានចាត់ទុកថាជាកម្មាភិបាលចាស់ឬប្រជាជនមូលដ្ឋាន ហើយអ្នកដែលជម្លៀសទៅថ្មីត្រូវបានចាត់ទុកថាជាប្រជាជនថ្មី ។ ប្រជាជនមូល-ដ្ឋានត្រូវបានតែងតាំងជាប្រធានភូមិ គណៈឃុំ គណៈតំបន់ ទៅតាមការមើលឃើញរបស់អង្គការ ។ ចំណែកប្រជាជនជម្លៀសត្រូវស្ថិតនៅក្រោមការតាមដានរបស់ខ្មែរក្រហមជាប់ជាប្រចាំ ។

ជាបន្ដបន្ទាប់ ក្រោយពីការប្រមូលផ្ដុំប្រជាជនឲ្យទៅរស់នៅក្នុងស្រុកកោះញែក ខ្មែរក្រហមបានបង្កើតជាក្រុមប្រវាស់ដៃ ប៉ុន្ដែការហូបចុកនៅមានលក្ខណៈគ្រួសារនៅឡើយ ។ រយៈពេលមួយឆ្នាំបន្ទាប់ពីការផ្លាស់ប្ដូរ គឺនៅក្នុងឆ្នាំ១៩៧២ ខ្មែរក្រហមបានចាប់ផ្ដើមអនុវត្តគោលនយោបាយរបស់ខ្លួនបន្ដិចម្ដងៗដោយបង្វែរទិសដៅពីក្រុមប្រវាស់ដៃមកជាក្រុមសាមគ្គីវិញ ។ ប៉ុន្ដែទ្រព្យសម្បត្ដិដីធ្លីរបស់ប្រជាជនមិនទាន់ត្រូវបានប្រមូលដាក់រួមនៅឡើយទេ ។ រហូតមកដល់ឆ្នាំ១៩៧៣ ខ្មែរក្រហមបានបំបែកប្រជាជនចេញពីក្រុមសាមគ្គីទៅជាសហករណ៍រួមតូច ឬសហករណ៍សហគមន៍ដែលមានប្រជាជនប្រមាណពី២០ទៅ៣០គ្រួសារ ធ្វើការនិងហូបបាយរួមនៅក្នុងសហករណ៍មួយ ។ មិនយូរប៉ុន្មាន ទ្រង់ទ្រាយសហករណ៍ធំបានចេញជារូបរាងឡើងនៅពេលដែលប្រទេសកម្ពុជាធ្លាក់នៅក្រោមការគ្រប់គ្រងរបស់អង្គការបដិវត្តន៍នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

យុវជនយុវនារីនិងប្រជាកសិករចាស់ក្មេងតម្រូវឲ្យចូលបម្រើបដិវត្តន៍ក្រោមការបញ្ចុះបញ្ចូលថា "បម្រើជាតិ បម្រើវណ្ណៈកសិករក្រ" ។ ប៉ុន្ដែនៅទីបំផុតយុវជនយុវនារីមួយចំនួនត្រូវបានចាប់ខ្លួនយកទៅសម្លាប់ដោយសារតែមានប្រវត្តិរូបមិនល្អ ហើយត្រូវបានចោទថាក្បត់បដិវត្តន៍បម្រើឲ្យបក្សនេះបក្សនោះ ។

ជ័យ សាថន ជាកូនកាត់ខ្មែរភ្នងត្រូវបានជម្លៀសទៅរស់នៅឃុំស្រែសង្គម ស្រុកកោះញែក ដែលកាលនោះគាត់មានអាយុជាង២០ឆ្នាំ ។ សាថន ជាកូនទី២ក្នុងចំណោមបងប្អូន៧នាក់ នៅពេលដែលកងទ័ពរំដោះកាន់កាប់ខេត្តមណ្ឌលគិរីទាំងមូល គាត់បានចូលធ្វើឈ្លបរយៈពេលជាងពីរឆ្នាំក៏ត្រូវចាប់ខ្លួនដោយសារ

ការចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធជាមួយខ្មែរ-ស ។ តាមបទសម្ភាស៍របស់គាត់បានឲ្យដឹងថា ៖ សាថន បានបញ្ចប់ការសិក្សាត្រឹមថ្នាក់ឌីប្លូមនៅវិទ្យាល័យព្រះកុសុមៈខេត្តក្រចេះ នៅឆ្នាំ១៩៦៤ ។ ដោយពុំមានលទ្ធភាពក្នុងការចំណាយថវិកាទៅលើការរៀនសូត្របន្តនៅភ្នំពេញ សាថន បានសម្រេចចិត្តវិលត្រឡប់មកស្រុកកំណើតវិញ ដើម្បីជួយធ្វើស្រែចម្ការម្តាយមួយរយៈ និងជួយសម្រាលបន្ទុកគ្រួសារដែលជួបប្រទះនឹងមហន្តរាយភ្លើងឆេះផ្ទះ ។ ចំណែកឪពុកពិការជើង ។ សាថន មិនទាន់រកការងារបានធ្វើភ្លាមទេ គាត់នៅធ្វើស្រែចម្ការជាមួយម្តាយបានរយៈពេលបី-បួនឆ្នាំស្ថានភាពស្រុកទេសក៏ប្រែប្រួល ។ សាថន នៅចាំបានថា កាលណោះមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងរយៈពេលបីថ្ងៃរវាងកងទ័ពរំដោះនិងកងទ័ពលន់នល់ដែលគាំទ្រដោយសហរដ្ឋអាមេរិក ។ កងទ័ពរំដោះដណ្តើមកាន់កាប់បានខេត្តនេះស្ទើរតែទាំងមូលនៅក្នុង១៩៧០ ។

សាថន និយាយថា ពេលកាន់កាប់ខេត្តនេះដំបូងខ្មែរក្រហមបានប្រើប្រាស់ពាក្យសម្តីសមរម្យទៅកាន់ប្រជាជន ដូចជាពាក្យ "ឪម៉ែ" "ពុកម៉ែ" ជាដើម ។ ក្រោយមកខ្មែរក្រហមបានដើរបំផុសចលនាជ្រើសរើសក្មេងៗឲ្យទៅបម្រើជាតិមាតុភូមិប្រជាជនក៏បានបញ្ជូនកូនចៅទៅឲ្យចូលបម្រើកងទ័ពតាមការឃោសនានេះ ។ មិនយូរប៉ុន្មានការហៅ"ពុកម៉ែ" ត្រូវបានបន្ថែមនូវបុព្វបទថ្មីមួយថា "មិត្តពុក មិត្តម៉ែ មិត្តបង មិត្តប្អូន មិត្តកូន" ។


ជ័យ សាថន

នៅពេលដែលក្រុមគ្រួសាររបស់គាត់ត្រូវបានជម្លៀសទៅស្រុកកោះញែកបានមួយឆ្នាំ សាថន ត្រូវបានចាត់តាំងឲ្យធ្វើឈ្លបឃុំជាមួយក្រុមយុវជន២៥នាក់ទៀត ។ សាថន មាននាទីដើរល្បាតតាមព្រៃនិងវាយប្រយុទ្ធជាមួយយន្តហោះអាមេរិកាំង ។ ក្នុងឆ្នាំ១៩៧២ សាថន ត្រូវបានបញ្ជាឲ្យបោះទីតាំងត្រៀមបាញ់សត្រូវនៅម្តុំស្ពានដែកក្នុងឃុំពូជ្រៃអស់រយៈពេលបីខែ ។ ប៉ុន្តែគាត់មិនដែលបាញ់យន្តហោះធ្លាក់បានមួយគ្រឿងឡើយ ។ ពេលគាត់បាញ់ម្តងៗ គាត់តែងរត់ប្រាសអាយុដើម្បីគេចពីការទម្លាក់គ្រាប់បែក ។ សាថន រំឭកថា ទ្រឹស្តីរបស់ ប៉ុល ពត មិនបានគិតពីការស្លាប់រស់ឬការការពារខ្លួនបែបណានោះទេ "សំខាន់ គឺស្មារតី ហើយធ្វើម៉េចបាញ់ឲ្យបាន" ។ បើមានឈ្លបណាម្នាក់ ហ៊ាននិយាយថាអាវុធមិនទំនើបបាញ់មិនបាន ហើយប្រសិនបើអង្គការឮនោះ នឹងត្រូវស្លាប់ភ្លាម ។ ទោះជាយ៉ាងណា សាថន និងមិត្តភក្តិមិនបានទទួលរងរបួសនៅក្នុងសមរភូមិឡើយ ក៏ប៉ុន្តែបរិវេណដីនៅក្បែរនោះត្រូវគ្រហូងដោយសារគ្រាប់បែកដែលយន្តហោះទម្លាក់ ។ សាថន មិនដឹងពិតប្រាកដថាយន្តហោះខាងណាទម្លាក់ទេ គាត់គ្រាន់តែដឹងថា ពេលដែលពួកគាត់បាញ់បានម្នាក់បីគ្រាប់យន្តហោះក៏មកដល់ "មិនដឹងថាយន្តហោះមកខាងណាទេ លឿនពេក បាញ់តែ៥នាទី យន្តហោះមកដល់ ។ ពួកខ្ញុំបាញ់បានម្នាក់បីគ្រាប់ស្រាប់តែ(យន្តហោះ)មកដល់តែម្តង" ។ សាថន ធ្វើជាកងឈ្លបល្បាតបានរយៈពេលប្រហែល២ឆ្នាំ ហើយដើរល្បាតជាច្រើនកន្លែង ក្រោយមកគាត់ក៏ត្រូវបានចាប់ខ្លួន ។

## មូលហេតុនិងការដកខ្លួនចេញពីបដិវត្តន៍

ដោយសារឃើញសកម្មភាពដឹកនាំរបស់ខ្មែរក្រហមប្រព្រឹត្តមកលើប្រជាជនកាន់តែសាហាវពីមួយថ្ងៃទៅមួយថ្ងៃ សាថន លែងមានចំណង់ចំណូលចិត្តបម្រើបដិវត្តន៍ខ្មែរក្រហមតទៅទៀត ។ អ្វីដែលធ្វើឲ្យ សាថន ត្រូវតែដកខ្លួនចេញពីបដិវត្តន៍នោះ គឺ(១)ការសម្លាប់មនុស្សបួននាក់ដែលគាត់បានឃើញផ្ទាល់ភ្នែក ។ អ្នកទាំងបួននាក់នេះសុទ្ធតែជាមនុស្សដែលគាត់ធ្លាប់ស្គាល់ដែលមានឈ្មោះ សៅ និង ស្រេង ជាអតីតទាហានពីសង្គមចាស់ មេឃុំឈ្មោះ សុខ និងម្នាក់ទៀតមិនចាំឈ្មោះ ។ សុខ និងប្រពន្ធបានភៀសខ្លួនទៅខេត្តក្រចេះ ពេលដែលខ្មែរក្រហមគ្រប់គ្រងខេត្តមណ្ឌលគិរី ។ ក្រោយមក សុខ និងប្រពន្ធបានវិលត្រឡប់មករស់នៅភូមិកំណើតវិញ ហើយត្រូវខ្មែរក្រហមចាប់ខ្លួននិងសម្លាប់ចោល ។ ចំណែកជនរងគ្រោះម្នាក់ទៀតជាប្រជាជនសាមញ្ញ ។ ជននោះត្រូវឈ្លបខ្មែរក្រហមចាប់ចងឆ្កាងលើគំនរឫស្សីពីងពង់ ហើយដុតសម្លាប់ទាំងរស់ ។ ដោយឃើញទិដ្ឋភាពបែបនេះ សាថន បាត់បង់ការជឿជាក់ចំពោះបដិវត្តន៍ ហើយស្របពេលនោះ សាថន ក៏ត្រូវខ្មែរក្រហមដកសេចក្តីទុកចិត្តនិងដកហូតអាវុធដើម្បីធ្វើការតាមដានផងដែរ ។

### ***ទៅធ្វើសាលា***

បន្ទាប់ពីដកអាវុធបានប្រហែល១០ថ្ងៃ មាននិរសារម្នាក់បានមកហៅ សាថន ឲ្យទៅជួយធ្វើសាលា ។ ពេលនោះ សាថន មិនដឹងថាថ្នាក់លើកំពុងរៀបចំគម្រោងចាប់ខ្លួនគាត់ទេ ។ សាថន បានត្រៀមអង្ករចានឆ្នាំងនិងសំលៀកបំពាក់ខ្មៅជាស្រេចសម្រាប់ការធ្វើដំណើរ ។ ពេលទៅដល់មន្ទីរស្រុកកោះញែក តាឡោក ដែលមានតួនាទីជាប្រធានភស្តុភារស្រុកបានហៅ សាថន ឲ្យអង្គុយលើកៅអីរនាបឫស្សីមួយ ។ ភ្លាមនោះ មានឈ្លបប្រមាណពី២០ ទៅ ៣០នាក់ ចេញមកចាប់គាត់ហើយវាយទាត់ធាក់ដោយគ្មានសួររកមូលហេតុអ្វីទាំងអស់ ។ ក្រោយពីវាយអស់ចិត្ត ឈ្លបទាំងនោះបានបណ្តើរ សាថន យកទៅចងនៅក្នុងព្រៃជ្រៅ ។ ប្រមាណជាពីរម៉ោងក្រោយមក ឈ្លបបានបណ្តើរបងប្អូនថ្លៃរបស់ សាថន ម្នាក់ឈ្មោះ ញេប សារឹម និងឈ្មោះ បេង ដោយបោកបញ្ឆោតថាទៅកាប់ឫស្សី ។ អ្នកទាំងពីរក៏ត្រូវឈ្លបវាយទាត់ធាក់ដូច សាថន ដែរ ។ សាថន ត្រូវឈ្លបចងដៃទាំងពីរទៅក្រោយផ្អោបនឹងដើមឈើមួយដើម ។ ខ្លួនប្រាណនិងក្បាលរបស់គាត់ទទួលរងរបួសយ៉ាងដំណំ រហូតដល់លែងដឹងឈឺ ។ ចំណែកប្អូនថ្លៃ ត្រូវឈ្លបយកចំពុះទុងចាក់ស្ទើរសុសសាច់ ។ ព្រឹកឡើងអ្នកទាំងបីត្រូវឈ្លបបណ្តើរយកទៅជួបអង្គការ ។ សាថន មិនដឹងថាអង្គការនៅកន្លែងណាទេ ។ គាត់គ្រាន់តែឮឈ្លបនោះនិយាយថា "ទៅជួបអង្គការ" ។ ខ្លួនប្រាណដៃជើងរបស់ សាថន ត្រូវចងរឹតយ៉ាងតឹងដោយខ្សែនីឡុង ចំណែកដៃទាំងពីរត្រូវឈ្លបចងក្រពាត់ទៅក្រោយ ។ តាមផ្លូវធ្វើដំណើរឆ្លងកាត់ព្រៃ សាថន ត្រូវកងឈ្លបវាយទាត់ធាក់ជាច្រើនដង ។ ពេលណាគាត់ដើរលឿនបន្តិច ឈ្លបបានទាញខ្សែចំណងដែលចងដៃគាត់ធ្វើឲ្យគាត់ដាច់ផ្ងារមកក្រោយស្ទើរសន្លប់ម្តងៗ ។ លើសពីនេះ ឈ្លបបានឲ្យគាត់ស្រែកធ្វើត្រាប់តាមសំឡេងសត្វ ប្រសិនបើធ្វើមិនដូចទេ គាត់នឹងត្រូវឈ្លបវាយធ្វើបាបនិងជេរប្រមាថគ្រប់បែបយ៉ាង ។ សាថន ធ្វើដំណើរតាំងពីម៉ោង៣រសៀលទល់ម៉ោង៨ព្រឹក ទើបមកដល់ព្រៃចាស់មួយ នៅទីនោះ សាថន ត្រូវឈ្លបវាយបែកក្បាលហូរឈាមរហូតសន្លប់បាត់ស្មារតីជាច្រើនម៉ោង ។ ចំណែកបងប្អូនពីរនាក់ទៀត ត្រូវឈ្លបបណ្តើរយកទៅទុកនៅត្រើយម្ខាង ។ សាថន ក៏ត្រូវបានបញ្ជូនទៅទីនោះដែរ បន្ទាប់ពីជើងទាំងពីររបស់គាត់ត្រូវកងឈ្លបដាក់ខ្នោះឈើ ។

តាមស្ថានភាពនៅក្នុងព្រៃចាស់នេះ សាថន សន្និដ្ឋានថាមានមនុស្សជាច្រើនត្រូវបានចាប់ទៅទីនោះ ដោយហេតុថាមានស្លឹកឈើក្រៀមនិងស្លឹកឈើថ្មីជាច្រើនត្រូវបានអ្នកទោសកាច់មកទ្រាប់អង្គុយ ។ សាថន និងប្អូនថ្លៃត្រូវបានចងដាក់ឲ្យនៅក្បែរគ្នា ។ សាថន បានដឹងពីមូលហេតុច្បាស់នៃការចាប់ខ្លួនរបស់គាត់ នៅពេលដែលឈ្លបនោះ ស្រែកឲ្យគាត់ថា "អ្ហែងក្បាលរឹងណាស់អាខ្មែរ-ស" (រហូតមកដល់នេះ សាថន មិនដឹងថាខ្មែរសមានរូបរាងយ៉ាងណានោះទេ) ។ សាថន គិតថានេះគ្រាន់តែជាលេសមួយដើម្បីចាប់ខ្លួនគាត់ប៉ុណ្ណោះ ។

### ***លួចរត់គេចពីគ្រោះមរណៈ***

ឈ្លបពីរនាក់ដែលត្រូវបានបញ្ជូនឲ្យទៅយាមគាត់គឺជាអ្នកដែលធ្លាប់ធ្វើការជាមួយគ្នា ។ ឈ្លបទាំងពីរស្លុតចិត្តយ៉ាងខ្លាំង នៅពេលឃើញ សាថន ត្រូវបានចាប់ខ្លួន ។ ប៉ុន្តែអ្នកទាំងពីរមិនអាចដោះលែង សាថន បានទេព្រោះថានេះជាបញ្ជារបស់អង្គការ ។ សាថន ក៏មិនបន្ទោសដែរ គាត់គ្រាន់តែលួងលោមអ្នកទាំងពីរថា "អញឃ្លានបារីខ្លាំងណាស់ អ្ហែងគិតមើលមើល៍ អញជាប់ចំណងបីយប់បីថ្ងៃហើយ អញគ្មានផ្លូវរស់ទេ ពេលនេះអញលាមិត្តភក្តិទាំងអស់ហើយ" ឈ្លបម្នាក់មានចិត្តអាណិត សាថន ហើយបានមូរបារីស្លឹកសង្កែមួយដើមឲ្យគាត់និងជួយបន្ធូរចំណងដៃដើម្បីឲ្យគាត់អាចកាន់បារីជក់បាន ។

ភ្លើងកន្ទុយបារីអាចជួយឲ្យ សាថន រួចផុតពីចំណងបាន ។ សាថន បានភ្លើងកន្ទុយបារីអុចខ្សែចំណងដៃ រួចប្រើកម្លាំងរំកិលចំណងនោះរហូតរបូតចេញពីដៃ ។ សាថន បានពិគ្រោះជាមួយប្អូនថ្លៃថា "បើសិនជា យើងនៅដល់ថ្ងៃស្អែកក៏យើងស្លាប់ដែរ ព្រោះឈ្លបជីករណ្តៅក្បែរនោះរួចជាស្រេចទៅហើយ" ដូច្នេះត្រូវតែនាំគ្នារត់គេចចេញពីកន្លែងនេះ ។ ក្នុងចំណោមអ្នកទាំងបី បេង មិនបានរត់ទៅជាមួយទេ ដោយសារគាត់មានជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ ។ អ្នកទាំងពីរបានរត់ចូលព្រៃដោយបានតាំងចិត្តថា "បើទោះបីជាស្លាប់ឲ្យស្លាប់ដោយត្រូវគ្រាប់មួយដួងទៅចុះ កុំឲ្យគេយកទៅវាយចោល" ព្រោះមុននឹងវាយចោលខ្មែរក្រហមបានធ្វើទារុណកម្មហួសនិស្ស័យ ។ សាថន បានកញ្ឆក់ដៃប្អូនថ្លៃដែល

ខ្លាក់មាន់រត់ចូលព្រៃពេញមួយយប់ទើបអាចឆ្លងផុតពីគ្រោះមរណៈនេះ ប៉ុន្តែគាត់ទាំងពីរក៏ស្ថិតក្រោមការតាមចាប់ខ្លួនរបស់អង្គការដែរ ។

សាថន រំឮកថា នៅពេលនោះគឺនៅក្នុងខែមីនា ឆ្នាំ១៩៧៨ ។ អាកាសធាតុក្តៅហួតហែង សូម្បីតែសត្វពាហនៈក៏ពិបាកក្នុងការស្វែងរកទឹកនិងចំណីដែរ ។ នៅក្នុងព្រៃ គាត់ឃើញដំរីព្រៃមួយក្បាលកំពុងយកដើងឈូសដីដើម្បីរកប្រភពទឹក ។ ពេលទឹកជ្រាបចេញពីកន្លែងដំរីឈូសភ្លាម សាថន និងប្អូនថ្លៃដែលកំពុងតែស្រេកទឹកនិងអត់អាហារជាច្រើនថ្ងៃមកហើយនោះ បាននាំគ្នារត់ទៅដណ្តើមទឹកពីដំរី ។ ជាសំណាងល្អ ដំរីនោះភ័យនឹងសំឡេងមនុស្សក៏រត់បាត់ទៅ ។ សាថន បន្តថា គាត់មានក្រមាមួយដែលម្តាយគាត់បានប្រគល់ឲ្យមុនពេលចេញទៅធ្វើសាលា ។ ក្រមានេះអាចជួយផ្ទុកទឹកបានខ្លះ ដោយគាត់អាចពូតដឹកនៅពេលគាត់ស្រេក ហើយចេកព្រៃជាអាហារតែមួយគត់ដែលគាត់អាចហូបបានដើម្បីបំពេញក្រពះដែលរងការស្រេកឃ្លានអស់ជាច្រើនថ្ងៃ ។

សាថន និងប្អូនបានធ្វើដំណើរហូតដល់ភូមិអូរច្បារដែលប្រជាជននៅក្នុងភូមិនេះត្រូវបានជម្លៀសទៅស្រុកកោះញែក ។ អ្នកទាំងពីរនាក់បងប្អូនលាក់ខ្លួននៅត្រើយម្ខាងភូមិអូរច្បារ ហើយលួចបេះផ្លែឈើហូបមួយចម្អែតមុននឹងធ្វើដំណើរទៅមុខទៀត ។

## រត់គេចទៅប្រទេសវៀតណាម

ពេលទៅដល់ស្រុកអូររាំង មេឃចាប់ផ្តើមងងឹត ។ អាកាសធាតុក៏ចាប់ផ្តើមត្រជាក់ ។ ផ្គរលាន់គ្រហឹមដើមឆ្នាំជាមួយនឹងទឹកភ្លៀងរលឹមស្រិចៗគ្របដណ្តប់វាលរហោស្ថានដ៏ស្ងាត់ជ្រងំនេះ បានធ្វើឲ្យ សាថន ចាប់ផ្តើមអស់សង្ឃឹម ព្រោះថាពេលនោះ គាត់ស្លៀកតែខោខ្លីមួយប៉ុណ្ណោះ ហើយប្អូនថ្លៃរបស់គាត់មានសម្លៀកបំពាក់ហែករយីរយៃ មិនអាចទប់ទល់នឹងអាកាសធាតុត្រជាក់បានឡើយ ។ សាថន និយាយថា ផ្គរលាន់ដើមឆ្នាំ ធ្វើឲ្យគាត់ស្ទើរតែស្រក់ទឹកភ្នែក ។ គាត់និងប្អូនបានបោចស្មៅធ្វើជាសំបុកជ្រកដើម្បីសម្រាកនិងកម្តៅខ្លួន ។ សត្វសង្ហារបានខាំសុសអស់ទាំងខ្លួន ក៏ប៉ុន្តែអំណាចនៃការភ័យខ្លាចបានធ្វើឲ្យ សាថន ភ្លេចអស់នូវការឈឺចាប់ទាំងឡាយ ។ ត្រចៀកផ្ទៀងស្តាប់ ភ្នែករំពៃមើលក្រែងជួបកងទ័ពខ្មែរក្រហម ។ មិនយូរប៉ុន្មាន អ្នកទាំងពីរបានពើបប្រទះនឹងកងទ័ពរំដោះ(កងទ័ពវៀតណាម)មួយក្រុម ។ អ្នកទាំងនោះបានសួរគាត់ថា "*ទៅណាមកណា?*" បន្ទាប់មក កងទ័ពវៀតណាមបានចាប់គាត់ទាំងពីរទៅបន្ទាយរបស់ពួកគេ ។

ខ្មែរកម្ពុជាក្រោមម្នាក់បានជួយបកប្រែភាសាឲ្យជំនាញការវៀតណាម ។ ជំនាញការវៀតណាមបានសួរគាត់ដោយម៉ឺងម៉ាត់ថា "*លោកឯងឈ្មោះ ថន-សារឹម មែនទេ?*"(ថន ជាឈ្មោះហៅក្រៅរបស់ សាថន ហើយ សារឹម ជាឈ្មោះប្អូនថ្លៃ) ។ សាថន ឆ្លើយថា "*បាទ!*" ជំនាញការនោះនិយាយថា គាត់ទទួលបញ្ជាពីថ្នាក់លើឲ្យតាមស្កាត់ចាប់អ្នកទាំងពីរត្រឡប់ទៅវិញ ។ សាថន បានឆ្លើយទៅវិញថា "*ប្រសិនបើលោកឯងចាប់ខ្ញុំបញ្ជូនទៅវិញ លោកឯងសម្លាប់ខ្ញុំទៅ*" ។ មួយស្របក់ក្រោយអ្នកទាំងពីរត្រូវបានផ្តល់បាយនិងអំបិលគ្រួសឲ្យហូបមួយចម្អែត ។ បញ្ជាការវៀតណាមបានបញ្ជាឲ្យអ្នកបកប្រែនាំអ្នកទាំងពីរចុះទៅតាមផ្លូវមួយដែលគាត់មិនធ្លាប់ស្គាល់ទាល់តែសោះពីមុនមក ។ ខ្មែរកម្ពុជាក្រោមម្នាក់នេះបានណែនាំអ្នកទាំងពីរឲ្យភៀសខ្លួនទៅប្រទេសវៀត-ណាម ហើយថែមទាំងបានជួយគូសផែនទីបង្ហាញផ្លូវនិងផ្តល់ស្បៀងមួយចំនួនដូចជាអង្ករ គ្រឿងក្នុងជ្រូកឆាខ្ញី និងឆ្នាំងមួយសម្រាប់ដាំបាយហូបតាមផ្លូវទៀតផង ។ ប៉ុន្តែខ្មែរកម្ពុជាក្រោមម្នាក់នោះបានហាមគាត់ថា "*បើជួបអ្នកណាក្តី ខ្មែរក្រហមក្តី កុំប្រាប់ថាខ្ញុំឲ្យបាយឲ្យទឹកអ្នកឯង*" ។ ព្រោះតែសេចក្តីស្រេកឃ្លាន បាយមួយឆ្នាំងដែលសម្រាប់មនុស្សបរិភោគ៦នាក់ អ្នកទាំងពីរហូបគ្មានសល់ ។ សាថន និងប្អូនថ្លៃបានធ្វើដំណើរមួយយប់មួយថ្ងៃទើបទៅដល់ព្រំដែនវៀតណាម ។ នៅពេលឆ្លងព្រំដែនភ្លាម កងទ័ពអាវខ្មៅដែលមានសម្លៀកបំពាក់ដូចទាហានខ្មែរក្រហមបានចាប់ខ្លួនគាត់បញ្ជូនទៅឃុំ(នៅក្នុងទឹកដីវៀតណាម) ។ អ្នកជាប់ឃុំទាំងអស់នៅទីនោះសុទ្ធបងប្អូនជនជាតិ ដែលបានរត់គេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ។ ភាគច្រើនប្រជាជនដែលភៀសខ្លួនទៅទីនោះគឺជាជនជាតិស្ទៀង ។ សាថន និងប្អូនថ្លៃត្រូវបានបញ្ជូនទៅរស់នៅក្នុងខេត្តប៊ូដាង ហើយធ្វើស្រែចម្ការជាមួយកងទ័ពរហូតដល់ឆ្នាំ១៩៨០ ។

## ផ្ញើខ្លួននៅក្នុងទឹកដីវៀតណាម

ការរស់នៅរបស់ សាថន ក៏ដូចជាប្រជាជនជម្លៀសផ្សេង

ទៀត គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលវៀតណាម ។ ក្រៅពីប្រកបរបរធ្វើស្រែចម្ការ សាថន បានចូលរៀនវគ្គហ្វឹកហ្វឺនខ្លះៗ នៅតាមភូមិឃុំអំពីវិន័យនិងលទ្ធិកុម្មុយនីស្ត ។ រស់នៅទីនោះបានប្រហែលជាពីរឆ្នាំ សារឹម បានរៀបការជាមួយនារីខ្មែរកម្ពុជាក្រោមម្នាក់ ហើយអ្នកទាំងបីបានរស់នៅក្នុងដំបូលផ្ទះតែមួយ ។

ចុងឆ្នាំ១៩៧៨ ស្ថានភាពនយោបាយកំពុងតែជ្រួលច្របល់ខ្លាំង ។ នៅកម្ពុជាមានការបោសសម្អាតផ្ទៃក្នុងបក្ស ។ កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមជាច្រើនត្រូវបានសម្លាប់ ។ ប្រជាជននិងកងទ័ពដែលភៀសខ្លួនមកកាន់ប្រទេសវៀតណាមបានប្រមូលកម្លាំងគ្នាបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។ រណសិរ្សនេះមានទីតាំងធំ នៅខេត្តសុងបែរប្រទេសវៀតណាម ។ រាល់ការប្រជុំធំៗតែងធ្វើឡើងនៅទីនោះ ។ សាថន និងមិត្តភក្តិបានទទួលលិខិតអំពាវនាវដូចៗគ្នាពីខ្មែរម្នាក់ឲ្យចូលរួមក្នុងចលនារណសិរ្សដើម្បីរំដោះប្រទេសកម្ពុជាពីកណ្តាប់ដៃខ្មែរក្រហម ។ ប៉ុន្តែ សាថន មិនបានចូលរួមចលនានេះភ្លាមទេ ។ រហូតមកដល់ខែមករាឆ្នាំ១៩៨០ រដ្ឋាភិបាលវៀតណាមបានបញ្ជូន សាថន និងខ្មែរមួយចំនួនទៀតឲ្យត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងនាមជាអ្នកបកប្រែភាសាវៀតណាម ។ មុនពេលចូលមកកម្ពុជា សាថន ត្រូវបានបញ្ជូនឲ្យទៅបណ្តុះបណ្តាលផ្នែកបកប្រែនៅក្នុងខេត្តយូណាវរយៈពេលបីខែ ។ បន្ទាប់មក សាថន បានវិលត្រឡប់មកមាតុប្រទេសវិញ ហើយបានបម្រើការងារនៅក្នុងក្រសួងមហាផ្ទៃ ។

នៅឆ្នាំ១៩៨២ សាថន បានត្រឡប់ទៅខេត្តមណ្ឌលគិរីវិញ ក្រោយពីដឹងថាម្តាយនិងបងប្អូនរបស់គាត់នៅរស់ ។ សាថន រំឭកថា ពេលមកដល់ភ្នំពេញ គាត់គ្មានបំណងវិលត្រឡប់ទៅស្រុកកំណើតវិញឡើយ ពីព្រោះគាត់គិតថា សាច់ញាតិឪពុកម្តាយគាត់ច្បាស់ជាស្លាប់អស់ហើយ ។ ប៉ុន្តែជាចៃដន្យ ថ្ងៃមួយគាត់បានជួបគ្រូម្នាក់ឈ្មោះ វ៉ាលី ដែលបានមករៀនវគ្គបណ្តុះបណ្តាលនៅភ្នំពេញប្រាប់ថាសាច់ញាតិរបស់គាត់នៅរស់ ។ សាថន បានធ្វើដំណើរមកជាមួយគ្រូ វ៉ាលី អស់រយៈពេលបីថ្ងៃទើបទៅដល់ខេត្តមណ្ឌលគិរី ។ ពេលចូលដល់ក្នុងផ្ទះភ្លាមម្តាយរបស់ សាថន ស្មានថា សាថន ជាខ្មោច ។ ពេលនោះ ម្តាយគាត់បានរត់ចូលទៅក្នុងបន្ទប់ហើយយកភួយឃ្លុំយ៉ាងជិត ។ គាត់សម្ងំនៅក្នុងបន្ទប់ពេញមួយយប់ដោយមិននិយាយអ្វីទាំងអស់ ។ លុះព្រឹកឡើងទើបគាត់ចេញមកសួរថា "អ្ហែងខ្មោចឬមនុស្ស?" ។ ម្តាយរបស់គាត់សប្បាយចិត្តយ៉ាងខ្លាំង ក្រោយពីដឹងថាកូនប្រុសរបស់គាត់មួយនេះនៅរស់ ។ ទោះជាយ៉ាងនេះក្តី ក៏មានសមាជិកក្រុមគ្រួសាររបស់ សាថន ពីរនាក់បានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមដែរ ។

ក្រោយពីជួបជុំម្តាយនិងបងប្អូនវិញ សាថន បានឮពាក្យចចាមអារ៉ាមថា ឪពុករបស់គាត់ស្លាប់នៅចុងឆ្នាំ១៩៧៨ ។ តាមសម្តីរបស់អ្នកភូមិ ឪពុករបស់ សាថន ត្រូវខ្មែរក្រហមសម្លាប់ក្នុងអំឡុងពេលមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងខ្មែរក្រហមនិងកងទ័ពវៀតណាម ។ សាថន បានរៀបការប្រពន្ធឈ្មោះ អាយ ណាសឿន នៅឆ្នាំ១៩៨២ ហើយអ្នកទាំងពីរមានកូនប្រាំនាក់ ។

សាថន សព្វថ្ងៃជាមន្ត្រីរាជការចូលនិវត្តន៍ ។ សាថន បានដឹងពីដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមច្រើនដែរ ប៉ុន្តែមិនបានទូលំទូលាយដូចប្រជាជននៅតាមទីក្រុងទេ ព្រោះថាប្រព័ន្ធផ្សព្វផ្សាយនៅទីនោះមិនទាន់មានលក្ខណៈទូលំទូលាយ សាថន កំពុងតែទន្ទឹងរង់ចាំមើលថាតើតុលាការខ្មែរក្រហមសម្រេចបានជោគជ័យដែរឬទេ? ទោះបីជាយ៉ាង យើងសង្ឃឹមថាប្រជាជនទាំងអស់ ទាំងបងប្អូនជនជាតិនិងប្រជាជនដែលរស់នៅទីនោះនឹងទទួលបានព័ត៌មានច្រើនជាងមុនអំពីព្រឹត្តិការណ៍ថ្មីទាក់ទងនឹងសង្គម ពិសេសដំណើរនៃការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលមានឈ្មោះជាផ្លូវការថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ។ កាលពីថ្ងៃទី៥ ខែឧសភានេះ អង្គការអភិវឌ្ឍន៍សង្គមបានបើកវេទិកាមួយ ដោយបានអញ្ជើញតំណាងប្រជាជនចំនួន១០០នាក់ មកពីស្រុកផ្សេងៗនៅក្នុងខេត្តនេះ ដើម្បីចូលរួមស្តាប់ការបកស្រាយការរបស់មន្ត្រីតុលាការអំពីប្រព័ន្ធច្បាប់ ដំណើរការវិវត្តន៍របស់តុលាការ ថាតើជនប្រភេទណាខ្លះដែលនឹងត្រូវនាំមកកាត់ទោស និងឆ្លើយនូវចម្ងល់ផ្សេងៗរបស់ប្រជាជន ។ សង្ឃឹមថាប្រជាជនដែលបានចូលរួមនឹងពាំនាំព័ត៌មានទាំងនេះទៅចែករំលែកដល់អ្នកភូមិរបស់ខ្លួនបានគ្រប់គ្នាមិនខាន ។

**លី សុផល**

# គុកខ្មែរក្រហម

**(តពីលេខមុន)**

## ស្រុកស្នួល

### ៨) មន្ទីរសន្តិសុខភ្នំកំណាប់

ភ្នំកំណាប់ ឬទួលសំរ៉ែង មានចម្ងាយប្រហែលមួយគីឡូម៉ែត្រ ខាងលិចផ្លូវជាតិលេខ៧ (ស្នួល-ក្រចេះ) ស្ថិតនៅក្នុងភូមិសំរ៉ែង ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ ។ នៅឆ្នាំ១៩៧២ ខ្មែរក្រហមបានសាងសង់រោងធ្វើអំពីឈើប្រក់ស្បូវប្រមាណ១០ដែលរោងនីមួយៗមានទទឹង៧ម៉ែត្រ និងបណ្តោយ១០ម៉ែត្រ សម្រាប់ធ្វើជាមន្ទីរសន្តិសុខដែលគ្រប់គ្រងដោយឈ្មោះ ដែន។ មន្ទីរនេះឃុំឃាំងអ្នកទោសជាច្រើននាក់ដែលត្រូវអង្គការបញ្ជូនមកមុននឹងសម្លាប់ចោល ឬបញ្ជូនបន្តទៅកាន់ការដ្ឋានលត់ដំខ្លួននៅកន្លែងផ្សេងទៀត។ ភិន គ្រឿន អាយុ៥៧ឆ្នាំ សព្វថ្ងៃជាប្រធានភូមិសំរ៉ែង ឃុំឃ្សឹម ស្រុកស្នួល បាននិយាយថា អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខភ្នំកំណាប់នេះ ជាប្រភេទអ្នកទោសធ្ងន់ ដែលរង់ចាំតែពេលនាំទៅសម្លាប់ចោលប៉ុណ្ណោះ។ ព្រំ អ៊ិន បានរៀបរាប់រឿងរ៉ាវស្តីពីការចាប់មិត្តភក្តិគាត់ចំនួនជាង៧០នាក់មកដាក់នៅក្នុងមន្ទីរនេះ ដោយសារមូលហេតុក្បត់នឹងអង្គការបដិវត្តន៍មានប្រវត្តិរូបមិនល្អ មានបងប្អូនធ្លាប់ធ្វើទាហាន ឬ មន្ត្រីរដ្ឋការជំនាន់លន់នល់ ។ មិត្តភក្តិរបស់ ព្រំ អ៊ិន ទាំងនោះជាអតីតកងទ័ពខ្មែរក្រហមដែលឈរជើងនៅសមរភូមិមុខ មានតួនាទីការពារព្រំដែន និងត្រៀមវាយវៀតណាម ។ អ៊ិន ក៏ធ្លាប់ត្រូវចាប់ខ្លួនម្តងដែរពីបទបានលួចបាយឲ្យខ្មាំងយួន ។ ក្នុងរយៈពេលតែជាងមួយសប្តាហ៍ប៉ុណ្ណោះ គិតចាប់តាំងពីថ្ងៃចាប់ខ្លួនមកកាន់ភ្នំកំណាប់ដំបូង អ្នកទោសទាំងជាង៧០នាក់ត្រូវកងឈ្លបបញ្ជូនបន្តទៅកាន់ការដ្ឋានកោះស្រកានិងអូរសម្ពោច ។ ការដ្ឋានកោះស្រកានិងអូរសម្ពោច ជាទីតាំងលត់ដំខ្លួនរបស់ខ្មែរក្រហមប្រចាំស្រុកក្រចេះ ខេត្តក្រចេះ ។ អ៊ិន ធ្លាប់ឃើញកងឈ្លបធ្វើទារុណកម្មអ្នកទោសនៅលើភ្នំកំណាប់ និងឃើញរោងឃុំឃាំងប្រមាណជាង១០ ដែលសាងសង់ឃ្លាតៗពីគ្នា ។ អ្នកទោសដែលយកទៅឃុំឃាំងនៅទីនោះ មានរយៈពេលមិនលើសពីមួយសប្តាហ៍ឡើយ ។

ក្រោយថ្ងៃរំដោះភ្លាម សុខ ព្រំ បានរាប់រណ្តៅនៅលើភ្នំកំណាប់ ឃើញមានចំនួនជាង៣០រណ្តៅ ។



ព្រំ អ៊ិន ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ

### ៩) មន្ទីរសន្តិសុខព្រៃកូនដៃ

ព្រៃកូនដៃ ជាកន្លែងមួយដែលត្រូវខ្មែរក្រហមជ្រើសរើសសម្រាប់ឲ្យប្រជាជនដែលជម្លៀសមកពីទីឆ្ងាយៗស្នាក់នៅជាបណ្តោះអាសន្ន។ មិនយូរប៉ុន្មាន ព្រៃនេះបានក្លាយទៅជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ដែលស្ថិតនៅភូមិកាត់ដៃ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ ។ មន្ទីរនេះភាគច្រើនឃុំឃាំងជនរងគ្រោះជាប្រជាជន១៧មេសាក្រោយពីបានបំពេញប្រវត្តិរូបរួច ។ គោលបំណងក្នុងការធ្វើប្រវត្តិរូបនេះ គឺខ្មែរក្រហមចង់បានបញ្ជីពិតប្រាកដដើម្បីបញ្ជូនទៅថ្នាក់លើថាបានកម្ទេចអ្នកជាប់និន្នាការពីសង្គមចាស់ និស្សិត និងបញ្ញវន្តដែលមាននៅក្នុងបញ្ជីនេះរួច

ហើយ ។ ចំណែកប្រជាជនដែលពុំមានជាប់ពាក់ព័ន្ធត្រូវខ្មែរក្រហម បញ្ជូនបន្តទៅកាន់ជំរំថ្មីមួយទៀត ។ ការសួរចម្លើយអ្នកទោសបាន ចាប់ផ្តើមជាមួយនឹងការធ្វើទារុណកម្ម តាមវិធីមួយដែលសាហាវ បំផុត ដូចជាចងព្យួរជើងទាញឡើងលើរួចទម្លាក់ចុះមកវិញ និង ចាក់ម្ជុលក្នុងក្រចកបន្តិចៗម្តងជាដើម ។ ទី ញ៉ិ ជាប្រធានភូមិកាត់ ដៃ ឃុំស្នួល បានរៀបរាប់ថា ថ្វីដ្បិតតែមានការធ្វើទារុណកម្មក៏



ទី ញ៉ិ ឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ

ពិតមែន ប៉ុន្តែពុំមានសម្លាប់នៅនឹងកន្លែងទេ គឺបញ្ជូនទៅសម្លាប់ នៅចម្ការកៅស៊ូផ្អក ហៅ “ចម្ការកៅស៊ូលេខ៦៤”ឯណោះ ។

ហេង បេ អាយុ៦៣ឆ្នាំ រស់នៅភូមិកាត់ដៃ ឃុំស្នួល ស្រុក ស្នួល ខេត្តក្រចេះ បានដឹងពីការធ្វើទារុណកម្មនិងបានឃើញកង ឈ្លបបណ្តើរអ្នកទោសទៅធ្វើការបន្ទាប់ពីសួរចម្លើយនិងធ្វើទារុណ- កម្ម ។ ប្រជាជនមូលដ្ឋានខ្លះក្លាយទៅជាអ្នកទោសនៅមន្ទីរសន្តិសុខ ព្រៃកូនជ៉ៃដែរ ដោយសារប្រព្រឹត្តខុសវិន័យរបស់អង្គការ ។ អ្នកទោសប្រភេទនេះត្រូវខ្មែរក្រហមចាត់ទុកជាអ្នកទោសប្រភេទ ស្រាលដែលត្រូវទទួលការអប់រំណែនាំពីកងសន្តិសុខប៉ុណ្ណោះ ។

ជឹង ថ្វាង និង ជឹង កែវ សព្វថ្ងៃរស់នៅភូមិស្នួលវត្ត ឃុំស្នួល ស្រុកស្នួល បានរួចខ្លួនពីការធ្វើទណ្ឌកម្ម និងកាប់សម្លាប់នៅព្រៃ កូនជ៉ៃ ព្រោះអ្នកទាំងពីរជាប្រជាជនមូលដ្ឋាន ។ នួន សម្អាត ជា ប្រធានមន្ទីរសន្តិសុខនៅព្រៃកូនជ៉ៃ សព្វថ្ងៃនៅមានជីវិតនៅ ឡើយ ។ នៅឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះលែងមានអត្ថិភាព ទៀតហើយ ប៉ុន្តែនៅមានស្លាកស្នាមបន្សល់ទុកជាច្រើន ដូចជា ឈើឆ្កាងនិងខ្នោះឃ្នាងជាដើម ។ រហូតមកដល់ពេលនេះ ស្លាក ស្នាមទាំងនោះបានរលាយបាត់ស្ទើរតែទាំងអស់ ។

## ខេត្តមណ្ឌលគិរី

### មន្ទីរសន្តិសុខភ្នំក្រោល

មន្ទីរសន្តិសុខភ្នំក្រោល មានទីតាំងស្ថិតនៅក្នុងភូមិលេខ៩ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។

នៅឆ្នាំ១៩៧០ ខ្មែរក្រហមបាន សាងសង់ផ្ទះមួយខ្នងកម្ពស់ពីរជាន់ធ្វើ អំពីឈើនៅភ្នំក្រោលដែលជាន់លើមាន ១០បន្ទប់ និងជាន់ក្រោមមានមួយបន្ទប់ ដើម្បីធ្វើជាមន្ទីរតំបន់១០៥ ។ ជាន់លើ ជាកន្លែងស្នាក់នៅរបស់កម្មាភិបាល ដែល មកពីកន្លែងឆ្ងាយៗ ហើយជាន់ក្រោម ជាកន្លែងប្រជុំរៀនសូត្រ ។ ឡេង និង សុភា គឺជាប្រធាន និងអនុប្រធានមន្ទីរ នេះ ។

ចាប់ពីឆ្នាំ១៩៧៥មក មន្ទីរនេះបាន ក្លាយទៅជាមន្ទីរសន្តិសុខប្រចាំតំបន់របស់ខ្មែរក្រហម ។ រហូត ដល់ឆ្នាំ១៩៧៧ មន្ទីរសន្តិសុខនេះបានឃុំឃាំងកម្មាភិបាលខ្មែរ ក្រហមបន្ថែមទៀតដែលមានទោសក្បត់នឹងអង្គការ ។ កងសន្តិ សុខបានបែងចែកអ្នកទោសជាពីរផ្នែក ៖ ជាន់លើសម្រាប់ឃុំ ឃាំងអ្នកទោសជាកម្មាភិបាលមានឋានៈធំៗ ហើយជាន់ក្រោម សម្រាប់ឃុំឃាំងអ្នកទោសជាប្រជាជនទូទៅ ។ តាហម តាខាំភូន ដែលជាអតីតប្រធានមន្ទីរសន្តិសុខភ្នំក្រោលត្រូវអង្គការចាប់ខ្លួនពី បទក្បត់បដិវត្តន៍ គាត់ត្រូវបានឃុំឃាំងនៅជាន់លើជាមួយតា ភាន ឃោន។ នេត សាវ៉ាត ជាអនុប្រធានឃុំណងឃីឡឹក និងជា អតីតអ្នកទោសនៅមន្ទីរសន្តិសុខភ្នំក្រោលបានបញ្ជាក់បន្ថែមថា ឈ្មោះ នូ សារុន ហៅ នូ បៃ បានមកគ្រប់គ្រងមន្ទីរបន្តពី តាហម និង តាខាំភូន ហើយបើតាមសម្តីរបស់ ឌួយ ដែន ថាសព្វថ្ងៃនេះ នូ បៃ នៅមានជីវិតនៅឡើយ គឺនៅស្រុកអន្លង់វែង ខេត្តឧត្តរមាន ជ័យ ។ ចាន់ គួច ជាអតីតនិសារគណៈស្រុកកោះញែកឈ្មោះ រ៉ា ហៅ ខាំ តាន ត្រូវអង្គការចាប់ខ្លួននៅភូមិអូរបួនក្រោម ស្រុក

*កោះញែក ខេត្តមណ្ឌលគិរី កាលពីខែវិច្ឆិកា ឆ្នាំ១៩៧៧ ពីបទរួមគំនិតក្បត់ជាមួយ ខាំ ភួន ។ នៅឆ្នាំ១៩៧៩ គួច បានរួចខ្លួនពីការឃុំឃាំងនេះ ។ សាវ៉ាត បន្តថា អ្នកទោសនៅជាន់លើត្រូវកងសន្តិសុខដាក់ខ្នោះជាប់រហូត ហើយក្រោយមកត្រូវដឹកតាមរថយន្តនៅពេលយប់យកទៅសម្លាប់ចោលនៅត្រពាំងគៀន ស្ថិតនៅភូមិព្រៃ ឃុំស្រែសង្គម ស្រុកកោះញែក ។*

*ប៊ុន ឡីងចយ បច្ចុប្បន្នជាអនុប្រធានមន្ទីរព័ត៌មាន បានដឹងច្បាស់ថា អ្នកទោសនៅមន្ទីរសន្តិសុខភ្នំក្រោល ត្រូវកងសន្តិសុខនាំយកទៅសម្លាប់ដាក់ក្នុងរណ្តៅធំមួយនៅទីតាំងត្រពាំងគៀន ។ ប្អូនថ្លៃម្នាក់របស់ សាវ៉ាត ឈ្មោះ អនសារ ជនជាតិឡាវ ក៏ស្ថិតនៅក្នុងចំណោមអ្នកទោសដែលកងសន្តិសុខដឹកទៅសម្លាប់ដែរ ។*

*ក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខភ្នំក្រោលត្រូវប្រជាជនរុះរើបំផ្លាញស្ទើរគ្មានសល់ នៅសេសសល់តែកម្ទេចឥដ្ឋជញ្ជាំងថ្មបែកបាក់ខ្លះៗ និងជណ្តើរថ្មចាស់ទ្រុឌទ្រោមមួយប៉ុណ្ណោះ ។*

## ក្រុងភ្នំពេញ

## ខណ្ឌចម្ការមន

### ១) មន្ទីរសន្តិសុខទួលស្លែង ឬ មន្ទីរ ស-២១

*មន្ទីរសន្តិសុខទួលស្លែង ឬមន្ទីរស-២១ ស្ថិតនៅក្នុងសង្កាត់បឹងកេងកង៣ ខណ្ឌចម្ការមន ទីក្រុងភ្នំពេញ ។*

*ពាក្យថា "ទួលស្លែង" ត្រូវបានមនុស្សជាច្រើនដឹងឮជាទូទៅថាជាទីកន្លែងដែលរបបកម្ពុជាប្រជាធិបតេយ្យ ដឹកនាំដោយ ប៉ុល ពត បង្កើតគុកមួយនៅខែឧសភា ឆ្នាំ១៩៧៥ សម្រាប់ឃុំឃាំងសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ជនទាំងឡាយណាដែលខ្មែរក្រហមចោទប្រកាន់ថាជាខ្មាំងរបស់អង្គការ ។*

*ឆ្នាំ១៩៦២ ទីតាំងនេះជាគ្រឹះស្ថានសិក្សាមួយមានឈ្មោះថា "វិទ្យាល័យពោពញាយ៉ាត" ។ ក្នុងសម័យលន់នល់វិទ្យាល័យនេះត្រូវបានប្តូរឈ្មោះទៅជា"វិទ្យាល័យទួលស្វាយព្រៃ"វិញ ។ នៅជាប់របង ផ្នែកខាងក្រោយមានអគារឈើប្រក់ស្បូវពីរខ្នងជារបស់សាលាបឋមសិក្សាបឹងកេងកង ដែលក្រោយមកទៀតបានប្រែឈ្មោះថា"សាលាបឋមសិក្សាទួលស្លែង"វិញ ។ សព្វថ្ងៃទីតាំងនេះត្រូវបានមនុស្សទូទៅស្គាល់ថាជាកន្លែងឃុំឃាំងមនុស្សធំជាងគេរបស់របបខ្មែរក្រហមដែលមានឈ្មោះថា"គុកទួលស្លែង" ។*

*មន្ទីរស-២១ ឬ គុកទួលស្លែង ស្ថិតនៅក្នុងសង្កាត់ទួលស្វាយព្រៃ ក្រុងភ្នំពេញ ដែលគ្របដណ្តប់លើផ្ទៃដីទំហំ ២៨.០០០ ម៉ែត្រក្រឡា ។ ក្នុងរបបខ្មែរក្រហមបរិវេណមន្ទីរស-២១ ត្រូវបានហ៊ុមពទ្ធ័ដោយរបងស័ង្កសីពីរជាន់ និងមានរាយលួសបន្លាពីលើយ៉ាងស្អេកស្កះ ព្រមទាំងភ្ជាប់ខ្សែភ្លើងដែលមានបញ្ចូលចរន្តអគ្គិសនីទៀតផង ដើម្បីការពារកុំឲ្យអ្នកទោសរត់រួច ។ លើសពីនេះ នៅជុំវិញអគារឃុំឃាំងមានផ្ទះជាច្រើនខ្នងដែលខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរ ឬកន្លែងសម្រាប់ធ្វើកិច្ចការរដ្ឋបាល សួរចម្លើយ និងធ្វើទារុណកម្ម ។*

*មន្ទីរស-២១ មានសាខាជាច្រើនទៀតស្ថិតនៅកន្លែងផ្សេងៗគ្នា ដូចជា មន្ទីរស-២១(ក) មានទីតាំងស្ថិតនៅក្រុងតាខ្មៅ ខេត្តកណ្តាល និងមន្ទីរស-២១(ឃ) នៅព្រៃសជាអតីតគុកសម័យអាណានិគមបារាំង និងស្ថិតនៅប៉ែកខាងលិចទីក្រុងភ្នំពេញក្នុងស្រុកដង្កោ ខេត្តកណ្តាល ។ មន្ទីរស-២១(ឃ) មានឈ្មោះហៅម្យ៉ាងទៀតថា"មន្ទីរ-២៤" ដែលត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជា"ជំរំកសាងខ្លួន" មិនមែនសម្រាប់តែយុទ្ធជនកងពលធំលេខ១៧០របស់ខ្មែរក្រហមប៉ុណ្ណោះទេ គឺសម្រាប់ប្រជាជនគ្រប់ប្រភេទ រួមបញ្ចូលទាំងកម្មាភិបាលមកពីមន្ទីរស-២១ផង ។ មន្ទីរស-២១(ឃ) មាននាទីទទួលខុសត្រូវបង្កបង្កើនផលកសិកម្ម និងផ្គត់ផ្គង់ស្បៀងអាហារសម្រាប់មន្ទីរស-២១ទាំងមូល ។*

*បន្ទប់រៀនទាំងអស់របស់វិទ្យាល័យទួលស្លែង ត្រូវបានប្រែក្លាយជាបន្ទប់ឃុំឃាំងតូចៗជាច្រើន ហើយបង្អួចទាំងអស់នៃអគារឃុំឃាំងនោះ ត្រូវបានបន្ថែមដោយចម្រឹងដែកយ៉ាងរឹងមាំ ។ នៅពីមុខអគារនីមួយៗមានព័ទ្ធទៅដោយលួសបន្លាដែលត្បាញជាក្រឡាសំណាញ់សម្រាប់ការពារកុំឲ្យអ្នកទោសរត់ឬលោតចុះពីខាងលើមកក្រោម ។ បន្ទប់រៀននៅជាន់ក្រោមនិងជាន់ទី១នៃអគារទាំងបួននេះមានខណ្ឌចែកជាបន្ទប់តូចៗទំហំ ០,៨ x ២ ម៉ែត្រ សម្រាប់ឃុំឃាំងអ្នកទោសម្នាក់ៗដាច់ដោយឡែកពីគ្នា ។ នៅជាន់ខាងលើអគារទាំងបួនគឺជាកន្លែងដាក់អ្នកទោសរួមដែលមានទំហំ ៨ x ៦ ម៉ែត្រ ហើយនៅជាន់កណ្តាលជាបន្ទប់សម្រាប់ឃុំឃាំងអ្នកទោសជាស្ត្រីភេទ ។*

*នៅពេលដំបូង អ្នកទោសភាគច្រើន ត្រូវខ្មែរក្រហមយក*

មកឃុំឃាំងនៅបន្ទប់ជាន់ក្រោមនិងជាន់ទី១ ។ កងសន្តិសុខបានយកអ្នកទោសចេញពីបន្ទប់ឃុំឃាំងតូចៗ ទៅសួរចម្លើយនិងធ្វើទារុណកម្មជាសម្ងាត់នៅតាមផ្ទះល្វែងដែលនៅជុំវិញមន្ទីរស-២១ ។ អ្នកទោសស្ត្រីដែលកងសន្តិបាលយកទៅសួរចម្លើយនៅតាមផ្ទះជុំវិញមន្ទីរស-២១ ត្រូវកម្មាភិបាលសួរចម្លើយចាប់រំលោភ ។ ដោយសារមូលហេតុនេះ នៅក្នុងឆ្នាំ១៩៧៨ប្រធានមន្ទីរស-២១ ក៏បានសម្រេចចិត្តយកអគារ(ខ) ធ្វើជាកន្លែងសួរចម្លើយវិញ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងការសួរចម្លើយអ្នកទោសនារី ។

មន្ទីរស-២១ និងសាខាទាំងអស់របស់មន្ទីរនេះស្ថិតនៅក្រោមឱវាទផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម និងសមមិត្ត សុន សេន រដ្ឋមន្ត្រីក្រសួងការពារប្រទេសខ្មែរក្រហម ។ ប៉ុល ពត បានតែងតាំងសមមិត្ត ឌុច ឲ្យធ្វើជាប្រធានគ្រប់គ្រងមន្ទីរសន្តិសុខស-២១នេះ ។ ឌុច ជាឈ្មោះបដិវត្តន៍មានឈ្មោះដើមថា កាំង ហ្កេចអៀវ ជាជនជាតិខ្មែរ ស្រុកកំណើតនៅភូមិជីយោក សង្កាត់កំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ និងមានមុខរបរជាគ្រូបង្រៀន ។

គណៈកម្មាធិការស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានធ្វើរបាយការណ៍នៅក្នុងឆ្នាំ១៩៨៣ថា ក្នុងឆ្នាំ១៩៧៦ដើម្បីរក្សាសន្តិសុខនិងចាត់ចែងរាល់សកម្មភាពទាំងអស់នៅក្នុងមន្ទីរសន្តិសុខស-២១ ខ្មែរក្រហមបានប្រើប្រាស់កម្មាភិបាលយ៉ាងច្រើន ដោយចែកចេញជាបួនអង្គភាព គឺអង្គភាពស-២១, ស-២១(ក), ស-២១(គ) និង ស-២១(ឃ) ហើយបែងចែកកម្លាំងទៅតាមផ្នែកនីមួយៗជា ៈ ក) កម្លាំងផ្ទៃក្នុងចំនួន១៨១នាក់ ខ) ផ្នែកមន្ទីរចំនួន១៨៨នាក់ គ) ផ្នែកសួរចម្លើយចំនួន៥៨នាក់ និង ឃ) ផ្នែកអង្គភាព កម្លាំងអាចធ្វើការបានចំនួន១៣៧៧នាក់ ។ សរុប ១៧២០នាក់ ។

នៅក្នុងក្រុមនីមួយៗមានចែកចេញជាក្រុមតូចៗច្រើនទៀតដែលសុទ្ធតែកុមារានិងកុមារីអាយុពី១០ទៅ១៥ឆ្នាំ ហើយក្មេងៗទាំងអស់នោះ ត្រូវខ្មែរក្រហមជ្រើសរើសយកមកអប់រំបណ្តុះបណ្តាលឲ្យធ្វើជាឆ្មាំយាមអ្នកទោស ។

ការងារផ្សេងៗត្រូវបានចាត់ចែងដោយមន្ទីរចំនួនពីរគឺមួយជារបស់សមមិត្ត ឌុច និងមួយទៀតជាកន្លែងសម្រាប់ប្រមូលរបាយការណ៍សួរចម្លើយ និងធ្វើកិច្ចការរដ្ឋបាលទូទៅ ។ អ្នកទោសដែលមានជំងឺ ឬរងរបួសត្រូវទទួលការព្យាបាលនៅតាមបន្ទប់រៀងៗខ្លួន ហើយក្នុងមួយថ្ងៃព្យាបាល៣ដង ប៉ុន្តែគ្មានសេវាពេទ្យបម្រើនៅក្នុងគុកទេ ។ កម្មាភិបាលពេទ្យនៅក្នុងមន្ទីរ សុទ្ធតែជាយុទ្ធជនវ័យក្មេងៗ ដែលគ្មានចេះអ្វីក្រៅពីចែកថ្នាំអាចម៍ទន្សាយដែលខ្មែរក្រហមផលិតដោយខ្លួនឯងនិងរុំរបួសបន្តិចបន្តួចប៉ុណ្ណោះ ។

អ្នកទោសដែលខ្មែរក្រហមឃុំឃាំងក្នុងមន្ទីរស-២១ មានគ្រប់ស្រទាប់វណ្ណៈ គ្រប់ជនជាតិ ដែលរស់នៅក្នុងប្រទេសកម្ពុជាដូចជាវៀតណាម ឡាវ ថៃ ឥណ្ឌា ប៉ាគីស្ថាន អង់គ្លេស អាមេរិក និងកាណាដា ។ល។ អ្នកទោសជាជនស៊ីវិលវិញមានដូចជា កម្មករ កសិករ វិស្វករ អ្នកបច្ចេកទេស បញ្ញវន្ត សាស្ត្រាចារ្យ គ្រូបង្រៀន និស្សិត សិស្សានុសិស្ស រហូតដល់មន្ត្រី និងអ្នកការទូត លើសពីនេះទៀតគ្រួសារអ្នកទោសទាំងអស់រាប់ចាប់ពីក្រោម ទៅលើរួមបញ្ចូលទាំងទារកដែលទើបនឹងកើតផង ត្រូវខ្មែរក្រហមប្រមូលយកមកទីនេះទាំងហ្វូងៗដើម្បីសម្លាប់ឲ្យផុតពូជ ។

យោងតាមឯកសារខ្មែរក្រហមដែលរកឃើញនៅក្នុងបណ្ណសារដ្ឋានទួលស្លែងបានឲ្យដឹងថា រាល់ពេលនាំអ្នកទោសចូលនិងចេញពីគុកទួលស្លែងចាប់ពីឆ្នាំ១៩៧៥ដល់ខែមិថុនា ឆ្នាំ១៩៧៨ ត្រូវបានកត់ត្រាទុកយ៉ាងច្បាស់នៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅទីនោះ ។ ក្រៅពីឯកសារទាំងនេះពុំមានឯកសារផ្សេងទៀតត្រូវបានរកឃើញទេ ។ ឯកសារមួយចំនួនត្រូវបានបាត់បង់ ។ ក្នុងនោះមានឯកសារមួយបានកត់ត្រាពីចំនួនអ្នកទោសដូចតទៅ ៈ ឆ្នាំ១៩៧៥មាន ១៥៤នាក់, ឆ្នាំ១៩៧៦មាន ២.២៥០នាក់, ឆ្នាំ១៩៧៧មាន ២.៣៣០នាក់ និងឆ្នាំ១៩៧៨ មាន ៥.៧៦៥នាក់ ។

តួលេខទាំងអស់នេះ សរុបមានចំនួន១០៤៩៩នាក់ ដោយពុំទាន់រាប់បញ្ចូលកុមារតូចៗដែលខ្មែរក្រហមបានសម្លាប់ទេ ហើយបើតាមការប៉ាន់ប្រមាណនៅក្នុងឯកសារដដែលថា មានចំនួន២០០០នាក់ ។

របាយការណ៍ទាំងអស់នេះស្តែងឲ្យឃើញថា នៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ មន្ទីរសន្តិសុខទួលស្លែងបានចាប់

អ្នកទោសឃុំឃាំងជាមធ្យមចន្លោះពី១.២០០ទៅ១.៥០០នាក់ ក្នុងមួយលើកៗ ។ រយៈពេលឃុំឃាំងមានពី២ទៅ៤ខែ ហើយអ្នកទោសខ្លះទៀតដែលពាក់ពន្ធ័រឿងនយោបាយត្រូវឃុំឃាំងរហូតដល់៦ឬ៧ខែក៏មាន ។

អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងបន្ទប់តូចៗដាច់ដោយឡែកពីគ្នា ត្រូវបានដាក់ខ្នោះជើងដោយរនុងដែកដែលកិបសោភ្ជាប់ប្រវាក់ទៅនឹងជញ្ជាំង ឬកម្រាលឥដ្ឋ ។ នៅក្នុងបន្ទប់ឃុំឃាំងរួមវិញ អ្នកទោសត្រូវឆ្មាំគុកដាក់ខ្នោះជើងម្ខាង ឬទាំងសងខាងតាមទោសកំហុសរបស់អ្នកនោះដោយខ្ទាស់ជាប់នឹងរនុងដែកវែងឬខ្លីមួយ ។ រនុងដែកខ្លីមានប្រវែងពី០,៨០ម៉ែត្រទៅ១ម៉ែត្រ



អគារឃុំឃាំងអ្នកទោសនៅក្នុងមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

សម្រាប់ដាក់មនុស្សម្នាក់ឬបួននាក់ ។ រនុងដែកវែងមានប្រវែង៦ម៉ែត្រ អាចដាក់ខ្នោះជើងអ្នកទោសពី២០ទៅ៣០នាក់ ដោយឆ្មាំគុកតម្រូវឲ្យអ្នកទោសដេកបញ្ច្រាសក្បាលគ្នា ។

មុននឹងយកអ្នកទោសទៅដាក់នៅក្នុងបន្ទប់ឃុំឃាំង ខ្មែរក្រហមបានថតរូបអ្នកទោសទុកជាឯកសារមុននឹងឲ្យសរសេរប្រវត្តិរូបពិស្តារ និងដោះសម្លៀកបំពាក់ចេញទុកតែខោខ្លីប៉ុណ្ណោះ ។ របស់របរ ឬសម្ភារផ្សេងៗរបស់អ្នកទោសត្រូវដកយកទាំងអស់ សូម្បីតែក្រដាសតូចមួយសន្លឹកក៏មិនទុកឲ្យដែរ ។ អ្នកទោសត្រូវតែដេកលើកម្រាលឥដ្ឋផ្ទាល់ ដោយមិនចាំបាច់មានកន្ទេល មុងខ្នើយ ឬ ភួយឡើយ ។ រៀងរាល់ព្រឹកនៅម៉ោង៤កន្លះ អ្នកទោសត្រូវឆ្មាំគុកបញ្ជាឲ្យ ស្រាតខោត្រឹមក្បាល ជន្លង់ដើម្បីឲ្យបុគ្គលិកមន្ទីរស-២១ធ្វើការ ត្រួតពិនិត្យ ។ បន្ទាប់ មកអ្នកទោសត្រូវបញ្ជាឲ្យហាត់ប្រាណ រយៈពេលកន្លះម៉ោង ដោយធ្វើចលនាដៃ-ជើង លើកចុះឡើង ទាំងជើងនៅជាប់រនុង ដែកនិងខ្នោះដដែល ។ កងសន្តិសុខបានធ្វើការត្រួតពិនិត្យអ្នកទោស៤ដងក្នុងមួយថ្ងៃ ហើយជួនពេលខ្លះមានកងពិសេសមកពីថ្នាក់លើធ្វើការត្រួតពិនិត្យលើអ្នកទោសទាំងអស់ថែមទៀត ។ ក្នុងពេលត្រួតពិនិត្យម្តងៗ អ្នកទោសត្រូវដាក់ដៃទាំងពីរទៅក្រោយខ្នង ហើយលើកជើងឡើងលើដើម្បីឲ្យអ្នកយាមអាចត្រួតពិនិត្យមើលខ្នោះជើងថា តើរលុងឬអត់? អ្នកទោសត្រូវបន្ទោរបង់ដាក់ក្នុងសំបកកេសដែកដាក់គ្រាប់កាំភ្លើងមួយនិងនោមដាក់ក្នុងធុងជ័រតូចមួយដែលដាក់ក្នុងបន្ទប់ឃុំឃាំងតែម្តង ។ មុននឹងបន្ទោរបង់ អ្នកទោសត្រូវសុំការអនុញ្ញាតពីឆ្មាំគុកជាមុនសិន បើពុំនោះទេនឹងត្រូវឆ្មាំគុកពិន័យ ដោយការវាយដំ ឬក៏ទទួលរងការវាយនឹងខ្សែតីពី២០ទៅ៦០រំពាត់ ។ នៅក្នុងបន្ទប់គុកនីមួយៗមានវិន័យសន្តិបាលមួយច្បាប់បិទនៅលើក្តារខៀនមួយដែលមានអត្ថន័យដូចខាងក្រោម ៖

១) សួរអីឆ្លើយហ្នឹង មិនបង្វែងសំណួររបស់អញ ។

២) ហាមមិនឲ្យដោះសាយកលេសនេះលេសនោះតាមគំនិតឯង ឬប្រកែកតមាត់ជាដាច់ខាត ។

៣) មិនឲ្យធ្វើល្ងង់មិនយល់បញ្ហា ព្រោះឯងជាមនុស្សហ៊ានប្រឆាំងបដិវត្តន៍ ។

៤) សួរភ្លាមឆ្លើយភ្លាម មិនដំអក់មួយនាទីឡើយ ។

៥) រឿងខុះខាត កំហុសបន្តិចបន្តួច ដូចជាសីលធម៌ ខូចនេះខូចនោះ ក៏មិនឲ្យនិយាយរឿងខ្លឹមសារបដិវត្តន៍ក៏មិនឲ្យនិយាយ ។

៦) វាយ ឬឆក់ខ្សែភ្លើង មិនឲ្យស្រែកឮជាដាច់ខាត ។

៧) មិនឲ្យធ្វើអ្វីទាំងអស់ គឺអង្គុយស្ងៀមរង់ចាំបញ្ជារបស់អញ អត់បញ្ជាកុំធ្វើ អញបញ្ជាអ្វីធ្វើហ្នឹងភ្លាម ប្រកែកប្រិមប្រុមមិនបាន ទេ ។

៨) កុំយកលេសកម្ពុជាក្រោម បាំងមុខមាត់ក្បត់បដិវត្តន៍របស់អាឯងឲ្យសោះ ។

៩) គ្រប់បញ្ហាខាងលើមិនធ្វើតាម គឺមួយថ្ងៃៗរងរំពាត់ខ្សែភ្លើងឆក់រាប់មិនឈ្នះទេ ។

១០) ប្រឆាំងវិន័យអញមួយចំណុច ត្រូវរងរំពាត់១០រំពាត់ ឬឆក់ខ្សែភ្លើង៥ឆាប់ ។

វិន័យសន្តិបាលខាងលើនេះ តម្រូវឲ្យអ្នកទោសគោរពឲ្យបានហ្មត់ចត់ ។ នៅពេលដេកទោះជាចង់ប្រែខ្លួន ងើបអង្គុយ ឬធ្វើអ្វីៗទៀត ក៏ត្រូវមានការអនុញ្ញាតពីអ្នកយាមដែរ ។ អ្នកទោសណាដែលរំលោភលើបទបញ្ជានេះ ត្រូវទទួលរងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរមួយរំពេច ។ រយៈពេល២ឬ៣ថ្ងៃ ជួនកាល១៥ថ្ងៃ ទើបឲ្យងូតទឹកម្តងទៀត អ្នកទោសត្រូវងូតទឹកនៅក្នុងបន្ទប់ឃុំឃាំងរួម ដោយខ្មែរក្រហមបានបញ្ចូលទុយោទឹកតាមប្រឡោះបង្អួចបាញ់ស្រោចលើអ្នកទោសតែមួយភ្លែតប៉ុណ្ណោះ ។ ការខ្វះអនាម័យជាហេតុបណ្តាលឲ្យអ្នកទោសកើតកមរមាស់ពេញខ្លួន និងជំងឺផ្សេងៗ ហើយគ្មានថ្នាំព្យាបាលឲ្យបានត្រឹមត្រូវឡើយ ។

បន្ទាប់ពីបរាជ័យរបស់ខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មន្ទីរសន្តិសុខទួលស្លែងបានក្លាយទៅជាសារមន្ទីរឧក្រិដ្ឋ-កម្មប្រល័យពូជសាសន៍ទួលស្លែង ហើយបានចាប់ផ្តើមបើកទ្វារឲ្យភ្ញៀវជាតិនិងអន្តរជាតិយ៉ាងច្រើនកុះករចូលទស្សនារហូតមកដល់សព្វថ្ងៃ ។ ចំនួនភ្ញៀវទេសចរដែលចូលមកទស្សនាមាន២ដំណាក់កាល ៖ ដំណាក់កាលទី១ ក្រោយឆ្នាំ១៩៧៩ ជាសម័យកាលគ្រប់គ្រងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា អ្នកមកទស្សនាភាគច្រើនជាភ្ញៀវជាតិ ។ ចំណែកភ្ញៀវបរទេសច្រើនតែជាភ្ញៀវមកពីប្រទេសសង្គមនិយមដូចជា វៀតណាម សូវៀត ឡាវ ហុងគ្រី ប៉ូឡូញ និងបណ្តាប្រទេសនៅអឺរ៉ុបខាងកើតជាដើម ។ ដំណាក់កាលទី២ ៖ ក្រោយពេលបោះឆ្នោតឆ្នាំ១៩៩៣ ភ្ញៀវទេសចរភាគច្រើនជាភ្ញៀវមកពីប្រទេសតៃវ៉ាន់ ជប៉ុន បារាំង អាល្លឺម៉ង់ កូរ៉េ អាមេរិក អង់គ្លេស និងបណ្តាប្រទេសប៉ែកខាងលិចមួយចំនួនទៀត ។

ចំនួនភ្ញៀវជាតិនិងអន្តរជាតិ ដែលចូលមកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង គិតជាមធ្យមប្រហែល ៥០នាក់ក្នុងមួយថ្ងៃ ។ ស្ទើរតែគ្រប់ភ្ញៀវទេសចរដែលធ្វើដំណើរមកកម្សាន្តក្នុងព្រះរាជាណាចក្រកម្ពុជា តែងតែឆៀងចូលមកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងមិនសូវអាក់ខានឡើយ ។

## ២) មន្ទីរសន្តិសុខ នៅវិទ្យាល័យបឹងត្របែក

មន្ទីរសន្តិសុខនៅវិទ្យាល័យបឹងត្របែក ស្ថិតនៅសង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន ក្រុងភ្នំពេញ ។ វិទ្យាល័យបឹងត្របែកជាជំរំឃុំឃាំងនិស្សិតដែលត្រឡប់មកពីសិក្សានៅបរទេស ។ មន្ទីរនេះបង្កើតឡើងបន្ទាប់ពីជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

តាំងពីឆ្នាំ១៩៧៥រហូតមកដល់ឆ្នាំ១៩៧៨ មាននិស្សិតច្រើននាក់ណាស់ដែលធ្វើដំណើរមកស្រុកវិញ ដើម្បីជួយកសាងប្រទេស ប៉ុន្តែពេលមកដល់អ្នកទាំងនេះត្រូវអង្គការបញ្ជូនទៅកាន់មន្ទីរឃុំឃាំងនៅវិទ្យាល័យបឹងត្របែក ដើម្បីអប់រំសតិអារម្មណ៍ និងហាត់រៀនធ្វើការមុននឹងបញ្ជូនទៅកាន់កន្លែងផ្សេងទៀត ។ វិទ្យាល័យបឹងត្របែកត្រូវខ្មែរក្រហមផ្តល់ឈ្មោះថា "មន្ទីរអប់រំសតិអារម្មណ៍និងការងារ" ។ ជាកន្លែងសម្រាប់លាងជម្រះចិត្តគំនិតរបស់និស្សិតដែលនៅជាប់កម្អែលសក្តិភូមិនាយទុន.... ពីសង្គមមុនឲ្យជ្រះស្រឡះ ដើម្បីបន្តវេនកសាងបដិវត្តន៍មួយស្អាត


ទិដ្ឋភាពខាងក្រោយរបស់មន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

ស្ពុំ និងគ្មានការជិះជាន់គ្នាទៅវិញទៅមក ។ ការស្នាក់នៅ ការហូបចុក ការស្លៀកពាក់ អង្គការមិនសូវរើសបន្តិចប៉ុន្មានឡើយ ប៉ុន្តែនិស្សិតទាំងអស់ត្រូវតែគោរពតាមបទបញ្ជារបស់ថ្នាក់លើជាដាច់ខាត ទោះជាក្នុងកាលៈទេសៈណាក៏ដោយ ។

ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងមួយត្រូវបានអនុវត្តឡើងសម្រាប់និស្សិតទាំងអស់ ទាំងការស្នាក់នៅ ការធ្វើការងារ និងការហូបចុក ។ រចនាសម្ព័ន្ធនេះមានចែកចេញជាពីរផ្នែកធំៗគឺ ការគ្រប់គ្រងកម្រិតខ្ពស់ និងកម្រិតទាប ។ ការគ្រប់គ្រងកម្រិតខ្ពស់ គឺមានកម្មាភិបាលខ្មែរក្រហមដែលអង្គការចាត់តាំងមកពីថ្នាក់លើជាអ្នកត្រួតត្រាដោយផ្ទាល់ ។ ចំណែកការគ្រប់គ្រងកម្រិតទាបវិញ មានចែកចេញជា៣មណ្ឌលទៀតគឺមណ្ឌល៣០ មណ្ឌល៣១ និងមណ្ឌល៣២ ។ មណ្ឌលទាំង៣នេះគ្រប់គ្រងដោយនិស្សិតដែលមកពីបរទេសដូចគ្នាក្រោមការចាត់តាំង និងរៀបចំពីកម្មាភិបាលខ្មែរក្រហមដែលជាអ្នកត្រួតត្រាចម្បងនៅក្នុងមន្ទីរ ។ ក្នុងមណ្ឌលនីមួយៗមាន ក្រុមតូចៗជាច្រើនទៀតជាចំណុះ ហើយដែលក្នុងមួយក្រុមៗមាននិស្សិតម្នាក់ជាប្រធាន និងសមាជិកចំនួន១០នាក់ ។ ប្រធានមណ្ឌលត្រូវទទួលធ្វើកិច្ចការផ្សេងៗពីកម្មាភិបាលខ្មែរក្រហមដែលជាអ្នកគ្រប់គ្រងពីលើ ។ ចំណែកប្រធានក្រុមនីមួយៗ ជាអ្នកទទួលការងារយកទៅធ្វើបន្តជាមួយសមាជិកក្រុមរបស់ខ្លួនពីប្រធានមណ្ឌល ។

ហែម វណ្ណា ជាជនរងគ្រោះម្នាក់នៅមន្ទីរសន្តិសុខវិទ្យាល័យបឹងត្របែកកាលពីជំនាន់ខ្មែរក្រហម ។ បច្ចុប្បន្ន វណ្ណា ជាសាស្ត្រាចារ្យម្នាក់បង្រៀនមុខវិជ្ជាភាសាបារាំងនៅសកលវិទ្យាល័យភ្នំពេញ ។ វណ្ណា រស់នៅក្នុងបរិវេណគុកបឹងត្របែករហូតដល់ថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ។ វណ្ណា និយាយប្រាប់ថា មានអ្នកទោសជានិស្សិតនិងបញ្ញវន្តជាង១០០នាក់ ដែលស្ម័គ្រចិត្តវិលត្រឡប់មកពីបរទេស ដើម្បីចូលរួមបម្រើជាតិមាតុភូមិតាមការឃោសនាគួរឲ្យទុកចិត្តមួយ បានជាប់ឃុំឃាំងនៅក្នុងវិទ្យាល័យបឹងត្របែកនេះ ដោយត្រូវរស់នៅក្រោមការគ្រប់គ្រងយ៉ាងតឹងរឹងរបស់ខ្មែរក្រហម ។

ទេព វុត្ថា ជាប្រធាននាយកដ្ឋានឧស្សាហកម្មរ៉ែនិងថាមពលនៃទីស្ដីការគណៈរដ្ឋមន្ត្រី ក៏ជាជនរងគ្រោះម្នាក់ដែរ ក្នុងចំណោមជនរងគ្រោះជាង១០០នាក់ដែលជាប់នៅក្នុងមន្ទីរអប់រំសតិអារម្មណ៍និងការងារបន្ទាប់ពីវិលត្រឡប់មកពីប្រទេសរូម៉ានីវិញ ។ វុត្ថា បាននិយាយឲ្យដឹងពីការឃោសនាមួយដែលបញ្ចុះបញ្ចូលឲ្យនិស្សិតគ្រប់រូបវិលត្រឡប់មកកាន់មាតុប្រទេសដើម្បីពួតដៃគ្នាកសាងប្រទេសឡើងវិញ ។ ចំណែកនិស្សិតមួយចំនួនដែលជាជនជាតិផ្សេងៗ ក៏មកជាប់នៅក្នុងមន្ទីរសន្តិសុខបឹងត្របែកជាមួយនិស្សិតខ្មែរដែរ ព្រោះខ្លះជាប្តី ឬប្រពន្ធរបស់និស្សិតខ្មែរ ។

នៅជុំវិញបរិវេណវិទ្យាល័យទាំងមូលគឺជាវាលស្រែដែលខ្មែរក្រហមបង្កើតឡើងសម្រាប់ឲ្យនិស្សិតទាំងនោះ រៀនលត់ដំខ្លួន ។ នៅខាងក្នុងបរិវេណមន្ទីរ ខ្មែរក្រហមបានបង្កើតឲ្យមានកន្លែងសិប្បកម្មតូចៗ និងរោងជាងជួសជុលគ្រឿងយន្តផ្សេងៗ ។ ការងារជំនាញបច្ចេកទេសត្រូវបានបង្ហាត់បង្រៀនដល់និស្សិតទាំងឡាយណាដែលពុំសូវថ្នឹក ឲ្យកាន់តែមានជំនាញច្បាស់លាស់ថែមទៀត តាមរយៈការលត់ដំហាត់រៀនជាប្រចាំដែលមិនអាចគេចវេះបាន ។ ប៉ុន្តែសម្រាប់អ្នកទោសជានិស្សិតដែលគ្មានជំនាញអ្វីសោះ ត្រូវសន្តិបាលបណ្តើរចេញទៅធ្វើការនៅទីឆ្ងាយៗ ពីមន្ទីរសន្តិសុខ ដូចជាទៅច្រូតស្រូវ ស្ទូងស្រូវ បារកំប្លោក និងលើកទំនប់ជាដើម ។ ក្នុងរយៈពេលប្រហែល១ខែ ឬ ២ខែម្ដង ទើបក្រុមកសិកម្មនេះត្រូវបានអនុញ្ញាតឲ្យមកកាន់វិទ្យាល័យបឹងត្របែកវិញ ។

ក្រៅពីក្រុមខាងលើនេះ នៅមានក្រុមផ្សេងៗទៀតដែលមានមុខងារខុសៗគ្នាទាំងប្រភេទការងារជំនាញ កម្លាំងកាយ និងសមត្ថភាព ។ ដោយហេតុថាមានការងារជាច្រើនត្រូវបំពេញ ទើបកម្មាភិបាលខ្មែរក្រហមបានបែងចែកការងារសម្រាប់អ្នកទោសជា៤ផ្នែកផ្សេងពីគ្នាទៅតាមកម្រិតសមត្ថភាពរបស់ក្រុមនីមួយៗ ។ ផ្នែកទាំង៤នេះមាន ៖ ផ្នែកកសិកម្ម ផ្នែកសិប្បកម្ម ផ្នែកឧស្សាហកម្មធុនតូច និងផ្នែកកើបលាមក ។ ផ្នែកកសិកម្មមានការងារធ្វើច្រើនអនេកដូចជា ធ្វើស្រែ ដកស្ទូង ច្រូតកាត់ បោកបែន ចិញ្ចឹមសត្វ (ជ្រូក មាន់ ទា) ដាំបន្លែ (ល្ពៅ ត្រកួន ននោង ត្រាវ ស្ពៃ ។ល ។) ។ ក្រុមសិប្បកម្មត្រូវមានការងារធ្វើដូចជាធ្វើចៅត ធ្វើដែកគោល ធ្វើកន្ត្រៃកាត់ដែកនិងសំណ ធ្វើកញ្ជៀវ កាំបិត ញញួរ ។ល ។ ចំណែកក្រុមឧស្សាហកម្មធុនតូចវិញ គឺជួសជុល

គ្រឿងយន្តចាស់ៗដូចជា ជួសជុលម៉ាស៊ីនកាណូត កប៉ាល់ និង ជួសជុលរថយន្តគ្រប់ប្រភេទ ។ ការងារទាំងអស់ត្រូវអនុវត្តការបង្ខំឲ្យធ្វើគ្មានពេលសម្រាក ជួនពេលខ្លះធ្វើ ទាំងយប់ទាំងថ្ងៃថែមទៀត ។ បើបំពេញកិច្ចការមិនបានសម្រេចតាមផែនការទេ ប្រាកដជាត្រូវផ្ទាក់លើផ្ទាស់ទៅធ្វើការខាងផ្នែកកើបលាមកវិញមិនខាន ។ ក្រុមកើបលាមក ជាក្រុមមួយដែលបញ្ចេញកម្លាំងពលកម្មតិចបំផុត ព្រោះជាក្រុមដែលសម្បូរទៅដោយមនុស្សខ្ជិល និងធ្វើកិច្ចការធ្ងន់មិនបាន ។ កិច្ចការមួយទៀតរបស់ក្រុមកើបលាមកគឺ ជញ្ជូនយកទៅលាយជាមួយនឹងទឹកដើម្បីត្រៀមទុកឲ្យក្រុមកសិកម្មយកទៅស្រោចស្រព ដំណាំ ឬយកទៅដាក់ស្រែ ។ ក្រុមការងារទាំងអស់ត្រូវតែបំពេញកិច្ចការឲ្យបានដិតដល់ និងមិនអាចធ្វេសប្រហែសបានឡើយ ព្រោះវាទាក់ទងនឹងរបបអាហារប្រចាំថ្ងៃរបស់ពួកគេ ។ រោងបាយនៅក្នុងមន្ទីរសន្តិសុខបឹងត្របែក គឺជារោងបាយរួមសម្រាប់អ្នកទោសនិស្សិតទូទៅ ។ ការហូបចុកត្រូវធ្វើឡើងនៅតាមក្រុមរៀងៗខ្លួន ទោះបីជាមានក្រុមសេដ្ឋកិច្ចជាអ្នកមើលការខុសត្រូវលើរបបស្បៀងអាហារក៏ដោយ ។ របបអាហារប្រចាំថ្ងៃសម្រាប់អ្នកទោសគឺបបរលាយពោត ។ ចំណែកម្ហូបក្រុមនីមួយៗត្រូវស្វែងរកដោយខ្លួនឯង ។ អ្នកទោសភាគច្រើនតែងតែទៅនេសាទ ឬស្ទូចត្រីពីក្នុងថ្លុកត្រពាំងដែលស្ថិតនៅក្នុងបរិវេណវិទ្យាល័យបឹងត្របែក ដើម្បីយកមកស្ងជាមួយបន្លែផ្សេងៗ ។ ក្នុងការស្វែងរកម្ហូបអាហារនេះ កម្មាភិបាលគ្រប់គ្រងមន្ទីរទាំងមូលមិនដែលហាមឃាត់ ឬដាក់ទោសអ្វីឡើយ ។ អ្នកទោសក៏មិនដែលបានហូបបាយដែរ លើកលែងតែថ្ងៃចូលឆ្នាំខ្មែរប៉ុណ្ណោះ ដែលអ្នកទោសអាចហូបបាយជាមួយសម្លមានសាច់ ។

យូរៗទើបមានការប្រជុំម្តង ដែលភាគច្រើននិយាយតែពីបញ្ហាការងារប៉ុណ្ណោះ ។ អ្នកទោសខ្លះត្រូវបាត់ខ្លួន បន្ទាប់ពីចប់ការប្រជុំ ពីព្រោះអ្នកទាំងនោះហ៊ានរិះគន់របៀបដឹកនាំរបស់អ្នកគ្រប់គ្រងវិទ្យាល័យបឹងត្របែក លើកឡើងនូវបញ្ហាខ្លះៗ ដូចជាការផ្តល់របបអាហារមិនគ្រប់គ្រាន់ ការបង្ខំឲ្យធ្វើការងារហួសកម្លាំងជាដើម និងបានទាញហេតុផលមួយចំនួនពីការឃោសនារបស់ អៀង សារី ដោយធ្វើការប្រៀបធៀបនឹងស្ថានភាពបច្ចុប្បន្ននេះផង ។ បន្ទាប់ពីប្រជុំរួមក្នុងមន្ទីរទាំងមូលរួច ប្រធានមណ្ឌលនីមួយៗបានតម្រូវឲ្យមានការប្រជុំតាមក្រុមតូចៗទៀត ហើយការប្រជុំនេះបានកើតមានស្ទើរតែពីរដងក្នុងមួយថ្ងៃ ភាគច្រើននៅពេលល្ងាច និងពេលសម្រាកពីការងារ ។ របៀបវារៈនៃអង្គប្រជុំគឺទិតៀនកែលម្អគ្នាទៅវិញទៅមក និងលើកទិសដៅការងារទៅថ្ងៃមុខ ទៀត ។

នៅក្នុងមន្ទីរទាំងមូលពុំមានការធ្វើទារុណកម្ម ឬសួរចម្លើយឡើយ ។ តាំងពីឆ្នាំ១៩៧៥មក សកម្មភាពការងារនៅក្នុងមន្ទីរបានប្រព្រឹត្តទៅជាធម្មតានិងពុំមានផ្លាស់ប្តូររបៀបរបបឡើយ ។

ទួលស្លែង គឺជាទីតាំងចុងក្រោយនិងជាកន្លែងធ្វើទារុណកម្មហួសប្រមាណតែមួយគត់សម្រាប់និស្សិត ដែលហ៊ានទិតៀនរបបបដិវត្តន៍ ។ វណ្ណា បានឃើញរូបថតមិត្តភក្តិដែលធ្លាប់ជាប់នៅក្នុងមន្ទីរអប់រំសតិអារម្មណ៍ជាមួយគាត់រហូតដល់ទៅជិត ១០០នាក់ ដែលបិទភ្ជាប់នឹងជញ្ជាំងសារមន្ទីរឧក្រិដ្ឋកម្មទួលស្លែង កាលពីអំឡុងឆ្នាំ១៩៨០ ។ ព្រឹត្តិការណ៍នេះបានធ្វើឲ្យ វណ្ណា នឹកឃើញដល់ការបញ្ជូនអ្នកទោសចេញម្តង ១០ ឬ ២០នាក់ដោយប្រើពាក្យមួយឃ្លាថា ត្រូវផ្លាស់ប្តូរទីលំនៅ ។ ការនាំយកអ្នកទោសចេញបន្ទាប់ពីការប្រជុំចប់ បានធ្វើឲ្យ វណ្ណា ចាប់អារម្មណ៍ពីការនិយាយតវ៉ា និងជជែកវែកញែករបស់អ្នកទោសនៅក្នុងពេលប្រជុំម្តងៗ ។

ក្រោយរបបខ្មែរក្រហមដួលរលំ និស្សិតដែលជាប់នៅក្នុងមន្ទីរសន្តិសុខបឹងត្របែក ត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើដំណើរតាមរថភ្លើងចេញទៅកាន់ព្រំដែនថៃ ។ ទេព វុត្ថា បាននិយាយពីគោលបំណងនេះថា ដើម្បីគេចឲ្យផុតពីការវាយលុករបស់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ ប៉ុន្តែការធ្វើដំណើរនេះត្រូវបានកាត់ផ្តាច់នៅត្រង់ស្ពានីយស្តុកអាចម៍រមាសស្ថិតនៅក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។

មន្ទីរអប់រំសតិអារម្មណ៍ និងការងារនៃវិទ្យាល័យបឹងត្របែក បានបន្សល់ទុកនូវឧបករណ៍ប្រើប្រាស់មួយចំនួន ដែលស្ថិតនៅរាយប៉ាយពាសពេញទីធ្លាវិទ្យាល័យទាំងមូល ។ សព្វថ្ងៃវិទ្យាល័យបឹងត្របែក ជាគ្រឹះស្ថានសិក្សាមួយ ដែលបំពេញតួនាទីទទួលសិស្សឲ្យចូលរៀនរៀងរាល់ឆ្នាំ ។

**ផេង ពង្សរ៉ាស៊ី**

# ដំណើរចុងក្រោយឆ្លងកាត់បឹងទន្លេសាប

ដំណើរនៅក្នុងរបបខ្មែរក្រហមជាដំណើរមួយវែងឆ្ងាយនិងប្រកបដោយគ្រោះថ្នាក់ ។ ប្រជាជនថ្មីឬប្រជាជន១៧មេសាគ្រប់រូបត្រូវបានបញ្ជូនពីកន្លែងមួយទៅកន្លែងមួយដោយគ្មានគោលដៅពិតប្រាកដ ។ ទោះជាប្រជាជនចាស់ឬប្រជាជនមូលដ្ឋានមានបុព្វសិទ្ធិច្រើនជាងប្រជាជនថ្មីក៏ដោយ ក៏អ្នកទាំងនេះមួយចំនួនត្រូវបានបង្ខំឲ្យធ្វើដំណើរទៅរស់នៅនិងធ្វើការនៅកន្លែងផ្សេងៗទៀត ។ ជា យាន និងក្រុមគ្រួសារដែលជាអ្នកមូលដ្ឋានចាស់ក្នុងខេត្តព្រៃវែងនៃភូមិភាគបូព៌ាត្រូវបានជម្លៀសទៅជាច្រើនកន្លែង ហើយចុងក្រោយត្រូវបានផ្លាស់ឲ្យទៅរស់នៅស្រុកមោងឫស្សីក្នុងខេត្តបាត់ដំបង ។ យាន និងក្រុមគ្រួសារ បានត្រឡប់មករស់នៅស្រុកកំណើតវិញក្រោយការដួលរលំនៃរបបនេះ ។ យាន បានរៀបរាប់ពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហមដែលមានដូចខាងក្រោមនេះ ។


ជា យាន

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ជីវិតរស់នៅរបស់ប្រជាជនក្នុងខេត្តព្រៃវែងបានជួបប្រទះនូវការប្រទាញប្រទង់គ្នាយ៉ាងខ្លាំងរវាងកងទ័ពរំដោះដែលដឹកនាំដោយ សោ ភឹម (លេខាភូមិភាគបូព៌ា) និងទាហានលន់នល់ ។ នៅក្នុងភូមិឃុំរបស់ យាន កងកម្លាំងខ្មែរក្រហមបានរៀបចំរចនាសម្ព័ន្ធដឹកនាំនិងធ្វើការជ្រើសរើសមនុស្សពេញវ័យឲ្យចូលបម្រើក្នុងជួរកងទ័ព ។ បងប្រុសពីរនាក់ក្នុងចំណោមបងប្អូន៦នាក់របស់ យាន បានចូលបដិវត្តន៍ក្នុងឆ្នាំ១៩៧០ មកដល់ឆ្នាំ១៩៧៥ អ្នកទាំងពីរក៏បាត់ដំណឹងរហូត ។

នៅឯសហករណ៍ព្រៃឆ្កូតឯណេះវិញ យាន ធ្វើការងារដូចប្រជាជនដទៃនៅក្នុងភូមិដែរ ។ យាន បានរៀបរាប់ថា ប្រជាជន១៧មេសាជាច្រើនត្រូវបានសម្លាប់ ដោយសារតែមិនទទួលបានការទុកចិត្តពីអង្គការ ហើយអ្នកខ្លះទៀតមិនអាចបំពេញការងារតាមការកំណត់បាន ។ ចំណែកប្រជាជនមូលដ្ឋានក៏ទទួលរងការគាបសង្កត់យ៉ាងធ្ងន់ធ្ងរដែរ ។ ក្រុមគ្រួសាររបស់ យាន ស្ទើរតែត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងពូជទៅហើយ ដោយសារតែអ្នកទាំងនោះបានជជែកគ្នាលេងអំពីការបំបាត់ព្រះពុទ្ធសាសនា ។ ឈ្លបភូមិ ដែលបានស្តាប់ឮក៏រាយការណ៍ទៅថ្នាក់លើ ហើយបានហៅក្រុមគ្រួសាររបស់មីងទាំងអស់ទៅអប់រំ ។ សំណាងល្អ ដោយសារបងប្រុសរបស់មីងជាកម្មាភិបាលនៅក្នុងភូមិ អ្នកទាំងអស់គ្នាត្រូវបានដោះលែងមកវិញ ។

ក្រោយមក យាន ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅអ្នកលឿងដែលនៅទីនោះមានយុវជនម្នាក់ដែលជាអ្នក១៧មេសាបានស្នើសុំ យាន រៀបការ ។ ថ្ងៃបើកវគ្គកាន់តែខិតចូលមកដល់ ប្រជាជនទាំងអស់រួមទាំងអ្នកដែលត្រូវរៀបការផង ត្រូវបានតម្រូវឲ្យចុះច្រូតកាត់ឲ្យរួចរាល់នៅមុនថ្ងៃបើកវគ្គមកដល់ ។ នៅពេល យាន និងអ្នកភូមិឯទៀតកំពុងច្រូតកាត់ កងទ័ពនិរតីបានចូលមកកៀរប្រជាជន ប៉ុន្តែត្រូវប្រជាជនដេញកាប់ហើយអ្នកទាំងអស់នេះក៏ដកថយទៅវិញ ។ មួយសប្តាហ៍ក្រោយមក កងទ័ពខាងនិរតីបានចូលមកប្រជុំ ហើយជម្លៀសប្រជាជនមួយចំនួននៅក្នុងភូមិឲ្យទៅរស់នៅកន្លែងថ្មី ដោយប្រាប់ថា“ទៅកន្លែងដីខ្សាច់” ។ យាន និងក្រុមគ្រួសារទាំងអស់ក៏មានឈ្មោះក្នុងបញ្ជីជម្លៀសដែរ ។ អ្នកទាំងអស់គ្នាត្រូវធ្វើដំណើរដោយថ្មើរជើងឆ្ពោះមកទីក្រុងភ្នំពេញ ។ អ្នកទាំងអស់គ្នាត្រូវបានដាក់ឲ្យនៅក្នុងផ្ទះមួយដែល យាន បាន«ឃើញឈាមប្រឡាក់ជញ្ជាំងនៅស្រស់ៗនៅឡើយ» ។

យាន និងក្រុមគ្រួសារត្រូវបានបញ្ជូនតាមរថភ្លើងឲ្យទៅរស់នៅភូមិអូរគ្រោត ឃុំការ ស្រុកមោងឫស្សីដែលនៅទីនោះ យាន រស់នៅជួបការលំបាកច្រើន ដោយសារអ្នកទាំងអស់គ្នារស់នៅក្នុងនាមជាប្រជាជនថ្មីៗ ។ ទោះជាយ៉ាងនេះក្តី ការភ័យខ្លាចបែបនេះមានរយៈពេលខ្លីប៉ុណ្ណោះ ។ បានរយៈពេលប្រហែលមួយខែ បងរបស់ យាន ឈ្មោះ ផាត ដែលមានកូនវិទ្យុតូចមួយ

ទទួលបានដំណឹងថា កងទ័ពវៀតណាមនិងកងទ័ពរណសិរ្សកំពុងតែធ្វើការវាយលុកចូលក្នុងប្រទេសកម្ពុជា ហើយចូលជិតមកដល់ទីក្រុងភ្នំពេញទៀតផង ។ ផាត បានណែនាំបងប្អូនខំប្រឹងធ្វើការកុំឲ្យមានកំហុសខុសឆ្គងអ្វីឲ្យសោះ ។ នៅក្នុងភូមិអូរគ្រោត ប្រជាជនមួយចំនួនបានលួចរត់ចូលក្នុងជួររណសិរ្ស ហើយមួយចំនួនបានរត់ទៅរស់នៅក្នុងព្រៃក្បែរនោះ ។ ដោយសារសភាពការណ៍ពេលនោះមានភាពជ្រួលច្របល់ ខ្មែរក្រហមមិនសូវចុះមកត្រួតពិនិត្យឲ្យបានហ្មត់ចត់ទេ ។ សភាពការណ៍វិវត្តន៍នេះបានអនុញ្ញាតឲ្យ ផាត និងក្រុមរបស់ខ្លួនអាចលួចដឹកស្រូវនិងស្បៀងអាហារយកទៅចែកឲ្យអ្នកដែលកំពុងរស់នៅលាក់ខ្លួនក្នុងព្រៃ ។

មិនយូរប៉ុន្មាន កងទ័ពវៀតណាមបានវាយចូលមកដល់ស្រុកមោងឫស្សី ដោយមានផ្សែងខ្មៅឆេះខ្ទួលខ្មាញ់ឡើងលើ ។ ខ្មែរក្រហមម្នាក់បានជិះសេះមក ហើយបញ្ជាឲ្យប្រធានឃុំជម្លៀសប្រជាជនឡើងភ្នំទាំងអស់ ។ ដោយបានដឹងពីសភាពការណ៍នេះ ផាត បានត្រឡប់មកផ្ទះដើម្បីផ្តល់ដំណឹងដល់ក្រុមគ្រួសារឲ្យត្រៀមខ្លួនរត់គេចចេញពីការជម្លៀសឡើងទៅលើភ្នំ ។ ផាត និងបងប្អូនពីរនាក់ទៀតបានរត់ចូលព្រៃនៅថ្ងៃនោះ ។ មួយថ្ងៃក្រោយមក គណៈឃុំបានកោះហៅប្រជាជនទាំងអស់ចូលរួមប្រជុំ ហើយបានស្នើឲ្យប្រជាជនហៅបងប្អូនដែលរត់ចូលព្រៃឲ្យវិលត្រឡប់ចូលភូមិវិញ ដោយថែមទាំងនិយាយថា *«អង្គការអត់មានសម្លាប់ប្រជាជនទេ អង្គការយកប្រជាជនឲ្យមកជួយធ្វើការ»* ។ ជាងនេះទៅទៀត មេឃុំបានអប់រំប្រជាជនថា *«កុំចុះចាញ់ យើងត្រូវតស៊ូឡើង ព្រោះវៀតណាមតែវាមកដល់ច្បាស់ជាចាប់យើងវះពោះច្រកស្មៅហើយ»* ។ ទោះជាយ៉ាងណា យាង និងក្រុមគ្រួសារនៅតែមានគំនិតចង់រត់គេចចេញពីកន្លែងនោះដដែល ។

យាង និងបងប្អូនបីនាក់ទៀតបានចូលទៅក្នុងព្រៃដើម្បីស្វែងរកបងប្រុស ផាត និងប្រជាជនឯទៀតដែលបានរត់ចូលព្រៃលាក់ខ្លួនមុននោះបន្តិច ។ ប្តីរបស់ យាង បានឡើងលើដើមអម្ពិលមួយខ្ពស់ដើម្បីស្រែកហៅ ផាត ។ ផាត បានចេញមកជួបដោយជាប់នឹងខ្លួននូវកាំបិតផ្គាក់មួយ ខោខ្លីមួយ និងក្រមាមួយប៉ុណ្ណោះ ។ ផាត បានពន្យល់ណែនាំប្អូនៗថា *«ខ្លួនមិនអាចត្រឡប់ទៅវិញបានទេ តែទៅគេសម្លាប់ហើយ»* ។ ផាត បានប្រាប់ យាង ឲ្យត្រឡប់ទៅភូមិវិញហើយនាំបងប្អូននិងឪពុកម្តាយទាំងអស់រត់ចូលព្រៃឲ្យបានមុនម៉ោង៦ឬម៉ោង៧ល្ងាច បើមិនដូច្នេះនឹងត្រូវស្លាប់ទាំងអស់គ្នា ។

យាង បាននាំដំណឹងនេះមកខ្សឹបប្រាប់បងប្អូននិងអ្នកជិតដិតមួយចំនួនឲ្យត្រៀមស្បៀងអាហារនិងសម្ភាររត់ចេញពីភូមិ ។ នៅយប់នោះ អ្នកទាំងអស់គ្នាបានចេញដំណើរសំដៅទៅព្រៃដោយមាន ផាត ជាអ្នកនាំផ្លូវ ។ យាង បានដឹកដៃម្តាយនិងម្តាយក្មេកចាស់ជរាដែលមានជំងឺប្រចាំកាយនោះ រត់កាត់ភ្លឺស្រែខ្ពស់ៗយ៉ាងលំបាកហើយបានដួលជាច្រើនសា ។ ក្នុងពេលនោះដែរ កងទ័ពខ្មែរក្រហមបានដេញតាមបាញ់ពីក្រោយ ។ អ្នកទាំងអស់គ្នារត់មួយយប់ទល់ភ្លឺ សូម្បីតែបងថ្លៃរបស់ យាង ដែលទើបសម្រាលកូនហើយថ្មីៗក៏មិនអាចឈប់សម្រាកបានដែរ ។ ជាកុសលល្អកូនតូចនោះមិនបានយំសូម្បីតែបន្តិចក្នុងអំឡុងពេលនៃការរត់គេចខ្លួននោះ ។

ព្រឹកឡើង អ្នកទាំងអស់គ្នាបានឈប់សម្រាកនៅក្នុងព្រៃមួយ ។ សម្រាកបានបន្តិច ស្រាប់តែ យាង បានឮសំឡេងរទេះគោនិងមនុស្សជាច្រើនកំពុងបរសំដៅមកកន្លែងសម្រាករបស់ខ្លួន ។ អ្នកទាំងអស់គ្នានាំគ្នាសំងំ ខ្លាចក្រែងសំឡេងនោះជាកងទ័ពខ្មែរក្រហម ។ ផ្ទុយទៅវិញ នោះគឺជាសំឡេងរបស់កងទ័ពរណសិរ្សដែល ផាត បានស្នើសុំឲ្យមកជួយរំដោះ ។ កងទ័ពរណសិរ្សបាននាំអ្នកទាំងអស់គ្នាទៅរស់នៅក្នុងព្រៃមួយដែលមានសុវត្ថិភាព ។ ទោះជានៅទីនោះមិនមានអ្វីហូបក៏ដោយ ក៏ យាង និយាយថាវាប្រសើរជាងការរស់នៅប្រកបដោយភាពភ័យខ្លាចក្នុងតំបន់កាន់កាប់របស់ខ្មែរក្រហមដែរ ។

ក្រោយមក យាង បានឃើញប្រជាជនជាច្រើនក្រុមផ្សេងទៀត បាននាំគ្នារត់ចូលព្រៃជាបន្តបន្ទាប់ ។ អ្នកទាំងអស់គ្នាប្រមូលផ្តុំគ្នាបានប្រហែល៣០គ្រួសារ ហើយរស់នៅដោយលួចស្រូវនិងគោអ្នកភូមិក្បែរនោះយកមកកាប់ចែកគ្នាហូប ។ ស្នាក់នៅទីនោះ បានប៉ុន្មានសប្តាហ៍ អ្នកទាំងអស់គ្នាបានត្រៀមទូកដើម្បីឆ្លងបឹងទន្លេសាបឆ្ពោះទៅកាន់ខេត្តសៀមរាប ។ យាង ព្រមទាំងប្តី ឪពុក បងប្រុស និងប្អូនថ្លៃ បាននាំគ្នាមុជទឹកទៅបាតទន្លេរាវរកទូកដែលលិចនៅក្នុងបឹងទន្លេសាបបានមួយ ។ អ្នកទាំង

អស់គ្នា បានជួសជុលទូកបាក់បែកមួយនេះ ហើយបានដឹកចម្លងមួយគ្រួសារឆ្លងបឹងទន្លេសាប ហើយកងទ័ពរណសិរ្សរំដោះជាតិបានយកទូកមានម៉ាស៊ីនមួយមកសណ្តោងទូករបស់ប្រជាជនដែលរត់គេចខ្លួនទាំងនេះបន្តកន្ទុយគ្នា ។ យាង និងក្រុមគ្រួសារបានមកសំណាក់នៅជាមួយប្រជាជនតាមដងទន្លេសាប ដែលអ្នកទាំងនេះបានជួយផ្គត់ផ្គង់ជាអង្ករ និងសម្ភារបន្តិចបន្តួច ។ បន្ទាប់ពីការប្រមូលកាត់ស្រូវប្រាំងប្រហែលជានៅក្នុងខែមេសា យាង និងក្រុមគ្រួសារ បានវិលត្រឡប់ទៅរស់នៅក្នុងស្រុកកំណើតវិញ ។

ដំណើរឆ្លងកាត់របបខ្មែរក្រហមជាបទពិសោធន៍មួយដែលមិនអាចបំភ្លេចបាន ។ ដំណើរឆ្លងកាត់បឹងទន្លេសាបជាព្រឹត្តការណ៍ដ៏គួរឲ្យរន្ធត់ ព្រោះស្ថិតក្នុងកាលៈទេសៈស្លាប់រស់របស់ក្រុមគ្រួសារទាំងមូល ដែលកំពុងតែនៅក្នុងទូកកញ្ចាស់បាក់បែកមួយកណ្តាលបឹងទន្លេសាប ហើយដែលខ្មែរក្រហមអាចបាញ់ផ្តោងបានគ្រប់ពេលវេលាទាំងអស់ ។

**ឌី ខាំបូលី**

# រកឃើញផ្នូរសាកសពជនរងគ្រោះនៅភូមិស្រែលាវ

សាកសពជនរងគ្រោះក្នុងសម័យខ្មែរក្រហមប្រមាណ ៩០០០នាក់ ត្រូវបានរកឃើញនៅព្រៃអូរកំបុតត្រពាំងស្រងែ ក្នុងភូមិស្រែលាវ ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត តាមរយៈការគាស់កកាយរកមាសរបស់អ្នកភូមិស្រែលាវ ។

ហេតុការណ៍កាប់គាស់រណ្តៅសាកសពទាំងនេះបានកើតឡើងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៧ បន្ទាប់ពីប្រតិភូវៀត-ណាមមួយក្រុមក្រោមកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរខេត្ត និងស្រុកបានមកគាស់រណ្តៅមួយក្នុងចំណោមរណ្តៅផ្សេងទៀត ដើម្បីស្រាវជ្រាវរកឆ្អឹងកងទ័ពវៀតណាមដែលបានពលីជីវិតនៅលើទឹកដីកម្ពុជាកាលពីសម័យសង្គ្រាម ។ មួយថ្ងៃក្រោយមក គេឃើញវត្តមានប្រជាជនកាន់តែច្រើនឡើងៗ បានមកជីកគាស់រណ្តៅសាកសពទាំងអស់នេះ ។ អាជ្ញាធរមូលដ្ឋានឃុំត្រពាំងភ្លាំងបានចុះស្រង់ស្ថិតិដល់ទីតាំងផ្ទាល់ ។ តាមកំណត់ហេតុរបស់ ខឹម យូខឺន អាយុ៥៧ឆ្នាំ ជាជំទប់ទី១ឃុំត្រពាំងភ្លាំងបានឲ្យដឹងថា អ្នកភូមិស្រែលាវចំនួន១០នាក់ដែលបានគាស់កកាយរណ្តៅទាំងនេះបានប្រទះឃើញមាសសុទ្ធជាខ្សែកនិងក្រវិលប្រហែលមួយតម្លឹងកន្លះ ។



សម្លៀកបំពាក់និងអដ្ឋិធាតុជនរងគ្រោះនៅព្រៃអូរកំបុតត្រពាំងស្រងែ ខេត្តកំពត

ចាប់តាំងពីអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាបានដំណើរការនៅដើមឆ្នាំ២០០៦ នេះជាលើកទី៣ហើយបន្ទាប់ពីបានរកឃើញទីតាំងសម្លាប់មនុស្សនិងផ្នូរកប់សាកសពកាលពីជំនាន់ខ្មែរក្រហមនៅខេត្តកំពង់ស្ពឺនិងខេត្តកំពត ។ គួររំឭកថា កាលពីដើមឆ្នាំ២០០៦ ទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហមនៅស្រុកភ្នំស្រួចឈ្មោះថា «ព្រៃឈើនាង» ត្រូវបានរកឃើញតាមរយៈក្មេងឃ្វាលគោនិងក្មេងរកខសពីរបីនាក់ដែលរើសបានក្រវិលមាសមួយគូពីរណ្តៅមួយដែលខ្លួនបានរត់ប្រដេញគ្នាលេង ។ ចំណែក ទីតាំងសម្លាប់ «ព្រៃអូរជីបាក់» ដែលមានទីតាំងនៅក្បែរភ្នំវល្លិ៍ក្នុងក្រុងកែបត្រូវបានរកឃើញនៅខែមីនា ឆ្នាំ២០០៧ ហើយនៅដើមខែឧសភាថ្មីៗនេះផ្នូរសាកសពចំនួនប្រហែល២០០

ទៀតដែលស្ថិតនៅក្នុងតំបន់ចុងក្រោយរបស់ខ្មែរក្រហម គឺនៅកោះស្លា ស្រុកឈូក ខេត្តកំពត ក៏ត្រូវបានរកឃើញដែរ តាមរយៈការកាប់គាស់រណ្តៅរកមាសដែលនៅជាប់នឹងរាងកាយសាកសព ។

អ្នកភូមិស្រែលាវរាប់រយនាក់បានផ្អាកការងារប្រចាំថ្ងៃរបស់ខ្លួន មកជីករកមាសពីផ្នូរសាកសពជនរងគ្រោះសម័យខ្មែរក្រហម ។ ទោះជាអ្នកភូមិភាគច្រើនមិនបានទទួលផលប្រយោជន៍ពីការជីកនេះក៏ដោយ ក៏គាត់នៅតែបន្តជីកដដែល ។ កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៧ ភ្លៀងធ្លាក់មួយមេធំបានធ្វើឲ្យអ្នកភូមិដែលកំពុងមមាញឹកនឹងការជីកនេះបង្ខំចិត្តវិលទៅផ្ទះរៀងៗខ្លួន ដើម្បីរង់ចាំភ្លៀងរាំងឆ្អាលនឹងបានត្រឡប់ទៅទីកន្លែងនោះវិញ ។ អ្នកភូមិម្នាក់អាយុប្រមាណ៣០ឆ្នាំដែលកំពុងលីចបដើរសំដៅទៅកាន់ទីតាំងនោះបាននិយាយថា "ខ្ញុំចេះតែខំព្យាយាមជីកទៅទៀតក្រែងមានភ័ព្វសំណាងបានមាសនឹងគេ" ។ រណ្តៅទាំងអស់ដែលគាស់ហើយ ត្រូវទឹកភ្លៀងដក់ស្មើរពេញព្រៀប ហើយក្រណាត់សំពត់ខោអាវចម្រុះព៌ណបានអណ្តែតឡើងនៅរាយប៉ាយពាសពេញមាត់រណ្តៅ ។ ឆ្អឹងមួយចំនួនតូចដែលនៅសេសសល់មិនបានកប់ចូលទៅក្នុងរណ្តៅវិញ ត្រូវអ្នកភូមិប្រមូលគរទុកក្បែរគល់ដើមថ្កុំធំមួយ ដែលដុះនៅចំកណ្តាលបរិវេណកប់សាកសព ។ ស្រី ណែត អាយុ ៥០ឆ្នាំ ដែលបានរើសឆ្អឹងជាមួយអ្នកភូមិផ្សេងទៀតបាននិយាយថា គាត់បានចូលរួមគាស់រណ្តៅជាមួយអ្នកឯទៀតដែរ ប៉ុន្តែដោយសារគាត់គ្មានកម្លាំងគ្រប់គ្រាន់ដើម្បីជីក គាត់ក៏ផ្អាកការជីកនេះវិញ ។ កាលពីជំនាន់ខ្មែរក្រហម ណែត គឺជាអ្នកកប់សាកសពសមាជិកក្រុមរបស់ខ្លួនដែលស្លាប់ដោយសារជំងឺគ្រុនចាញ់និងអាសន្នរោគ ។ ណែត និយាយថា អ្នកស្លាប់ទាំងអស់សុទ្ធតែ ជាយុវជនកងចល័តមានអាយុក្រោម៣០ឆ្នាំ ដែលត្រូវអង្គការបញ្ជាឲ្យមកលើកទំនប់នៅកោះស្លា ។ ចំណែកសាកសពដែលស្លាប់នៅក្នុងមន្ទីរពេទ្យតំបន់៣៥ ត្រូវបាន


ស្រី ណែត អាយុ ៥០ឆ្នាំ

សែងយកទៅកប់នៅទីលានកប់សាកសពរួមមួយកន្លែង នៅលើដីទួលដែលកំពុងទទួលរងការជីកកកាយនាពេលថ្មីៗនេះ ។ មន្ទីរពេទ្យតំបន់៣៥ មានទីតាំងស្ថិតនៅប្រហែល២០០ម៉ែត្រពីទំនប់កោះស្លា ។ បច្ចុប្បន្នមន្ទីរពេទ្យនេះពុំមាននៅសេសសល់រូបរាងឬស្លាកស្នាមជាមន្ទីរពេទ្យទៀតទេ ។ ង៉ាយ យ៉ុន អាយុ៤៧ឆ្នាំ ជាអតីតកងចល័តធ្លាប់ចូលរួមលើកទំនប់កោះស្លាបាននិយាយថា "ខ្ញុំគិតថា អ្នកដែលស្លាប់ ដោយសារជំងឺមានតិចណាស់ ប៉ុន្តែអ្នកដែលស្លាប់ដោយចាក់ថ្នាំសម្លាប់គឺមានច្រើន" អ្នកជំងឺដែលទៅព្យាបាលនៅមន្ទីរពេទ្យតំបន់៣៥ ភាគច្រើនត្រូវបានសម្លាប់ដោយសារការចាក់ទឹកបញ្ចូលទៅក្នុងខ្លួន ។ ចំណែកមេឃុំត្រពាំងភ្លាំងឈ្មោះ សួស ភន អាយុ៥៣ឆ្នាំ បាននិយាយស្រដៀងគ្នាដែរថា អ្នកជំងឺភាគច្រើនដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យតំបន់៣៥បានស្លាប់ ។ ណែត និងអ្នកផ្សេងទៀតដែលមិនខ្លាចខ្មោចលងបានទទួលបញ្ជាឲ្យសែងខ្មោចចេញពីមន្ទីរពេទ្យយកទៅកប់ស្ទើរតែរាល់យប់ ។ ណែត និយាយដូច្នេះថា "ខ្ញុំសែងតែខ្មោចអ្នកដែលនៅក្នុងក្រុមជាមួយខ្ញុំប៉ុណ្ណោះ ហើយអ្នកដទៃទៀតគេសែងខ្មោចអ្នកដែលធ្វើការនៅក្នុងក្រុមរៀងៗខ្លួន ប៉ុន្តែខ្ញុំក៏ដូចអ្នកឯទៀតដែរ អង្គការមិនអនុញ្ញាតឲ្យនិយាយប្រាប់អ្នកផ្សេងទៀតឡើយ" ។ ណែត មិនចងចាំចំនួនសាកសពដែលខ្លួនធ្លាប់កប់កាលពីជំនាន់ខ្មែរក្រហមទេ ប៉ុន្តែគាត់បានប្រាប់ថា "ជួនកាលគេ [កម្មាភិបាលខ្មែរក្រហម] ប្រើខ្ញុំទៅកប់ខ្មោចទាំងកណ្តាលយប់ ជួនកាលម៉ោង២យប់ ក្នុងមួយយប់ៗ ខ្ញុំមិនដែលកប់ខ្មោចលើសពី៦នាក់ទេ ហើយក៏មិនក្រោម២នាក់ដែរ" ។

ការរកឃើញរណ្តៅសាកសពជនរងគ្រោះដែលកប់បាត់អស់រយៈពេល៣០ឆ្នាំ បានធ្វើឲ្យអតីតកងចល័តដែលធ្លាប់ចូលរួមលើកទំនប់កោះស្លា ហាក់ដូចជានឹកឃើញឡើងវិញនូវរឿងរ៉ាវរបស់ខ្លួនក្នុងពេលដែលខ្លួនស្នូគ្រប ម្រើឲ្យរបបខ្មែរក្រហម ។ សកម្មភាពដើររើសឆ្អឹងសាកសពរបស់ ណែត បានធ្វើឲ្យគាត់នឹកឃើញនៅពេលដែលខ្លួនគាត់សែងសាកកសពមិត្តរួមការងារយកមកកប់នៅទីនេះ ។ "ខ្ញុំមិនដឹងថា ឆ្អឹងមួយណាជាឆ្អឹងសាកសពដែលខ្ញុំបានកប់កាលពីពេលនោះ(ខ្មែរក្រហម) ទេ ខ្ញុំក៏សុំខមាទោសចំពោះប្រការណាដែលមិនគប្បីក្នុងពេលកប់ពួកគេមិនបានល្អ" ។

អាជ្ញាធរមូលដ្ឋានបានហាមប្រាមការជីកគាស់រណ្ដៅសាកសពទាំងនេះ ហើយបានបញ្ជាឲ្យមានការប្រមែប្រមូលឆ្អឹងដែលនៅសេសសល់ទាំងអស់យកមកគរទុកមួយកន្លែងដើម្បីជញ្ជូនយកទៅតម្កល់ទុកឲ្យបានត្រឹមត្រូវនៅក្នុងបូជនីយដ្ឋានវត្តស៊ឹង ដែលមានទីតាំងស្ថិតនៅខាងកើតសាលាស្រុកឈូក ។ មេឃុំ សួស ភន បានត្អូញត្អែរថា ការគាស់កកាយរបៀបនេះគឺជាការរំខានដល់ព្រលឹងសពដែលស្លាប់ទៅ ។ ខឹម យូខឹន អាយុ៥៧ឆ្នាំ ជាជំទប់ទី១ឃុំត្រពាំងភ្លាំង បានសម្ដែងការសោកស្ដាយថា «ពុំគួរអ្នកភូមិនាំគ្នាទៅជីកគាស់កកាយរណ្ដៅសាកសពទាំងគ្មានការពិចារណាបែបនេះសោះ ។ មិនជាការល្អទេ ប្រសិនបើប្រជា-ពលរដ្ឋនៅតែបន្តជីកគាស់រណ្ដៅសាកសពទាំងនេះតទៅទៀត» ។

ដោយសារភាពក្រីក្រ អ្នកភូមិភាគច្រើនពុំធ្វើតាមបំរាមទាំងនេះឡើយ ។ ផ្នូរសាកសពជាច្រើនទៀតនៅតែទទួលរងនូវការគាស់បំផ្លាញ ។ ស៊ាយ សារឿន អាយុ៥០ឆ្នាំ ជាជំទប់ទី២ឃុំត្រពាំងភ្លាំងបានហាមអ្នកភូមិមិនឲ្យជីកតទៅទៀត ប៉ុន្តែគាត់នៅតែមិនអាចហាមឃាត់បាន ។ សារឿន បានឃើញកន្លែងកប់ខ្មោចជំនាន់ខ្មែរក្រហមនេះតាំងពីខែកញ្ញា ឆ្នាំ១៩៧៩មកម្ល៉េះ គឺនៅពេលដែលគាត់ដើរឆ្លងកាត់ទីនេះ ដើម្បីទៅនេសាទត្រីក្បែរៗទំនប់កោះស្លា ។ សា រឿន បានរៀបរាប់ថា ផ្នូរមាន៧០ជួរជាប់ៗគ្នា ដែលក្នុងមួយជួរៗមាន១៣០រណ្ដៅ ។ ផ្នូរខ្លះមានផ្លាកឈ្មោះចំណាំផង ។ ជាច្រើនឆ្នាំបានកន្លងផុតទៅផ្នូរសាកសពទាំងប៉ុន្មានត្រូវដើមឈើតូចធំជាច្រើនដុះពីលើមើលទៅមិនដឹងថាជាកន្លែងកប់សាកសពជំនាន់ខ្មែរក្រហមឡើយ ។ ម្ចាស់ដីចម្ការមួយកន្លែងឈ្មោះ ស្រី ប៊ិយ ក៏បានដឹងច្បាស់ដែរថាដីរបស់គាត់ជាកន្លែងកប់សាកសពជំនាន់ខ្មែរក្រហម ហើយដីនេះគាត់ក៏មិនទាន់បានរានធ្វើចម្ការនៅឡើយ ។

នៅក្រោយឆ្នាំ១៩៩៨ ប្រជាជនចំណាកស្រុកមកពីកន្លែងផ្សេងៗដូចជា ខេត្តតាកែវ ប៉ៃលិន និងអន្លង់វែង បានចូលមករស់នៅក្នុងតំបន់កោះស្លាកាន់តែច្រើនឡើងដោយមិនបានដឹងថាទីតាំងនេះ ជាកន្លែងកប់សាកសពមនុស្សរបស់ខ្មែរក្រហមទេ លើកលែងតែអ្នកភូមិចាស់ៗប៉ុន្មាននាក់ និងជាអតីតកងចល័តដែលត្រូវអង្គការបញ្ជូនឲ្យមកលើកទំនប់កោះស្លានេះប៉ុណ្ណោះ ។ សោ សុន អាយុ៦៥ឆ្នាំ ដែលមានស្រុកកំណើតនៅខេត្តតាកែវ បានមកតាំងលំនៅដ្ឋានក្បែរទីតាំងកប់សាកសពនេះអស់រយៈពេលជាង១០ឆ្នាំ ក៏នៅតែមិនដឹងថាទីនេះជាកន្លែងកប់ខ្មោចច្រើនបែបនេះដែរ ។ ក៏ប៉ុន្តែ សុន មានការមន្ទិលសង្ស័យ ដោយសារថាមានខ្មោចលងនៅក្នុងបរិវេណដីជាងមួយហិកតានេះ ។ «ជួនកាលខ្ញុំឮសូរសំឡេងជជែកគ្នាពេញព្រៃ ជួនកាលឮសន្ទឹកបរទេះគោកាត់មុខផ្ទះខ្ញុំហើយចូលមកដល់ព្រៃកន្លែងនេះ ស្រាប់តែបាត់ឈឹង ។ ខ្ញុំតាមដានមកដល់ព្រៃនេះក៏លែងហ៊ានចូល ព្រោះដឹងថា ខ្មោចលងហើយ» ។ ទោះជាដឹងច្បាស់ថា ជាកន្លែងកប់សាកសពរាប់ពាន់នាក់ក៏ដោយ ក៏គាត់នៅតែព្យាយាមជីករកមាសបន្តទៀត ហើយផ្ទះរបស់គាត់ក៏មិនត្រូវរុះរើទៅកាន់កន្លែងផ្សេងដែរ ។ អ្នកភូមិម្នាក់ដែលកំពុងជីកគាស់ផ្នូរសាកសព ក្រោយពេលភ្លៀងនិយាយថា ក្រោយពីជីកគាស់បានពីរថ្ងៃ អ្នកភូមិដែលរស់នៅក្បែរទីនេះ បានឮសូរសំឡេងយំទ្រហឹងពេញព្រៃនៅពាក់កណ្ដាលអធ្រាត្រ ហើយស្អែកឡើងអ្នកភូមិលែងឃើញមកជីកតទៅទៀត ។ មេឃុំ និងជំទប់ទី១ព្រមទាំងក្រុមប្រឹក្សាឃុំត្រពាំងភ្លាំងយល់ឃើញថា ការស្រែកយំនេះគឺដោយសារសពត្រូវទទួលរងនូវអំពើទារុណកម្មម្ដងទៀត ។ ស្រី ណែត និយាយពីរឿងហេតុដែលកើតឡើង ក្រោយការជីកគាស់ប៉ុន្មានថ្ងៃថា អ្នកភូមិដែលជីក


ខឹម យូខឹន (ជំទប់ទី១) និង សួស ភន (មេឃុំ) ឃុំត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត

បានមាសទាំងប៉ុន្មានហាក់មានអារម្មណ៍មិននឹងនរ និងមានហេតុ-ការណ៍ចម្លែកៗកើតឡើងក្នុងក្រុមគ្រួសារ ដូចជាធ្លាក់ខ្លួនឈឺក្លាមៗ ។ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៧ រយៈពេលមួយសប្តាហ៍ក្រោយការជីកគាស់រណ្តៅសាកសពទាំងនោះ អ្នកភូមិដែលជីកបានមាសទាំងប៉ុន្មាននាក់បានរៃអង្គាសលុយគ្នាធ្វើបុណ្យនៅកន្លែងជីកសាកសព ដើម្បីបួងសួងសុំឲ្យវិញ្ញាណក្ខន្ធសាកសពទាំងអស់ឆាប់បានទៅកាន់សុគតិភព និងចាប់កំណើតថ្មី ព្រមទាំងបួងសួងកុំឲ្យមានបាតុភូតចម្លែកកើតឡើងក្នុងភូមិតទៅទៀត ។ មេឃុំត្រពាំងភ្លាំងនិយាយថា គាត់គ្រេកអរណាស់ចំពោះការធ្វើបុណ្យឧទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកដែលបានចែកឋាន ប៉ុន្តែយុត្តិធម៌សម្រាប់ជនរងគ្រោះនៅមិនទាន់ត្រូវបានរកឃើញនៅឡើយ ។ «នៅពេលណាភាពយុត្តិធម៌មិនទាន់ត្រូវបានរកឃើញការបូជាឆ្អឹងដែលគាស់បានទាំងនេះ ក៏មិនទាន់គ្រប់គ្រាន់ឲ្យព្រលឹងអ្នកដែលស្លាប់បានសេចក្តីសុខដែរ» ។ មេឃុំ ក៏ដូចជាសមាជិកក្នុងឃុំទាំងអស់មានគំនិតចង់សង់ស្តូបមួយនៅលើដីដែលកំពុងទទួលរងការជីកគាស់សម្រាប់តម្កល់អដ្ឋិធាតុដែលគាស់បានទាំងនោះ ជានិមិត្តរូបនៃការធ្វើទារុណកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ប៉ុន្តែអាជ្ញាធរស្រុកឈូកមានគម្រោងថា ឆ្អឹងដែលគាស់បានទាំងប៉ុន្មាន នឹងត្រូវនាំយកទៅដាក់តម្កល់នៅក្នុងបូជនីយដ្ឋានមួយនៅវត្តស៊ីងវិញ ។

ទាក់ទិននឹងផ្នូរសាកសពជនរងគ្រោះដែលកំពុងទទួលរងការគាស់កកាយនៅទីនេះ ប្រជាជនមូលដ្ឋានចាស់ៗដូច មេឃុំ សួស ភន, ង៉ាយ យ៉ុង និង ណែត បាននិយាយពីប្រវត្តិខ្លះៗទាក់ទងនឹងការកេណ្ឌប្រជាជនឲ្យមកលើកទំនប់នៅកោះស្លានេះ ។

ដំបូងឡើយប្រជាជនមកពីឃុំតាកែននិងឃុំល្បើក ក្នុងស្រុកឈូក ជាអ្នកកសាងទំនប់នេះមុនគេ ដោយចាប់ផ្តើមពីចំណុចអូរកំបុតត្រពាំងស្រង៉ែឆ្ពោះមកកាន់ចំណុចកោះស្លា ។ លុះដល់ឆ្នាំ១៩៧៣ ដោយសារទំនប់នេះមានទំហំធំនិងបណ្តោយវែង អង្គការខ្មែរក្រហមបានជម្លៀសប្រជាជនមួយចំនួនពីស្រុកផ្សេងៗក្នុងខេត្តកំពតដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនឲ្យមកជួយលើកបន្ថែម ប៉ុន្តែទំនប់នេះក៏នៅមិនទាន់ធ្វើរួចនៅឡើយ ។ នៅក្រោយថ្ងៃជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលកងចល័តពីស្រុកនានាទូទាំងខេត្តកំពត ក្នុងនោះមានភាគច្រើនជាប្រជាជនមូលដ្ឋាន និងមួយភាគជាប្រជាជន១៧មេសាឲ្យមកជួយលើកទំនប់នេះដើម្បីសម្រេចតាមផែនការនៅចុងឆ្នាំ១៩៧៦ ។ សួស ភន ប្រាប់ថា ក្នុងពេលលើកទំនប់នេះ ផលវិបាកជាច្រើនបានធ្លាក់មកលើកងចល័តទាំងអស់ដូចជាការហូបចុកមិនគ្រប់គ្រាន់ ជំងឺគ្រុនចាញ់ ជំងឺអាសន្នរោគ បាក់ទំនប់សង្កត់និងពស់ចឹក ។ កងចល័តភាគច្រើនបានធ្លាក់ខ្លួនឈឺនិងស្លាប់ជាបន្តបន្ទាប់ ។ ដោយឃើញសភាពបែបនេះ គណៈតំបន់៣៥បានបង្កើតមន្ទីរពេទ្យមួយឈ្មោះថា «មន្ទីរពេទ្យតំបន់៣៥» សម្រាប់ព្យាបាលជំងឺពួកកងចល័ត ។ អ្នកជំងឺជាច្រើននាក់ត្រូវបានសែងចូលព្យាបាលក្នុងមន្ទីរពេទ្យជារៀងរាល់ថ្ងៃ ហើយអ្នកទាំងនោះមិនដែលឃើញវិលត្រឡប់ទៅកាន់ការដ្ឋានរបស់ខ្លួនវិញឡើយ ។ នៅចុងឆ្នាំ១៩៧៦ ទំនប់កោះស្លាមិនអាចសម្រេចបានតាមផែនការឡើយ ដូច្នេះអង្គការតម្រូវឲ្យធ្វើបន្តរហូតដល់ឆ្នាំ១៩៧៧ ។ លោកមេឃុំនិយាយថា កងចល័តរាប់ពាន់នាក់បានស្លាប់ដោយជំងឺគ្រុនចាញ់និងអាសន្នរោគក្នុងចន្លោះឆ្នាំ១៩៧៣ ដល់ចុងឆ្នាំ១៩៧៥ ។ មកដល់ឆ្នាំ១៩៧៧ អង្គការបានរុះរើមន្ទីរពេទ្យតំបន់៣៥ ហើយបានប្រមូលយុវជនមួយចំនួនដែលនៅសេសសល់ពីការស្លាប់ឲ្យចូលបម្រើក្នុងជួរទ័ពការពារព្រំដែន ។ ចំណែកយុវនារីក៏ត្រូវបានជ្រើសរើសទៅធ្វើការជានារីស្រែអំបិល និងក្រោយមកត្រូវបានជ្រើសរើសបន្តឲ្យមកធ្វើការនៅភ្នំពេញទៀត ។

រហូតមកដល់បច្ចុប្បន្ន ទំនប់កោះស្លានៅតែជាទំនប់ដ៏ធំសម្បើមមួយដែលមិនគួរឲ្យជឿថា ជាទំនប់ដែលកសាងឡើងដោយកម្លាំងមនុស្សដែលពុំមានការហូបចុកគ្រប់គ្រាន់ និងពុំមានថ្នាំសង្កូវសម្រាប់ព្យាបាល ។ ទំនប់ប្រវត្តិសាស្ត្រមួយនេះ នៅតែមិនបានធ្វើឲ្យក្មេងៗជំនាន់ក្រោយជឿថាកសាងដោយកម្លាំងមនុស្សផ្ទាល់និងសឹងតែមិនជឿថាមានមនុស្សរាប់ពាន់នាក់បានស្លាប់ដោយសារតែកសាងទំនប់នេះឡើយ ។ សួស ភន និយាយទាំងទឹកមុខស្មើថា ទំនប់កោះស្លានិងរណ្តៅសាកសពប្រហែល២០០រណ្តៅដែលទើបនឹងគាស់នាពេលថ្មីនេះ គឺជាមេរៀនប្រវត្តិសាស្ត្រមួយសម្រាប់បង្រៀនក្មេងៗជំនាន់ក្រោយឲ្យដឹងពីវិធីសម្លាប់មនុស្សរបស់ខ្មែរក្រហមតាមរបៀបឃោរឃៅបំផុត ។ **ផេង ពង្សរ៉ាស៊ី**

# ជីវិតដូចនៅក្នុងឋាននរក

“ដូចចុះនរកទាំងរស់” នេះជាសម្តីរបស់តា អ៊ឹម ព្រឿង អាយុ ៦៦ឆ្នាំបច្ចុប្បន្នរស់នៅ ឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ អតីតជនរងគ្រោះម្នាក់នេះត្រូវបានកងយោធាខ្មែរក្រហមចាប់ខ្លួនយកទៅឃុំឃាំងនៅមន្ទីរសន្តិសុខសង់ទន្លេបាទីចាប់តាំងពីជម្លៀសពីភ្នំពេញបាន ៣-៤ខែដរាបូនរហូតដល់ថ្ងៃរំដោះឆ្នាំ១៩៧៩ ។ នេះជាការរៀបរាប់របស់ ព្រឿង ÷

បន្ទាប់ពីព្រឹត្តិការណ៍ទម្លាក់ព្រះបាទសម្តេច នរោត្តម សីហនុ ក្នុងឆ្នាំ១៩៧០ ភាពចលាចលកើតឡើងនៅស្ទើរគ្រប់ទីកន្លែងទាំងអស់ក្នុងផ្ទៃប្រទេសទាំងមូល ព្រឿង និងក្រុមគ្រួសារ បានភៀសខ្លួនទៅរស់នៅកោះអន្លង់ចិនបានមួយរយៈពេលខ្លី ហើយពេលដែលកងទ័ពរំដោះ (កងទ័ពខ្មែរក្រហម) វាយបែក ព្រឿង និងគ្រួសារភៀសខ្លួនបន្តមកវត្តព្រែកសំរោង ប៉ុន្តែនៅទីនោះក្រុមគ្រួសាររបស់គាត់រស់នៅមិនបានសេចក្តីសុខឡើយ ដូច្នោះទើបគាត់សម្រេចចិត្តភៀសខ្លួនមករស់នៅមុំវត្តព្រែកឫស្សី (ចាក់អង្រែ) វិញ ។ ព្រឿង ប្រកបរបរធាក់ស៊ីក្លូនិងលក់ការ៉េមកី ប៉ុន្តែមុខរបរទាំងនោះនៅតែមិនអាចជួយគ្រួសាររបស់ ព្រឿង ឲ្យមានជីវភាពប្រសើរឡើយ ។ ព្រឿង ក៏សម្រេចចិត្តផ្លាស់ប្តូរមកប្រកបរបរនេសាទ ។ ព្រឿង សប្បាយចិត្តយ៉ាងខ្លាំងដោយសារមុខរបរថ្មីនេះជួយឲ្យជីវភាពគាត់ប្រសើរជាងមុន ។ មិនយូរប៉ុន្មាន ទីក្រុងភ្នំពេញក៏ត្រូវកងទ័ពរំដោះដណ្តើមបាន ព្រឿង និងប្រជាជនទីក្រុងទាំងអស់ត្រូវអង្គការជម្លៀសទៅជនបទ ។ ក្រុមគ្រួសាររបស់ ព្រឿង ក៏ធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ ។


អ៊ឹម ព្រឿង

ព្រឿង ត្រូវបានជ្រើសតាំងដោយអង្គការឲ្យធ្វើជាជាងដែកនៅសិប្បកម្មធ្វើដែកនៅសៀមរាប(កន្ទួត) ស្រុកកណ្តាលស្ទឹង ។ ធ្វើការនៅរោងសិប្បកម្មបានប្រហែលជា៣-៤ខែ កងទ័ពខ្មែរក្រហមបានមកប្រាប់ប្រធានក្រុមដែលទទួលបន្ទុកក្តោបក្តាប់រោងសិប្បកម្មធ្វើដែកនោះថា ត្រូវការកម្លាំង២-៣នាក់ដើម្បីយកទៅលើបង្អួងនៅមុំទន្លេបាទី នៅក្នុងចំណោមនោះក៏មាន ព្រឿង ម្នាក់ដែរ ។ ព្រឿង មិនឆ្ងល់អ្វីទេ ព្រោះមុននេះ កងទ័ពក៏បានស្នើកម្លាំងប្រជាជនថ្មី៨០នាក់ទៅកាប់ព្រៃរានយកដីទុកសង់ផ្ទះឲ្យប្រជាជនជម្លៀសដែរ ។ ព្រឿង ឪពុកម្តាយ ឪពុកមាបងប្អូនជីដូនមួយម្នាក់ ប្អូនប្រុសពីរនាក់ រូបគាត់ និងប្រជាជន ២-៣នាក់ទៀត បានធ្វើដំណើរទៅជិតដល់គុកសង់ទន្លេបាទី ដែលមានព្រៃដុះយ៉ាងក្រាស់ ហើយមានកងទ័ព៣៤នាក់កំពុងតែឈរចាំនៅទីនោះ ។ អ្នកនាំផ្លូវបានប្រាប់ពួកគាត់ថា នៅឈរកន្លែងហ្នឹងសិនហើយ គាត់ទៅជួបកងទ័ពមួយភ្លែត គ្រាន់តែដើរផុតបានបន្តិចកងទ័ពទាំងនោះបានភ្ជង់កាំភ្លើងពួកគាត់ឲ្យលើកដៃទាំងពីរឡើងទៅលើ រួចឲ្យដេកផ្កាប់មុខយកដៃទាំងពីរទៅមុខ បន្ទាប់មកកងទ័ពទាំងនោះក៏បានយកដើងជាន់ចង្កេះចាប់ដៃគាត់ទាំងពីរចងស្លាបសេក ។ ព្រឿង និងអ្នកទាំងអស់ត្រូវកងទ័ពបណ្តើរសំដៅទៅកាន់គុកសង់ទន្លេបាទី ។ អ្នកទាំងនោះត្រូវធ្វើប្រវត្តិរូបសិនមុននឹងចូលទៅក្នុងបរិវេណគុក បន្ទាប់មកម្នាក់ៗត្រូវរើសយកកង (ខ្នោះជើង) ម្នាក់មួយ ។ ព្រឿង នៅតែមិនដឹងថា យកកងនោះសម្រាប់ធ្វើអ្វីនៅឡើយទេ ។ ព្រឿង មិនអាចអង្គុយបានទេដោយសារតែខ្សែចំណងដែលចងដៃរបស់គាត់តឹងណែនពេក ដើម្បីសម្រួលដល់ការដេកដង្ហើមគាត់ក៏សុំដេក ប៉ុន្តែបរិវេណនៅក្នុងបន្ទប់ស្ទើរតែទាំងអស់ពោរពេញទៅដោយសំបុកស្រមោចភ្លើងក្រហមប្រាលខ្លួនប្រាណរបស់គាត់ត្រូវស្រមោចខាំកន្ទួលពេញទាំងអស់ ។ បន្ទាប់មក គាត់ត្រូវបាននាំខ្លួនទៅកាន់គុកងងឹតដើម្បីឃុំឃាំងបណ្តោះអាសន្នមុនពេលសួរចម្លើយ នៅពេលនោះហើយ ព្រឿង ដឹងថា កងដែលឈ្លបខ្មែរក្រហមឲ្យគាត់រើសយកម្នាក់មួយនោះ គឺជាខ្នោះជើងសម្រាប់ដាក់ខ្លួនឯង ។ ព្រឿង ជាប់ឃុំឃាំងពីបទថា ជាពួកមូលធននិយម ។ ព្រឿង ត្រូវបានសួរចម្លើយចំនួន៣លើក ដែលនៅក្នុងមួយលើកៗមានមនុស្សបីនាក់

ផ្សេងៗគ្នាមកសួរគាត់ ។ ព្រឿង នៅចាំឈ្មោះអ្នកសួរចម្លើយបីនាក់គឺ រឿង, ញ៉ាន និង ហ៊ឹម ។ មុននឹងសួរចម្លើយ ព្រឿង បានជួបបងប្អូនជីដូនមួយម្នាក់ដែលជាប់នៅទីនោះដែរ ហើយជីដូនមួយបានផ្តាំគាត់ថា បើគេសួរអ្វីឆ្លើយស្របទៅទើបអ្នកធ្វើទារុណកម្មមិនធ្វើបាប ។ ព្រឿង បានឆ្លើយស្របនឹងសំណួររបស់អ្នកសួរចម្លើយដែលសួរថា *«តើឯងធ្លាប់ជាទាហានពាក់ស័ក្តិ៤?»* ។ ពេលសួរចម្លើយលើកទីពីរ ព្រឿង នៅតែឆ្លើយស្របដូចមុន ។ លើកទីបី ហ៊ឹម បានសួរសំណួរនេះដដែល ហើយថែមទាំងសួរដេញដោលដូចអ្នកមុនៗអ៊ីចឹង ។ បន្ទាប់ពីសួរចម្លើយ៣ដងក្នុងរយៈពេល៧ថ្ងៃ ព្រឿង ត្រូវបានដោះលែងពីបន្ទប់ងងឹតឲ្យមកនៅក្នុងបន្ទប់ឃុំឃាំងរួមដែលមានគ្នាពី២៥ទៅ៣០នាក់ ។ ជារៀងរាល់ព្រឹក អ្នកទោសទាំងអស់ត្រូវបានបញ្ចេញឲ្យមកធ្វើការនៅខាងក្រៅ ហើយដាក់ខ្នោះជើងនៅពេលយប់ ។ អ្នកទោសប្រុសដាក់ផ្សេងគ្នាពីអ្នកទោសស្ត្រី ។ អ្នកទោសខ្លះទ្រាំទ្រការឈឺចាប់និងការធ្វើទារុណកម្មនៅក្នុងគុកមិនបានក៏ធ្វើអត្តឃាតដោយចង-កសម្លាប់ខ្លួន ។

## របបអាហារនៅក្នុងគុកសង់ទន្លេបាទី

ពេលទៅដល់ដំបូង ខ្មែរក្រហមបានឲ្យរបបគាត់ហូប គឺគ្រាប់ពោតហាវ៉ៃស្ងោរម្នាក់មួយកែវដែលនៅក្នុងមួយកែវមានគ្រាប់ពោតប្រមាណពី៤០ទៅ៤១គ្រាប់ ថ្ងៃខ្លះទទួលបាន៤០គ្រាប់ ថ្ងៃខ្លះទៀតទទួលបាន៤១គ្រាប់ ។ ក្នុងមួយយប់ៗមានអ្នកទោសស្លាប់ពី៧ទៅ៨នាក់ ។ ក្រោយមកចំនួនអ្នកទោសស្លាប់កើនកាន់តែច្រើនដោយសារការងារធ្វើរឹតតែធ្ងន់ធ្ងរនិងរបបហូបចុកត្រូវកាត់បន្ថយទៅវិញដោយទទួលបានតែបបររាវកក្លុក ។ ការស្លាប់របស់អ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗចាប់ផ្តើមកើនឡើងទ្វេដងក្នុងមួយថ្ងៃៗ ។ បបររាវពីរវែកដែលអ្នកទោសទទួលបានគ្មានរសជាតិទេ ។ ព្រឿង ក៏ដូចអ្នកទោសទាំងអស់សុទ្ធតែជាប់ខ្នោះគាត់នៅសល់តែដៃពីរសម្រាប់កាន់ចានបបរហុតប៉ុណ្ណោះដោយបបរក្តៅពេកអ្នកទោសក៏ដាក់ចានបបរផ្ទាល់ដីរួចឱនហុត ។ ព្រឿង និយាយថា *«ដូចចុះនរកទាំងរស់អ៊ីចឹង»* មិនដឹងជាជាតិមុនគាត់ធ្វើអ្វីខុសទេបានជាជួបកម្មពៀរដូច្នេះ ។ នៅក្នុងបរិវេណបន្ទប់ឃុំឃាំងអ្នកទោសមួយចំនួនបន្ទោរបង់និងនោមពាសពេញបន្ទប់ ។ អ្នកទោសខ្លះដេកស្លាប់៤-១០ថ្ងៃទើបឆ្មាំគុកយកចេញក៏មានដែរ ដូច្នេះ ដើម្បីជីវិតរស់ម្នាក់ៗសុខចិត្តឱនលិតបបរដ៏កខ្វក់ដែលកំពុបនៅលើដី ។

## នៅក្នុងបន្ទប់ឃុំឃាំង

នៅក្នុងបន្ទប់ឃុំឃាំងនីមួយៗមានផ្ទុកអ្នកទោសពី៣០-៤០នាក់ ។ អ្នកទោសមិនអាចដើរប្តូរឈរនៅក្នុងបរិវេណបន្ទប់បានទេពីព្រោះជើងទាំងសងខាងជាប់ខ្នោះរួមដែលមានរន្ធសម្រាប់ស៊ករនុករួមចាក់សោភ្ជាប់ទៅនឹងដី ។ នៅក្នុងមួយជួរមានអ្នកទោសដប់នាក់ ភាគច្រើនអ្នកទោសតែងជួបគ្រោះថ្នាក់នៅពេលចាក់សោបញ្ចូលរនុកក្នុងជួរវិញប្រសិនបើមិនប្រុងប្រយ័ត្នដាក់ខ្នោះឲ្យត្រូវរន្ធរនុក ឬក៏ដកជើងមិនទាន់នោះនឹងត្រូវអ្នកយាមរុញរនុកទៅបុកនឹងកែងជើងមិនខាន ។ មានធុងសាំងពីរដាក់នៅកៀនជញ្ជាំងសម្រាប់ផ្ទុកលាមកនិងទឹកមូត្ររបស់អ្នកទោស បើសិនជានរណាម្នាក់ចង់បន្ទោរបង់ត្រូវប្រាប់តគ្នាទៅអ្នកដែលនៅជិតកន្តោរដើម្បីហុចកន្តោរតគ្នាមកឲ្យ ហើយត្រូវហុចតៗគ្នាទៅវិញបន្ទាប់ពីបន្ទោរបង់រួច ។ ព្រឿង លំបាកយ៉ាងខ្លាំងនៅពេលបន្ទោរបង់ម្តងៗ ។ ក្នុងបន្ទប់ទាំងមូលមានបទបញ្ជាមិនឲ្យនិយាយគ្នាទេ ប្រសិនបើអ្នកយាមមកទាន់នឹងត្រូវទទួលទារុណកម្មជាមិនខាន ។ មានអ្នកទោសម្នាក់ដែលនៅជិតគាត់បានស្រែកថា *«ខ្ញុំសុខចិត្តស្លាប់ ឲ្យតែឲ្យបាយមួយដុំឲ្យខ្ញុំហូបសិនមក»* ឮដូច្នេះអ្នកយាមគុកក៏បើកទ្វារចូលមកយកដំបងវាយព្រមទាំងបុកដើមទ្រូងរបស់អ្នកទោសយ៉ាងខ្លាំង ហើយព្រមានឲ្យឈប់មាត់បើមិនដូច្នេះទេនឹងត្រូវឈឺសាច់ជាងនេះទៅទៀត ។ ក្រោយឆ្នាំ១៩៧៩ អ្នកទោសម្នាក់នេះបានស្លាប់ដោយសាររបួសដើមទ្រូងដំបៅខ្ទុះមិនបានទៅព្យាបាលទាន់ពេលវេលា ។ អ្នកទោសខ្លះអស់កម្លាំងពេកដេកស្លាប់ក៏មាន ហើយអ្នកដែលនៅជិតៗគ្នាក៏មិនបានដឹងដែរ លុះដល់ព្រឹកព្រលឹមឡើងអ្នកយាមហៅទៅធ្វើការទើបបានដឹងថាស្លាប់ ។ រៀងរាល់មួយម៉ោងទៅពីរម៉ោងតែងតែមានការផ្លាស់ប្តូរអ្នកយាមម្តង ហើយនៅពេលដែលមានការផ្លាស់ប្តូរអ្នកយាមថ្មីត្រូវឲ្យអ្នកទោសរាប់ចំនួនតៗគ្នាដើម្បីឲ្យដឹងចំនួនចៀសវាងអ្នកទោសលួចរត់ ហើយប្រសិនបើរាប់ដល់ត្រឹមណាហើយមិនដឹងចំនួនប៉ុន្មានអ្នកនោះនឹងត្រូវទារុណកម្មដោយវាយនឹងរំពាត់ ឬក៏ទាត់ធាក់ជាដើម ។

ព្រឿង បានមកធ្វើការជាជាងដែកដោយសារគាត់មានជំនាញជាងដែក ។ ការងាររបស់គាត់គឺ ធ្វើខ្នោះច្រវាក់ សោ និងរនុកដែកសម្រាប់ដាក់អ្នកទោស ធ្វើកាំបិត ពូថៅ ញញួរ ចបកណ្តៀវ សម្រាប់ទុកឲ្យអ្នកទោសប្រើប្រាស់ ។ មានពេលខ្លះ ព្រឿង និងក្រុមរបស់គាត់មួយចំនួនត្រូវកាប់ដើមឈើ ឬដើមឫស្សីដើម្បីទុកធ្វើជាដងកាំបិត ពូថៅ ញញួរ ចប និងកណ្តៀវជាដើម ។ ក្រៅពីនោះ ព្រឿង ត្រូវបានចាត់តាំងឲ្យទៅធ្វើការជាមួយក្រុមអ្នកទោសផ្សេងទៀត ដូចជាលើកភ្លឺស្រែ ជីកប្រឡាយ ដកស្ទូង និងដាំដំណាំផ្សេងៗតាមរដូវកាល ។ ពីមួយថ្ងៃទៅមួយថ្ងៃ ព្រឿង ដឹងថាអ្នកទោសត្រូវបានយកទៅសម្លាប់សមាជិកម្នាក់ក្នុងក្រុមរបស់គាត់ត្រូវបានយកទៅសម្លាប់ដោយចោទថាខ្ជិលច្រអូសមិនខិតខំធ្វើការងារជូនអង្គការ ។ ដើម្បីឲ្យអង្គការទុកជីវិត ព្រឿង ខំធ្វើការទាំងជួលទាំងឈឺ (ជំងឺហើម) អាវដែលគាត់ធ្លាប់ពាក់រលុងប្រែជាចង្អៀត ។ ខ្លួនប្រាណរបស់គាត់គ្រប់កន្លែងសូម្បីតែក្បាលក៏ហើមដែរ ។ ព្រឿង ដឹងថាជំងឺហើមរបស់គាត់មកពីខ្វះជីវជាតិ ។ ក្រោយមកជំងឺហើមរបស់គាត់បានស្រកទៅវិញដោយសារតែបានហូបត្រីឆ្អិន និងចៃក្រពើ ។

### ការឃើញហេតុការណ៍រន្ធត់ផ្សេងៗ

ថ្ងៃមួយ ព្រឿង និងមិត្តរួមក្រុមម្នាក់បានដើរកាប់ដើមឫស្សីដើម្បីយកមកធ្វើដងកាំបិត-ដងចប ពេលមកដល់ព្រៃឫស្សីខាងកើតមន្ទីរគុកសង់ទន្លេបាទីដែលជាតំបន់ហាមឃាត់ដាច់ខាតមិនឲ្យនរណាម្នាក់ទៅក្បែរ សូម្បីតែប្រជាជនមូលដ្ឋាន ឬអ្នកទោសក៏មិនអនុញ្ញាតឲ្យធ្វើការនៅជិតកន្លែងនោះដែរ ។ ព្រឿង និងមិត្តភក្តិមិនបានចាប់អារម្មណ៍ពីតំបន់ហាមឃាត់នោះឡើយ ពួកគាត់គ្រាន់តែឃើញព្រៃឫស្សីក្រាស់ ហើយគិតថានៅទីនោះសម្បូរដើមឫស្សីច្រើនមិនចាំបាច់ដើររកឆ្ងាយ ។ ចូលដល់ក្នុងព្រៃឫស្សីបានបន្តិច គាត់បានឃើញដានផ្លូវលំមួយយ៉ាងរលោងដែលមានលក្ខណៈហាក់ដូចជាត្រូវបានប្រើប្រាស់រាល់ថ្ងៃ ប៉ុន្តែប្រសិនមើលពីខាងក្រៅគេមិនអាចដឹងថាខាងក្នុងមានផ្លូវសម្រាប់ដើរនោះទេ ។ គាត់ទាំងពីរបានធ្វើដំណើរតាមផ្លូវលំនោះទៅខាងក្នុងទៀត ហើយមានអារម្មណ៍ថាធុំក្លិនអសោចដូចជាសាកសព ឬគំរង់សត្វដែលស្លាប់ស្អុយរលួយនៅក្នុងព្រៃ ។ នៅពេលដែលគាត់ដើរចូលទៅជិតគាត់បានឃើញរណ្តៅធំៗជាច្រើន ដែលសាកសពគ្រាន់តែធ្វើកប់សើៗប៉ុណ្ណោះ កន្លែងខ្លះឃើញជើង ដៃ ក្បាល និងដងខ្លួនជាដើម ហើយឃើញមានឧបករណ៍សម្លាប់មនុស្សមានដូចជាដំបងឫស្សី គ្រឿវទេះ និងខ្សែចំណងជាច្រើន ព្រមទាំងខ្នោះដៃ និងខ្នោះជើងខ្លះៗដែលដោះចេញពីអ្នកទោសក្រោយពេលសម្លាប់ ។ ព្រឿង និងមិត្តរបស់គាត់ភ័យតក់ស្លុតយ៉ាងខ្លាំង ហើយប្រញាប់ប្រញាល់ចាកចេញពីទីនោះយ៉ាងលឿន ប៉ុន្តែពេលធ្វើដំណើរបានពាក់កណ្តាលផ្លូវមិនទាន់ចេញផុតពីផ្លូវលំនោះផង គាត់បានឮសំឡេងមនុស្សមួយក្រុមដើរតម្រង់ទៅកន្លែងនោះ គាត់ទាំងពីរក៏លាក់ខ្លួននៅក្នុងគុម្ពឫស្សីក្បែរផ្លូវលំ ហើយបានឃើញកងឈ្លបខ្មែរក្រហមពីរ-បីនាក់បណ្តើរអ្នកទោសមួយក្រុមប្រមាណដប់នាក់ទៅកាន់ទីនោះ ។ ពីដំបូង គាត់បានឮសំឡេងអ្នកទោសស្រែកសុំអង្វរឃាតករឲ្យទុកជីវិត បន្ទាប់មកឮសំឡេងដំបងវាយផូសៗ មួយសន្ទុះក្រោយមកសំឡេងទាំងនោះក៏ស្ងប់ស្ងាត់ទៅវិញ ។ ពេលត្រឡប់មកដល់កន្លែងវិញ គាត់មិនហ៊ានប្រាប់អំពីហេតុការណ៍ទាំងអស់នេះដល់នរណាម្នាក់ឡើយ សូម្បីតែមិត្តភក្តិស្និទ្ធស្នាលបំផុតក៏គាត់មិនហ៊ានប្រាប់ដែរ ។ ហេតុការណ៍រន្ធត់មួយទៀត គឺបានកើតឡើងនៅក្នុងការដ្ឋានរបស់គាត់ ខណៈពេលដែលគាត់កំពុងបាចទឹកបញ្ចូលស្រែកងឈ្លបខ្មែរក្រហមម្នាក់កំពុងតែវាយធ្វើបាបអ្នកទោសនឹងផាងត្នោត ព្រមទាំងជ្រមុជទឹករហូតដល់ស្លាប់ ព្រឿង មិនបានស្គាល់ថាជនរងគ្រោះនោះជានរណាទេ ហើយក៏មិនដឹងថាអ្នកនោះបានធ្វើអ្វីខុសដែរ ។ ក្រោយពីសម្លាប់អ្នកទោសម្នាក់នេះ ឈ្លបនោះបានប្រាប់អ្នកទោសផ្សេងទៀតថា នេះគឺជាលទ្ធផលនៃការខ្ជិលច្រអូសមិនធ្វើការងារ បើមានអ្នកខ្ជិលច្រអូសផ្សេងទៀតនឹងទទួលលទ្ធផលបែបនេះដែរ ។ និយាយចប់ឈ្លបក៏បញ្ជាឲ្យអ្នកទោសពីរនាក់យកខ្សែមកចងជើងសាកសពរួចអូសបញ្ច្រាសយកទៅដាក់ក្នុងបន្ទប់ឃុំឃាំងមួយយប់សិនទើបយកទៅកប់ ។

### មន្ទីរឃុំឃាំងវត្តកកោះ

មួយខែមុនបែកឆ្នាំ១៩៧៩ ដោយសារតែការខិតខំប្រឹងប្រែងធ្វើការនិងពុំសូវឃើញមានកំហុសជាដុំកំភួន ហើយអ្នកដឹកនាំថ្មីមកគ្រប់គ្រងពុំសូវមានការតឹងតែងផង ព្រឿង ត្រូវបាន

អន្តការទុកចិត្តឲ្យដឹកអន្តរ និងអ្នកទោសពីរ-បីនាក់ទៅកាន់មន្ទីរឃុំឃាំងវត្តកកោះ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកបាទី ខេត្តតាកែវ ។ អ្នកទោសនៅទីនោះភាគច្រើនគឺជាអ្នកមូលដ្ឋាននិងកម្មាភិបាល ។ ការហូបចុកនៅមន្ទីរឃុំឃាំងវត្តកកោះមានលក្ខណៈប្រសើរជាងនៅគុកសន់ទន្លេបាទី ។ ប៉ុន្តែការសម្លាប់រង្គាលអ្នកទោសមិនចាញ់គុកសន់ទន្លេបាទីប៉ុន្មានទេ ។ រោងជាងដែករបស់ ព្រឿង នៅជិតរោងដាំបាយ ដូច្នេះការដាំស្លទាំងប៉ុន្មានគាត់អាចមើលឃើញទាំងអស់ ។ ព្រឿង បានឃើញចុងក្រោយកលៀសដែលស្ងោររួចហូបសាច់អស់ បន្ទាប់មកយកសំបកចាក់ចូលទៅក្នុងទឹកសម្លឲ្យអ្នកទោសហូប ។

**ផលវិបាកក្រោយពីជាប់គុក**

សព្វថ្ងៃ ព្រឿង អាចធ្វើការងារបានត្រឹមការងារស្រាលៗ ប៉ុណ្ណោះដូចជា លើកភ្លឺស្រែ និងកិច្ចការនៅក្នុងផ្ទះបន្តិចបន្តួច ក្រៅពីនេះគាត់ជាអាចារ្យដេញពេលាការ ។ ការឃើញហេតុការណ៍ដ៏គួរឲ្យរន្ធត់នៅក្នុងរបបប៉ុលពតដូចជា ការចាប់ចងធ្វើទារុណកម្មឃុំឃាំង សម្លាប់ ធ្វើការហួសកម្លាំង និងហូបចុកមិនគ្រប់គ្រាន់ បានធ្វើឲ្យ ព្រឿង ក្លាយទៅជាមនុស្សម្នាក់ដែលមានសតិ និងកាយសម្បទាពុំរឹងមាំដូចជាមនុស្សធម្មតា ។ គាត់តែងតែយល់សុបិនអាក្រក់ជាញឹកញាប់ ទាក់ទងនឹងការចាប់ចង និងការធ្វើទារុណកម្មនៅក្នុងរបបនេះ ។ ព្រឿង ជ្រើសរើសធម៌ព្រះពុទ្ធមកដោះស្រាយបញ្ហាដែលមាននៅក្នុងចិត្តតាំងពីអតីតកាល ។ គាត់មិនមានការគុំគួនចំពោះជនដែលធ្លាប់ទាំងនោះឡើយ ប៉ុន្តែគាត់គ្រាន់តែចង់ដឹងនិងចង់ឃើញពីដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមផ្ទាល់ភ្នែក និងចង់ដឹងពីមូលហេតុពិតប្រាកដដែលនាំឲ្យមានការចាប់ប្រជាជនស្លូតត្រង់ទៅឃុំឃាំង បង្អត់អាហារ កាប់សម្លាប់យ៉ាងសាហាវព្រៃផ្សៃដោយមិនញញើតដៃដូច្នេះ ។ ព្រឿង បានបន្ថែមថា បំណងប្រាថ្នានៃការចង់ឃើញដំណើរនៃការកាត់ទោសនេះ មិនមែនជាការសងសឹកនោះទេ តែជាការស្វែងរកយុត្តិធម៌មួយសម្រាប់ខ្លួនគាត់ផ្ទាល់ក៏ដូចជាប្រជាជនស្លូតត្រង់ផ្សេងទៀតបន្ទាប់ពីបានឆ្លងកាត់ការរស់នៅក្នុងរបបមួយដែលអយុត្តិធម៌ គ្មានច្បាប់ទម្លាប់ត្រឹមត្រូវនិងគ្មានសិទ្ធិគ្រប់គ្រាន់ ។

**គង់ សុភគឿន**

# អតីតនារីពេទ្យ ៣-១៧ និយាយអំពី អៀង ធីរិទ្ធ

នៅអំឡុងឆ្នាំ១៩៧០ និង ឆ្នាំ១៩៧៥ ទីតាំងភាគច្រើននៃស្រុកឧដុង្គនិងស្រុកថ្ពងក្នុងខេត្តកំពង់ស្ពឺ ស្ថិតនៅក្នុងភូមិភាគពិសេសរបស់ខ្មែរក្រហម ជាសមរភូមិក្តៅរវាងកងទ័ពខ្មែរក្រហមនិងទាហានលន់ នល់ ។ ភូមិភាគនេះ ក៏ជាទីតាំងមន្ទីរពេទ្យមជ្ឈិមរបស់ខ្មែរក្រហមដែរ ។ នៅចុងឆ្នាំ១៩៧៤និងដើមឆ្នាំ១៩៧៥ នៅពេលដែលការវាយប្រហារចូលទីក្រុងភ្នំពេញ កាន់តែមានសភាពខ្លាំងក្លា កងទ័ពខ្មែរក្រហមជាច្រើនត្រូវរងរបួស ហើយត្រូវបញ្ជូនទៅសម្រាកនៅមន្ទីរពេទ្យដែលស្ថិតនៅក្នុងស្រុកទាំងពីរនេះ ។ បុគ្គលិកមួយចំនួនដែលបម្រើការនៅក្នុងមន្ទីរពេទ្យត្រូវបានជ្រើសរើសចេញពីប្រជាជនមូលដ្ឋាននៅក្នុងស្រុកទាំងពីរ និងស្រុកផ្សេងទៀតនៃខេត្តកំពង់ស្ពឺ ។

បាត់ ណាន ដែលមានស្រុកកំណើតនៅឃុំមានជ័យ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បានស្ម័គ្រចិត្តចូលបម្រើការងារជានារីពេទ្យរបស់ខ្មែរក្រហមក្នុងឃុំចន្ទរៀលក្នុងឆ្នាំ១៩៧៤ ។ ណាន បានរៀបរាប់ថា ភូមិភាគពិសេសទាំងមូលមានមន្ទីរពេទ្យពីរកន្លែង ។ មន្ទីរពេទ្យទី១ នៅទន្លេស្ងួត មានឈ្មោះថាមន្ទីរពេទ្យព-២៨ មន្ទីរពេទ្យទី២និងទី៣នៅនៅចន្ទរៀល ដែលមានឈ្មោះថា មន្ទីរពេទ្យព-២៧ ។ មន្ទីរពេទ្យព-២៨មានទទួលព្យាបាលរបួសកងទ័ព ហើយមន្ទីរពេទ្យព-២៧ ទទួលព្យាបាលកងទ័ពផង និងប្រជាជនទូទៅផង ។ កងទ័ពដែលត្រូវរបួសធ្ងន់ៗត្រូវបញ្ជូនទៅសម្រាកព្យាបាលនិងវះកាត់នៅមន្ទីរពេទ្យព-២៨ ។ ពេលរបួសធូរស្រាលអ្នកជំងឺនឹងត្រូវបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យព-២៧ ឯចន្ទរៀលវិញ ។

ណាន ត្រូវបានចាត់តាំងឲ្យធ្វើការនៅមន្ទីរពេទ្យព-២៧


បាត់ ណាន ឆ្នាំ២០០៥

ក្រោមការដឹកនាំរបស់សមមិត្ត ហុង ដែលជាអ្នកស្រុកមកពីខេត្តកំពង់ចាម ។ ចំណែកមន្ទីរព-២៧ មួយទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់ ពឿន ។ ហុង មានអនុប្រធានបីនាក់ឈ្មោះ ឡា, ម៉ៅ និង មុិញ ។ មុិញ គឺជាកូនស្រីរបស់ អៀង សារី និង អៀង ធីរិទ្ធិ ។ ណាន និយាយថា មុិញ ជាមនុស្សនិយាយច្រើន តែត្រង់ «ឃើញអីថាហ្នឹង» ។ នៅក្នុងមន្ទីរពេទ្យទាំងមូលមានតែ មុិញ ទេ ដែលមានសម្ភារប្រើប្រាស់ទំនើបៗ ដែលឪពុកម្តាយផ្ញើមកពីបរទេស ។ នៅក្រោយរំដោះភ្នំពេញឆ្នាំ១៩៧៥ មុិញ បានរៀបការជាមួយ ពឿន នៅទីក្រុងភ្នំពេញ ។

ក្រោយពេលខ្មែរក្រហមឡើងកាន់កាប់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ មន្ទីរពេទ្យក្នុងភូមិភាគពិសេសទាំងអស់ ត្រូវបានផ្លាស់មកប្រមូលផ្តុំនៅមន្ទីរពេទ្យ១៧មេសា (ព-១៧) នៅទីក្រុងភ្នំពេញ ។ នៅខណៈពេលនោះ ហុង នៅតែជាប្រធាន ហើយ មុិញ, ម៉ៅ និង ឡា មាននាទីជាអនុប្រធានដដែល ។ មកដល់ភ្នំពេញដំបូង ណាន ត្រូវបានចាត់តាំងឲ្យធ្វើការនៅបន្ទប់ពិសោធន៍របស់មន្ទីរពេទ្យព-១៧ ។ ថន ជាប្រធានបន្ទប់ពិសោធន៍ ។

បន្ទប់ពិសោធន៍នោះនៅជាប់នឹងបន្ទប់ធ្វើការរបស់ ដួន ជឿន ។ ណាន បានប្រាប់ថា ដួន ជឿន មានរូបរាងស្រដៀងនឹងសម្តេចឪ ប៉ុន្តែមានសម្បុរស្រអែម ។ ដួន ជឿន ជាមនុស្សមិនសូវនិយាយស្តីច្រើនទេ ភាគច្រើនគាត់ចំណាយពេលនៅម្នាក់ឯង និងគិតតែពីរឿងវះកាត់អ្នកជំងឺដែលចូលមកសម្រាកព្យាបាលរាល់ថ្ងៃ ។

ថ្ងៃមួយ កម្មាភិបាលម្នាក់បានចូលមកមន្ទីរពេទ្យព-១៧ ដើម្បីពិនិត្យឈាមរកមេរោគថ្លើម ។ ណាន ជាអ្នកបូមឈាមឲ្យកម្មាភិបាលនោះ ។ កម្មាភិបាលម្នាក់នោះបានមូរដៃអាវដោយខ្លួនឯង និងបានបញ្ជាឲ្យ ណាន យកម្ជុលមកបូមឈាម ។ ណាន មិនបានស្គាល់ថាកម្មាភិបាលនោះជាអ្នកណាទេ គាត់គ្រាន់តែដឹងថា «ម្នាក់នោះប្រាកដជាកម្មាភិបាលធំហើយ ពីព្រោះដៃគាត់មើលទៅស ទ្រលុកទ្រលន់មិនដូចអ្នកដែលបានតស៊ូនៅក្នុងព្រៃ ឬក៏អ្នកដែលធ្លាប់ធ្វើការនៅមន្ទីរពេទ្យព-២៧ កាលពីមុនឆ្នាំ១៩៧៥នោះទេ» ។ រយៈពេលមួយឆ្នាំក្រោយមក ទើប ណាន បានដឹងថា កម្មាភិបាលដែលគាត់បូមឈាមយកទៅវិភាគរកមេរោគថ្លើមនោះ គឺជាម្តាយរបស់ មុិញ ដែលមានឈ្មោះថា អៀង ធីរិទ្ធិ ហៅ (អ៊ំភា) ដែលជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ។

នៅក្នុងឆ្នាំ១៩៧៧ អៀង ធីរិទ្ធិ បានកោះហៅកម្មាភិបាលយុទ្ធជនយុទ្ធនារីពេទ្យទាំងអស់ដើម្បីប្រជុំអប់រំឲ្យខិតខំធ្វើការងារ និងព្យាបាលជំងឺជូនប្រជាជននិងកងទ័ពដែលបានប្រយុទ្ធនៅសមរភូមិមុខ ។ នៅចុងឆ្នាំដដែលនេះ បងប្រុសរបស់ ណាន ម្នាក់ឈ្មោះ វឿន ដែលជាកម្មាភិបាលពេទ្យធ្មេញនៅមន្ទីរពេទ្យ១៧មេសា ត្រូវអង្គការចាប់ខ្លួន ហើយបាត់ដំណឹងរហូតដល់បច្ចុប្បន្ន ។ រយៈពេលមួយខែក្រោយការចាប់ខ្លួនរបស់ វឿន និងកម្មាភិបាលពេទ្យផ្សេងៗទៀត អៀង ធីរិទ្ធិ បានកោះហៅកម្មាភិបាលយុទ្ធជនយុទ្ធនារីពេទ្យទាំងអស់មកប្រជុំម្តងទៀត ក៏ប៉ុន្តែលើកនេះ អៀង ធីរិទ្ធិ មិនបាននិយាយដូចការប្រជុំពីលើកមុនទេ គាត់គ្រាន់តែនិយាយអំពីអ្នកដែលបានក្បត់អង្គការ ហើយត្រូវអង្គការដកចេញ ។ អៀង ធីរិទ្ធិ បានយកបញ្ជីអានឈ្មោះកម្មាភិបាលពេទ្យ ដែលក្បត់នឹងអង្គការ ។ នៅក្នុងបញ្ជីនោះមានឈ្មោះបងប្រុសម្នាក់របស់ ណាន ដែរ ។ ពេលអានចប់ អៀង ធីរិទ្ធិ បានសួរទៅកម្មាភិបាលពេទ្យដែលចូលរួមប្រជុំថា «តើអ្នកណាមានពាក់ព័ន្ធនឹងអ្នកក្បត់ទាំងអស់នេះទេ? បើបងប្អូនណាមានជាប់ពាក់ព័ន្ធ ត្រូវលើកដៃ ហើយឡើងប្តេជ្ញាចំពោះមុខសមូហភាព» ។ នៅពេលនោះ ណាន បានលើកដៃនិងឡើងប្តេជ្ញាថា «ខ្ញុំនឹងដើរតាមបក្ស អត់ដើរតាមបងប្រុស ដែលក្បត់អង្គការនោះទេ» ។ ណាន និយាយបែបនេះ ដោយសារតែគាត់ខ្លាចអង្គការដកយកទៅដូចបងប្រុសរបស់ខ្លួនដែរ ។

នៅអំឡុងឆ្នាំ១៩៧៧ដល់១៩៧៨ ណាន ធ្លាប់បានឃើញ នួន ជា និង ខៀវ សំផន មកធ្វើទស្សនកិច្ចនៅមន្ទីរពេទ្យ១៧មេសាជាច្រើនដង ។ នួន ជា និង ខៀវ សំផន ក៏ធ្លាប់បានដើរពិនិត្យមើលអគារមន្ទីរពេទ្យនិងផ្ទះបាយ ហើយថែមទាំងបានបញ្ជាឲ្យជួសជុលផ្នែកខ្លះនៃមន្ទីរពេទ្យទៀតផង ។ ណាន ដឹងថា

កាលណោះ ខៀវ សំផន មានតួនាទីជាប្រធានគណៈប្រធានរដ្ឋ ហើយ នួន ជា ជាប្រធានសភា ។ នៅក្នុងអំឡុងពេលនោះដែរ ណាន ក៏ធ្លាប់បានឃើញថ្នាក់ដឹកនាំធំៗ ដែលបានមកព្យាបាលធ្មេញនៅមន្ទីរពេទ្យ១៧មេសា ។ ពេលអ្នកទាំងនេះមកម្តងៗ មានកងការពារជាច្រើនយាមនៅក្នុងមន្ទីរពេទ្យ ហើយមិនមានបុគ្គលិកពេទ្យណាម្នាក់ត្រូវបានអនុញ្ញាតឲ្យដើរនៅក្បែរកន្លែងនោះទេ ។ ណាន ក៏ធ្លាប់បានឃើញគណៈភូមិភាគបស្ចិមឈ្មោះ តាស៊ី និងប្រពន្ធឈ្មោះ លី និង គណៈតំបន់៣១ ឈ្មោះ តាប៉ុល មកសម្រាកព្យាបាលនៅមន្ទីរពេទ្យ១៧មេសា និងធ្លាប់បូមឈាម លី យកមកពិនិត្យនៅមន្ទីរពិសោធន៍ដែរ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ណាន ឃើញគណៈប្រតិភូមកពីប្រទេសរូម៉ានី អូស្ត្រាលី និងកូរ៉េខាងជើងមកធ្វើទស្សនកិច្ចនៅមន្ទីរពេទ្យនេះ ។ ណាន ក៏ធ្លាប់បានទៅទទួលគណៈប្រតិភូមកពីប្រទេសទីម័រខាងកើតនៅមហោស្រពចតុមុខផងដែរ ។ ក្រៅពីនោះ ណាន ធ្លាប់បានរៀនវគ្គបច្ចេកទេសពេទ្យជាមួយជំនាញការចិននៅក្នុងបន្ទប់ពិសោធន៍ ហើយ ថន ជាអ្នកបកប្រែភាសាព្រោះគាត់ធ្លាប់ទៅរៀននៅប្រទេសចិន ។

នៅចុងឆ្នាំ១៩៧៨ ណាន បានអះអាងថា មានកងទ័ពថៃក្រហមមួយចំនួនបានមកសម្រាកព្យាបាលនៅមន្ទីរពេទ្យ១៧មេសា ។ ជាងនេះទៅទៀត មានជនជាតិថៃប្រមាណ៦-៧នាក់ផ្សេងទៀត បានមករៀនសូត្របច្ចេកទេសពេទ្យនៅមន្ទីរពេទ្យ១៧មេសានេះដែរ ។ នៅក្នុងចំណោមនោះ ណាន នៅចាំមនុស្សម្នាក់ដែលរៀនវគ្គបណ្តុះបណ្តាលជាមួយគ្នាឈ្មោះ ដួងចៃ ។ ពេលបែកភ្នំពេញនៅដើមឆ្នាំ១៩៧៩ ទាំងជនជាតិថៃនិងជំនាញការចិនបានរត់ភៀសខ្លួនទៅភាគខាងលិចប្រទេសរហូតដល់ខេត្តបាត់ដំបង ។ អ្នកទាំងអស់ត្រូវបែកគ្នានៅទីនោះ ។ ណាន បានរត់ត្រឡប់ក្រោយមកស្រុកកំណើតវិញ ហើយបានរស់នៅជួបជុំបងប្អូនជាថ្មីម្តងទៀត ។ ការស្ម័គ្រចិត្តចូលធ្វើការជាកម្មាភិបាលពេទ្យដើម្បីបម្រើបដិវត្តន៍ នៅទីបំផុតមិនមានប្រយោជន៍អ្វីទាំងអស់ ហើយថែមទាំងត្រូវបាត់បង់បងប្រុសជាទីស្រលាញ់ម្នាក់ថែមទៀតផង ។

**ឡុង ដានី**

# មិនចង់រំឭក

នៅក្នុងជីវភាពជាកសិករ ហាយ បច្ចុប្បន្នជាស្ត្រីសាមញ្ញម្នាក់ ប៉ុន្តែនៅពេលខ្ញុំពិនិត្យមើលសន្លឹកដំបូងនៃប្រវត្តិរូបរបស់គាត់ ដែលបានធ្វើនៅក្នុងឆ្នាំ១៩៧៥ ហាយ មានបង្កប់នូវ



ហាយ ឆ្នាំ២០០៦

ជីវិតតស៊ូមួយផ្សេងពីអ្នកភូមិដទៃទៀតនៅក្នុងរយៈនៃការកាន់កាប់របស់ខ្មែរក្រហមកាលពីអំឡុងពេល៣០ឆ្នាំមុន ។ ហាយ ហាក់ដូចមិនចង់រំឭកពីអតីតកាលរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមទេ ព្រោះថាអ្វីដែល ហាយ ផ្តោតអារម្មណ៍ជាខ្លាំងរៀងរាល់ថ្ងៃនេះ គឺខិតខំធ្វើស្រែចម្ការដើម្បីទំនុកបម្រុងកូនៗឲ្យបានទៅសាលារៀនគ្រប់គ្នាប៉ុណ្ណោះ ។ «ខ្ញុំមិនចង់ចាំប្រគិតគូរអីទេ របស់ធ្លាប់លំបាកធ្លាប់កម្សត់ ធ្លាប់ក្រ នៅតាមព្រឹក្សតាមព្រៃ ក៏នឹកថាខ្ជិលនឹកនាអី» ។ យ៉ាងណាក៏ដោយ ដើម្បីឲ្យកូនៗបានដឹងពុទ្ធនិងស្វែងយល់ពីអតីតកាលរបស់ឪពុកម្តាយ ហាយ សម្រេចទម្លាយការពិតនេះ ។

កាលពីកុមារ ហាយ រៀននៅសាលាបឋមសិក្សានៅក្នុងភូមិបានត្រឹមតែថ្នាក់ទី១១ (ថ្នាក់ទី២ បច្ចុប្បន្ន) ដោយសារគ្រូបង្រៀនរបស់ ហាយ ត្រូវគេបាញ់សម្លាប់ ហើយគ្រូបង្រៀនផ្សេងទៀតបានរត់ចោលសាលានៅពេលឃើញព្រឹត្តិការណ៍នេះ ។ ហាយ ក៏ឈប់រៀនហើយមកជួយធ្វើស្រែចម្ការឪពុកម្តាយវិញ ។ ក្នុងឆ្នាំ១៩៧២ ប្រធានភូមិបានជ្រើសរើស ហាយ និងកុមារៗនៅក្នុងភូមិមួយចំនួនទៀតធ្វើឈ្លបដើម្បីយាមគិញនិងសួរនាំពីដំណើរចេញចូលរបស់អ្នកភូមិ ។ ហាយ មិនពេញចិត្តនឹង

ការជ្រើសតាំងនេះទេ ក៏ប៉ុន្តែគាត់ក៏មិនអាចបដិសេធបានដែរ ព្រោះថាវ័យរបស់គាត់ជាវ័យដែលត្រូវបម្រើជាតិ ។ ឪពុកម្តាយរបស់ ហាយ មិនដាច់ចិត្តឲ្យគាត់ចាកចេញពីផ្ទះទេ ប៉ុន្តែក្រោយមកអ្នកទាំងពីរមានការកក់ក្តៅក្នុងចិត្តបន្តិចដោយសារ មានកុមារី៦នាក់ទៀតទៅជាមួយ ហាយ ដែរ ។

រយៈពេលជិតមួយឆ្នាំក្រោយមក កងឈ្លបរបស់ ហាយ ត្រូវបានជ្រើសតាំងជាកងទ័ពវិញ ។ ហាយ ធ្វើដំណើរជាមួយកងទ័ពរំដោះក្មេងៗដែលរស់នៅភូមិក្បែរៗនោះប្រមាណ១០០នាក់ដើរកាត់ព្រៃតាមបណ្តោយផ្លូវជាតិលេខ៦ ឆ្ពោះមកទីក្រុងភ្នំពេញ ។ ក្រុមរបស់ ហាយ ធ្វើដំណើរដោយថ្មើរជើងផង និងជិះឡានផង ឆ្លងកាត់ខេត្តកំពង់ធំនិងកំពង់ចាមសំដៅទៅចូលរួមសមរភូមិនៅព្រែកព្នៅដើម្បីវាយរំដោះទីក្រុងភ្នំពេញ ។ ហាយ ត្រូវដើរឡើងដោរពងជើងទម្រាំធ្វើដំណើរដល់គោលដៅ ហើយយុទ្ធជនយុវនារីមួយចំនួនបានស្លាប់នៅតាមផ្លូវដោយជំងឺគ្រុនចាញ់ និងពុលអាហារ ។ នៅសមរភូមិព្រែកព្នៅ ហាយ មាននាទីជាអ្នកយាមកាំភ្លើង ជញ្ជូនគ្រាប់ទៅសមរភូមិមុខនិងសែងអ្នករបួសពីខ្សែត្រៀមមកសមរភូមិក្រោយ ។ បន្ទាប់ពីការប្រយុទ្ធយ៉ាងស្វិតស្វាញ កងទ័ពរំដោះបានទទួលជ័យជម្នះលើទាហានសាធារណរដ្ឋខ្មែរ ។ ក្រុមរបស់ ហាយ ក៏ធ្វើដំណើរដោយថ្មើរតាមផ្លូវជាតិលេខ៥ចូល ទីក្រុងភ្នំពេញបញ្ច្រាសទិសគ្នាជាមួយប្រជាជនដែលកំពុងជម្លៀសចេញពីទីក្រុងភ្នំពេញទៅកាន់ជនបទ ។ ហាយ មិនហ៊ានសួរនាំប្រជាជនពីដំណើរនោះទេព្រោះខ្លួនស្ថិតក្នុងជួរកងទ័ព គាត់គ្រាន់តែដឹងតាមអ្នកនៅក្នុងក្រុមថា នេះជាផែនការបោសសម្អាតប្រជាជនចេញពីទីក្រុងមួយរយៈពេលខ្លីតែប៉ុណ្ណោះ ។

ពេលធ្វើដំណើរដល់ទីក្រុងភ្នំពេញ ហាយ ស្នាក់នៅក្នុងទីក្រុងមួយរយៈដើម្បីរង់ចាំទទួលភារកិច្ចថ្មី ។ ក្នុងរយៈកាលស្នាក់នៅនេះ ហាយ បានឃើញយុទ្ធជននៅកងផ្សេងដែលបានមកដល់ភ្នំពេញមុន ដើររុះរើផ្ទះប្រជាជននិងជញ្ជូនសម្ភារដែលអាចប្រើប្រាស់បានដាក់រថយន្តដើម្បីយកមកទុកប្រើប្រាស់តាមកង ។ ពីរថ្ងៃបន្ទាប់ កងរបស់ ហាយ ទទួលផែនការទៅជួយវាយរំដោះក្រុងកំពង់សោម និងខេត្តកោះកុងបន្តទៀត ។ ធ្វើដំណើរជិតដល់ក្រុងកំពង់សោម ហាយ បានឮសូរគ្រាប់កាំភ្លើងបាញ់តទល់គ្នានៅកណ្តាលទីក្រុង ហើយប៉ុន្មានម៉ោងក្រោយមក ក្រុងកំពង់សោមត្រូវបានរំដោះទាំងស្រុង ។ បន្ទាប់មកខេត្តកោះកុងក៏ត្រូវបានរំដោះដែរ ។ ក្រុមរបស់ ហាយ មិនបានឡើងសមរភូមិប្រយុទ្ធទេ ប៉ុន្តែក្រុមរបស់គាត់ត្រូវបានចាត់តាំងឲ្យធ្វើជាកម្មករលីសែងនៅកំពង់ផែកំពង់សោម និងស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធាននារីឈ្មោះ ថា ។ ហាយ លីសែងទំនិញ ដូចជាលីកៅស៊ូពីរថយន្តដឹកជញ្ជូនដាក់កប៉ាល់ និងលីអង្ករពីកប៉ាល់យកមកដាក់នៅឃ្លាំង ឬដាក់បន្តតាមរថយន្តដឹកជញ្ជូន ។ ការងារដឹកជញ្ជូននៅកំពង់ផែនេះ មិនមានពេលវេលាធ្វើការច្បាស់លាស់ទេ ។ មានថ្ងៃខ្លះ ហាយ ត្រូវធ្វើការដល់យប់ជ្រៅនិងថ្ងៃខ្លះទំនេរ ហើយពេលទំនេរ ហាយ យាមល្បាតទំនិញទាំងនោះ រង់ចាំរថយន្តឬកប៉ាល់មកដឹក ។

ហាយ ធ្វើការនៅកំពង់ផែបានមួយឆ្នាំ ក៏ត្រូវផ្លាស់ទៅធ្វើការនៅរោងចក្រប្រេងកាតនៅតាមមាត់សមុទ្រវិញ (ហាយ មិនអាចសម្គាល់បានថារោងចក្រប្រេងកាតស្ថិតនៅទីតាំងណាច្បាស់ទេ ព្រោះទីនោះហ៊ុមព័ទ្ធទៅដោយព្រៃក្រាស់ៗ) ។ ហាយ មានភារកិច្ចយាមល្បាតនៅក្នុងរោងចក្រនោះ ដោយផ្លាស់វេនជាមួយសមាជិកនៅក្នុងក្រុម ។ «*គេឲ្យយាមក៏យាមទៅ មិនដឹងយាមស្អីមិនដែលឃើញមានស្អីផង ។ ផ្លាស់គ្នាយាមម្នាក់ម្តងក្រែងអ្នកណាគេមកដុតរោងចក្រប្រេងកាត*» ។

នៅដើមឆ្នាំ១៩៧៧ កងរបស់ ហាយ ត្រូវផ្លាស់ទៅធ្វើជាកម្មករនៅខេត្តកំពតវិញ ។ ហាយ ជញ្ជូនអំបិលពីវាលស្រែ(អំបិល) យកទៅដាក់តាមរថយន្តដឹកជញ្ជូនដែលកំពុងតែតម្រៀបជួរបន្តគ្នា ។ ទាំងការរស់នៅក្រុងកំពង់សោម ក៏ដូចជានៅខេត្តកំពត ហាយ ត្រូវហូបបបរនៅពេលណាមិនសូវមានការងារធ្ងន់ធ្វើ ហើយនៅពេលធ្វើការធ្ងន់ ហាយ ទទួលបានបាយរឹងនិងនំបុ័ងម្តងម្កាលដែរ ។ ហាយ បានរំឭកថា «*នៅកំពង់សោមនិងនៅកំពត ហូបចុកមិនសូវបានគ្រប់គ្រាន់ទេ ។ បើសិនមិនសូវបានធ្វើការធ្ងន់ហូបបបរ បើធ្វើការធ្ងន់ហូបបាយហូបនំបុ័ង ។ នំបុ័ងមិនដឹងគេបានពីណាមកទេ ស្រាប់តែគេដាក់នំបុ័ងឲ្យ ។បុិនធ្វើការសម្បើមណាស់ សុទ្ធតែលីរាប់រយគីឡូនោះ* ។

ប្រហែលជាកន្លះឆ្នាំ ហាយ ក៏ត្រូវបានបញ្ជូនឲ្យមកធ្វើការ

នៅក្រសួងពាណិជ្ជកម្មឯទីក្រុងភ្នំពេញវិញ ហើយស្នាក់នៅម៉ុំផ្សារចាស់ ។ ហាយ ស្ថិតនៅក្នុងកងឆ្វាស់ក្រោមការគ្រប់គ្រងរបស់មេកងនារីឈ្មោះ ថា ដដែល ។ ក្រោយពីទទួលបានកន្លែងស្នាក់នៅសមរម្យ ហាយ ត្រូវបានចាត់តាំងឲ្យទៅដឹកជញ្ជូនស្បៀងនៅក្នុងអង្គភាពពាណិជ្ជកម្មក្រៅប្រទេសដោយឆ្លាស់គ្នាជាក្រុមៗ ។ ហាយ ដឹកជញ្ជូន ពោត គ លូ គ្រាប់ឈូក ស្បែកពស់ថ្លាន់ និងសណ្ដែក ដែលដឹកមកពីសហករណ៍យកមកផ្ទុកក្នុងឃ្លាំងនៅតាមផ្ទះម៉ុំផ្សារចាស់យកទៅដាក់នៅស្ថានីយរថភ្លើង ។ នៅថ្ងៃបន្ទាប់មក ហាយ ត្រូវបានផ្លាស់ទៅបកគគនៅក្បែរវត្តខណ្ឌលោមនិងវត្តទួលទំពូង ហើយគដែលបករួចត្រូវដឹកយកទៅដាក់នៅកន្លែងគ្រីបនៅតាខ្មៅ ។ រាល់ពេលទៅបកគ ហាយ និងក្រុមរបស់គាត់ត្រូវបានរថយន្តដឹកយកទៅ ដល់ម៉ោងសម្រាកទើបរថយន្តដឹកក្រុមគាត់មកកន្លែងស្នាក់នៅវិញ ។

ហាយ ធ្វើការច្រើនតែទទួលបានអាហារតិចតួច ប៉ុន្តែគាត់មិនដែលតវ៉ាឬមានយោបល់ចំពោះការចាត់តាំងរបស់អង្គការឡើយ ។ ទោះជាយ៉ាងណា ហាយ មិនអាចគេចផុតពីក្រសែភ្នែករបស់មេកងដែលតែងចាប់អារម្មណ៍និងឃ្លាំមើលគ្រប់សកម្មភាពរបស់យុវជននិងយុវនារីឡើយ ។ នៅចុងឆ្នាំ១៩៧៧ ខណៈពេលដែល ហាយ លួចងាកមកនិយាយជាមួយមិត្តភក្តិដែលធ្វើការជាមួយគ្នា មេកងបានហៅគាត់ទៅព្រមាននិងចោទប្រកាន់ថាក្បត់ ។ ស្របពេលជាមួយគ្នានេះ អង្គការចាប់ផ្ដើមកម្ទេចខ្សែក្បត់នៅភូមិភាគនោះ និងតាមចាប់ខ្លួនកម្មាភិបាលដែលចេញមកពីភូមិភាគបូព៌ា ។ មេកងដែលចោទប្រកាន់ ហាយ ក៏ត្រូវចាប់ខ្លួននិងនាំខ្លួនយកទៅដែរ ។

នៅដើមឆ្នាំ១៩៧៨ ឈានចូលវ័យ១៩ឆ្នាំ ហាយ បានរៀបការជាមួយយុទ្ធជនឈ្មោះ ភាព តាមការស្នើសុំរបស់អង្គការជាមួយយុវជននិងយុវនារីពាក់ទៀត ។ ភាព មានអាយុលើសហាយ ៤ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ធំ ។ មុនពេលរៀបការ ហាយ និង ភាព មិនធ្លាប់បាននិយាយឆ្លើយឆ្លងគ្នាទេ ថ្វីដ្បិតតែអ្នកទាំងពីរខស្សាហ៍ហូបបាយរួមនៅរោងបាយក៏ដោយ ។ អាពាហ៍ពិពាហ៍ប្រព្រឹត្តទៅក្នុងរយៈខ្លីបំផុត សូម្បីតែឪពុកម្ដាយនិងសាច់ញាតិក៏មិនបានដឹងឮដែរ ។ មង្គលការនេះស្ថិតក្រោមអធិបតីភាពរបស់ វ៉ាន់ រិទ្ធ ប្រធានមន្ទីរក-១៥ នៅក្រសួងពាណិជ្ជកម្ម ព្រោះភាព ជានិរសាររបស់ រិទ្ធ ។ ហាយ បានឲ្យដឹងថា "គេចាប់ដាក់ឈរទីមុខគ្នាក៏ឡើងចាប់អារម្មណ៍និងប្ដេជ្ញាចិត្តរៀងខ្លួន រួចហើយទើបនាំគ្នាហូបបាយហូបទឹក ហើយក៏មកផ្ទះ ។ រៀបការហ្នឹងតែ៣គូទេ" ។ ហាយ បានទទួលការអនុញ្ញាតឲ្យសម្រាកពីការងារចំនួនបីថ្ងៃក្នុងឱកាសរៀបការនេះ ។

រិទ្ធ បានប្រគល់ផ្ទះមួយល្វែងដែលនៅក្បែរផ្សារចាស់ដល់អ្នកទាំងពីររស់នៅដាច់ដោយឡែកពីកម្មករ ។ ហាយ ឈប់លីសែងទៀតហើយ គាត់ផ្លាស់ទៅដាំបាយនិងរៀបបាយឲ្យកម្មករវិញ ក៏ប៉ុន្តែអ្នកទាំងពីរត្រូវទៅហូបបាយនៅរោងបាយរួមដដែល ។

ហាយ ធ្លាប់បានទៅចូលរួមប្រជុំនិងរៀនវគ្គនយោបាយនៅស្ពានអូឡាំពិកចំនួនពីរដងដែលមានការចូលរួមពីកម្មាភិបាលជាន់ខ្ពស់របស់អង្គការ ។ ក្រៅពីនេះ ហាយ ក៏ធ្លាប់បានទៅទទួលគណៈប្រតិភូចិននៅព្រលានយន្តហោះដែរ ។ នេះជាឱកាសមួយដែល ហាយ បានស្លៀកសម្លៀកបំពាក់ថ្មីនិងបានឃើញទិដ្ឋភាពនៅក្រៅកន្លែងធ្វើការ ។ ផ្ទុយទៅវិញ ហាយ មិនបានដឹងថាប្រជាជន ជាពិសេសឪពុកម្ដាយនិងក្រុមគ្រួសាររបស់ខ្លួនរស់នៅក្នុងជីវភាពបែបណានៅតាមសហករណ៍នោះទេ ។

ដើមឆ្នាំ១៩៧៨ ហាយ បានទទួលការអនុញ្ញាតពី រិទ្ធ ទៅលេងឪពុកម្ដាយនៅឯស្រុកកំណើត រយៈពេល១២ថ្ងៃ ។ ហាយ ធ្វើដំណើរតាមរថយន្តដឹកជញ្ជូនរបស់អង្គការ ដោយគាត់ត្រូវបង្ហាញលិខិតអនុញ្ញាតនិងសុំលិខិតធ្វើដំណើរបន្តនៅគ្រប់កន្លែងដែលគាត់ផ្ទេររថយន្ត ។ ហាយ ភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលឃើញឪពុកម្ដាយនិងអ្នកភូមិធ្វើការធ្ងន់ ហើយច្រើនម៉ោងជាងការដែលខ្លួនធ្វើនៅភ្នំពេញទៅទៀត ជាមួយនឹងរបបអាហារដ៏តិចតួចបំផុត ។ ហាយ តូចចិត្តដែលខ្លួនមិនអាចជួយសម្រាលទុក្ខលំបាករបស់ឪពុកម្ដាយបាន ។

បន្ទាប់ពីត្រឡប់មកពីសួរសុខទុក្ខឪពុកម្ដាយវិញ ហាយ ចាប់មានផ្ទៃពោះ ហើយគាត់បានទទួលការអនុញ្ញាតឲ្យសម្រាកពីការងាររយៈពេលមួយខែនៅមុនពេលសម្រាលកូន ។ នៅចុងខែធ្នូ ហាយ សម្រាលបានកូនប្រុសម្នាក់នៅមន្ទីរពេទ្យ១៧មេសា ។

នៅថ្ងៃទី៦ ខែមករាឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយជិតចូលដល់ទីក្រុងភ្នំពេញ ។ ហាយ ដែលទើបតែសម្រាលកូនបាន១សប្តាហ៍បានភៀសខ្លួនជាមួយស្ត្រីនិងក្មេងៗដទៃទៀត ឆ្ពោះទៅភាគខាងលិចប្រទេសទាំងកណ្តាលអធ្រាត្រ ។ ចំណែកយុទ្ធជនមិនបានរត់ចេញនៅថ្ងៃនោះទេ ព្រោះត្រូវនៅចាំការពារមន្ទីរ ។ ចេញផុតពីភ្នំពេញបន្តិច រថយន្តបានខូច ហាយ ត្រូវបីកូនដើរបន្តដើម្បីគេចពីការតាមប្រកិតរបស់កងទ័ពវៀតណាម ។

ហាយ ធ្វើដំណើរដល់ជាយដែនថៃនិងស្នាក់នៅភូមិទួលបារាំងដើម្បីរង់ចាំប្តី ។ ក្នុងរយៈកាលរង់ចាំ ហាយ បានជួបនូវការដាច់ស្បៀងជាញឹកញាប់ គាត់ដើរគាស់ ទំពាំង ដំឡូង និងគល់ចេកយកមកដាំលាយបាយហូប ។ ដោយសារកង្វះជីវជាតិនិងកង្វះការថែទាំកូនរបស់ ហាយ បានស្លាប់នៅទីនោះ ។

ហាយ រង់ចាំប្តីអស់រយៈពេលជិតកន្លះឆ្នាំ ទើបបានទទួលដំណឹងតាមអ្នកធ្លាប់ស្គាល់គ្នាម្នាក់ថា ភាព ត្រូវបានកងទ័ពវៀត-ណាមឃាត់ខ្លួននៅខេត្តបាត់ដំបងរួចបញ្ជូនឲ្យត្រឡប់ទៅក្រោយវិញ ។ ពេលបានទទួលដំណឹងនេះភ្លាម ហាយ បានសុំប្រធានអង្គភាពត្រឡប់មករកប្តីនៅខាងក្រោយវិញ ប៉ុន្តែប្រធានអង្គភាពមិនអនុញ្ញាតព្រោះខ្លាចជួបកងទ័ពវៀតណាម ។ ណាមួយកូនស្លាប់ ណាមួយអស់សង្ឃឹមក្នុងការរង់ចាំផង ហាយ ក៏សម្រេចចិត្តត្រឡប់មកស្រុកកំណើតដើម្បីជួបជុំឪពុកម្តាយវិញ ។

ហាយ មកដល់ភូមិកំណើតនៅឆ្នាំ១៩៨១ ហើយឪពុកម្តាយគាត់បានប្រាប់ថា ភាព បានមករកខ្លួនចំនួនពីរបីដងដែរ ។ ដោយនឹកស្មានថា ហាយ និងកូនបាត់បង់ជីវិតនៅក្នុងដំណើររត់គេចទៅភាគខាងលិចនោះ ភាព ក៏ត្រឡប់ទៅភូមិកំណើតវិញ ។ គ្រាន់តែឮដំណឹងនេះ ហាយ បានទៅតាមរកប្តីនៅឯខេត្តកំពង់ធំ ។ ក៏ប៉ុន្តែយឺតពេលមួយជំហានទៅហើយ ព្រោះ ភាព បានរៀបការជាមួយភរិយាថ្មីម្នាក់ ។ នៅពេលនោះ ហាយ មានអារម្មណ៍ប្រចូកប្រចល់ជាខ្លាំងមិនដឹងថាខ្លួនត្រូវដើរទៅមុខទៀត ឬក៏ដកខ្លួនថយក្រោយវិញឡើយ ។ ក្រោយពីពិភាក្សាជាមួយឪពុកម្តាយ ហាយ បានសម្រេចចិត្តបោះបង់ចោលអាពាហ៍ពិពាហ៍នាសម័យខ្មែរក្រហមជាមួយ ភាព ហើយចាប់ផ្តើមជីវិតថ្មី ដោយព្រមរៀបការជាមួយអ្នកភូមិក្បែរគ្នាម្នាក់ឈ្មោះ ហ៊ាញ នៅឆ្នាំ១៩៨២ តាមការផ្សំផ្គុំរបស់ឪពុកម្តាយ ។

សព្វថ្ងៃ ហាយ មានអាយុ៥១ឆ្នាំ មានកូនចំនួន៦នាក់ ។ ក្នុងរយៈពេលជិត៣០ឆ្នាំមកនេះ ហាយ នឹកស្តាយកុមារភាពរបស់ខ្លួនដែលមិនបានរស់នៅនិងទទួលការថ្នាក់ថ្នមពីឪពុកម្តាយ និងមិនបានសិក្សាខ្ពង់ខ្ពស់ ។

**ណាយ សុផារី**

# ពាក្យស្លោកខ្មែរក្រហម

- **ស្លាប់ក្នុងសង្គ្រាមប្រសើរថ្លៃថ្លា។**
- **ខ្លះខ្លែងកម្ទេចកម្លាំងខ្មាំង ថែរក្សានិងបំប៉នកម្លាំងយើង កាន់តែខាយកាន់ខ្លាំង កាន់តែខាយកាន់ឈ្នះ។**
- **ក្តាប់ឱ្យជាប់នូវសតិអារម្មណ៍ខាយសម្រុក ខ្លះខ្លែងសម្រុក ខាយសម្រុកជាប់ជានិច្ច។** *(សៀវភៅកំណត់ហេតុលេខ២០០)*

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិត និងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ស៊ិន សុធីតា**

# អ៊ុយ ស៊ិន : ដំណើរចាកចេញពីក្រុងបាត់ដំបង

អ៊ុយ ស៊ិន ជាសិស្សពូកែម្នាក់នៅខេត្តបាត់ដំបង ដែលបានរៀនរហូតដល់ថ្នាក់ទី១(ថ្នាក់បាក់ឌុបពីសង្គមចាស់) ។ នៅឆ្នាំ ១៩៦៤ ស៊ិន បានប្រលងចូលសាលាគរុកោសល្យកំពង់កន្ទួត ជាយរាជធានីភ្នំពេញ ។ ការប្រឡងនោះមានការតឹងតែងជាខ្លាំង ស៊ិន ជាបេក្ខជនម្នាក់ក្នុងចំណោមបេក្ខជនពីររយនាក់ដែលត្រូវបានជ្រើសចេញពីបេក្ខជនប្រឡងចំនួនបីពាន់នាក់ ហើយអ្នកដែលមានសិទ្ធិចុះឈ្មោះប្រឡងចូលរៀនសាលានេះគឺមានតែអ្នកនៅលីវប៉ុណ្ណោះ ប្រសិនបើដឹងថាបេក្ខជនមានប្រពន្ធត្រូវគេបញ្ឈប់ភ្លាម ។

បន្ទាប់ពីបញ្ចប់ការសិក្សាផ្នែកគរុកោសល្យបឋមសិក្សារយៈពេលពីរឆ្នាំ ស៊ិន បានទៅបង្រៀននៅសាលាបឋមសិក្សាទក្សិណ (សព្វថ្ងៃសាលាបឋមសិក្សាវត្តកំផែង) ។ ក្នុងចំណោមគរុសិស្សប្អូនរយនាក់ ស៊ិន ជាប់ចំណាត់ថ្នាក់លេខ៣៨ ដូច្នេះទើប ស៊ិន មានអាទិភាពជ្រើសរើសយកសាលាបង្រៀនដែលស្ថិតនៅស្រុកកំណើតរបស់ខ្លួន ។ បង្រៀនបានបួនឆ្នាំ ស៊ិន បានចាប់ចិត្តស្រឡាញ់អ្នកគ្រូម្នាក់ឈ្មោះ អែម គីមហាន ដែលបង្រៀននៅសាលាទក្សិណជាមួយគ្នា ។ ស៊ិន បានសុំឲ្យឪពុកម្តាយចូលស្តីដណ្តឹងដល់ចាស់ទុំ ហើយអ្នកទាំងពីរក៏បានរៀបការពីរខែមុនរដ្ឋប្រហារឆ្នាំ១៩៧០ ។

ក្រុងបាត់ដំបងជាទីក្រុងធំទីពីរបន្ទាប់ពីភ្នំពេញ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់របបសាធារណរដ្ឋខ្មែររហូតដល់ខែមេសា ឆ្នាំ១៩៧៥ ។ ទោះជាយ៉ាងនេះក្តី មកត្រឹមឆ្នាំ១៩៧៤ ស្រុកភាគច្រើននៃខេត្តបាត់ដំបងត្រូវកងទ័ពខ្មែរក្រហមឬ "កងទ័ពរំដោះ"កាន់កាប់រួចទៅហើយ ។ បន្ទាប់ពីកាន់កាប់បានទីក្រុងភ្នំពេញ ស៊ិន បានឮសេចក្តីប្រកាសរបស់ខ្មែរក្រហមតាមវិទ្យុថា *"យើងយកបានទីក្រុងភ្នំពេញហើយ ទាំងអស់គ្នាសូមទម្លាក់អាវុធចុះ"* ។ ស៊ិន បានរៀបរាប់ថា ប្រជាជននៅក្រុងបាត់ដំបងនឿយណាយនឹងសង្គ្រាមខ្លាំងណាស់ គ្រាន់តែក្រុមខ្មែរក្រហមចូលមកដល់ក្រុងបាត់ដំបងភ្លាម ប្រជាជនមួយចំនួនមានទឹកចិត្តរីករាយដោយសង្ឃឹមថាប្រទេសជាតិនឹងចាកផុតពីសង្គ្រាម និងបានរស់នៅដោយសុខដុមរមនាក្រោមការគ្រប់គ្រងរបស់អ្នកដឹកនាំថ្មី ដែលពេលនោះប្រជាជនខ្លះថែមទាំងយកកង់ម៉ូតូរបស់ខ្លួនទៅដឹកខ្មែរក្រហមចូលក្រុងបាត់ដំបងទៀតផង ។


អ៊ុយ ស៊ិន ឆ្នាំ២០០៦

ស៊ិន នៅចាំបានយ៉ាងច្បាស់ពីព្រឹត្តិការណ៍បន្ទាប់ពីការចូលមកដល់ក្រុងបាត់ដំបងរបស់ខ្មែរក្រហម ។ ប្រជាជននៅបាត់ដំបងត្រូវបានជម្លៀសចេញមួយសប្តាហ៍បន្ទាប់ពីខ្មែរក្រហមជម្លៀសចេញប្រជាជនពីទីក្រុងភ្នំពេញ ។ ពេលចូលមកដល់ភ្លាម កងទ័ពខ្មែរក្រហមបានដើរឆក់ប្លន់យករបស់របរក្នុងហាងនិងតាមផ្ទះប្រជាជន ។ បន្ទាប់មក ខ្មែរក្រហមបានប្រកាសតាមមីក្រូឲ្យអតីតពលទាហាន នាយទាហាន អ្នករដ្ឋការ និងអ្នកដែលមានបណ្តាស័ក្តិទាំងអស់ ទៅប្រជុំគ្នានៅសាកលវិទ្យាល័យបាត់ដំបង (បច្ចុប្បន្នសាកលវិទ្យាល័យជាតិគ្រប់គ្រង) ដើម្បីទៅទទួលសម្តេចឪ ។ ចំណែកមន្ត្រី និងនាយទាហានថ្នាក់ក្រោមទៅជួបប្រជុំគ្នានៅសាលា សោ ហ៊ី ។ ស៊ិន បន្តថា ដោយសារតែចង់ដឹងចង់ឮពីសភាពការណ៍ប្រទេសជាតិ សិស្ស និស្សិត សាស្ត្រាចារ្យ ពលទាហាន នាយទាហាន និងមន្ត្រីជាច្រើនបានទៅចូលរួមប្រជុំតាមសេចក្តីប្រកាសនេះ ដោយមិនដឹងថា ក្រុមគ្រួសារនៅឯផ្ទះត្រូវបានជម្លៀសចេញពីផ្ទះឡើយ ។ ស៊ិន និយាយថា ដោយសារហេតុផលនេះ ហើយ*"ដែលអ្នកខ្លះត្រូវបែកគ្នាជារៀងរហូត ដោយសារតែ ហេតុផលមិនសមហេតុផលហ្នឹង"* ។

ចប់ការប្រជុំ ស៊ិន ក៏ប្រញាប់ប្រញាល់វិលត្រឡប់មកផ្ទះវិញ ។ ក្រុមគ្រួសាររបស់ ស៊ិន បានរៀបចំអីវ៉ាន់និងរបស់របរចាំបាច់មួយចំនួនរួចជាស្រេច ។ ស៊ិន បាននាំក្រុមគ្រួសារធ្វើដំណើរឆ្ពោះទៅអូរដំបង ពីព្រោះមានបងប្អូនគាត់រស់នៅទីនោះ ។ ទៅ

ដល់អូរដំបង ខ្មែរក្រហមបានបញ្ជាឲ្យគាត់បន្តដំណើរទៅមុខទៀត ដោយសារកន្លែងនោះមានមនុស្សពេញហើយ ។ អ្នកទាំងអស់គ្នាក៏ធ្វើដំណើរកាត់វាលស្រែទៅភូមិអន្លង់វិលដែលនៅទីនោះក៏មានបងប្អូនរបស់គាត់មួយចំនួនដែរ ។ ប៉ុន្តែពេលទៅដល់ទីនោះអ្នកទៅជាមួយគ្នាបានខ្សឹបខ្សៀវគ្នាថា «គេមិនឲ្យនៅទេ» ស៊ិន ក៏បាននាំក្រុមគ្រួសារធ្វើដំណើរបន្តទៅនាភូមិកំណប់ ។ ស៊ិន និយាយថា ខ្មែរក្រហមមិនបានគិតដល់សុខទុក្ខរបស់ប្រជាជនទេ «វាដេញយ៉ាងម៉េចឲ្យតែចេញផុតពីមុខវា» ។

ទោះជាយ៉ាងនេះក្តី ក្នុងអំឡុងពេលដំបូងនៃការជម្លៀសទៅដល់ភូមិកំណប់ ស៊ិន និងក្រុមគ្រួសារអាចរស់នៅជួបជុំគ្នា ហើយអាចហូបចុករួមនិងមានកម្មសិទ្ធិលើរបស់របរផ្ទាល់ខ្លួន ។ ប៉ុន្តែការរស់នៅនិងធ្វើការងារត្រូវបានកំណត់យ៉ាងតឹងរ៉ឹងពីមួយថ្ងៃទៅមួយថ្ងៃ ។ ស៊ិន រស់នៅលាយឡំជាមួយប្រជាជនមូលដ្ឋាន និងមានភារកិច្ចភ្ជួររាស់ដីនិងធ្វើស្រែ ។ រស់នៅភូមិកំណប់បានមួយវស្សា ខ្មែរក្រហមបានធ្វើការផ្លាស់ប្តូរភូមិ ហើយបញ្ជូនអ្នកភូមិទៅរស់នៅទួលរវាង ដែលក្រោយមកត្រូវបានបញ្ជូនបន្តទៅរស់នៅសហករណ៍វត្តស្វាយ ។ សហករណ៍នេះនៅក្បែរមន្ទីរសន្តិសុខស្រុកសង្កែ ។ ប្រជាជននៅក្នុងភូមិបានស្គាល់មន្ទីរសន្តិសុខនេះថាជា «ផ្ទះតាវ៉ៃ» ដែលជាប្រធានសន្តិសុខស្រុក ។ ស៊ិន បានរៀបរាប់ថា នៅក្បែរផ្ទះមានធុំក្លិនស្អុយយ៉ាងខ្លាំង ដោយសារមនុស្សជាច្រើនត្រូវបានចាប់ខ្លួននិងសម្លាប់ចោលក្បែរៗនោះ ។ ទោះជាយ៉ាងណា ស៊ិន មិនដែលឃើញការសម្លាប់ផ្ទាល់ភ្នែកទេ «ព្រោះការដែលវាសម្លាប់ហ្នឹងគឺសម្លាប់តែពេលយប់» ។

ការហូបចុកនៅទីនោះមានការលំបាកខ្លាំង ។ ស៊ិន និយាយថា ក្នុងមួយឆ្នាំប្រជាជនអាចហូបសាច់ជ្រូកបានតែពីរដងប៉ុណ្ណោះ ហើយក្នុងម្នាក់ៗទទួលបានសាច់ជ្រូកប៉ុនមេដើង ។ ជនជាតិចាមដែលត្រូវបានជម្លៀសមករស់នៅលាយឡំគ្នាជាមួយប្រជាជនខ្មែរពីដំបូងឡើយមិនព្រមទទួលយកចំណែកសាច់ជ្រូកដែលខ្មែរក្រហមចែកឲ្យទេ ។ ប៉ុន្តែដោយសារភាពអត់ឃ្លានខ្លាំងពេក ជនជាតិចាមទាំងនោះបានបង្ខំចិត្តទទួលយកសាច់ជ្រូកមួយដុំតូចនេះ ដើម្បីទុកទៅប្តូរយករបស់របរឬម្ហូបអាហារផ្សេងៗទៀតពីប្រជាជនខ្មែរ ។ ជនជាតិចាមជាច្រើនបានស្លាប់ដោយសារអត់អាហារ ។ ស៊ិន រំឭកថា ខ្មែរក្រហមបានដឹកស្រូវចេញពីសហករណ៍ជាច្រើនឡាន ដោយទុកឲ្យប្រជាជននៅក្នុងភូមិទទួលរងភាពអត់ឃ្លាន «កាលណាផ្ទះបាយ(ចុងភៅ)តែថាអត់មានអង្ករ គឺអត់ហើយ ។ គេគ្មានទទួលខុសត្រូវ ឬខ្វាចអ្នកឯងខឹងទេ» ។

ស៊ិន រស់នៅសហករណ៍ស្វាយរហូតដល់ពេលវៀតណាមវាយចូលនៅដើមឆ្នាំ១៩៧៩ ។ សំណាងល្អ ស៊ិន និងក្រុមគ្រួសារមិនត្រូវបានជម្លៀសឡើងភ្នំដូចប្រជាជនផ្សេងៗទៀតឡើយ ។ ដោយសារពេលនោះជារដូវច្រូតកាត់ផង ស៊ិន និងអ្នកភូមិបាននាំគ្នាចុះទៅច្រូតស្រូវយកមកដាំបាយហូប ។ ស៊ិន បានរៀបរាប់ថា កងទ័ពវៀតណាមបានបាញ់វត្តសង្កែឆេះហុយទ្រលោម ដែលជាឃ្លាំងគ្រាប់របស់ខ្មែរក្រហម ។ ចំណែកកម្មាភិបាលខ្មែរក្រហមបានរត់គេចចេញពីទីនោះអស់ហើយ ។ ក្នុងពេលនោះ មានប្រជាជនស្លាប់ជាច្រើន ដោយសារតំបន់នោះជាតំបន់ប្រទាញប្រទង់គ្នារវាងកងទ័ពវៀតណាមនិងកងទ័ពខ្មែរក្រហម ។ ពីរ-បីថ្ងៃក្រោយការវាយចូលរបស់វៀតណាម អ្នកភូមិមួយចំនួនបានវិលត្រឡប់ចូលក្រុងបាត់ដំបងវិញ ហើយ ស៊ិន ក៏បាននាំក្រុមគ្រួសារវិលត្រឡប់មករស់នៅស្រុកកំណើតវិញ ។

**យិន ឆាយ**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខ: (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# យុវជនស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហម

នាព្រឹកថ្ងៃពុធ ទី៩ ខែឧសភា ឆ្នាំ២០០៧ យុវជនចំនួន៤០ នាក់បានមកធ្វើទស្សនកិច្ចជាលើកទីមួយ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ យុវជនខ្លះស្ពាយកាបូប និងមានពាក់ប័ណ្ណសម្គាល់ខ្លួនសិស្សនៅនឹងក ។ ទាំងអស់គ្នាដើរចូលបន្ទប់ព័ត៌មានសាធារណៈ ដែលស្ថិតនៅជាន់ក្រោមនៃអគារមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នេះជាដំណើរទស្សនកិច្ចជាលើកទីមួយក្នុងចំណោមដំណើរទស្សនកិច្ចកិច្ចដែលស្នើសុំដោយសមាគមយុវជនខ្មែរសម្រាប់កម្មវិធីប្រចាំខែឧសភា ឆ្នាំ២០០៧ មានឈ្មោះថា «ការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការកសាងអនាគតយុវជនឲ្យបានភ្លឺស្វាង» ។ សមាគមយុវជនខ្មែរបានស្នើសុំមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យចូលរួមកម្មវិធីនេះ ដោយជួយផ្តល់មេរៀនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមជ្ឈមណ្ឌលក៏បានទទួលយល់ព្រមសំណើនេះដោយរីករាយ ។ យោងតាមលិខិតស្នើសុំកាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ កម្មវិធីគ្រោងនឹងអញ្ជើញយុវជនមកពីតាមខេត្តក្រុងចំនួន៧គឺ ៖ ខេត្តកំពង់ចាម តាកែវ សៀមរាប ស្វាយរៀង ព្រៃវែង បាត់ដំបង និង បន្ទាយមានជ័យ ។ ក្រៅពីទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានសកម្មភាពជាច្រើនទៀត នៅក្នុងកម្មវិធីនេះរួមមានការទៅទស្សនាអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលអាចជំរុញឲ្យយុវជនមានការយល់ដឹងកាន់តែប្រសើរអំពីរបបខ្មែរក្រហម ។ យើងសង្ឃឹមថា នៅពេលដែលយុវជនត្រឡប់ទៅវិញ អ្នកទាំងអស់នេះនឹងចែករំលែកចំណេះដឹងទាំងឡាយដែលទទួលបានពីដំណើរទស្សនកិច្ចនេះទៅឲ្យយុវជនឯទៀត ក៏ដូចជាសហគមន៍របស់ខ្លួនទាំងមូល ។



និស្សិតស្តាប់នៅអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅបន្ទប់ព័ត៌មានសាធារណៈ យុវជនស្តាប់ការពន្យល់របស់ ឌី ខាំបូលី អ្នកនិពន្ធសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» និង លី សុខឃាង ប្រធានក្រុមគម្រោងឯកសាររស់ ។ យុវជនដែលបានចូលរួមដំណើរទស្សនកិច្ចលើកដំបូងមកពីខេត្តកំពង់ចាម និងព្រៃវែង ។ លី សុខឃាង បានចាប់ផ្តើមរៀបរាប់ជាសង្ខេបប្រាប់យុវជននូវប្រវត្តិនិងសកម្មភាពនានារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ទាប់មក ឌី ខាំបូលី ចាប់ផ្តើមពន្យល់បង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ខណៈពេលដែល ឌី ខាំបូលី និយាយរៀបរាប់អំពីព្រឹត្តិការណ៍ និងកត្តាដែលបង្កឲ្យមានរបបនោះ ដោយលើកបង្ហាញរូបថតក្នុងសៀវភៅប្រវត្តិសាស្ត្រយុវសិស្សជាច្រើនបានលើកដៃសួរសំណួរ ។

បន្ទាប់ពីអ្នកទាំងពីរបញ្ចប់ការបង្ហាញរបស់ខ្លួន យុវជនទស្សនាភាពយន្តឯកសារមានចំណងជើងថា «នៅកៀនជញ្ជាំងមន្ទីរ ស-២១ ៖ រឿងរ៉ាវពីគុកទួលស្លែង» ដែលផលិតដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្សែភាពយន្តឯកសារនេះ ចងក្រងប្រវត្តិអតីតអ្នកទោសពីររូបនិងអតីតកម្មាភិបាលថ្នាក់ខ្ពស់នៃមន្ទីរសន្តិសុខស-២១ ។ រឿងរ៉ាវរបស់អ្នកទាំងបីមានការពាក់ព័ន្ធគ្នាទៅវិញទៅមក ប៉ុន្តែសាច់រឿងផ្ទុយគ្នាស្រឡះ ។ តាមរយៈភាពយន្តឯកសារនេះ សិស្សានុសិស្សស្វែងយល់ពីការចាប់ខ្លួនអ្នកទោសពីររូបដែលបានឆ្លងកាត់ទារុណកម្ម និងបទពិសោធន៍ដ៏ជូរចត់ដែលអ្នកទាំងពីរអាចរស់រានមានជីវិតពីអំពើដ៏ព្រៃផ្សៃ និងការអត់ឃ្លាននៅក្នុងគុក ។ រឿងរ៉ាវរបស់អ្នកទាំងពីរប្រឈមនឹងការរៀបរាប់របស់កម្មាភិបាលអ្នកយាមគុកមជ្ឈិម ដែលអះអាងថា រាល់សកម្មភាពរបស់ខ្លួនមិនដែលហួសពីព្រំដែនតួនាទីអ្នក

យាមឡើយ ។ ពេលខ្សែភាពយន្តឯកសារកំពុងចាក់ផ្សាយ យុវជនខ្លះមិនត្រឹមតែផ្តោតអារម្មណ៍មើលខ្សែភាពយន្តប៉ុណ្ណោះទេ ថែមទាំងឆ្លៀតបើកសៀវភៅកត់ត្រារឿងរ៉ាវជីវិតរបស់តួអង្គទាំងនោះផងដែរ ។

ពេលខ្សែភាពយន្តឯកសារកំពុងបញ្ចាំង យុវជនគ្រប់គ្នាទស្សនាយ៉ាងយកចិត្តទុកដាក់ ជាពិសេសត្រង់វគ្គមានរូបភាពសង្គ្រាមច្បាំងគ្នា រូបគំនូរអ្នកទោសជាប់ខ្នោះជើងតៗគ្នា ការធ្វើទារុណកម្មនិងការសម្លាប់មនុស្ស ។

ការចូលរួមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងកម្មវិធីនេះ រៀបចំឡើងដើម្បីអប់រំសិស្សានុសិស្សកម្ពុជាអំពីរបបខ្មែរក្រហម ។ កញ្ញា ហុង អៀង ជំនួយការក្រុមស្ថាបនាសន្តិភាពនៃសមាគមយុវជនខ្មែរសង្កត់ធ្ងន់ថា មានយុវជនមួយចំនួនធំមិនបានយល់ដឹងច្រើនពីព្រឹត្តិការណ៍ឆ្នាំ១៩៧៥-១៩៧៩ ពេលដែលខ្មែរក្រហមឡើងកាន់អំណាចទេ ។ នេះជាទំព័រប្រវត្តិសាស្ត្រកម្ពុជាដែលស្ថិតនៅក្នុងភាពស្រពេចស្រពិល និងចម្ងល់មិនទាន់មានចម្លើយពិតប្រាកដនៅឡើយ ។ ទោះបីជាឪពុកម្តាយយុវជនជំនាន់ក្រោយធ្លាប់បានរៀបរាប់បទពិសោធន៍ជីវិតដ៏ជូរចត់ដូចជា ការធ្វើការឥតស្រាកស្រាន្ត មានពេលសម្រាកតិចតួច កង្វះអាហារ និងការសម្លាប់មនុស្សក្នុងរបបនោះក៏ដោយ ក៏យុវជនទាំងនោះហាក់បីដូចជាមិនជឿរឿងរ៉ាវទាំងនោះ ឬជឿដោយផ្នែកខ្លះប៉ុណ្ណោះ ។ ហុង អៀង ប៉ាន់ស្មានថា ៨០ភាគរយនៃយុវជនដែលមកចូលរួមទស្សនកិច្ចទើបតែចាប់ផ្តើមយល់រឿងរ៉ាវនេះ ។ យុវជនទាំងនោះមានអារម្មណ៍រន្ធត់តក់ស្លុតចំពោះអ្វីដែលកើតឡើងនៅក្នុងបរិវេណមន្ទីរឃុំឃាំង ដូចជារូបថតអ្នកទោសក្នុងសភាពដ៏សែនលំបាកវេទនា រណ្តៅសាកសពរួម និងឧបករណ៍ធ្វើទារុណកម្ម ។ នៅក្នុងរបបខ្មែរក្រហមសារមន្ទីរនេះជាមូលដ្ឋានគុកនយោបាយកម្រិតខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមការប៉ាន់ស្មាន អ្នកទោសប្រមាណ១ម៉ឺន៧ពាន់នាក់ ត្រូវបញ្ជូនចូលគុកនេះ និងបាត់បង់ជីវិតបន្ទាប់ពីឆ្លងកាត់ទារុណកម្ម និងការសម្លាប់ជាក្រុមនៅវាលពិឃាតក្បែរនោះ ។ ទាក់ទិននៅនឹងអតីតមន្ទីរសន្តិសុខនេះ យុវជនម្នាក់និយាយថា «នេះជាការពិតណាស់ ។ ពីមុនមកខ្ញុំធ្លាប់តែឮរឿងនេះតៗគ្នា តែមិនដែលបានមកឃើញផ្ទាល់ភ្នែកទេ ព្រោះជាក្មេងជនបទកើតក្រោយរបប ប៉ុល ពត» ។ ហុង អៀង បន្តទៀតថា យុវជនរូបនោះមានកែវភ្នែករលីងរលោង ហើយបានត្រឹមតែបន្តសង្ស័យថាតើហេតុអ្វីបានជាខ្មែរសម្លាប់ខ្មែរគ្នាឯង ។

បន្ទាប់ពីខ្សែភាពយន្តឯកសារត្រូវបានបញ្ចប់ លី សុខឃាង និង ឌី ខាំបូលី ផ្តល់យោបល់ផ្ទាល់ខ្លួនជាច្រើនចំណុចចំពោះខ្សែភាពយន្ត ។ បន្ទាប់ពីអ្នកទាំងពីរធ្វើការកត់សម្គាល់ចុងក្រោយ កញ្ញា ហុង អៀង ជំរុញឲ្យយុវជនមកពីខេត្តកំពង់ចាម និងព្រៃវែងបញ្ចេញគំនិតផ្ទាល់ខ្លួនស្តីពីខ្សែភាពយន្ត និងផ្តល់ជាយោបល់ផ្សេងៗចំពោះអ្វីដែលខ្លួនបានរៀនសូត្រក្នុងដំណើរទស្សនកិច្ចថ្ងៃនេះ ។ យុវជនពីររូបក្រោកឈរនិយាយ ។ វាសនាមកពីខេត្តកំពង់ចាមបង្ហាញយោបល់ផ្ទាល់ខ្លួនថា ÷ «ខ្ញុំសប្បាយរីករាយណាស់ ដែលមានឱកាសចូលរួមដំណើរទស្សនកិច្ច មជ្ឈមណ្ឌលឯកសារកម្ពុជាជាលើកទី១» ។ សុភារក្ស មកពីខេត្តព្រៃវែងសម្តែងពីការអាណិតអាសូររបស់ខ្លួនចំពោះអ្នកទោសនៅក្នុងខ្សែភាពយន្តឯកសារ និងការរួមចំណែកសោកស្តាយចំពោះជនរងគ្រោះបាត់បង់ជីវិត ។ សុភារក្ស និយាយថា «នេះជាលើកទីមួយដែលខ្ញុំមើលខ្សែភាពយន្តឯកសារបែបនេះ ។ ខ្ញុំយល់ថានេះមិនមែនជារឿងធម្មតាទេ ដែលតួអង្គទាំងបីអាចមានជីវិតឆ្លងកាត់ពីរបបនេះ» ។ បន្ទាប់មក អ្នកទាំងពីរមានពាក្យពេចន៍ចុងក្រោយចង់ថ្លែងអំណរគុណដល់គ្រូបង្វឹករបស់ខ្លួននៅខេត្ត និងសុំជូនពរដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

នៅចុងបញ្ចប់នៃការជួបជុំគ្នា មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំទស្សនាវដ្តីស្វែងរកការពិតចែកជូនយុវជនម្នាក់មួយច្បាប់ ។ ក្នុងនោះមានយុវជន៧នាក់សុំសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលទើបនឹងចេញផ្សាយជាភាសាអង់គ្លេស ដោយសារអ្នកឯទៀតពុំទាន់មានលទ្ធភាពអានសៀវភៅជាភាសាអង់គ្លេសនៅឡើយ ។ ថ្មីៗនេះសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលបោះពុម្ពជាភាសាខ្មែរបាន និងកំពុងចែកចាយតាមសាលាគ្រប់បណ្តាខេត្តក្រុងទូទាំងប្រទេស ។ បន្ទាប់ពីជួបជុំនៅមជ្ឈមណ្ឌលឯកសារកម្ពុជា យុវជនទាំងអស់បានធ្វើដំណើរឆ្ពោះទៅអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៀត ។

**លី សុខឃាង**

# ធ្វើបដិវត្តន៍ទទួលបានត្រឹមតែការព្រាត់ប្រាស

សុង ស៊ុំ មានឈ្មោះបដិវត្តន៍ សែម ។ ស៊ុំ កើតនៅភូមិត្រពាំងស្វាយ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប ។ កាលពីក្មេង ស៊ុំ រៀនបានតែបន្តិចបន្តួចប៉ុណ្ណោះ ព្រោះត្រូវជួយធ្វើការងារឪពុកម្តាយដូចជា គើបអាចម៍គោធ្វើជី និងធ្វើស្រែចម្ការ ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ដោយសារប្រទេសជាតិស្ថិតក្នុងភាពច្របូកច្របល់មិនសូវមានគ្រូបង្រៀននិងមានការចាប់ទាហានផង ស៊ុំ បានសម្រេចចិត្តឈប់រៀន ហើយស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ខ្មែរក្រហម ដែលមាន សឿន គណៈស្រុកបន្ទាយស្រី ជាអ្នកខ្ទេសនាម ។ ខាងក្រោមនេះជាការរៀបរាប់របស់ សុង ស៊ុំ ៖

នៅពេលនោះ មានគេមកឃោសនាថា ចូលបម្រើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិពីរបបចក្រពត្តិ រួចយាងសម្តេច សីហនុមកកាន់អំណាចវិញ ។ ដូច្នេះយើងត្រូវរស់នៅរួបរួមគ្នាប្រមូលអីវ៉ាន់ដាក់រួម ហូបបាយរួម និងធ្វើការរួម ។ ពេលចូលបដិវត្តន៍ដំបូង ខ្ញុំត្រូវបញ្ជូនឲ្យទៅហាត់ក្បួនយុទ្ធសាស្ត្រនៅសាលាស្រុកបន្ទាយស្រី ហាត់ពីរបៀបគប់គ្រាប់បែក របៀបវាយសម្រុកទៅលើខ្មាំងដោយបែងចែកជាកងដែលក្នុងមួយកងមានមនុស្សពី៣០ទៅ៤០នាក់ ។ ហាត់បានកន្លះខែ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅស្រុកស្វាយលើចំនួនបួនថ្ងៃទៀតដើម្បីហាត់រៀនពីរបៀបយាមបន្ទាយនិងពេលមានខ្មាំងវាយប្រហារ ។ ខ្ញុំធ្វើជាអ្នកយាម ហើយកូនទាហានផ្សេងទៀតធ្វើជាខ្មាំងបង្កប់នៅក្នុងព្រៃ ។ យើងមិនបានរៀនអ្វីច្រើនទេ គឺនាំគ្នាបាញ់សត្វយកមកហូបតែប៉ុណ្ណោះ ។

នៅខែមេសាឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រាប់ឲ្យពួកយើងត្រឡប់មកស្រុកបន្ទាយស្រីវិញ ។ យើងទាំងអស់គ្នាត្រូវមកឈប់សម្រាកនៅឃុំស្វាយធំចំនួន៤ថ្ងៃសិន ទើបមានឡានមកដឹកបន្តទៅទៀត ។ ប៉ុន្តែតាមការពិត រថយន្តមកដឹកមនុស្សយកទៅភ្នំពេញទៅវ៉ៃជាមួយទាហានលន់នល់សោះ ។ ដោយឮថាត្រូវបញ្ជូនទៅភ្នំពេញដូច្នេះ មនុស្សមួយចំនួនបានលួចរត់មកផ្ទះវិញព្រោះឮថាមានការប្រយុទ្ធគ្នាយ៉ាងខ្លាំង ទាំងយប់ទាំងថ្ងៃរវាងកងទ័ពខ្មែរក្រហមនិងកងទ័ពលន់នល់ ។ នៅពេលនោះ ដោយសារខ្ញុំនៅក្មេងមិនទាន់ចេះគិតវែងឆ្ងាយ ហើយម្យ៉ាងទៀតចង់ជិះឡានផង ព្រោះមិនដែលបានជិះឡានដល់គេហៅឡើងឡានខ្ញុំក៏ឡើងជិះភ្លាម ។ ខ្ញុំមិនដឹងថាគេដឹកទៅណាទេ លុះត្រាតែរថយន្តឈប់ទើបខ្ញុំបានមកដល់ភ្នំពេញតែម្តង ។

ទោះជាយ៉ាងនេះក្តី ខ្ញុំមិនបានប្រយុទ្ធជាមួយទាហានលន់នល់ទេ ព្រោះពេលចូលដល់ភ្លាម ទីក្រុងភ្នំពេញត្រូវបានរំដោះរួចទៅហើយ ។ នៅពេលនោះ ខ្ញុំបានឃើញហេតុការណ៍ដ៏អស្ចារ្យមួយគឺកងទ័ពខ្មែរក្រហមកំពុងតែជម្លៀសប្រជាជនចេញពីទីក្រុង ។ ក្រុមរបស់ខ្ញុំត្រូវបានដាក់ឲ្យនៅម្តុំឆ្ងាយពីផ្លូវថ្នល់ ។ ក្រោយមកខ្មែរក្រហមបានបញ្ចូលពួកយើងទៅក្នុងក្រុមផ្សេងៗ រួមមានក្រុមយោធា សេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម និងដឹកជញ្ជូន ។ ខ្ញុំត្រូវបានបញ្ចូលទៅក្នុងក្រុមខាងកសិកម្ម ។

មួយរយៈក្រោយមក ខ្ញុំត្រូវបានផ្លាស់ឲ្យមកនៅខាងពាណិជ្ជកម្មនៅគីឡូម៉ែត្រលេខ៦ ប៉ែកខាងជួរប្រាំងចំរេះ ។ ខ្ញុំមានភារកិច្ចឃ្វាលគោ ។ អ្នកគ្រប់គ្រងកន្លែងធ្វើការរបស់ខ្ញុំឈ្មោះ តានុស ដែលជាអ្នកស្រុកកំពង់ចាម ។ នៅទីនោះ សម្បូរត្រីណាស់ នៅក្នុងស្រះនីមួយៗមានសុទ្ធតែត្រីប្រានិងត្រីព្រួល ប៉ុន្តែយើងមិនអាចយកហូបតាមចិត្តបានទេ ហើយក៏មិនដឹងថាត្រីទាំងអស់ត្រូវដឹកយកទៅកន្លែងណាដែរ ។

ចេញពីប្រាំងចំរេះ ខ្ញុំផ្លាស់ទៅនៅខាងកើតវត្តទួលទំពូងដែលជាកន្លែងបកផ្លែគ ។ វត្តទួលទំពូងគឺជាឃ្លាំងគ អំបិល អង្ករនិងសម្ភារផ្សេងៗទៀត ។ អ្នកគ្រប់គ្រងនៅទីនោះឈ្មោះ តារិទ្ធដែលជាអ្នកស្រុកកោះធំ ។ ខ្ញុំត្រូវបកគឲ្យបានមួយបាវក្នុងមួយថ្ងៃ ។ ក្រៅពីការងារបកគ ខ្ញុំត្រូវទៅលីអង្ករ សណ្តែក និងល្ង ពីកប៉ាល់យកទៅដាក់លើរថយន្តនៅកំពង់ផែភ្នំពេញ ។ ការរស់នៅរបស់ខ្ញុំនៅទីនោះមានលក្ខណៈប្រសើរច្រើន ដោយមានរបបអាហារប្រចាំថ្ងៃគ្រប់គ្រាន់ ។ ពេលថ្ងៃមានបាយ ហើយពេលយប់មានបបរជាមួយត្រីងៀត ។ ប៉ុន្តែ មានការប្រជុំទិទៀនច្រើន ហើយមនុស្សមួយចំនួនបានបាត់ខ្លួនដោយគ្មានមូលហេតុច្បាស់

លាស់ ។ នៅពេលដែលយើងសួរថាយកទៅណា? អង្គការប្រាប់ថាឲ្យទៅធ្វើការនៅកន្លែងថ្មី ។ តែតាមការពិត គឺយកទៅសម្លាប់ចោល ព្រោះអ្នកដែលត្រូវសម្គាល់ គឺយកទៅមិនដែលឃើញត្រឡប់មកវិញទេ ។ ធ្វើការនៅទីនោះ ខ្ញុំធ្លាប់ឮថាមានគុកទួលស្លែងនៅខាងជើងវត្តទួលទំពូងដែរ តែមិនដែលហ៊ានទៅក្បែរកន្លែងនោះទេ ព្រោះខ្លាចគេយកទៅសម្លាប់ចោល ម្យ៉ាងទៀត គ្រាន់តែឮសំឡេងស្រែកថ្ងូរខ្ញុំខ្លាចណាស់ទៅហើយ ។ ខ្ញុំធ្វើការនៅមន្ទីរក្បែរវត្តទួលទំពូងបានមួយឆ្នាំ ។ នៅដើមឆ្នាំ១៩៧៧ ខ្ញុំត្រូវផ្លាស់មកធ្វើការនៅតាខ្មៅក្នុងខេត្តកណ្តាល ។ នៅទីនោះ ខ្ញុំធ្វើការនៅរោងចក្រគ្រីបគ ។ គគ្រូវបានប្រមូលពីគ្រប់ទីកន្លែងទាំងអស់មកទុកនៅក្នុងរោងចក្រនេះដើម្បីគ្រីបជាដុំធំៗ ។ បន្ទាប់មក មានរថយន្តមកដឹកយកទៅអស់ ។ ជួនកាល មានថ្នាក់ដឹកនាំមកធ្វើទស្សនកិច្ចនៅកន្លែងខ្ញុំធ្វើការដែរ ដែលរួមមាន ប៉ុល ពត, ខៀវ សំផន និងភ្ញៀវចិន ។

នៅចុងឆ្នាំ១៩៧៨ មានការវាយលុកយ៉ាងខ្លាំងក្លារបស់កងទ័ពវៀតណាមនៅភាគខាងកើតក្រុងភ្នំពេញ ។ ពេលនោះ សភាពការណ៍នៅភ្នំពេញនិងកន្លែងធ្វើការរបស់ខ្ញុំនៅតាខ្មៅមានសភាពច្របូកច្របល់ ដោយមានឮសំឡេងគ្រាប់ផ្លោងយ៉ាងសន្ធឹកសន្ធាប់ ។ ប្រធានរោងចក្របានកោះប្រជុំអ្នកធ្វើការទាំងអស់ ហើយបានលើកឡើងថា «យើងទាំងអស់គ្នាជាប្រុសត្រូវ ចងក្រងជាក្រុម ដើម្បីត្រៀមប្រយុទ្ធជាមួយពួកខ្មាំងយួនឈ្លានពាន» ។ គណៈដឹកនាំមានគម្រោងចែកកាំភ្លើងឲ្យម្នាក់មួយដើមដែរ ក៏ប៉ុន្តែលុះព្រឹកឡើង ខ្ញុំដើរទៅរោងបាយស្រាប់តែបាត់ចុងភៅស្រីៗអស់ ។ ខ្ញុំចាប់ផ្តើមភ័យ ខ្ញុំរត់មកផ្ទល់ស្រាប់តែបាត់មេធំៗអស់ទៀត គឺនៅតែអ្នកធ្វើការតូចតាច ដូចជាប្រធានកងនិងប្រធានក្រុមប៉ុណ្ណោះ ។ ពួកយើងបានប្រមូលផ្តុំគ្នាជាក្រុមដើម្បីរៀបចំរត់ព្រោះគិតថាយើងមិនអាចទប់ទល់ជាមួយកងទ័ពវៀតណាមបានទេ ។

នៅខែមករាឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលកាន់តែកៀកក្រុងភ្នំពេញ គឺមកដល់ម្តុំច្បារអំពៅ ។ ខ្ញុំបានប្រាប់កងខ្ញុំថា បើនរណានៅវាយទប់ទល់និងយួនក៏នៅចុះ តែខ្ញុំមិននៅទេ ខ្ញុំទៅស្រុកវិញហើយ ។ មានមនុស្ស១០នាក់បានយល់ព្រមត្រឡប់ទៅស្រុកកំណើតជាមួយខ្ញុំ ។ ពេលកងទ័ពវៀតណាមវ៉ៃចូលដល់ទីក្រុងភ្នំពេញ ខ្ញុំបានរត់ចេញទៅទិសខាងលិចឆ្ពោះទៅវាលយន្តហោះពោធិចិនតុង ។ ខ្ញុំចេះតែរត់បន្តទៅទិសខាងលិចរហូតហើយបានមកជួបប្រជាជនដែលខ្មែរក្រហមកៀរទៅជាមួយ ។ ខ្ញុំមិនបានទៅជាមួយអ្នកទាំងនោះទេ ពីព្រោះខ្ញុំពុំមានស្បៀងអាហារគ្រប់គ្រាន់សម្រាប់បរិភោគតាមផ្លូវ ។ ពេលមកដល់ភូមិអមលាំង ខ្ញុំបានគេចចូលក្នុងសហករណ៍ ហើយសុំប្រជាជនសម្រាកនៅទីនោះ ។ ខ្ញុំចំណាយអស់រយៈពេលមួយខែទើបមកដល់ភូមិកំណើតវិញ ។

ពេលមកដល់ភូមិ ខ្ញុំដឹងថាប្រជាជននៅក្នុងភូមិរងទុក្ខវេទនាគ្មានម្ហូបអាហារបរិភោគគ្រប់គ្រាន់ ធ្វើការបាក់កម្លាំង គ្មានថ្នាំសង្កូវសម្រាប់ព្យាបាល និងជាពិសេសត្រូវបានបំបែកចេញពីក្រុមគ្រួសារ ។ ជាងនេះទៅទៀត គ្រួសារមួយចំនួនត្រូវបានចោទ ថាជាខ្មាំង ហើយត្រូវចាប់យកទៅសម្លាប់ចោលយ៉ាងអាណោចអាធ័មដោយគ្មានការជំនុំជម្រះ ឬសាកសួររកមូលហេតុអ្វីឡើយ ។


កងទ័ពខ្មែរក្រហម

អ្វីដែលខ្ញុំសោកស្តាយនិងបំភ្លេចមិនបាននៅក្នុងជីវិតរបស់ខ្ញុំ គឺខ្ញុំបានស្ម័គ្រចិត្តលះបង់អស់ពីកម្លាំងកាយចិត្ត បែកបាក់បងប្អូន ឪពុកម្តាយ និងភូមិកំណើតដើម្បីចូលបម្រើបដិវត្តន៍ ។ ទីបំផុតអ្វីដែលខ្ញុំទទួលបានគឺត្រឹមតែការនិរាសព្រាត់ប្រាសគ្រួសារប៉ុណ្ណោះ ។

**សោម ប៊ុនថន**

# ការផ្តល់យុត្តិធម៌ចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ជំពូកនេះផ្តោតជាសំខាន់ទៅលើរបៀបដែលតុលាការខ្មែរក្រហមអាចសម្រេចនូវគោលដៅសំខាន់របស់ខ្លួន ដើម្បីធានាឲ្យបាននូវយុត្តិធម៌សម្រាប់ជនរងគ្រោះដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ច្បាប់សំខាន់ៗ វិធានច្បាប់ និងការអនុវត្តន៍ដែលផ្អែកលើភ័ស្តុតាងដែលបានរៀបរាប់នៅជំពូកមុនៗ គឺជាផ្នែកទាំងឡាយនៃបទដ្ឋានទូទៅមួយដែលអាចជួយឲ្យតុលាការនេះសម្រេចបាននូវគោលដៅសំខាន់របស់ខ្លួន ។ គុណភាពនៃច្បាប់និងនីតិវិធីទាំងឡាយមានសារសំខាន់ខ្លាំងណាស់ ដោយហេតុថាការផ្តល់យុត្តិធម៌ជូនប្រជាជនកម្ពុជាតម្រូវឲ្យមានអ្វីមួយ ដែលលើសពីការកាត់ទោសនិងការដាក់ទោសទៅលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាងនេះទៅទៀត យុត្តិធម៌តម្រូវឲ្យការកាត់ក្តីនេះប្រព្រឹត្តទៅដោយមិនលម្អៀង ហើយត្រូវមានការគោរពនូវសិទ្ធិរបស់គូភាគីទាំងអស់ ទោះបីជាជននោះត្រូវបានចោទប្រកាន់ពីបទល្មើសធ្ងន់ធ្ងរក៏ដោយ ។ លុះត្រាតែមានឧទាហរណ៍អំពីបទដ្ឋានច្បាប់កម្រិតខ្ពស់មួយ ទើបតុលាការនេះអាចត្រួសត្រាយផ្លូវឆ្ពោះទៅកាន់ការគោរពច្បាប់ឲ្យបានខ្ជាប់ខ្ជួននៅកម្ពុជា ។

ផ្នែកដំបូងនៃជំពូកនេះនឹងពិភាក្សាពីគោលគំនិតនៃយុត្តិធម៌ ដោយធ្វើការបែងចែកទៅជា “យុត្តិធម៌តាមផ្លូវតុលាការ” និង “យុត្តិធម៌តាមការសុំខមាទោស” និងពិភាក្សាថាតើផ្នែកនីមួយៗទាក់ទងនឹងសាលាក្តីដែលនឹងមកដល់ខាងមុខនេះដោយរបៀបណា ។ ផ្នែកទីពីរនឹងពិភាក្សាអំពីរបៀបដែលដំណើរការរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀតបានប្រឹងប្រែងពុះពារ ដើម្បីស្វែងរកយុត្តិធម៌អំពីការរំលោភបំពានធ្ងន់ធ្ងរទៅលើសិទ្ធមនុស្ស ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាផ្នែកមួយនៃចលនាអន្តរជាតិក្នុងការធានានូវយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មរបៀបនេះ ហើយតុលាការនេះនឹងប្រឈមមុខនឹងរឿងរ៉ាវប្រហាក់ប្រហែលគ្នានេះដែរ ។ ផ្នែកទីបីផ្តោតទៅលើសារសំខាន់នៃដំណើរការប្រកបដោយយុត្តិធម៌របស់អង្គសវនាការដើម្បីផ្តល់នូវលទ្ធផលយុត្តិធម៌ និងជាឧទាហរណ៍ដ៏ល្អមួយសម្រាប់តុលាការនាពេលអនាគត ។ ផ្នែកបន្ទាប់បង្ហាញពីវិធីដែលដំណើរការរបស់តុលាការមួយដែលប្រព្រឹត្តទៅដោយត្រឹមត្រូវនិងយុត្តិធម៌ អាចជួយសម្រេចឲ្យបាននូវគោលបំណងសំខាន់លើផ្នែកសីលធម៌សង្គមនិងនយោបាយនៅក្នុងប្រទេសកម្ពុជា ។ គោលបំណងទាំងនេះរាប់បញ្ចូលនូវការលាតត្រដាងការពិត លុបបំបាត់ចោលនូវវប្បធម៌និទ្ទណ្ឌភាព ការពារមិនឲ្យមានឧក្រិដ្ឋកម្មរបៀបនេះនាពេលអនាគត និងការកសាងនីតិរដ្ឋ ។ តុលាការនេះគឺជាផ្នែកសំខាន់នៃដំណើរការតុលាការក្នុងស្រុកនៅកម្ពុជាដើម្បីកសាងអនាគតល្អប្រសើរ និងចៀសឲ្យផុតពីស្រមោលអតីតកាល ។ ហេតុដូច្នេះ ជំពូកនេះនឹងធ្វើការសន្និដ្ឋាន ដោយធ្វើការពិនិត្យមើលទៅលើធាតុផ្សំទាំងឡាយដែលចាំបាច់ត្រូវតែបង្ហាញដើម្បីទទួលបាននូវការកាត់ក្តីប្រកបដោយយុត្តិធម៌ ។

## អត្ថន័យនៃពាក្យ “យុត្តិធម៌”

ពាក្យ“យុត្តិធម៌”គឺជាគោលគំនិតអរូបីមួយដែលជាទូទៅសំដៅលើការប្រព្រឹត្តដោយត្រឹមត្រូវនិងយុត្តិធម៌របស់បុគ្គលនិងសហគមន៍ ។ វាជាគោលគំនិតមួយដែលលំបាកក្នុងការកំណត់និយមន័យ ហើយវាមានន័យខុសៗគ្នាចំពោះជនរងគ្រោះដោយរបបខ្មែរក្រហម ។ អត្ថន័យដែលប្រជាជនកម្ពុជានិងអ្នកអង្កេតការណ៍ពាក់ព័ន្ធដទៃទៀតបានកំណត់ចំពោះពាក្យយុត្តិធម៌ គឺមានសារសំខាន់ខ្លាំងណាស់ ព្រោះការកំណត់នេះគឺបង្ហាញអំពីការរំពឹងទុករបស់សាធារណជនទៅលើដំណើរការតុលាការ ។ ប្រជាជនដែលចាត់ទុកយុត្តិធម៌គឺជា“ការសងសឹក” រំពឹងថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះនឹងផ្តល់នូវលទ្ធផលម្យ៉ាង ។ បុគ្គលដែលគិតថាយុត្តិធម៌សំដៅទៅលើភាពស្មើគ្នាផ្នែកសេដ្ឋកិច្ច រំពឹងចង់បានលទ្ធផលមួយផ្សេងទៀត ។

## “យុត្តិធម៌តាមផ្លូវតុលាការ” និង “យុត្តិធម៌ផ្សះផ្សា”

គោលគំនិតសំខាន់ពីរនៃយុត្តិធម៌ចំពោះដំណើរការទទួល

ខុសត្រូវនៅកម្ពុជាគឺ "យុត្តិធម៌តាមផ្លូវតុលាការ" និង "យុត្តិធម៌ផ្សះផ្សា" ។ យុត្តិធម៌តាមផ្លូវតុលាការផ្តោតលើអំពើឧក្រិដ្ឋរបស់បុគ្គលនិងការដាក់ទោសឧក្រិដ្ឋជន ។ ភាពសមហេតុផលខាងសីលធម៌នៅពីក្រោយយុត្តិធម៌តាមផ្លូវតុលាការគឺសាមញ្ញ ៖ ជនល្មើសបានបង្កគ្រោះថ្នាក់នៅក្នុងសង្គម ដូច្នេះជននេះត្រូវតែទទួលទោសទៅតាមកម្រិតនៃបទល្មើស ។ យុត្តិធម៌តាមផ្លូវតុលាការ គឺជាកម្លាំងសីលធម៌ពិតប្រាកដមួយរបស់ក្រមព្រហ្មទណ្ឌ ។ តាមគោលការណ៍ច្បាប់បទឧក្រិដ្ឋត្រូវបានចាត់ទុកជាការរំលោភបំពានប្រឆាំងនឹងរដ្ឋមិនមែនប្រឆាំងនឹងបុគ្គលម្នាក់ឬក្រុមមួយនោះទេ ។ បទល្មើសជាទូទៅត្រូវបានកាត់ទោសតាមរយៈប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញាជាតំណាងឲ្យរដ្ឋក្នុងការចោទប្រកាន់លើជនជាប់ចោទនិងបង្ហាញពីទោសកំហុសរបស់ជននោះ ។ ជាទូទៅ ការដាក់ទោសទណ្ឌចំពោះបទឧក្រិដ្ឋទាំងនេះ ធ្វើឡើងតាមរយៈការដាក់ពិន័យជាប្រាក់ការដកហូតសិទ្ធិសេរីភាព និងក្នុងប្រព័ន្ធច្បាប់ខ្លះ តាមរយៈការប្រហារជីវិត ។ ទោះបីជាជនរងគ្រោះអាចមានការពេញចិត្តចំពោះព័ត៌មានដែលថាឧក្រិដ្ឋជនត្រូវបានដាក់ទោសក្តី ការដាក់ទោសផ្នែកព្រហ្មទណ្ឌជាទូទៅពុំមានទាក់ទងនឹងការបង់ប្រាក់ ឬផ្តល់ផលប្រយោជន៍ដោយផ្ទាល់ទៅដល់ជនរងគ្រោះឡើយ ។

ការរិះគន់ចម្បងមួយចំពោះការកាត់ទោស លើបទរំលោភសិទ្ធិមនុស្សតាមរយៈប្រព័ន្ធយុត្តិធម៌ ព្រហ្មទណ្ឌ គឺថាការដាក់ទោសមានសារជាតិជាការដាក់ទោសតាមផ្លូវតុលាការ ។ ដោយហេតុថា ការដាក់ទោសជាទូទៅពុំមានពាក់ព័ន្ធទៅនឹងការសងជំងឺចិត្តដល់ជនរងគ្រោះ ការសុំទោស ឬក៏វិធីដោយផ្ទាល់ផ្សេងទៀតដើម្បីជួសជុលការខូចខាតដល់ជនរងគ្រោះ ការដាក់ទោសផ្នែកព្រហ្មទណ្ឌពុំបានគិតគូរដល់តម្រូវការផ្នែកសង្គម សីលធម៌និងសេដ្ឋកិច្ចរបស់ជនរងគ្រោះ ឬសហគមន៍នៅជុំវិញនោះឡើយ ។ ការរិះគន់ផ្សេងទៀតគឺថា ដោយផ្តោតការយកចិត្តទុកដាក់តែទៅលើការដាក់ទោសឧក្រិដ្ឋជន ការកាត់ទោសបទឧក្រិដ្ឋកម្មបានចាត់ទុកជនរងគ្រោះគ្រាន់តែជាឧបករណ៍មួយនៅក្នុងដំណើរការកាត់ទោសឧក្រិដ្ឋជនប៉ុណ្ណោះ ។ តុលាការឧក្រិដ្ឋកម្មកម្រព្យាយាមប្រឹងប្រែងដើម្បីសងការខាតបង់ផ្នែកសង្គមនិងសេដ្ឋកិច្ចរបស់ជនរងគ្រោះណាស់ ។

យុត្តិធម៌ផ្សះផ្សា ជាជម្រើសមួយផ្សេងទៀត ឬក៏ជាការបំពេញបន្ថែមទៅលើយុត្តិធម៌តាមផ្លូវតុលាការ ។ វាជាគោលគំនិតមួយដែលយកចិត្តទុកដាក់តិចតួចចំពោះការដាក់ទោសជនល្មើស ប៉ុន្តែផ្តោតសំខាន់លើទំនាក់ទំនងរវាងជនល្មើសនិងជនរងគ្រោះ និងសហគមន៍ទាំងមូល ។ វិធីក្នុងការសុំខមាទោសបន្ទាប់ពីបទល្មើសបានកើតឡើងរួចហើយ ហាក់ដូចជាផ្តោតលើការសន្ទនានិងការចរចាគ្នារវាងជនរងគ្រោះនិងជនល្មើស ។ គោលបំណងរបស់យុត្តិធម៌ផ្សះផ្សា គឺដើម្បីប៉ះប៉ូវ ឬស្តារឡើងវិញនូវសុខុមាលភាពដែលជនរងគ្រោះមានមុនពេលបទឧក្រិដ្ឋបានកើតឡើង ។ នៅក្នុងប្រព័ន្ធច្បាប់ខមមិនឡភាគច្រើន ជនរងគ្រោះមិនអាចប្តឹងទាមទារសំណងចំពោះការខូចខាតនៅក្នុងតុលាការព្រហ្មទណ្ឌបានឡើយ ។ ផ្ទុយទៅវិញ ប្រព័ន្ធច្បាប់ស៊ីវិលជាទូទៅជាវេទិកាមួយដែលជនរងគ្រោះអាចប្រើប្រាស់ដើម្បីទទួលបាននូវការទាមទារឲ្យមានការស្តារឡើងវិញចំពោះការបាត់បង់របស់ខ្លួន ។ ប្រសិនបើជនរងគ្រោះនិងជនល្មើសមិនអាចចរចាគ្នាពីសំណងនៅក្រៅតុលាការបានទេ ជនរងគ្រោះអាចពឹងពាក់តុលាការដើម្បីកំណត់ថា តើការខូចខាតណាខ្លះនឹងត្រូវទទួលសំណង ។ សកម្មភាពដូចគ្នាដែលធ្វើឲ្យមានបទល្មើសនៅក្នុងបរិបទមួយក្លាយទៅជាកំហុស ឬ "ការប្រព្រឹត្តខុស" នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ហើយអាចធ្វើជាមូលដ្ឋានក្នុងការផ្តល់សំណងផ្នែកសេដ្ឋកិច្ច ។ ខុសពីតុលាការព្រហ្ម-ទណ្ឌ ជនរងគ្រោះក្នុងបណ្តឹងស៊ីវិលចូលរួមដោយផ្ទាល់ក្នុងឋានៈជាគូក្តី ។ បណ្តឹងស៊ីវិលមិនមែនមិនគិតអំពីការដាក់ទោសទណ្ឌតាមផ្លូវតុលាការនោះទេ ប៉ុន្តែបានផ្តោតជាសំខាន់លើការខូចខាតខាងសង្គមនិងសេដ្ឋកិច្ចរបស់ដើមបណ្តឹងដែលជាលទ្ធផលនៃការប្រព្រឹត្តខុស ។

យុត្តិធម៌ទាំងពីរប្រភេទនេះមានគោលបំណងល្អដូចគ្នា ដូច្នេះមិនអាចធ្វើការប្រៀបធៀបបានទេ ។ ប្រសិនទទួលបានជោគជ័យ ដំណើរការដែលផ្តោតលើការដាក់ទោសអាចផ្តន្ទាទោសខាងសីល-ធម៌ និងធ្វើឲ្យជនល្មើសញញើតចំពោះអាកប្បកិរិយារបស់ខ្លួននាពេលអនាគត ។ ដូច្នេះ ការដាក់ទោសតាមផ្លូវតុលាការអាចជួយលើកកម្ពស់នីតិរដ្ឋ និងលុបបំបាត់ចោលនូវវប្បធម៌និទ្ទណ្ឌភាព ។

យុត្តិធម៌តាមការសុំខមាទោសដើរតួនាទីផ្សេង ។ ការសងការខូចខាតផ្នែកសង្គមនិងសេដ្ឋកិច្ចធ្វើឲ្យជនរងគ្រោះនិងសហគមន៍កាន់តែទទួលរងគ្រោះថែមទៀត ។ ជាលទ្ធផលនៃគ្រប់បទឧក្រិដ្ឋទាំងអស់ ជាពិសេសការរំលោភបំពានដែលមានលក្ខណៈជាប្រព័ន្ធនិងក្នុងទ្រង់ទ្រាយធំ ដំណើរការទាំងពីរនេះសំខាន់ណាស់ ។ មិនមានដំណើរការណាមួយតែម្នាក់ឯងអាចផ្តល់យុត្តិធម៌ពេញលេញជូនជនរងគ្រោះនិងសហគមន៍បានទេ ។

### ***សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ៖ ការផ្តោតជាសំខាន់ទៅលើយុត្តិធម៌តាមផ្លូវតុលាការ***

ប្រព័ន្ធច្បាប់កម្ពុជាយកតាមប្រព័ន្ធច្បាប់ស៊ីវិល ហើយពុំមានការបែងចែកច្បាស់លាស់រវាងរឿងក្តីស៊ីវិលនិងរឿងក្តីព្រហ្មទណ្ឌ ដូចប្រព័ន្ធច្បាប់ខមមិនឡទេ ។ នៅប្រទេសកម្ពុជា ដំណើរការក្តីរឿងព្រហ្មទណ្ឌជាប្រពៃណីមានទំនាក់ទំនងទៅវិញទៅមករវាងយុត្តិធម៌តាមផ្លូវតុលាការនិងយុត្តិធម៌តាមការសុំខមាទោស ។ ជនល្មើសដែលត្រូវបានចោទប្រកាន់នឹងត្រូវនាំមកវិនិច្ឆ័យទោសនៅចំពោះមុខតុលាការព្រហ្មទណ្ឌប្រសិនបើរកឃើញថា មានកំហុស ប៉ុន្តែជនរងគ្រោះក៏អាចចូលរួមក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ និងអាចដាក់ពាក្យបណ្តឹងដើម្បីទាមទារនូវសំណងផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ហាក់ដូចជាប្រកាន់យកគោលការណ៍យុត្តិធម៌តាមផ្លូវតុលាការស្ទើរតែទាំងស្រុង ។ តុលាការអន្តរជាតិ និងតុលាការចម្រុះភាគច្រើនទៀតមានគោលដៅដូចគ្នា គឺចង់បាននូវយុត្តិធម៌តាមផ្លូវតុលាការ ហើយបានធ្វើការតិចតួចណាស់ដើម្បីផ្តល់នូវយុត្តិធម៌តាមការសុំខមាទោស ។ តុលាការយោធានៅ នូរឹមប៊ឺក និងតូក្យូ តុលាកាព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន សុទ្ធតែផ្តោតជាសំខាន់លើការដាក់ទោសទណ្ឌដោយមិនគិតពីបទបញ្ញត្តិនៃការស្តារឡើងវិញចំពោះជនរងគ្រោះដែលរងទុក្ខវេទនាឡើយ ។

ការបង់បាននូវយុត្តិធម៌តាមផ្លូវតុលាការ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ មិនមែនមិនសមស្របនោះទេ ។ ភាគច្រើន ជនរងគ្រោះតែងតែទាមទារឲ្យមានការកាត់ទោសចំពោះជនល្មើសដែលប្រព្រឹត្តនូវអំពើឃោរឃៅ និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ នៅកម្ពុជា បន្ទាប់ពីមានអំពើឃោរឃៅនៃរបបខ្មែរក្រហមមានការទាមទារជាច្រើនឲ្យមានការកាត់ទោសជនដៃដល់ខ្មែរក្រហមចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្ត ។ អង្គជំនុំជម្រះវិសាមញ្ញនឹងព្យាយាមដោះស្រាយនូវការទាមទារនេះ ដោយធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញនឹងកំណត់នូវការទទួលខុសត្រូវជាបុគ្គលដាក់ទោសជនដែលត្រូវបានរកឃើញថាមានទោស និងផ្ញើសារមួយដើម្បីបង្ហាញថាទង្វើដែលជនទាំងនោះបានប្រព្រឹត្តមិនអាចទទួលយកបានតាមរយៈការផ្តន្ទាទោសពីសាធារណជន ។


វត្តកំពង់លួង ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

ការដាក់ទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ នឹងមិនរាប់បញ្ចូលនូវការបង្ខំឲ្យចុងចោទបង់សំណងដ៏«ថ្លៃហួសហេតុ»នោះទេ ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានកម្រិតបទល្មើស

ត្រឹមការដាក់ពន្ធនាគារអស់មួយជីវិត ដោយពុំមានទោសប្រហារជីវិតដូចដែលជនរងគ្រោះមួយចំនួនទាមទារនោះទេ ។ អ្នកចរចារបស់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានជ្រើសរើសអនុលោមតាមច្បាប់ទំនៀមទម្លាប់សិទ្ធិមនុស្សទូលំទូលាយមួយ (ប៉ុន្តែមិនមែនច្បាប់សិទ្ធិមនុស្សជាសកលទេ) ដែលដកចេញទោសប្រហារជីវិត ទោះបីជាក្នុងករណីបទឧក្រិដ្ឋដ៏អាក្រក់យ៉ាងណាក៏ដោយ ។ បន្ថែមលើការសម្រេចចិត្តកំណត់យកត្រឹមការដកហូតសេរីភាពទាំងស្រុង អ្នកចរចាទាំងនេះក៏បានមើលឃើញថាទោសប្រហារជីវិតពុំមានចែងនៅក្នុងច្បាប់កម្ពុជា ហើយក៏មិនត្រូវបានអនុញ្ញាតឲ្យប្រើនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការចម្រុះដទៃទៀតដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏នឹងមានការពិភាក្សាគ្នាអំពីការដាក់ពន្ធនាគារនេះ ថាតើការដាក់ទោសមួយជីវិតនេះ សមស្របទៅនឹងការកាប់សម្លាប់រង្គាលយ៉ាងឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យដែរឬទេ?



ជាការពិតណាស់ គោលបំណងនៃដំណើរការក្តីព្រហ្មទណ្ឌមិនមែនធ្វើឡើងដើម្បីសងសឹកនោះទេ ។ ការថ្កោលទោសនិងការដាក់ទោសពីសង្គមដែលធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញនេះអាចការពារមិនឲ្យមានការរំលោភដូចគ្នានេះ កើតមានសាជាថ្មីម្តងទៀតនៅពេលអនាគត ហើយជោគជ័យរបស់តុលាការគឺជាសញ្ញានៃការពុះពារផលវិបាកទាំងឡាយ ឬប្រហែលជាអាចបញ្ចប់និទ្ទណ្ឌភាពនៅប្រទេសកម្ពុជាទៀតផង ។ ជាងនេះទៅទៀត ការនាំជនជាប់ចោទដែលទទួលខុសត្រូវចំពោះសោកនាដកម្មនេះមកកាត់ទោសតាមរយៈតុលាការជាផ្លូវការនិងផ្លូវច្បាប់មួយ នឹងអាចជួយប្រជាជនកម្ពុជានៅក្នុងដំណើរការព្យាបាលរបួសផ្លូវចិត្ត ។ សង្គមកម្ពុជាបានតស៊ូអស់ជាច្រើនឆ្នាំនឹងរបបដ៏កំណាចមួយនេះ ។ តុលាការនេះអាចបង្ហាញអ្នកសង្កេតការណ៍ឲ្យឃើញថា នៅទីបញ្ចប់យុត្តិ-ធម៌ត្រូវបានលាតត្រដាង ហើយសង្គមកម្ពុជាអាចធ្វើដំណើរចាកចេញពីអតីតកាលមួយនេះបាន ។

សម្រាប់បុគ្គលដែលទទួលរងការឈឺចាប់នៅក្នុងរបបខ្មែរក្រហម ការនាំយកជនដៃដល់មកកាត់ទោសជារឿងមួយសំខាន់ណាស់ក្នុងការព្យាបាលរបួសផ្លូវចិត្ត ។ នៅកម្ពុជាក៏ដូចជានៅប្រទេសផ្សេងៗទៀតដែរ ជនរងគ្រោះជាច្រើននឹងមិនចាត់ទុកថាមានយុត្តិធម៌ទេ ដរាបណាអ្នកទាំងនេះមិនទាន់ឃើញជនដៃដល់ដែលបានបង្កការឈឺចាប់ត្រូវបាននាំយកមកទទួលខុសត្រូវឬកាត់ទោសនៅក្នុងកម្រិតណាមួយនោះ ។ ការមើលឃើញសេចក្តីសម្រេចរបស់តុលាការដែលគួរទុកចិត្តបានអាចជួយធ្វើឲ្យជនរងគ្រោះមានជំនឿទៅលើច្បាប់ទំនៀមទម្លាប់ និងប្រព័ន្ធច្បាប់ និងស្ថាប័នទាំងឡាយដែលត្រូវបានបង្កើតឡើងដើម្បីពង្រឹង ។

## ការស្តារឡើងវិញ និងតុលាការខ្មែរក្រហម

ទោះបីជាដំណើរការព្រហ្មទណ្ឌជាច្រើន ដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ផ្តោតសំខាន់ទៅលើយុត្តិធម៌តាមផ្លូវតុលាការក៏ដោយ ក៏បំណងក្នុងការដាក់ទោសនិងការថ្កោលទោសតាមផ្លូវសីលធម៌ មិនគួរគ្របដណ្តប់លើការចង់បានយុត្តិធម៌តាមការសុំខមាទោសរបស់ជនរងគ្រោះដែរ ។ ប្រការនេះកើតមានឡើងពិតប្រាកដនៅក្នុងប្រទេសកម្ពុជាដែលអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលដូចជាកម្ពុជា ដែលយុត្តិធម៌ទាំងពីរប្រភេទ ជាទំនៀមទម្លាប់អាចត្រូវបានយកមកប្រើនៅក្នុងដំណើរក្តីព្រហ្មទណ្ឌ ។ មាត្រា៣៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញអនុញ្ញាតឲ្យមានការដកហូតទ្រព្យសម្បត្តិនិងលុយកាក់ដែលទទួលបានដោយខុសច្បាប់របស់ឧក្រិដ្ឋជន ។ នេះមានន័យថាថវិកាដែលរកបានដោយខុសច្បាប់របស់ទណ្ឌិតនឹងត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។ ទោះជាយ៉ាងនេះក្តី វាបានបង្ហាញឲ្យឃើញថា តុលាការខ្មែរក្រហមនឹងផ្តោតការយកចិត្តទុកដាក់តិចតួចណាស់ចំពោះសំណងជាសម្ភារ

ដល់ជនរងគ្រោះ ។

មានហេតុផលជាច្រើនដែលអង្គជំនុំជម្រះវិសាមញ្ញទំនងជាមិនបញ្ចូលយន្តការសំខាន់មួយ សម្រាប់យុត្តិធម៌តាមការសុំខមាទោស ។ ទីមួយ វានឹងមានបញ្ហាជាច្រើនកើតមានឡើងទាក់ទងនឹងសំណើឲ្យមានសំណងពីជនរងគ្រោះរាប់ពាន់ឬអាចដល់រាប់លាននាក់ ។ ទីពីរ ប្រសិនបើទណ្ឌិតពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការសងមូលនិធិសាធារណៈនឹងមិនគ្រប់គ្រាន់សម្រាប់ការប៉ះប៉ូវនេះទេ និងទីបី សំណើច្រើនលើសលប់នឹងអាចជាបន្ទុកធ្ងន់ធ្ងរដល់តុលាការ និងកំណត់លទ្ធភាពរបស់តុលាការក្នុងការកាត់សេចក្តីរឿងព្រហ្មទណ្ឌឲ្យបានហ្មត់ចត់ ។ បញ្ហាទាំងអស់នេះមានសារៈសំខាន់ណាស់ ហើយថែមទាំងអាចជួយពន្យល់ពីមូលហេតុដែលតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀតហាក់ដូចជាចៀសវាងការដោះស្រាយបញ្ហាតាមផ្លូវតុលាការដោយសារហេតុផលស្រដៀងគ្នា ។

ដោយឈរលើហេតុផលខាងលើនេះ យុត្តិធម៌ផ្សះផ្សាមានការលំបាកច្រើនក្នុងការយកមកអនុវត្តនៅក្នុងតុលាការខ្មែរក្រហម ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើជនរងគ្រោះមិនត្រូវបានសងជំងឺចិត្តចំពោះការខូចខាតទាំងប៉ុន្មានទេនោះ តុលាការនេះនឹងសម្រេចបានត្រឹមតែយុត្តិធម៌ផ្នែកណាមួយប៉ុណ្ណោះ ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិនិងតុលាការចម្រុះនៅកូសូវ៉ូ ជាឧទាហរណ៍នៃតុលាការដែលព្យាយាមអនុវត្តនូវយុត្តិធម៌ទាំងពីរប្រភេទចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ។ អង្គការក្នុងស្រុកនៅកម្ពុជានិងបុគ្គលិកសង្គមស៊ីវិលមួយចំនួនបានទាមទារថា ជនរងគ្រោះគួរតែទទួលបានសំណងពីតុលាការខ្មែរក្រហមនេះ ។ ជាពិសេសអ្នករិះគន់បានស្នើឲ្យមានការបញ្ចូលគ្នានូវយុត្តិធម៌ទាំងពីរប្រភេទ ដោយមិនធ្វើឲ្យប៉ះពាល់ដល់តួនាទីចម្បងរបស់តុលាការក្នុងការស៊ើបអង្កេត និងការកាត់សេចក្តី ។ ឧទាហរណ៍ ជនរងគ្រោះអាចរើសតំណាងរួមមួយទៅតុលាការជាជាងការឡើងប្តឹងផ្តល់ជាបុគ្គល ។ មនុស្សមួយចំនួនផ្សេងទៀតបានលើកឡើងថា គួរតែមានសំណងជានិមិត្តរូបមួយដើម្បីគូសបញ្ជាក់ពីសារសំខាន់នៃយុត្តិធម៌តាមការសុំខមាទោស ។ ទោះជាយ៉ាងនេះក្តី រហូតមកដល់ពេលនេះ អង្គជំនុំជម្រះវិសាមញ្ញទំនងជាមិនធ្វើតាមសំណើនេះទេ ។

## យុត្តិធម៌សម្រាប់ការរំលោភសិទ្ធិមនុស្សក្នុងទ្រង់ទ្រាយធំ

ទំហំពិតប្រាកដនៃការរំលោភបំពាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញពីការលំបាកក្នុងការផ្តល់នូវយុត្តិធម៌គួរឲ្យទុកចិត្តបានជូនអ្នកនៅរស់រានមានជីវិតពីរបបនេះ ។ វាលើសពីភាពមន្ទិលសង្ស័យខាងប្រវត្តិសាស្ត្រទៅទៀត ដែលមន្ត្រី និងកម្មាភិបាលខ្មែរក្រហមរាប់ពាន់នាក់បានចូលរួមប្រព្រឹត្តអំពើឃោរឃៅនៅក្នុងអំឡុងពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ។ សកម្មជនបរទេសមួយចំនួនសុខចិត្តទទួលយកអំពើឃោរឃៅនេះ ហើយថែមទាំងបានផ្តល់ថវិកាឬគាំទ្ររបបខ្មែរក្រហមទៀតផង ។ មានជនរងគ្រោះច្រើនណាស់ ។ ប្រជាជនកម្ពុជារាប់លាននាក់និងជនបរទេសមួយចំនួនធំស្លាប់ឬទទួលរងទុក្ខក្រោមស្នាដៃរបស់ខ្មែរក្រហម ។ ផ្ទុយទៅវិញ មានតែជនដៃដល់មួយចំនួនតូចប៉ុណ្ណោះ ដែលនឹងត្រូវនាំយកមកកាត់ទោសនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ តើយុត្តិធម៌អាចនឹងទទួល



ធនាគារជាតិនៃកម្ពុជាឆ្នាំ១៩៧៩

បានដែរឬទេ ប្រសិនបើមានតែជនជាប់ចោទមួយចំនួនតូចត្រូវនាំយកមកកាត់ទោស បន្ទាប់ពីប្រជាជនរាប់លាននាក់រងទុក្ខវេទនាយ៉ាងខ្លោចផ្សា?

### តុលាការពីអតីតកាល និងបញ្ហា"យុត្តិធម៌ជ្រើសរើស"

វិធីម្យ៉ាងដើម្បីឆ្លើយតបនឹងសំណួរដ៏លំបាកនេះ គឺការសង្កេតមើលការអនុវត្តន៍របស់តុលាការពីអតីតកាល ដែលបានកាត់ក្តីពីបទល្មើសធ្ងន់ធ្ងរនិងក្នុងទ្រង់ទ្រាយធំ ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ គ្រប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនិងតុលាការចម្រុះទាំងអស់ត្រូវបានបង្កើតឡើងដោយដឹងជាមុនថា ខ្លួននឹងធ្វើការកាត់ទោសតែទៅលើជនជាប់ចោទចំនួនកំណត់មួយប៉ុណ្ណោះ ។ គ្រប់រឿងក្តីទាំងអស់ តុលាការអន្តរជាតិត្រូវបានបង្កើតឡើងនៅក្នុងរបៀបមួយដែលជនទទួលខុសត្រូវចំពោះបទឧក្រិដ្ឋភាគច្រើននឹងត្រូវកាត់ទោសតាមរូបភាពជាវេទិកាផ្សេងទៀត ។

ឧទាហរណ៍ដំបូងស្តីពីការកាត់ទោសចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរក្នុងកម្រិតស្តង់ដារអន្តរជាតិ គឺតុលាការយោធាអន្តរជាតិនូរ៉ឺមប៊ឺក ។ តុលាការនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៥ ដើម្បីកាត់ទោសឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗ នៅអឺរ៉ុបពីឧក្រិដ្ឋកម្មអន្តរជាតិ ហើយការកាត់ទោសពីឧក្រិដ្ឋជនថ្នាក់ក្រោមធ្វើឡើងនៅតុលាការថ្នាក់ជាតិរបស់ប្រទេសសម្ព័ន្ធមិត្ត ។ សហរដ្ឋអាមេរិកនិងប្រទេសក្នុងទ្វីបអឺរ៉ុបខាងលិចដែលជាអ្នកបង្កើតសាលាក្តីនេះឡើងបង្ហាញភាពត្រឹមត្រូវរបស់ខ្លួនក្នុងការផ្តោតការកាត់ទោសតែទៅលើមេដឹកនាំកំពូលរបស់អង្គការណាហ្ស៊ីអាល្លឺម៉ង់ ដោយសង្កត់ធ្ងន់ទៅលើចរិតលក្ខណៈរួមនៃការសម្លាប់រង្គាលរបស់អង្គការណាហ្ស៊ីប៉ុណ្ណោះ ។ លក្ខណៈរួមរបស់ឧក្រិដ្ឋកម្មមានន័យថា មនុស្សរាប់សែនបានចូលរួមនៅក្នុងសកម្មភាពខុសច្បាប់ ហើយការកាត់ទោសជនទាំងអស់នោះមិនអាចធ្វើទៅបានទេ ។ ការកាត់ទោសក្នុងទ្រង់ទ្រាយធំបែបនេះមិនមែនជាការចង់បាននោះទេ ដោយហេតុថាប្រទេសលោកខាងលិចចង់កសាងឡើងវិញនូវរដ្ឋអាល្លឺម៉ង់ខាងលិចរឹងមាំមួយ នៅដើមដំបូងនៃសង្គ្រាមត្រជាក់ ។ វាជាការប្រសើរជាងក្នុងការដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទៅដល់អ្នកផ្តើមគំនិតរបស់អង្គការណាហ្ស៊ី ។ ជាពិសេស ប្រការនេះបានដាក់ថ្នាក់ដឹកនាំប្រទេស ដោយឡែកពីប្រជាជនសាមញ្ញ ហើយអនុញ្ញាតឲ្យប្រទេសសម្ព័ន្ធមិត្តដាក់ការរឹតបន្តឹងផ្នែកសីលធម៌ និងការវិនិច្ឆ័យខាងផ្លូវច្បាប់ ដោយកាត់បន្ថយបាននូវគ្រោះថ្នាក់ពីការប្រឆាំងរបស់ក្រុមអ្នកជាតិនិយមចំពោះការបង្កើតតុលាការ និងមិនប៉ះពាល់ដល់ប្រជាជនក្នុងរដ្ឋធានីរបស់អាល្លឺម៉ង់ ។

តុលាការយោធាតូក្យូឆ្នាំ១៩៤៦អនុវត្តយុទ្ធសាស្ត្រក្នុងការកាត់ទោសស្រដៀងគ្នានេះដែរ ហើយធ្វើការកាត់ទោសតែមន្ត្រីជាន់ខ្ពស់ជប៉ុនប៉ុណ្ណោះ ។ ដូចនៅប្រទេសអាល្លឺម៉ង់ដែរ មហាអំណាចលោកខាងលិចដែលឈ្នះសង្គ្រាម និងជាពិសេសសហរដ្ឋអាមេរិកព្យាយាមដាក់ការស្តីបន្ទោសនិងដាក់ទោសមេដឹកនាំអធិរាជជប៉ុន និងកសាងប្រទេសជប៉ុនថ្មីមួយដែលបម្រើជាកំពែងខាងកើតការពារប្រឆាំងនឹងកុម្មុយនិស្ត ។ នេះមានន័យថា ការបង្កើតតុលាការដែលនឹងមិនបង្កឲ្យមានការតស៊ូហួសប្រមាណ ឬកាត់បន្ថយមុខងាររបស់ប្រទេសជប៉ុន ។

ការឈឺចាប់ពិតប្រាកដរបស់អាល្លឺម៉ង់និងជប៉ុនគឺថា អ្នកវិទ្យាសាស្ត្រ រដ្ឋការ និងសមាជិកផ្សេងទៀតនៃក្រុមដែលមានជំនាញច្បាស់លាស់ បានបម្រើការឲ្យក្រុមអ៊ែកស៊ីសនៅក្នុងអំឡុងពេលសង្គ្រាម ។ ការនាំយកអ្នកទាំងនេះមកកាត់ទោស ឬដកពួកគេចេញពីតួនាទីក្នុងរដ្ឋាភិបាលគឺមិនអាចធ្វើទៅកើតទេ ប្រសិនបើចង់ឲ្យប្រទេសជប៉ុនក្លាយទៅជាប្រទេសមួយរឹងមាំមានលទ្ធិប្រជាធិបតេយ្យ និងទប់ទល់នឹងសម្ពាធកុម្មុយនិស្តពីខាងក្នុងនិងក្រៅ ។ ពេលមានការរួមបញ្ចូលគ្នារវាងតុលាការក្នុងស្រុកក្នុងការកាត់ទោសមន្ត្រីថ្នាក់ក្រោម អ្នកសង្កេតការណ៍ភាគច្រើនយល់ឃើញថា ការផ្តោតជាសំខាន់របស់តុលាការអន្តរជាតិទៅលើតែមេដឹកនាំកំពូល គឺជាវិធីមួយដ៏សមស្របក្នុងការដាក់ឲ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះបទឧក្រិដ្ឋឃោរឃៅ ដែលត្រូវបានប្រព្រឹត្តឡើងនៅអំឡុងសង្គ្រាមលោកលើកទីពីរ ។

ទោះបីជាតុលាការនូរ៉ឺមប៊ឺកតុលាការក្រុងតូក្យូមានការគាំទ្រពីអន្តរជាតិច្រើនក៏ដោយ ក៏តុលាការនេះនៅតែទទួលការរិះគន់ដដែរ ។ អ្នកជំទាស់នឹងតុលាការនេះបានលើកឡើងថា ក្រៅពីកាត់ទោសទៅលើចុងចោទដែលមានចំនួនកំណត់មួយ រដ្ឋអាជ្ញាអនុវត្តតាមតែរបៀបវារៈនយោបាយ និងអនុវត្តតាមយុត្តិធម៌របស់អ្នកឈ្នះសង្គ្រាម ដោយកាត់ទោសតែខាងមន្ត្រីចាញ់សង្គ្រាម

ប៉ុណ្ណោះ ។ ផ្ទុយពីតុលាការទាំងពីរនេះ តុលាការព្រហ្មទណ្ឌអន្តរ-ជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ត្រូវបានបង្កើតឡើងដើម្បីកាត់ទោសជនទាំងឡាយណាដែលរំលោភបំពានធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរ-ជាតិ ។ លក្ខន្តិកៈរបស់តុលាការនេះផ្តល់ឲ្យរដ្ឋអាជ្ញានូវឆន្ទានុសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដោយផ្អែកលើភ័ស្តុតាងដែលប្រមូលបាន ។ ចំណុចគួរឲ្យចាប់អារម្មណ៍នោះ គឺថា រដ្ឋអាជ្ញារបស់តុលាការទាំងពីរនេះបានផ្តួចផ្តើមនូវយុទ្ធសាស្ត្រពីរខុសប្លែកគ្នា ។

រដ្ឋអាជ្ញារបស់តុលាការសម្រាប់ប្រទេសរ៉្វាន់ដា យកគំរូតាមតុលាការនូរ៉ឹមប៊ឺក ដោយផ្តោតជាសំខាន់ពីដំបូងទៅលើតែមន្ត្រីកំពូលៗ ។ តុលាការនេះផ្តោតតែលើអ្នកដឹកនាំខាងយោធានិងស៊ីវិល ហើយទុកឲ្យតុលាការក្នុងស្រុកជាអ្នកកាត់ទោសជនល្មើសថ្នាក់ក្រោម ។ ផ្ទុយទៅវិញ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីកាត់ទោសជនជាប់ចោទពីកម្រិតផ្សេងៗគ្នា ទោះជាអ្នកទាំងនោះស្ថិតក្នុងឋានៈឬតួនាទីអ្វីក៏ដោយ ដែលរួមបញ្ចូលទាំងជនជាប់ចោទថ្នាក់ទាបទៀតផង ។ ការអនុវត្តរបៀបនេះធ្វើឲ្យចៅក្រមនៃតុលាការនេះផ្តល់ជាអនុសាសន៍ថា «ក្នុងទស្សនៈរបស់ពួកគេ បេសកកម្មរបស់តុលាការអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដូចដែលមានចែងនៅក្នុងលក្ខន្តិកៈរបស់ខ្លួន គឺកាត់សេចក្តីនិងដាក់ទណ្ឌកម្មដល់ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានប្រព្រឹត្តនៅអតីតយូហ្គោស្លាវី» ។

ដោយយោងទៅលើច្បាប់នេះ រដ្ឋអាជ្ញារបស់តុលាការនេះបានផ្តោតការយកចិត្តទុកដាក់ទៅលើតែជនជាប់ចោទថ្នាក់ខ្ពស់ ហើយទុកឲ្យតុលាការជាតិរបស់ប្រទេសពាក់ព័ន្ធកាត់ទោសជនជាប់ចោទថ្នាក់ទាប ។ ចំនួនជនជាប់ចោទក្នុងតុលាការកូសូវ៉ូ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី គឺជាក្រុមអ្នកចាញ់សង្គ្រាមជាមួយមហាអំណាចលោកខាងលិច ។ ការពិតដែលថាតុលាការទាំងនេះត្រូវបានសាធារណមតិមួយចំនួនមើលឃើញថាលម្អៀងទៅម្ខាងនោះ បានធ្វើឲ្យមានការខ្វល់ខ្វាយដល់ភាពស្របច្បាប់ និងសក្តានុពលក្នុងការនាំមកនូវការផ្សះផ្សារវាងគូបដិបក្ខ ។ ពេលវេលានឹងបង្ហាញឲ្យឃើញថា តើក្រុមអ្នករិះគន់នឹងលើកបញ្ហាប្រហាក់ប្រហែលគ្នានេះចំពោះតុលាការខ្មែរក្រហមដែរឬយ៉ាងណា? ។

ដូចគ្នានឹងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា តុលាការចម្រុះនៅទីម័រខាងកើតនិងសៀរ៉ាឡេអូន បានយកគំរូតាមតុលាការនូរ៉ឹមប៊ឺក និងផ្តោតតែទៅលើមេដឹកនាំជាន់ខ្ពស់តែប៉ុណ្ណោះ ដែលជាវិធីមួយដ៏មានប្រសិទ្ធភាពក្នុងការនាំមកនូវយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មអន្តរជាតិក្នុងទ្រង់ទ្រាយធំនៅក្នុងប្រទេសទាំងពីរនេះ ។ លក្ខន្តិកៈរបស់តុលាការពិសេសនៅប្រទេសសៀរ៉ាឡេអូនផ្តល់នូវការកាត់ទោសយ៉ាងតឹងតែង ចំណែកតុលាការនៅប្រទេសទីម័រខាងកើត គោលនយោបាយទាំងឡាយត្រូវបានបង្កើតឡើងតាមការអនុវត្តន៍ជាបន្តបន្ទាប់ ។ គោលបំណងនៃការកាត់ទោសជនសង្ស័យថ្នាក់ខ្ពស់ ឬទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិឬតុលាការចម្រុះ ជាជាងយកមកកាត់ទោសនៅតុលាការក្នុងស្រុកដើម្បីធានាឲ្យបានថាជនដែលទទួលខុសត្រូវនិងជាអ្នកដាក់ចេញនូវគោលនយោបាយក្នុងការរំលោភធ្ងន់ធ្ងរនោះ នឹងត្រូវបានកាត់ទោសដោយតុលាការមួយ ដែលមានសមត្ថភាពនិងឯករាជ្យភាព ហើយដែលអាចដោះស្រាយរឿងក្តីប្រកបដោយសុវត្ថិភាពនិងយុត្តិធម៌ ។ នៅក្នុងការអនុវត្តន៍ធនធានមានកម្រិតនិងបញ្ហានយោបាយពាក់ព័ន្ធនឹងការកាត់ទោសក្នុងទ្រង់ទ្រាយធំ ក៏តែងតែជាកត្តាសំខាន់មួយទៀតផងដែរ ។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិនិងតុលាការចម្រុះនៅទីម័រខាងកើតនិងសៀរ៉ាឡេអូនត្រូវបានបង្កើតឡើងនៅក្នុងបរិបទមួយដែលមានការបារម្ភអំពីសន្តិភាពនិងពីបូរណភាពរបស់តំបន់ និងសង្គមដែលប្រេះស្រាំបន្ទាប់ពីជម្លោះ ។

ដោយការផ្តោតតែទៅលើថ្នាក់ដឹកនាំជាន់ខ្ពស់អាចជាជម្រើសសមស្របតែមួយ ដោយយោងទៅលើហេតុផលមួយចំនួនទាក់ទងនឹងបញ្ហាថវិកានិងផ្នែកសម្ភារនោះ ការកាត់ទោសជាអន្តរជាតិតាមបែបជ្រើសរើសទទួលបានយុត្តិធម៌តែមួយផ្នែកប៉ុណ្ណោះ ។ ការកាត់ទោសទាំងនេះដោះស្រាយតែលើបទឧក្រិដ្ឋ

ខ្លះដែលបានកើតឡើង ។ ដូច្នេះ ជាទូទៅការកាត់ទោសបែបជ្រើសរើសនេះអាចបំពេញនូវតម្រូវការរបស់ប្រជាជនបាន លុះត្រាតែរួមបញ្ចូលជាមួយយន្តការផ្សេងទៀត ដូចជាការកាត់ទោសក្នុងតុលាការជាតិ ដូចដែលបានធ្វើឡើងនៅប្រទេសរ៉្វាន់ដា និងអតីតយូហ្គោស្លាវី ឬគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅសៀរ៉ាឡេអូននិងទីម័រខាងកើត ។

ទោះបីជាអ្នកស្រាវជ្រាវ សកម្មជន និងអ្នកនយោបាយមួយចំនួនបានពិភាក្សាជាយូរមកហើយអំពីលទ្ធភាពក្នុងការប្រើប្រាស់តុលាការក្នុងស្រុក ឬបង្កើតគណៈកម្មការស្វែងរកការពិតនៅកម្ពុជាក្តី ក៏យន្តការនេះមិនទាន់កើតមាននៅឡើយទេនាពេលបច្ចុប្បន្ននេះ ។ កិច្ចការចម្បងមួយរបស់អង្គការក្រៅរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងមជ្ឈមណ្ឌលឯកសារកម្ពុជាផង គឺរកវិធីផ្សេងៗដើម្បីបំពេញបន្ថែមការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយធ្វើការជាមួយសហគមន៍ក្នុងតំបន់នៅក្នុងដំណើរការជំរុញឲ្យមានការទទួលខុសត្រូវតាមមូលដ្ឋាន និងការបង្កើតឡើងនូវដំណើរការក្រៅផ្លូវការដើម្បីជំនួសគណៈកម្មការស្វែងរកការពិត ។


អ្នកស្រុកប្រមូលអដ្ឋិធាតុចេញពីអណ្តូងក្នុងខេត្តស្វាយរៀង

**ការកាត់ទោសបែបជ្រើសរើសនៅចំពោះមុខតុលាការខ្មែរក្រហម**

ផ្អែកលើបទពិសោធន៍នៃការអនុវត្តន៍កម្រិតអន្តរជាតិមួយចំនួន តុលាការខ្មែរក្រហមនឹងធ្វើការស៊ើបអង្កេត និងកាត់ទោសបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ឬ"ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋ និងការរំលោភបំពានធ្ងន់ធ្ងរ...." ។ មន្ត្រីអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់នូវហេតុផលជាច្រើនលើដែនយុត្តាធិការលើបុគ្គលនេះ ។ ហេតុផលចម្បងមួយគឺថាអង្គជំនុំជម្រះវិសាមញ្ញនឹងមិនមានថវិកានិងសម្ភារៈគ្រប់គ្រាន់ដើម្បីកាត់ទោសជនដែលដល់គ្រប់រូបចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។

ទោះបីជាមានការយល់ព្រមគ្នារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលថា ទំហំនៃការកាត់សេចក្តីគួរតែត្រូវបានកំណត់យ៉ាងណាក៏ដោយ ក៏ភាគីទាំងពីរនៅតែមានការលំបាកក្នុងការយល់ស្របគ្នាលើចំនួនមនុស្សពិតប្រាកដដែលត្រូវកាត់ទោសដោយតុលាការនេះ ។ នៅដើមឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថា មានតែមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ៤ ឬ៥នាក់ប៉ុណ្ណោះដែលនឹងត្រូវយកមកកាត់ទោសភាគីអង្គការសហប្រជាជាតិបានទាមទារឲ្យមានការកាត់ទោស "ជនដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្រោមការកាន់អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា" ដែលមានចំនួនពី២០ ទៅ៣០ នាក់ ។ ក្រុមអ្នកជំនាញក៏បញ្ជាក់បន្ថែមទៀតថា តុលាការ "មិនត្រឹមតែកាត់ទោសមេដឹកនាំកំពូលដែលទទួលខុសត្រូវចំពោះការរំលោភបំពាននោះទេ ប៉ុន្តែនឹងធ្វើការកាត់ទោសផងដែរនូវជនថ្នាក់ក្រោមដែលបានប្រព្រឹត្តអំពើឃោរឃៅដោយផ្ទាល់" ។ ដោយសារតែការមិនយល់ព្រមលើយុត្តាធិការលើបុគ្គលនេះ ទើបនាំឲ្យមានការខ្វែងគំនិតគ្នារវាងមន្ត្រីអង្គកាសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។

អ្នកផ្តល់អនុសាសន៍ខ្លះបានឲ្យយោបល់ថា ទស្សនៈផ្ទុយគ្នារវាងមន្ត្រីអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញការពិតដែលថា ភាគីទាំងពីរមានគោលដៅផ្សេងគ្នា ដែល

មានការលំបាកក្នុងការសម្រុះសម្រួល ។ ជំនួយការរបស់អង្គការសហប្រជាជាតិដើម្បីបង្កើតការតុលាការនេះ មានគោលបំណងបី គឺ ថ្កោលទោសចំពោះការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ បញ្ចប់នូវវប្បធម៌និទ្ទណ្ឌភាព និងបង្កើតនីតិរដ្ឋនៅកម្ពុជា ។ ដោយជួយបង្កើតឲ្យមានតុលាការខ្មែរក្រហមនេះ អង្គការសហប្រជាជាតិនឹងបញ្ចប់បេសកកម្មដែលខ្លួនចាប់ផ្តើមធ្វើតាំងពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដែលបានជួយកម្ពុជាឲ្យក្លាយទៅជាប្រទេសប្រជាធិបតេយ្យប្រកបដោយសន្តិភាព ដែលនឹងមានការរីកលូតលាស់ខាងសង្គមនិងសេដ្ឋកិច្ច ។ មន្ត្រីចរចារបស់អង្គការសហប្រជាជាតិបានលើកឡើងថា ការកាត់ទោសជនដៃដល់មួយចំនួនធំ នឹងនាំមកនូវយុត្តិធម៌និងជួយឲ្យមានការផ្សះផ្សាដ៏ល្អប្រសើរមួយ ។

មន្ត្រីកម្ពុជាមិនយល់ស្របនឹងជំហររបស់អង្គការសហប្រជាជាតិ ហើយបានអះអាងថាការផ្សះផ្សាបានធ្វើរួចរាល់ហើយ ។ អ្នកទាំងនេះបានតវ៉ាថា ការកាត់ទោសច្រើនពេកនឹងនាំឲ្យមានការប្រេះឆាចំពោះសន្តិភាពដ៏ក្មេងខ្ចី ។ ដូចនេះ មានតែមេដឹកនាំកំពូលរបស់កម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះដែលត្រូវនាំយកមកកាត់ទោស ។ ក្រុមអ្នករិះគន់ចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាបានលើកឡើងពីគោលបំណងចម្បងរបស់រដ្ឋាភិបាលក្នុងការបង្កើតឲ្យមានតុលាការនេះ គឺដើម្បីទទួលបាននូវអំណាចនយោបាយក្នុងស្រុកកាន់តែច្រើន ដោយធានាឲ្យបាននូវការទទួលស្គាល់ថា រដ្ឋាភិបាលបានបោសសម្អាតចលនាខ្មែរក្រហម ។ អ្នករិះគន់ក៏បានបន្ថែមទៀតថា លោកនាយករដ្ឋមន្ត្រីកំណត់ការកាត់ក្តី គឺដើម្បីការពារដល់មន្ត្រីបម្រើការយូរអង្វែងនៃគណបក្សប្រជាជនដែលជាអតីតកម្មាភិបាល ឬជាមន្ត្រីខ្មែរក្រហម ។ លើសពីនេះទៀត អ្នករិះគន់បានអះអាងថា តួនាទីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាអតីតកម្មាភិបាលយោធាខ្មែរក្រហមអាចជាឥទ្ធិពលមួយដែលនាំឲ្យលោកដាក់ដែនកំណត់លើការកាត់ទោសនេះ ។

ទោះជាយ៉ាងនេះក្តី នៅខែមេសាឆ្នាំ១៩៩៩ ការបង្ហាញមុខជាសាធារណៈ និងក្រោយពីការចាប់ខ្លួន ឌុច បានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ទៅលើជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ។ ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យទេ ប៉ុន្តែតួនាទីរបស់គាត់ជាប្រធានគុកទួលស្លែងធ្វើឲ្យគាត់ក្លាយទៅជាគោលដៅមួយចំពោះការកាត់ទោស ។ គណបក្សប្រជាជនកម្ពុជាបានបង្ហាញនូវការគាំទ្រក្នុងការកាត់ទោស ឌុច ទោះបីជា ឌុច មិនមែនជា«មេដឹកនាំជាន់ខ្ពស់ក្តី» ។ ដើម្បីអាចកាត់ទោស ឌុច បានអ្នកចរចារបស់រាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមពង្រីកដែនយុត្តាធិការរបស់តុលាការ ដោយរួមបញ្ចូលមិនត្រឹមតែមេដឹកនាំជាន់ខ្ពស់ប៉ុណ្ណោះទេ ថែមទាំងរាប់បញ្ចូលដល់ជនទាំងឡាយណាដែល «ទទួលខុសត្រូវខ្ពស់បំផុត» ចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។

អ្នករិះគន់ខ្លះបានលើកឡើងថា តុលាការខ្មែរក្រហមគួរតែកាត់ទោសជនជាប់ចោទច្រើនជាង១០នាក់ ឬកាត់ទោសរាប់រយនាក់ប្រសិនបើចង់បានយុត្តិធម៌ពិតប្រាកដ ។ អតីតព្រះមហាក្សត្រសម្តេច ព្រះនរោត្តម សីហនុ បានរិះគន់តុលាការចំពោះការកំណត់ដែនយុត្តាធិការតែលើមេធ្វើទារុណកម្មនិងមេឃាតករតែប៉ុន្មានរូបប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តី បន្ទាប់ពីការចរចាគ្នាអស់រយៈពេលយ៉ាងយូរ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យកាត់ទោសតែ«មេដឹកនាំជាន់ខ្ពស់» និង «អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភបំពានធ្ងន់ធ្ងរផ្សេងទៀត» នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រវត្តិវិទូនិងអ្នកជំនាញការច្បាប់បានអះអាងថា បើព្រះរាជអាជ្ញាពិតជាស្រាវជ្រាវតាមភស្តុតាងនៅគ្រប់ទីកន្លែង នោះការកាត់ទោសអាចធ្វើទៅបានលើមនុស្សជាច្រើនថែមទៀតនៅគ្រប់លំដាប់ថ្នាក់ក្នុងសង្គមកម្ពុជាពីអតីតនិងបច្ចុប្បន្ន ។ បើធ្វើការកាត់សេចក្តីច្រើនជាងនេះ វានឹងបង្កឲ្យមានគ្រោះថ្នាក់នៃ«ចំណោតដីរអិលមួយ» ដែលប៉ះពាល់ដល់ធនធានរបស់តុលាការ និងបើយោងតាមអ្នកអត្ថាធិប្បាយមួយចំនួនថា វានឹងធ្វើឲ្យសន្តិភាពក្នុងប្រទេសជួបគ្រោះថ្នាក់ ។ ដោយឈរលើហេតុផលទាំងនេះ ទើបអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា បានយល់ព្រមថា មានជនជាប់ចោទប្រហែលពី៥ ទៅ១០នាក់ ប៉ុណ្ណោះនឹងត្រូវបាននាំយកមកកាត់ទោស ។ ***(នៅមានត)***

**រអេឡែន អ៊ុយណាក និង ស្ទីវ ហេឌ**

# ភាពតក់ស្លុត និងការប៉ះទង្គិចផ្លូវចិត្ត នៅក្នុងអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ខ្ញុំនៅតែចង់សងសឹក ។ ខ្ញុំពុំដឹងថាការគិតសងសឹកនេះ ត្រូវបញ្ឈប់ដោយរបៀបណានោះទេ ។ យើងគ្មានគំនិតសងសឹកបែបនេះទេ ប្រសិនបើយើងមានគំនិតចង់សងសឹកមែននោះ បញ្ហានឹងកើតមានឡើងមិនចេះចប់ឡើយ ពីព្រោះយើងកាន់នូវធម៌ព្រះពុទ្ធ ។ អ្នកដែលចង់សងសឹកបានត្រឹមតែបង្កទុក្ខវេទនាដល់សង្គមយើងប៉ុណ្ណោះ ។ នេះគឺជាជំងឺសង្គម ។ ក៏ប៉ុន្តែខ្ញុំនៅតែគិតអំពីការសងសឹក... ។ អ្នកដែលបានសម្លាប់បងប្រុសរបស់ខ្ញុំ និងអ្នកដែលបានហៅឈ្មោះបងប្រុសខ្ញុំឡើងឡាន នៅរស់ទាំងអស់នៅក្នុងភូមិជាមួយខ្ញុំដែរ ។ រហូតទល់នឹងថ្ងៃនេះ ខ្ញុំនៅតែចង់សងសឹក ។ ខ្ញុំចេះតែសង្កេតមើលអ្នកទាំងនោះជាប់ជានិច្ច ។ ក៏ប៉ុន្តែខ្ញុំមិនដឹងថាតើខ្ញុំត្រូវធ្វើដូចម្តេច...ពីព្រោះរាជរដ្ឋាភិបាលកម្ពុជាបានហាមឃាត់មិនឲ្យមានការសងសឹក ។

គ្រួសារបងប្រុសរបស់ ឆ្លាត ត្រូវខ្មែរក្រហមសម្លាប់ ។

ប្រជាជនខ្មែរបានស្លាប់ដោយរបៀបផ្សេងៗគ្នាក្នុងអំឡុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដែលជារបបប្រល័យពូជសាសន៍មួយគ្រប់គ្រងដោយខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា (ឆ្នាំ ១៩៧៥-១៩៧៩) ។ ប្រជាជនខ្មែរខ្លះ ត្រូវបានបង្អត់អាហាររហូតដល់ស្លាប់ ។ ខ្លះទៀត ស្លាប់ដោយគ្មានអាហារហូបគ្រប់គ្រាន់និងជំងឺ ។ ប្រជាជនកម្ពុជាជាច្រើននាក់ទៀត ត្រូវខ្មែរក្រហមសម្លាប់ ភាគច្រើនត្រូវបានសម្លាប់ជាក្រុម ។ អំពើប្រល័យពូជសាសន៍នេះបានឆក់យកអាយុជីវិតប្រជាជនខ្មែរជាង១,៧លាននាក់ប្រហែលជាមួយភាគបួននៃចំនួនប្រជាជនកម្ពុជាសរុប ។ ចំនួនមនុស្សស្លាប់នេះ គឺពិបាកនឹងយល់ខ្លាំងណាស់ ក៏ប៉ុន្តែចំនួននេះមិនគិតអំពីចំនួនមនុស្សស្លាប់និងការខូចខាតនៃអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានទទួលនូវការឈឺចាប់ដោយការបាត់បង់មិត្តភក្តិនិងមនុស្សជាទីស្រឡាញ់ដែលតស៊ូរស់ក្នុងពិភពខ្វះខាតនិងការងារផតឈប់ឈរ ខិតខំប្រឹងប្រែងរស់ដើម្បីមួយថ្ងៃជាមួយនឹងការភ័យខ្លាច តក់ស្លុត និងការប៉ះពាល់ផ្លូវចិត្តមាននៅគ្រប់ទីកន្លែង ហើយដែលបានប្រឹងប្រែងផ្សារភ្ជាប់ជីវិតបែកបាក់របស់ខ្លួនក្នុងសង្គមមួយដែលក្រឡាប់ចាក់បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ។

ជោគជ័យក្នុងការព្យាបាលការប៉ះទង្គិចផ្លូវចិត្តនេះ គឺជាជោគជ័យគួរឲ្យកត់សម្គាល់ បើទោះបីជាសញ្ញានៃការប៉ះទង្គិចផ្លូវចិត្តដែលមាននៅឡើយនេះលេចចេញម្តងម្កាលយ៉ាងណាក៏ដោយ ។ តាមការជួបសម្ភាសន៍របស់ខ្ញុំជាមួយ មីងយុំ ដែលប្តីនិងសមាជិកគ្រួសាររបស់មីងជាច្រើននាក់បានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អត្ថបទនេះនឹងបកស្រាយទៅលើវិធីដែលប្រជាជនខ្មែរ ដូចជាពិសោធន៍របស់ មីងយុំ ការប៉ះទង្គិចផ្លូវចិត្តអាចយល់បានតាមរយៈការស្វែងយល់អំពីជីវភាពរស់នៅនិងសកម្មភាពប្រចាំថ្ងៃរបស់ប្រជាជនខ្មែរក្នុងតំបន់នៅក្នុងប្រទេសកម្ពុជា ។ នេះមានន័យថា ការបកស្រាយជំងឺប៉ះទង្គិចផ្លូវចិត្តតាមគំរូឱសថលោកខាងលិចក្នុងការព្យាបាលជំងឺប៉ះទង្គិចផ្លូវចិត្ត ឬជំងឺបាក់ស្បាត មិនបានយល់ពីទិដ្ឋភាពសំខាន់ៗនៃបទពិសោធន៍ជីវិតរបស់ប្រជាជនខ្មែរនោះឡើយ ។

## រឿងរ៉ាវរបស់ យុំ

យុំ ជាស្ត្រីម្នាក់ដែលមានវ័យ៥០ឆ្នាំប្លាយ បានរៀបរាប់រឿងរ៉ាវរបស់ខ្លួនទាក់ទិននឹងការប៉ះទង្គិចផ្លូវចិត្តនេះ ។ ទោះបីជាស្ត្រីមេម៉ាយជាច្រើនដែលរស់នៅក្នុងប្រទេសកម្ពុជា ជាញឹកញាប់ មានសញ្ញាណនៃជំងឺប៉ះទង្គិចផ្លូវចិត្តនេះយ៉ាងណាក៏ដោយ នៅក្នុងភូមិ“បានយ៉ាន” ដែលខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវអំពីជាតិពន្ធ យុំ ជាស្ត្រីម្នាក់ដែលលេចធ្លោជាងគេ ដោយសារតែគាត់ មានភាពឈ្លាសវៃ មានការរាក់ទាក់ និងមានទ្រព្យធនហើយអ្នកភូមិគោរពរាប់អានគាត់ថែមទៀត ។ ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលសង្គមនិយម បន្ទាប់ពីកងទ័ពវៀតណាមបានវាយបណ្តេញខ្មែរក្រហមចេញពីទីក្រុងភ្នំពេញនៅក្នុងខែមករា ឆ្នាំ១៩៧៩ យុំ

ត្រូវបានជ្រើសរើសជាប្រធានសមាគមស្ត្រីមូលដ្ឋាន គាត់មានភារកិច្ចជួយកុមារកំព្រា ស្ត្រីមេម៉ាយ និងគ្រួសារទាហានបាត់ខ្លួន ។ ជាងនេះទៅទៀត យ៉ុំ ក៏មាននាទីជាអ្នកផ្តល់ប្រឹក្សានិងជាអ្នកសម្របសម្រួលដល់គ្រួសារដែលមានទំនាស់ប្តីប្រពន្ធ ដោយរាប់បញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសារផង ។ គេរដំណែលមួយក្នុងចំណោមកេរដំណែលពីសង្គ្រាមស៊ីវិលនិងអំពើហិង្សានៅកម្ពុជានោះគឺ ចំនួននៃគ្រួសារដែលដឹកនាំដោយស្ត្រីនិងទំនាក់ទំនងមិនច្បាស់រវាងស្ត្រីនិងបុរសដោយសារតែអត្រាមរណភាពរបស់បុរសខ្ពស់ជាងអត្រាមរណភាពរបស់ស្ត្រី (ថ្វីបើចំនួននេះមានការធ្លាក់ចុះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ) ។

កេរ្តិ៍ឈ្មោះរបស់ យ៉ុំ ល្បីរន្ទឺនៅក្នុងសហគមន៍របស់គាត់ ព្រោះថាទោះបីជាគាត់ជាស្ត្រីមេម៉ាយក៏ដោយ ក៏កូនស្រីរបស់មីងបានរៀបការត្រឹមត្រូវតាមប្រពៃណី ហើយកូនប្រុសរបស់មីងបានខិតខំរៀនសូត្រធ្វើជាជាងទង ។ម្យ៉ាងវិញទៀត ផ្ទះរបស់មីងមានលក្ខណៈពិសេសជាផ្ទះខ្មែរបុរាណសង់នៅលើសសរធំៗដែលចម្លែកខុសគេនៅក្នុងភូមិដោយចាក់គ្រឹះយ៉ាងមាំក្នុងស៊ីម៉ង់ត៍ ដូចជាយានដ្ឋានមួយប្រភេទអ៊ីចឹង ។ ទោះបីជាការខ្ជះខ្ជាយសាងសង់ផ្ទះនេះ ត្រូវបានប្រើប្រាស់ដោយទ្រព្យធនរបស់កូនប្រសាប្រុសគាត់ក៏ដោយ ក៏មីងមានគំនិតឲ្យកូនប្រសាធ្វើស្រែចម្ការលើដីរបស់គាត់ ដោយជួលកម្មករឲ្យជួយធ្វើម្តងម្កាល ស្របគ្នានោះ យ៉ុំ រកប្រាក់ចិញ្ចឹមជីវិតដោយរៀបចំអាហារថ្ងៃត្រង់ទុកសម្រាប់គ្រូពេទ្យមួយក្រុមនៅមន្ទីរពេទ្យតំបន់ ។ ដោយកម្លាំងជំរុញទឹកចិត្តក្នុងភូមិនិងជាស្ត្រីចំណាស់ដែលត្រូវអ្នកភូមិគោរពនោះ យ៉ុំ បានបួសជាដូនជី បន្ទាប់ពីរៀបការកូនស្រីពៅរបស់គាត់រួច ហើយបច្ចុប្បន្ន យ៉ុំ ចំណាយពេលវេលាច្រើននៅវត្តក្បែរភូមិបានយ៉ាន ជាជាងចំណាយពេលវេលានៅផ្ទះ ។

នៅពេលដែលខ្ញុំបានជួប យ៉ុំ ជាលើកដំបូង ខ្ញុំចាប់អារម្មណ៍នឹងភាពឈ្លាសវៃនិងសេចក្តីគោរពគួរសមរបស់គាត់ ។ យ៉ុំ បាននិយាយដោយទឹកមុខញញឹមរីករាយ ។ ក៏ប៉ុន្តែ ស្នាមញញឹមរបស់គាត់បានរសាយបាត់ទៅវិញ នៅពេលដែល យ៉ុំ ចាប់ផ្តើមនិយាយអំពីសម័យខ្មែរក្រហម ។ ជាញឹកញាប់ យ៉ុំ និយាយរឿងដដែល ហាក់បីដូចជាចង់ប្រាប់ថា គាត់ស្អប់ខ្មែរក្រហមជាទីបំផុត ហើយជីវិតរបស់គាត់នៅពេលនោះជួបការលំបាកខ្លាំងណាស់ ។ យ៉ុំ បាននិយាយទៀតថា «មិនគួរឲ្យជឿសោះថាមានការឈឺចាប់បែបនេះ ។ វាវេទនាពន់ពេកក្រៃ» ។ យ៉ុំ ឈឺចាប់ខ្លាំងនឹងការសម្លាប់ប្តីរបស់គាត់ឈ្មោះ សារួន ជានាយទាហានរបស់ លន់ នល់ ដែលជាបច្ចាមិត្ររបស់ខ្មែរក្រហមនៅក្នុងសម័យសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ។ ដំបូង យ៉ុំ បានរៀបរាប់ប្រាប់ខ្ញុំអំពីការស្លាប់របស់ប្តីគាត់ ដោយសំឡេងរអាក់រអួលបន្តិចហើយមីងបានស្រក់ទឹកភ្នែកពីរ-បីតំណក់ ក៏ប៉ុន្តែគាត់ឆាប់មានអារម្មណ៍ស្ងប់ទៅវិញ ហើយបានរៀបរាប់រឿងរ៉ាវបន្តទៅទៀត ។ យ៉ុំ ប្រៀបដូចជាអ្នកផ្តល់ព័ត៌មានដែលមានឧត្តមគតិម្នាក់ នៅពេលដែលខ្ញុំសួរថា តើមីងអាចផ្តល់បទសម្ភាសន៍ស៊ីជម្រៅជាងមុនខ្លះបានដែរឬទេអំពីជីវិតរបស់មីងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? យ៉ុំ យល់ព្រមតាមសំណូមពរ ។

យ៉ុំ បានចម្រើនវ័យធំធាត់នៅក្នុងខេត្តបាត់ដំបងដែលត្រូវស្គាល់ថាជា«ជង្រុកស្រូវ»របស់កម្ពុជា ពីព្រោះខេត្តបាត់ដំបង ជាតំបន់ប្រមូលផលស្រូវធំជាងគេនៅក្នុងប្រទេសកម្ពុជា ។ កាលពីកុមារភាព យ៉ុំ បានជួបនូវព្រឹត្តិការណ៍សំខាន់ពីរ គឺឪពុកដែល យ៉ុំ ស្រឡាញ់បំផុត បានស្លាប់នៅពេលដែលគាត់អាយុ១២ឆ្នាំ និងប្អូនស្រីគាត់មានជំងឺជាច្រើនឆ្នាំចាប់តាំងពីកើតមកម្ល៉េះ ។ ដោយសារតែព្រឹត្តិការណ៍ទាំងពីរនេះ យ៉ុំ បានឈប់រៀនដើម្បីជួយទ្រទ្រង់គ្រួសារ ។ នៅក្នុងឆ្នាំ១៩៦១ នៅពេលមានអាយុ២០ឆ្នាំ យ៉ុំ បានរៀបការជាមួយនឹង សារួន និងផ្លាស់មករស់នៅក្នុងទីក្រុងភ្នំពេញ ។ នៅទីក្រុងភ្នំពេញ យ៉ុំ ខស្សរាហ៍ឈឺជាញឹកញាប់ ។ យ៉ុំ រស់នៅទីក្រុងភ្នំពេញក្នុងខណៈពេលដែលសហរដ្ឋអាមេរិកពង្រីកសង្គ្រាមនៅក្នុងទឹកដីវៀតណាមកាន់តែខ្លាំងឡើងៗនៅទសវត្សរ៍ឆ្នាំ១៩៦០ ដែលបានជ្រាបចូលបន្តិចម្តងៗមកក្នុងទឹកដីកម្ពុជា ។ នៅពេលនោះ សម្តេច ព្រះនរោត្តម សីហនុ ជាអ្នកដឹកនាំប្រទេសកម្ពុជា ដែលបានប្រកាន់យកអព្យាក្រឹតភាពមិនចូលរួមក្នុងសង្គ្រាមហើយទាមទារឲ្យប្រជាជនកម្ពុជាប្រកាន់យកជំហរអព្យាក្រឹតដូចព្រះអង្គដែរ ។ សម្តេច ព្រះនរោត្តម សីហនុ ត្រូវបានទម្លាក់ចេញពីអំណាចដោយសេនាប្រមុខ លន់ នល់ នៅក្នុងឆ្នាំ១៩៧០ ដែលជាព្រឹត្តិការណ៍មួយបង្កឲ្យមានការតវ៉ា

ប្រឆាំងយ៉ាងខ្លាំងក្លា ហើយបានដឹកនាំប្រជាជនកម្ពុជារាប់ម៉ឺនរាប់សែននាក់ដែលគាំទ្រសម្តេច ព្រះនរោត្តម សីហនុ ឲ្យងាកមកចូលរួមចលនាជាមួយខ្មែរក្រហមវិញ ។ រយៈពេលប្រាំឆ្នាំក្រោយមកខ្មែរក្រហមបានហ៊ុមព័ទ្ធទីក្រុងភ្នំពេញនិងមណ្ឌលពាណិជ្ជកម្មដទៃទៀតនៅក្នុងទីក្រុងដែលគ្រប់គ្រងដោយសេនាប្រមុខ លន់ នល់ ពេលនោះ យុំ បានឃើញទីក្រុងភ្នំពេញពោរពេញទៅដោយប្រជាជនខ្មែររត់ភៀសខ្លួនគេចពីសង្គ្រាម ដែលភាគច្រើននៃអ្នកទាំងនោះរស់នៅក្នុងភាពក្រីក្រតោកយ៉ាកបំផុត ។ យុំ មានវាសនាល្អជាងគេ ។ ទោះបីជា យុំ និង សារួន ត្រូវបានផ្លាស់ទៅរស់នៅជិតបេះដូងទីក្រុងភ្នំពេញដើម្បីគេចពីគ្រាប់កាំភ្លើងសត្រូវក៏ដោយក៏ យុំ នៅតែមានគំនិតជួញដូរ ។ យុំ បានធ្វើឲ្យជីវភាពគ្រួសាររស់នៅប្រកបដោយជាសុខសមរម្យ ។


រូបគំនូរដោយ ៖ វ៉ាន់ ណាត អតីតអ្នកទោសគុកទួលស្លែង(ស-២១)

នៅពេលដែលខ្មែរក្រហមជាក្រុមឧទ្ទាមប្រកាន់លទ្ធិម៉ៅ ដឹកនាំដោយ ប៉ុល ពត ចូលដល់ទីក្រុងភ្នំពេញ ដោយជោគជ័យ នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ អ្វីៗត្រូវផ្លាស់ប្តូរទាំងស្រុង ។ ភ្លាមៗនោះដែរ ខ្មែរក្រហមបានចាប់ផ្តើមប្រែក្លាយសង្គមកម្ពុជាទាំងមូលដោយបានប្រាប់ឲ្យប្រជាជនខ្មែរទាំងអស់ជម្លៀសខ្លួនចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទ ។ យុំ ចាំបានថា នៅពេលដែលកងទ័ពខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ សារួន កំពុងតែយាមល្បាតក្នុងឯកសណ្ឋានជាទាហាន ។ កម្មាភិបាលខ្មែរក្រហមបានបញ្ជា សារួន ឲ្យដោះឯកសណ្ឋានចេញ ។ ខ្មែរក្រហមក៏បាញ់ចំបន្ទោះជើងរបស់គាត់ទាំងពីរ និងបាញ់ទៅលើម៉ូតូដែលគាត់ជិះយាមល្បាតរាល់ថ្ងៃ ។ សារួន បានដោះឯកសណ្ឋានចេញនិងវិលត្រឡប់មកផ្ទះរបស់បងគាត់វិញ [ដែលយើងទាំងពីរនាក់រស់នៅ] ។ ចាប់តាំងពីថ្ងៃនោះមក ខ្មែរក្រហមបានបញ្ជាប្រជាជនទាំងអស់ឲ្យចាកចេញពីទីក្រុងភ្នំពេញដោយបានគំរាមកំហែងថានឹងសម្លាប់អ្នកណាដែលរឹងទទឹងមិនព្រមចាកចេញទៀតផង ។

គ្រួសារ យុំ បានចូលរួមដំណើរជាមួយនឹងប្រជាជនរាប់សែននាក់ទៀតចាកចេញពីទីក្រុងភ្នំពេញយ៉ាងសន្សឹមៗក្រោមកម្តៅថ្ងៃដ៏ក្តៅហែង ។ យុំ បានបន្តទៀតថា «យើងប្រញាប់ប្រញាល់រៀបចំរបស់របរយកទៅដាក់ក្នុងរថយន្តបងប្រុសរបស់ប្តីខ្ញុំមុនពេលយើងចាកចេញ ។ ពិតហើយ យើងបានចំណាយពេលយូរណាស់ទើបចាកចេញផុតពីទីក្រុងភ្នំពេញ ។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងមិនអាចធ្វើដំណើរបានឆ្ងាយឡើយ» ។ នៅតាមផ្លូវប្រជាជនដែលត្រូវបានជម្លៀសបានឃើញទិដ្ឋភាពជាច្រើនដូចជាមនុស្សជាច្រើនម៉ឺននាក់កំពុងប្រជ្រៀតគ្នានៅតាមផ្លូវដែលណែនតាន់តាប់ អ្នកជំងឺដែលស្នាក់នៅមន្ទីរពេទ្យត្រូវបានសែងដាក់លើគ្រែនិងកៅអីរុញចេញពីមន្ទីរពេទ្យ សាកសពហើមស្អុយរលួយដោយសង្គ្រាម ស្ត្រីកំពុងតែសម្រាលកូននៅលើចិញ្ចើមផ្លូវនិងការសម្លាប់មនុស្ស ។

អស់រយៈពេល១០ថ្ងៃ ទើបក្រុមគ្រួសាររបស់ យុំ បានមកដល់ជ្រោយអម្ពិល ដោយឃ្លានអាហារនិងនឿយហត់យ៉ាងខ្លាំង ។ នៅភូមិជ្រោយអម្ពិល ក្រុមគ្រួសាររបស់ យុំ ពុំត្រូវបានផ្តល់អង្ករឬអ្វីផ្សេងៗនោះឡើយ គឺត្រូវដោះស្រាយបញ្ហាទាំងនេះដោយខ្លួនឯង ។ គ្រួសារ យុំ បានយល់ដឹងយ៉ាងរហ័សអំពីពិតភាពនៃការបោកប្រាស់ ការនិយាយបំភ័ន្ត ភាពតក់ស្លុត និងអំពើហិង្សាដែលប្រជាជនកម្ពុជាឆ្លងកាត់ជាងបីឆ្នាំកន្លះ ។

បន្ទាប់ពីយើងបានមកដល់ភូមិជ្រោយអម្ពិល ខ្មែរក្រហមបានប្រកាសថា «អ្នកដែលជានាយទាហានក្នុងរបបមុននឹងមាន

តំណែងដដែល[ក្នុងរបបថ្មីនេះ] ហើយនឹងវិលត្រឡប់ទៅកាន់កន្លែងធ្វើការរបស់ខ្លួនវិញ» ។ ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅស្នាក់នៅក្នុងផ្ទះដ៏ធំមួយរបស់លោកយាយម្នាក់ ។ លោកយាយពុំមានសារុងសម្រាប់ស្លៀកឡើយ គាត់បានសុំសារុងមួយពីខ្ញុំ ហើយខ្ញុំក៏បានជូនសារុងមួយដល់គាត់ ។ បន្ទាប់ពីបានសារុង លោកយាយបានខ្សឹបប្រាប់ខ្ញុំថា «ប្រសិនបើចៅមានតំណែងពីមុន ចៅកុំប្រាប់ពួកវាឲ្យសោះ ។ អ្នកណាម្នាក់ប្រាប់ពួកវាថាមានតំណែងពីមុន អ្នកនោះត្រូវពួកវាយកទៅសម្លាប់ចោលជាមិនខាន» ។ ដោយហេតុនេះ ខ្ញុំមិនបានបណ្តែតបណ្តោយឲ្យប្តីរបស់ខ្ញុំនិយាយប្រាប់[ខ្មែរក្រហមឡើយ] ។ ក៏ប៉ុន្តែ នៅពេលដែលខ្ញុំនិយាយប្រាប់បងថ្លៃប្រុសរបស់ខ្ញុំអំពីរឿងនេះ គាត់ជាវរសេនីយ៍ឯកក្នុងរបបចាស់ គាត់ពុំជឿខ្ញុំទេ ។ គាត់និយាយថា «គ្មានទេក្នុងលោកនេះដែលខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯងនោះ» ។ គាត់បាននិយាយការពិតប្រាប់ខ្មែរក្រហមនៅវេលាព្រឹក ។ នៅវេលាល្ងាចថ្ងៃនោះ ខ្មែរក្រហមបានចាប់បញ្ជូនគាត់ទៅ «រៀនសូត្រ» ហើយគាត់ត្រូវខ្មែរក្រហមសម្លាប់ក្នុងពេលនោះតែម្តង ។


រូបគំនូរដោយ : វ៉ាន់ ណាត អតីតអ្នកទោសគុកទួលស្លែង(ស-២១)

ហ៊ីនគុន : តើអ្នកមីងមានអារម្មណ៍យ៉ាងដូចម្តេចដែរ?

ខ្ញុំតក់ស្លុតយ៉ាងខ្លាំង តែខ្ញុំមិនហ៊ានយំឡើយ ។ ប្រសិនបើអ្នកតក់ស្លុតក៏ដោយ ក៏អ្នកមិនហ៊ានយំដូចនេះដែរ ។ អ្វីដែលអ្នកឈឺចាប់ អ្នកមិនហ៊ាននិយាយអ្វីទាំងអស់ ។ ប្រពន្ធបងថ្លៃរបស់ខ្ញុំបានយំនៅពេលដែលខ្មែរក្រហមយកប្តីគាត់ទៅ ។ គាត់តែងតែស៊ើបសួរព័ត៌មានអំពីប្តីរបស់គាត់ជានិច្ច ដោយហេតុនេះ ខ្មែរក្រហមបានយកគ្រួសាររបស់មីងទាំងមូលទៅសម្លាប់...។ វាដូចជាពាក្យស្លោក[ខ្មែរក្រហម]ថា «ដកស្មៅត្រូវដកទាំងឫស» ។ នេះមានន័យថាពួកវាត្រូវសម្លាប់ឲ្យផុតពូជ សូម្បីតែម្នាក់ក៏មិនត្រូវទុកឲ្យនៅរស់ដែរ ។

បន្ទាប់ពីរឿងរ៉ាវដ៏សោកសៅនេះ គ្រួសាររបស់ យុំ ត្រូវខ្មែរក្រហមបញ្ជូនទៅកាន់ភូមិមួយទៀតគឺភូមិព្រែកពោធិ៍ ។ នៅក្នុងភូមិ កម្មាភិបាលមូលដ្ឋានបានស្រាវជ្រាវប្រវត្តិរូបប្រជាជនដដែល និងប្រកាសថាអតីតទាហាន លន់ នល់ នឹងទទួលបាននូវមុខតំណែងដដែលនៅក្នុងរបបថ្មីនេះ ។ អ្នកភូមិដែលមានវ័យចំណាស់បានប្រាប់ យុំ ឲ្យនិយាយកុហកប្រាប់ខ្មែរក្រហមថា ប្តីរបស់គាត់ជាអ្នកធាក់ស៊ីក្លូ ។ យុំ និងប្តីបាននិយាយកុហកដូចនេះ តែកម្មាភិបាលមូលដ្ឋាន «មិនជឿ ។ ខ្មែរក្រហមបានត្រៀមខ្លួនយកប្តីរបស់ យុំ ទៅមន្ទីរស្រុក នៅពេលនោះអ្នកភូមិដែលមានវ័យចំណាស់បានជួយនិយាយថាប្តីរបស់ យុំ ជាអ្នកធាក់ស៊ីក្លូនិងអ្នកយាមផ្ទះឲ្យអ្នកមានម្នាក់ពិតប្រាកដមែន ។ ដោយសារតែមានការជួយជ្រោមជ្រែងពីអ្នកភូមិ ប្តីរបស់ យុំ ក៏ត្រូវខ្មែរក្រហមដោះលែង» ។

មិនយូរប៉ុន្មាន យុំ ដឹងថាអ្វីទៅជាគ្រោះកម្មរបស់ប្តីគាត់ ។ ក្នុងខណៈពេលដែល យុំ ធ្វើដំណើរតាមផ្លូវកាត់ឆ្លងកាត់តាមព្រៃមួយរំពេចនោះ យុំ ក៏បានជួបប្រទះនឹងជំរំមួយមានសុទ្ធតែអតីតទាហានលន់នល់ ដែលត្រូវខ្មែរក្រហមឃុំខ្លួនមុនពេលយកទៅសម្លាប់ ។ យុំ បាននិយាយប្រាប់ខ្ញុំថា «ទាហានទាំងនោះ មានរាងកាយស្គមស្គាំង ដោយសារតែគ្មានអាហារបរិភោគ ។ មានទាហានប្រមាណបីរយនាក់កំពុងអង្គុយក្នុងជំរំនោះ ។ ខ្ញុំមានអារម្មណ៍តក់ស្លុតយ៉ាងខ្លាំង រហូតដល់ជង្គង់របស់ខ្ញុំទាំងពីរខ្សោយស្ទើរតែគ្មានកម្លាំងទប់ ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចថា បើឆ្មាំយាមទាហានឃើញខ្ញុំ មុខជាសម្លាប់ខ្ញុំមិនខាន ដូច្នេះបានជាខ្ញុំរត់គេច ។ ក៏ប៉ុន្តែ

ឆ្មាំម្នាក់បានឃើញខ្ញុំ ហើយសួរខ្ញុំថា *«តើអ្នកទៅណាហ្នឹង? តើហេតុអ្វី បានជាអ្នកមកដល់ទីនេះ?»* ខ្ញុំបានឆ្លើយប្រាប់គាត់ថា *«ខ្ញុំកំពុងតែធ្វើដំណើរត្រឡប់ទៅផ្ទះរបស់ខ្ញុំវិញក៏ស្រាប់តែវង្វេងផ្លូវ»* ។ ឆ្មាំយាមនោះ បានចង្អុលប្រាប់ខ្ញុំឲ្យធ្វើដំណើរទៅទិសខាងស្តាំ ហើយខ្ញុំក៏បានធ្វើដំណើរចេញទៅតាមទិសខាងស្តាំនោះ ។

ភូមិចុងក្រោយដែលគ្រួសាររបស់ យុំ ផ្លាស់មកនោះ គឺភូមិអម្ពិលក្រញាញ់ ដែលជាភូមិមួយនៅជិតនឹងភូមិបានយ៉ាន ក្នុងខេត្តកំពង់ចាម ។ យុំ និងគ្រួសារបានស្វែងយល់ឃើញដោយខ្លួនឯងថា ខ្លួនកំពុងតែរស់នៅក្នុងសង្គមដ៏ចម្លែកខុសគេមួយដែលគ្មានការចាយប្រាក់ គ្មានផ្សារ គ្មានតុលាការ គ្មានប្រព័ន្ធទូរគមនា-គមន៍ គ្មានស្ថានីយប្រៃសណីយ៍ ឬគ្មានវត្តអារាម ។ ក្នុងទិសដៅសម្រេចឲ្យបាននូវដំណើរ «មហាលោតផ្លោះ» ដែលជាលទ្ធិកុម្មុយនីស្តរបស់ខ្លួនហើយដែលការលោតផ្លោះនោះ ដើរលឿនជាងការគ្រប់បដិវត្តន៍សង្គមទាំងអស់ ខ្មែរក្រហមបានលុបបំបាត់ចោលអ្វីៗទាំងអស់ដែលអាចនាំឲ្យមាន «ឯកជននិយម» និងដែលនាំឲ្យអន្តរាយដល់ការបង្កើតសង្គមបដិវត្តន៍ ។ ខ្មែរក្រហមបានប្រមែប្រមូលផលិតកម្មសេដ្ឋកិច្ចភាពជាម្ចាស់កម្មសិទ្ធិ និងសម្ភារប្រើប្រាស់ឬម្ហូបអាហារដាក់ជារួមទាំងអស់ ដោយបង្ខំប្រជាជន ដូចជា យុំ ជាដើម ឲ្យធ្វើការងារជាច្រើនម៉ោងគ្មានពេលសម្រាកហើយទទួលបានរបបអាហារតិចបំផុត ។ យុំ បាននិយាយថា *«ខ្ញុំស្គមស្គាំងអត់ឃ្លានមិនបានទេ ព្រោះអីវាធ្វើឲ្យខ្ញុំឈឺចាប់ខ្លាំងណាស់ក្មួយ»* ។ ជួនកាលបាយប្រាំកំប៉ុងចែកគ្នាហូប៥០០នាក់ ។ វាពិតជាវេទនាខ្លាំងណាស់ ។ អ្នកខ្លះដាំដំណាំដូចជា ដំឡូងពោតនៅក្បែរខ្ទមរបស់ខ្លួន ប៉ុន្តែពុំត្រូវបានអនុញ្ញាតឲ្យបរិភោគឡើយ ។ អ្នកដែលបរិភោគនឹងត្រូវបញ្ជូនទៅរៀនសូត្រ សូម្បីតែប្រធានសហករណ៍ ជួនកាលក៏ចែករំលែកអាហារតែជាមួយ «ប្រជាជនចាស់» ដែលជាប្រជាជនធ្លាប់បានរស់នៅក្នុងតំបន់ខ្មែរក្រហមក្នុងអំឡុងសម័យសង្គ្រាមស៊ីវិល ។ ភាពអយុត្តិធម៌បែបនេះ បង្ហាញឲ្យឃើញអំពីវិធីបង្វិលឋានានុក្រមក្នុងសង្គមឲ្យវិលបញ្ច្រាសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអ្នកក្រជំនួសអ្នកមាន ហើយមនុស្សវ័យក្មេងជំនួសមនុស្សវ័យចំណាស់ក្នុងគោលដៅសម្រេចបាននូវសង្គមថ្មីមួយ ។ ប្រជាជនដែលត្រូវជម្លៀសចេញពីទីក្រុងត្រូវបានចាត់ទុកជា «ប្រជាជនថ្មី» ដែលជាទូទៅពុំមានសិទ្ធិ មានតែការឈឺចាប់ និងត្រូវបានសម្លាប់ច្រើនជាង «ប្រជាជនចាស់» ។ ទោះយ៉ាងណាក៏ដោយ ទាំងប្រជាជនថ្មីនិងប្រជាជនចាស់ សុទ្ធតែរងទុក្ខវេទនាទាំងអស់ក្នុងរបបខ្មែរក្រហម ដែលរបបនេះបានលុបបំបាត់ចោលទាំងស្រុងនូវសេរីភាពក្នុងការនិយាយស្តី និងរាល់ទំនាក់ទំនងផ្សេងៗ ដោយបានដាក់កម្រិតលើការរៀបការហាមឃាត់មិនឲ្យមានការគោរពព្រះពុទ្ធសាសនា បែកបាក់គ្រួសារ និងចុងក្រោយបំផុតនោះ គឺគ្រប់គ្រងលើអ្វីដែលប្រជាជនគិត និយាយ ឬធ្វើថែមទៀត ។

ទិសដៅសំខាន់របស់ខ្មែរក្រហម គឺការបង្កើតនូវសង្គមបដិវត្តន៍ដែលពោរពេញទៅដោយសតិអារម្មណ៍ «ជឿនលឿន» ។ ជនដែលមានសតិអារម្មណ៍បែបនេះ ត្រូវធ្វើការឥតឈប់ឈរនិងគ្មានការសង្ស័យ ដើម្បីកសាងនិងការពារសណ្តាប់ធ្នាប់សង្គមថ្មីដែលជំរុញដំណើរមហាអស្ចារ្យ មហាលោតផ្លោះ ឆ្ពោះទៅកាន់សង្គមបរិសុទ្ធ ។ ក៏ប៉ុន្តែនៅពេលដែលផែនការសេដ្ឋកិច្ចរបស់បក្សដ៏ក្លាហាន និងដែលដឹងអ្វីៗទាំងអស់ចាប់ផ្តើមបរាជ័យនោះ មេដឹកនាំខ្មែរក្រហមដែលសង្ស័យអំពីផែនការនិងរដ្ឋប្រហារដែលត្រូវបានគ្រោងទុករួចទៅហើយនោះ បានទម្លាក់កំហុសអំពីបរាជ័យផែនការនេះទៅលើគំនិតវិទ្ធង្សនា មិនបានទម្លាក់កំហុសការបរាជ័យទៅលើផែនការដែលមានបញ្ហាមិនពិតប្រាកដនិងមិនប្រាកដនិយមផ្ទាល់របស់ខ្លួននោះឡើយ ។

ឆ្លើយតបទៅនឹងបញ្ហានោះ ប៉ុល ពត និងសមាជិករបស់ខ្លួនបានធ្វើវិសុទ្ធកម្មស្វែងរក «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» ចាប់ពីពួកក្បត់ដែលមានឋានៈនៅក្នុងបក្សរហូតដល់ធាតុដែលមិនជឿនលឿនដែលមាននៅក្នុងមហាជន ជាពិសេសប្រជាជនថ្មីៗ ។ ក៏ដូចគ្នានឹង យុំ ដែរ ជាប្រជាជនថ្មីដែលមកពីទីក្រុងភ្នំពេញ ម៉ម ធីតា បាននៅចាំបញ្ជីឈ្មោះសម្លាប់របស់ខ្មែរក្រហមថា ៖

*អតីតទាហាន ប៉ូលិស សេ.អ៊ី.អា និង កា.ហ្សេ.បេ មានទោសឧក្រិដ្ឋដោយបានចូលរួមប្រយុទ្ធក្នុងសង្គ្រាមស៊ីវិល ។ ពួកឈ្មួញពួកពាណិជ្ជករ និងពួកមូលធន មានទោសឧក្រិដ្ឋដោយបានកេងប្រវ័ញ្ចលើប្រជាជនក្រីក្រ ។ កសិករមានធននិងម្ចាស់ដី មានទោសឧក្រិដ្ឋដោយបានកេងប្រវ័ញ្ចប្រជាកសិករក្រីក្រ ។ អ្នកចេះដឹង*

គ្រូពេទ្យ មេធាវី ព្រះសង្ឃ គ្រូបង្រៀន និងមន្ត្រីរដ្ឋការ មានសតិ និងគំនិតប្រឡាក់ដាប់នឹងពួកបស្ចិមប្រទេសដែលជាពួកបិសាច ។ និស្សិត ត្រូវបានអប់រំឲ្យចេះកេងប្រវ័ញ្ចអ្នកក្រ ។ អតីតជនល្បីល្បាញនិងកវីនិពន្ធមានសតិអារម្មណ៍នឹងសង្គមកម្ពុជាចាស់ដែលពុករលួយ...។ បញ្ជីឈ្មោះមានតទៅទៀត ។ ពួកបះបោរ ពួកបុគ្គលនិយម ពួកពាក់វ៉ែនតា ពួកចេះអានអក្សរ...និងពួកដែលមានដៃទន់ ។ អ្នកទាំងនេះ មានគំនិតពុករលួយនិងរស់នៅដោយកេងប្រវ័ញ្ចញើសឈាមកសិករ ។ មានមនុស្សតិចណាស់ដែលគេចផុតពីឈ្មោះដែលមានក្នុងបញ្ជី ។

ក្នុងខណៈពេលដែលការធ្វើវិសុទ្ធកម្មនិងរោគឆ្កួតជ្រុលហួសហេតុ មានសភាពកាន់តែខ្លាំងឡើង សកម្មភាពបំភិតបំភ័យ និងសម្លាប់បានក្លាយទៅជាទម្លាប់មួយនៃជីវិតរស់នៅរបស់ប្រជាជនកម្ពុជានៅពេលនោះ ។

ដើម្បីជីកកកាយស្វែងរកខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ខ្មែរក្រហមបានចុះស្រាវជ្រាវប្រវត្តិរូបប្រជាជននៅតាមមូលដ្ឋានតែម្តង ។ នៅក្នុងភូមិអម្ពិលក្រញាញ់ កម្មាភិបាលមូលដ្ឋានបានសួរអំពីតួនាទីប្តីរបស់ យុំ និងបងប្អូនប្រុសប្តីគាត់ជាច្រើននាក់ ដែលជាអតីតទាហានលន់នល់ ។ យុំ បានចាំថាខ្មែរក្រហមបានប្រើប្រាស់គ្រប់វិធីសាស្ត្រសួរប្តីរបស់គាត់ អំពីការងារដែលគាត់បានធ្វើនៅក្នុងរបបលន់នល់ ។ យុំ បាននិយាយថា «នៅពេលដែលពួកវាសួរខ្ញុំ ខ្ញុំឆ្លើយប្រាប់ថា គាត់ធាក់ស៊ីក្លូនិងយាមផ្ទះឲ្យគេ ។ ពួកវាបានសួរខ្ញុំទៀតថា បើដូច្នេះ តើហេតុអ្វីបានជាដៃជើង និងមុខមាត់របស់ប្តីអ្នកស្រស់ស្អាតម្ល៉េះ? ខ្ញុំបានឆ្លើយថា ប្រសិនបើគាត់ស្រស់ស្អាតដូចនេះមែននោះ តើគាត់អាចធ្វើអីបានទៅ?» ។ ភ្លាមៗនោះដែរ ខ្មែរក្រហមបានសួរពិសោធប្តីរបស់ យុំ ចង់ដឹងថាតើគាត់ពិតជាមកពីជនបទដូចដែល យុំ បានឆ្លើយដែរឬទេ ។ យុំ បានបន្តទៀតថា ÷

ដំបូង ពួកវាបានធ្វើពិសោធប្តីខ្ញុំ ដោយចង់ដឹងថាតើគាត់ចេះប្រើនង្គ័លដែរឬទេ? បន្ទាប់មក ពួកវាបានឲ្យគាត់ជួសជុលនង្គ័ល និងភ្ជួរស្រែ ។ «ប្រសិនបើសមមិត្តពិតជាមកពីជនបទមែន សមមិត្ត ប្រាកដជាចេះប្រើនង្គ័លជាមិនខាន» ។ ប្តីខ្ញុំបានមើលអ្នកដែលកំពុងភ្ជួរស្រែដោយយកចិត្តទុកដាក់ ហើយអាចភ្ជួរស្រែបានដូចអ្នកទាំងនោះដែរ ។ មួយសន្ទុះក្រោយមក ខ្មែរក្រហមបានសាកល្បងគាត់ម្តងទៀត ដោយឲ្យគាត់ធ្វើផ្ទះ ។ ប្តីខ្ញុំក៏បានសង់ផ្ទះនោះដោយជោគជ័យ ។ ក្រោយមកទៀត ពួកវាបានឲ្យគាត់ទៅផ្សាំងគោ ។ គាត់បានប្រឹងប្រែងដោយលំបាក ក៏គាត់នៅតែអាចផ្សាំងគោបាន ។ ការផ្សាំងគោពិតជាពិបាកខ្លាំងណាស់ប្រសិនបើយើងមិនធ្លាប់កាន់គោទេនោះ ។ យើងមិនអាចបង្ក្រាបគោបានទេ ។ ក៏ប៉ុន្តែ គាត់បានព្យាយាមម្តងហើយម្តងទៀត រហូតដល់គាត់អាចបង្ក្រាបគោបាន ។ បន្ទាប់មក ពួកវាបានឲ្យគាត់ដើរបេះផ្លែឈើនិងរកបន្លែ និងប្រមូលផ្លែខ្នុរ ។ ប្តីខ្ញុំ និងមនុស្ស១៥នាក់ទៀតត្រូវច្រូតកាត់ដីស្រែមួយហិកតា គាត់ក៏អាចធ្វើបានដែរ ។ ខ្មែរក្រហមបានឲ្យគាត់លើកទំនប់ព័ទ្ធជុំវិញស្រែ ។ នៅពេលដែលលើកទំនប់រួច ពួកវាបានបញ្ជូនគាត់ឲ្យទៅដាំបាយធ្វើម្ហូបបួនប្រាំយប់ ។ បន្ទាប់មក គាត់ត្រូវពួកវាបញ្ជូនឲ្យមកកាប់គាស់ដីតាមផែនការស្រោចស្រព គឺមួយព្រឹកកាប់គាស់ឲ្យបានមួយម៉ែត្រគូបមួយ រសៀលកាប់គាស់ឲ្យបានមួយម៉ែត្រគូប និងមួយល្ងាចកាប់គាស់ឲ្យបានមួយម៉ែត្រគូប ។

ក្នុងពេលនោះ ពួកវាបានចោទប្តីខ្ញុំថាជាទាហានលន់នល់ ។ អ្នកដែលស្គាល់គាត់បានរាយការណ៍ឲ្យពួកវា ។ ខ្មែរក្រហមបានធ្វើការស្រាវជ្រាវ ។ យើងបានវិលត្រឡប់ទៅកាន់ស្រុកកំណើតរបស់ប្តីខ្ញុំវិញ ។ ពួកវាបានដឹកមនុស្សដែលមកពីភូមិបានយ៉ាន ។ ប្រជាជនដែលមកពីភូមិបានយ៉ានស្គាល់ប្តីខ្ញុំ ។ អ្នកដែលស្អប់ប្តីខ្ញុំមិនដឹងថាអ្នកណានោះទេ បាននិយាយប្រាប់ [កម្មាភិបាលមូលដ្ឋាន] ថាប្តីរបស់ខ្ញុំជាទាហានលន់នល់ ។ ដោយសារតែប្តីរបស់ខ្ញុំបានឆ្លងផុតការពិសោធន៍ ជាច្រើនលើកមកហើយនោះ [កម្មាភិបាលខ្មែរក្រហម] បានគិតថាគាត់មិនមែនជាទាហានលន់នល់ ។ ដូចនេះ ពួកវាបានស៊ើបអង្កេតបន្ថែម និងជាចុងក្រោយ ពួកវាជឿថាប្តីខ្ញុំជាអតីតទាហានលន់នល់ ។

ដោយហេតុដូចនេះ ពួកវាបានហៅប្តីខ្ញុំទៅសួរចម្លើយ ។ នៅពេលដែលពួកវាសួរប្តីខ្ញុំអំពីការចោទប្រកាន់នេះ គាត់បានបដិសេធថាគាត់មិនមែនជាទាហានលន់នល់ទេ ដោយនិយាយថាគាត់យាមផ្ទះឲ្យគេ និងធាក់ស៊ីក្លូនៅពេលទំនេរ ។ បន្ទាប់ពីការសួរចម្លើយនេះ ពួកវាបានបញ្ជូនគាត់ទៅភ្ជួរស្រែ ជីកដី និងក្រោយ

មកទៀតបានទៅដកស្ទូង ។ នៅខែមេសា ពួកវាបានសម្រេចសម្លាប់គាត់តែម្តង ។

ដូចដែលការធ្វើពិសោធន៍ប្តីខ្ញុំបានបង្ហាញឲ្យឃើញថា ខ្មែរក្រហមមានចេតនាដឹកកកាយរកខ្មាំងបង្កប់ក្នុងមហាជន ។


កុយ ធួន

អតីតទាហានលន់នល់ ស្ថិតក្នុងលំដាប់ជិតកំពូលនៃបញ្ជីឈ្មោះសម្លាប់ ។ តាមចម្លើយសារភាពឆ្នាំ១៩៧៧របស់ ស្រេង ដែលជាអនុលេខាភូមិភាគឧត្តររស់នៅភូមិអម្ពិលក្រញាញ់ដែរនោះ បានរៀបរាប់អំពីវិធីធ្វើបញ្ជីឈ្មោះខ្មាំងដែលជាប់សង្ស័យទាំងនេះថា ត្រូវបានរៀបចំឡើងលំដាប់ពីប្រជាជនសាមញ្ញដល់មន្ត្រីថ្នាក់ខ្ពស់ ជាញឹកញាប់រកឃើញនៅមន្ទីរភូមិភាគដែលជាអ្នកសម្រេចអំពីអ្នកដែលត្រូវយកទៅសម្លាប់ ។


កងទ័ពខ្មែរក្រហម

តំបន់មូលដ្ឋានអនុវត្តឲ្យបានជោគជ័យតាមទិសដៅរបស់បក្សក្នុងការកម្ទេចពួកនាយទាហាន ។ គ្រប់តំបន់ទាំងអស់ ត្រូវអនុវត្តតាមទិសដៅរបស់បក្សក្នុងការកម្ទេចថ្នាក់អគ្គមេបញ្ជាការ មេបញ្ជាការ ថ្នាក់មូលដ្ឋាន និងមេបញ្ជាការថ្នាក់ក្រោម និងបន្ទាប់មកចុះមកដល់ទាហានដែលមានក្នុងបញ្ជី (ទាហានដែលសកម្ម) ដែលភូមិភាគបានកំណត់ ក៏ត្រូវលុបបំបាត់ចោលដែរ ។ មានកម្លាំងដ៏មានអានុភាពដែលទាក់ទិននឹងបញ្ហានេះ គឺគ្រប់តំបន់ទាំងអស់ ត្រូវធ្វើបញ្ជីឈ្មោះឲ្យបានច្រើនដែលត្រូវស្នើដល់ភូមិភាគ និងត្រូវបែងចែកបញ្ជីទាំងនោះ ។ សកម្មភាពស្រាវជ្រាវនាយទាហានទាំងនេះ ត្រូវបន្តឲ្យបានម៉ឺងម៉ាត់រហូតដល់ពេលបច្ចុប្បន្ន... ។ នាយទាហានទាំងនោះត្រូវបានរកឃើញពុំមែនដោយសារគណៈកម្មាធិការភូមិភាគស្គាល់អ្នកទាំងនោះជានរណានោះទេ ក៏ប៉ុន្តែអ្នកទាំងនោះត្រូវបានរកឃើញតាមរយៈការសួរនិងការស៊ើបអង្កេតរបស់ប្រជាជនមូលដ្ឋាន ។


យុវនារីសិល្បៈខ្មែរក្រហម

នេះជាការពិតនៃអ្វីដែលបានកើតឡើងចំពោះប្តីរបស់ យុំ ។ នៅពេលនោះ ប្អូនប្រុសពៅរបស់ប្តី យុំ ដែលខ្មែរក្រហមមិនបានដឹងថាមានជាប់ “ខ្សែគ្រួសារ” នឹងទាហានលន់នល់ មានតួនាទីនៅឯមន្ទីរសន្តិសុខស្រុក ។ នៅថ្ងៃមួយក្នុងឆ្នាំ១៩៧៦ មន្ទីរសន្តិសុខបានទទួលសំបុត្រណែនាំឲ្យក្រុមគាត់ទៅសម្លាប់ប្តីរបស់ យុំ និងបងថ្លៃប្រុសពីរនាក់ទៀត ដែលអ្នកទាំងអស់នោះជាអតីតទាហានលន់នល់ ។ យុំ បានពន្យល់ប្រាប់អំពីរបៀបដែល នីម បានប្រាប់ពួកគេអំពីសំបុត្រនោះ និងវិធីដែលគាត់ដឹកកាំភ្លើង គ្រាប់រំសេវ និងស្រូវ ដូចនេះ ពួកគេទាំងអស់គ្នាអាចរត់គេចនៅក្នុងពេលយប់ “នីម បានមកនិយាយប្រាប់យើងថា “បង [បងប្រុស] នៅវេលាម៉ោង៩យប់នេះ ថ្នាក់លើនឹងផ្ញើសំបុត្រមួយច្បាប់ណែនាំឲ្យខ្ញុំសម្លាប់បងហើយ... បងសូមបងរង់ចាំខ្ញុំនៅឯផ្ទះ ។ យើងមិនត្រូវទុកឲ្យពួកវាសម្លាប់យើងឡើយ ។ យើងទាំងអស់គ្នានឹងរត់គេចជាមួយគ្នា [នៅម៉ោង៩យប់នេះ] ។ ប្រសិនបើយើងស្លាប់នៅទីកន្លែងណាមួយនោះហើយជាពេលដែលយើងនឹងត្រូវស្លាប់” ។

ក្នុងពេលដែល យុំ និយាយរ៉ាយរ៉ាប់អំពីពេលវេលាដ៏ឈឺចាប់នេះ យុំ បានចាប់ផ្តើមយំ និងនិយាយដោយរអាក់រអួលថាគាត់មិនចង់និយាយរឿងរ៉ាវដែលបានកើតឡើងនេះទៀតទេ ។ សូម្បីតែពេលដែល យុំ និយាយ ខ្ញុំខិតខំបញ្ចប់ការសម្ភាសន៍នេះ តែ យុំ នៅតែបន្តរ៉ាយរ៉ាប់អំពីរឿងរ៉ាវរបស់គាត់ដោយមិនបានស្តាប់អ្វីដែលខ្ញុំកំពុងតែនិយាយនោះឡើយ ៖

នៅពេលដែលខ្ញុំគិតអំពីរឿងនេះ ខ្ញុំមិនចង់និយាយរឿង ដែលខ្ញុំបែកបាក់ពីប្តីខ្ញុំ និងអំពីគ្រួសាររបស់ខ្ញុំដែលបែកបាក់នោះទេ ។ មុនពេលដែលពួកគាត់ចាកចេញទៅភ្លៀងកំពុងតែធ្លាក់ ហើយពួកគាត់កំពុងតែយាមផ្ទះ ។ នៅពេលដែល [ខ្មែរក្រហម] មកយកប្តីខ្ញុំទៅសម្លាប់ខ្ញុំបាននិយាយកុហកពួកវាថា “គាត់បានចេញទៅកាប់ចេកហើយ” ។ ពួកវាបានចូលទៅឆែក

នៅក្នុងផ្ទះ ។ នៅពេលដែលប្តីខ្ញុំចាកចេញពីផ្ទះ គាត់បានស្រែកយំឱបថើបកូនៗនិងប្រពន្ធ...។ ប្តីរបស់ខ្ញុំដឹងច្បាស់ណាស់ថាគាត់នឹងស្លាប់ ។ ការលំបាកនិងការឈឺចាប់ដ៏ខ្លាំងណាស់នេះ កើតចេញពីគន្លងនេះតែម្តង...។ ប្តីរបស់ខ្ញុំពុំដែលធ្វើបាបកូនឡើយ ។ គាត់ស្រឡាញ់ប្រពន្ធកូនខ្លាំងណាស់ ។ ចាប់តាំងពីពេលដែលពួកវាចាប់យកប្តីខ្ញុំទៅ ខ្ញុំចិញ្ចឹមបីបាច់កូនទាំងប្រាំនាក់ដោយខ្លួនឯងផ្ទាល់រហូតដល់បច្ចុប្បន្ន ។ ខ្ញុំជួបការលំបាកខ្លាំងណាស់ ។ ខ្ញុំពុំចង់ជួបបញ្ហានេះម្តងទៀតទេ ។ នៅពេលដែលខ្ញុំគិតអំពីបញ្ហានេះ ខ្ញុំចាប់ផ្តើមឈឺក្បាល...។ សូមកុំសួរអំពីបញ្ហានេះតទៅទៀត ពីព្រោះក្បាលរបស់ខ្ញុំនឹងឈឺជាមិនខានឡើយ ។


យុទ្ធជនរោងពុម្ពខ្មែរក្រហម


យុទ្ធនារីតម្បាញខ្មែរក្រហម

តាមសម្តីយ៉ាងប្រត្យក្សទាំងនេះ ការឈឺចាប់និងការប៉ះទង្គិចផ្លូវចិត្តរបស់ យុំ មានសភាពច្រើនលើសលប់ ដែលមិនត្រឹមតែប៉ះពាល់ដល់ យុំ ប៉ុណ្ណោះទេ តែថែមទាំងប៉ះពាល់ដល់ខ្ញុំដែលជាគូសន្ទនា និងជាក់ស្តែងដល់អ្នកអានផងដែរ ។ ឱកាសបែបនេះ មិនត្រឹមតែជំរុញឲ្យយើងប្រឈមមុខនឹងការឈឺចាប់និងសេចក្តីស្លាប់ផ្ទាល់របស់យើងទេ តែថែមទាំងជំរុញឲ្យយើងចង់យល់ដឹងអំពីការឈឺចាប់និងការប៉ះទង្គិចផ្លូវចិត្តរបស់មនុស្សថែមទៀត ។ ជាងនេះទៅទៀត ដោយសារតែអ្នកដែលទទួលផលប៉ះពាល់នេះ ចង់ចងចាំនូវការឈឺចាប់និងការប៉ះទង្គិចផ្លូវចិត្តនេះ វាជាកិច្ចការរបស់ខ្ញុំក្នុងការជួយព្យាបាលការឈឺចាប់របស់គាត់ ។

ខ្ញុំបានគិតថាតើខ្ញុំនឹងធ្វើដូចម្តេច ប្រសិនបើខ្ញុំប្រឈមមុខនឹងស្ថានភាពបែបនេះ (ដែលប្រជាជនមួយក្រុមសោកសៅនិងយំនៅពេលដែលសម្ភាសន៍ ក៏ប៉ុន្តែ ការឆ្លើយរបស់ យុំ មានសភាពតានតឹងខ្លាំងណាស់) ។ ខ្ញុំក៏បានពិភាក្សារកវិធីសាស្ត្រព្យាបាលជាមួយ ប្រុស ដែលជាជំនួយការស្រាវជ្រាវជនជាតិខ្មែរម្នាក់របស់ខ្ញុំ ដែលមានវត្តមាននៅពេលសម្ភាសន៍នោះដែរ ។ ស្ថានភាពបែបនេះនៅតែបន្តការភ័យខ្លាច ដែលចាំបាច់ត្រូវតែស្វែងយល់អំពីវប្បធម៌ខ្មែរដើម្បីដោះស្រាយស្ថានភាពនេះប្រកបដោយជោគជ័យ ។ ការប៉ុនប៉ងចង់បញ្ឈប់ការសម្ភាសន៍របស់ខ្ញុំជាមួយ យុំ មិនបានសម្រេច ពីព្រោះ យុំ នៅតែនិយាយនិងយំទាំងក្តុកក្តួល ខ្ញុំបានខិតខំស្វែងរកវិធីសាស្ត្រផ្សេងៗដែលមានលក្ខណៈសមស្របទៅនឹងវប្បធម៌ខ្មែរដើម្បីជួយឲ្យ យុំ សម្រួលអារម្មណ៍ឲ្យនឹងនរឡើងវិញ ដែលប្រជាជនខ្មែរចាត់ទុកថាជាវិធីសាស្ត្រដ៏មានសារសំខាន់មួយក្នុងការជួយព្យាបាលការប៉ះទង្គិចផ្លូវចិត្ត ។

ក្រៅពីការសម្តែងនូវអារម្មណ៍សោកសៅចំពោះការឈឺចាប់របស់ យុំ (នៅក្នុងប្រទេសកម្ពុជា ការសម្តែងនូវអារម្មណ៍សោកសៅនេះមានសារសំខាន់ខ្លាំងណាស់ ពីព្រោះអ្នកដែលមានអារម្មណ៍មិនស្កប់ស្កល់ ងាយនឹងទទួលរងភាពអាម៉ាស់ប៉ះពាល់ដល់សមភាពសង្គម) តួយ៉ាង ខ្ញុំបានខិតខំប្រឹងប្រែងបង្វែរយ៉ាងទន់ភ្លន់នូវអារម្មណ៍របស់ យុំ ចេញពីការស្លាប់របស់ប្តីគាត់ ។ យុំ មានអារម្មណ៍ស្ងប់តែមួយសន្ទុះប៉ុណ្ណោះ ស្រាប់តែនឹកឃើញឡើងវិញនូវការស្លាប់របស់ប្តីគាត់ ។ ប្រុស ដែលបានរាក់ទាក់ជាមួយនឹង យុំ នៅក្នុងពេលចុះទៅធ្វើការសិក្សាស្រាវជ្រាវរបស់ខ្ញុំដែរនោះ ក៏បានសម្តែងនូវអារម្មណ៍សោកសៅចំពោះការឈឺចាប់របស់ យុំ ដែរ និងថែមទាំងបានរ៉ាយរ៉ាប់យ៉ាងសង្ខេបនូវការឈឺចាប់របស់គាត់ដែលទាក់ទិននឹងការស្លាប់ឪពុករបស់គាត់ ។ ក៏ប៉ុន្តែចំណុចមួយទៀត ប្រុស ចង់ជំរុញឲ្យមានការប្រើប្រាស់នូវវិធីសាស្ត្រព្យាបាលដ៏សាមញ្ញបែបខ្មែរមួយ គឺការបំភ្លេចរឿងរ៉ាវអតីត ដែលអាចទុកថាជា«ការបំភ្លេច» តាមបទដ្ឋានជីវឱសថរបស់លោកខាងលិច ក៏ប៉ុន្តែការបំភ្លេចបែបនេះ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងធម៌ព្រះពុទ្ធដែលថា លះបង់ទ្រព្យធន របស់ខ្លួននឹងធ្វើអារម្មណ៍ស្ងប់ឡើងវិញ ។

យុំ [បានចាប់យំម្តងទៀត] ៖ នៅពេលដែលខ្ញុំគិតអំពីព្រឹត្តិការណ៍នេះ ខ្ញុំមានអារម្មណ៍ឈឺចាប់ភ្លាម ។ ប្រសិនបើខ្ញុំចង់ធ្វើអ្វី

មួយនោះ ខ្ញុំមិនអាចធ្វើឲ្យអារម្មណ៍របស់ខ្ញុំស្ងប់បានឡើយ ។

ហ៊ុនគុន ៖ ឈប់គិតអំពីរឿងនេះតទៅទៀតទៅ ។ ខ្ញុំពុំចង់ឲ្យមីងមានបញ្ហាឡើយ ។

ប្រុស ៖ មីងឈប់គិតពីរឿងនេះទៀតទៅ ។ មីងត្រូវថែរក្សាសុខភាពរបស់មីង ពីព្រោះការគិតបែបនេះធ្វើឲ្យយើងពិបាកចិត្តខ្លាំងទៅវិញទេ ។

យុំ ៖ ពិបាកខ្លាំងណាស់ លោក ។

ប្រុស ៖ យើងអាចឈប់បាន វាមិនលំបាកនោះទេ ។ កុំនិយាយអំពីវាតទៅទៀត ។ វាបានត្រឹមតែធ្វើឲ្យមីងជួបការលំបាកនិងឈឺតែប៉ុណ្ណោះ ។

ភ្លាមៗនោះដែរ ការស្រែកយំរបស់ យុំ បានស្ងប់ចិត្តបន្តិចហើយ យុំ ត្រូវបាននាំយកទៅផ្ទះគាត់ ដោយសារគាត់ប្រាប់ថាគាត់ឈឺក្បាលខ្លាំងណាស់ ។ រយៈពេលតានតឹងនេះ បានបញ្ចប់ត្រឹមតែរយៈពេលប្រហែលប្រាំទៅដប់នាទីប៉ុណ្ណោះ ក៏ប៉ុន្តែពេលនោះហាក់ដូចជារយៈពេលដ៏វែងអីចឹង ។

ខ្ញុំ ក៏បានឲ្យ ប្រុស បើករថយន្តដឹក យុំ ត្រឡប់ទៅផ្ទះវិញនៅក្នុងភូមិបានយ៉ាន និងនៅជាមួយ យុំ រហូតដល់គាត់មានអារម្មណ៍ធូរស្បើយវិញ ព្រមទាំងជួយឲ្យ យុំ មានអារម្មណ៍វិលត្រឡប់ទៅរកជីវភាពនៅក្នុងភូមិរបស់គាត់វិញ ។ ការធ្វើបែបនេះមានន័យថា យើងកំពុងតែប្រើប្រាស់នូវវិធីសាស្ត្រព្យាបាលដ៏សំខាន់តាមបែបខ្មែរ គឺការចូលមករួមរស់នៅក្នុងសង្គមជាថ្មីដែលជួយឲ្យប្រជាជនមានអារម្មណ៍ស្ងប់ឡើងវិញ បំភ្លេចចោលនូវបញ្ហានិងលើកស្ទួយសតិបញ្ញារបស់គាត់តាមរយៈការធ្វើអន្តរកម្មនេះ ។

នៅពេលដែល យុំ និង ប្រុស មកដល់ផ្ទះកូនស្រីរបស់ យុំ ដែលបានទ្រហោយំបន្តិចនៅពេលដែលធ្វើដំណើរទៅផ្ទះនោះ បានចាប់ផ្តើមធ្វើសកម្មភាពធម្មតាវិញ ។ ទាំងប្រុស និង យុំ មិននិយាយប្រាប់កូនស្រីអំពីឧបទ្ទហេតុនៅតាមផ្លូវមកផ្ទះនោះឡើយ ។ ប្រុស បាននិយាយថា គាត់ឆ្ងល់ណាស់ថាតើហេតុអ្វីបានជា យុំ មិននិយាយប្រាប់កូនស្រីរបស់គាត់អីចឹង ។ ប្រុស បានពន្យល់ថា "ប្រជាជនកម្ពុជានិយាយរឿងរ៉ាវដ៏សោកសៅបែបនេះមួយដងក្នុងចន្លោះពេលនោះតែប៉ុណ្ណោះ... ។ ប្រសិនបើមនុស្សម្នាក់ចាប់ផ្តើមមានអារម្មណ៍ក្រៀមក្រំ ហើយចាប់ផ្តើមយំសោក [ដូចករណី យុំ] អ្នកនោះត្រូវឈប់និយាយអំពីបញ្ហានេះដែលធ្វើឲ្យមានអារម្មណ៍ឈឺចាប់ ហើយពួកគេគួរតែគិតអំពីរឿងផ្សេងវិញ ។ ប្រសិនបើយើងនៅតែបន្តនិយាយអំពី[រឿងរ៉ាវរបស់ យុំ] អារម្មណ៍ដែលមានបញ្ហារបស់ យុំ នឹងកាន់តែធ្ងន់ធ្ងរទៅទៀត" ។

ជាថ្មីម្តងទៀត វិធីសាស្ត្រព្យាបាលចម្ងតាមពុទ្ធសាសនាមានលក្ខណៈផ្ទុយទៅនឹងវិធីព្យាបាលរោគរបស់ពួកបស្ចិមប្រទេសដែលមានយូរលង់ណាស់មកហើយ ដោយការនិយាយ (ឬដោយការលេបថ្នាំដ៏សមរម្យ) ដែលមានជនណាម្នាក់អាចធ្វើការព្យាបាលបញ្ហាផ្លូវចិត្តរបស់ជនណាម្នាក់នោះ ។ ក្នុងរយៈពេលពីរបីថ្ងៃបន្ទាប់ ប្រុស និងខ្ញុំ បានអង្កេតតាមដាន យុំ ដើម្បីឲ្យដឹងច្បាស់លាស់ថា យុំ មិនមានបញ្ហាអ្វីទាំងអស់ ។ យើងជឿជាក់ថា យុំ មានអារម្មណ៍ធម្មតា ។ ប្រសិនបើ យុំ មានសញ្ញាណាមួយដែលបង្ហាញថា អារម្មណ៍សោកសៅគាត់នៅមាននោះ (ឧទាហរណ៍ ជំងឺដោយប្រយោលការដើរចេញពីសង្គម ការធ្វើអារម្មណ៍មិនស្កប់ស្កល់ ការជម្ពុះនឹង"ការឈឺចាប់") យើងចាំបាច់លើកទឹកចិត្តឲ្យ យុំ បញ្ចេញនូវអារម្មណ៍តានតឹងក្នុងខ្លួន ឬឲ្យទៅជួប"គ្រូពេទ្យព្យាបាលដែលជាជនជាតិខ្មែរ" គឺគ្រូខ្មែរបុរាណគ្រូទាយ ឬព្រះសង្ឃដែលគ្រូម្នាក់ៗមានមធ្យោបាយជួយសង្គ្រោះអ្នកជំងឺឲ្យបេះដោះស្រាយបញ្ហា"បេះដូង"ទៅតាមវប្បធម៌ខ្មែរ ។ ***(នៅមានត)***

**អាធិ្យចសេនជី ហ៊ីនគុន**



សកម្មភាពនេសាទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

# ការអប់រំដែលម្ដាយខ្ញុំផ្ដល់ឱ្យ

កាលពីខ្ញុំនៅតូច ខ្ញុំសម្គាល់ឃើញពេលម្ដាយរបស់ខ្ញុំរែងអង្ករ គាត់តែងតែហាមខ្ញុំមិនឲ្យទៅជិត ឬទៅជួយគាត់ទេព្រោះខ្លាចកំពប់ បើកំពប់ស្ដាយណាស់ ព្រោះជំនាន់ ប៉ុល ពត ក្នុងមួយថ្ងៃ រកតែអង្ករមួយស្លាបព្រាហូបមិនបានផង ក្រៅពីទទួលបបរ រាវកក្ដុកក្នុងមួយវែកមានគ្រាប់អង្ករតែ៤ទៅ៥គ្រាប់ ឬដំឡូងមី ៣កង់ប៉ុនមេជើង ជួនកាលដេកអត់ក៏មាន ។

៣ឆ្នាំ ៨ខែ ២០ថ្ងៃ ជារយៈពេលដ៏គួររន្ធត់សម្រាប់ប្រវត្តិសាស្ត្រខ្មៅងងឹតរបស់កម្ពុជា គ្មានរបបណាដែលពិបាកជាងរបបនេះទេ គ្មានសិទ្ធិសេរីភាពអ្វីទាំងអស់ គឺធ្វើតាមតែបញ្ជារបស់គេ(អង្គការ) គ្មានសិទ្ធិតវ៉ាប្រសិនបើហ៊ានតវ៉ានឹងត្រូវស្លាប់ ។ ម្ដាយខ្ញុំបាននិយាយប្រាប់ខ្ញុំថា កាលពីឆ្នាំ១៩៧០ គាត់រស់នៅភ្នំពេញ ប្រកបដោយសុភមង្គលជាមួយឪពុករបស់ខ្ញុំដែលជាគ្រូបង្រៀននៅសាលាបឋមសិក្សាបាក់ទូករដ្ឋធានីភ្នំពេញ ។


ក្រុមគ្រួសារ គាត លក្ខិណា ឆ្នាំ១៩៨៩

មកដល់ថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ ពេលនោះហើយដែលជីវិតរបស់គាត់បានចាប់ផ្ដើមផ្លាស់ប្ដូរទាំងស្រុង រស់នៅចល័តគ្រប់ទីកន្លែងតាមតែអង្គការបញ្ជា ។ ខ្មែរក្រហមបានប្រកាសប្រាប់ថា«សូមពុកម៉ែរក្សាការស្ងប់ស្ងាត់» ។ បន្ទាប់មកខ្មែរក្រហមប្រកាសឲ្យប្រជាជនទាំងអស់ចាកចេញពីភ្នំពេញ ដើម្បីរៀបចំទីក្រុង ។ ម្ដាយខ្ញុំភ័យតក់ស្លុត ញ័រដៃញ័រជើង ពេលខ្មែរក្រហមស្រែកគំរាមនិងបាញ់កាំភ្លើងមួយគ្រាប់បញ្ចិតជើងរបស់គាត់ទៅប៉ះនឹងជញ្ជាំងផ្ទះ គាត់ឈរស្រឡាំងកាំងក្ដោបទាំងពបងប្រុសរបស់ខ្ញុំដែលទើបតែមានអាយុប្រហែលជា៤ឆ្នាំប៉ុណ្ណោះ ។ ឪពុកខ្ញុំប្រញាប់ប្រញាល់អូសដៃម្ដាយខ្ញុំចាកចេញ ។ ធ្វើដំណើរប្រហែល ២ទៅ៣ថ្ងៃគាត់បានទៅដល់ខេត្តតាកែវដែលជាស្រុកកំណើតរបស់ឪពុកខ្ញុំ ។

ម្ដាយខ្ញុំត្រូវអង្គការចាត់តាំងឲ្យរែកដី ចំណែកឪពុកខ្ញុំធាក់រហាត់ទឹក ។ ៦ខែក្រោយមក អង្គការបានបញ្ជូនពួកគាត់ទៅខេត្តបាត់ដំបង ។ រថភ្លើងបាននាំគាត់ទៅដល់ខេត្តពោធិ៍សាត់ ឆៀតពេលឈប់សម្រាក ឪពុករបស់ខ្ញុំបានចុះទៅបូតស្រូវដើម្បីឲ្យមេមាន់ស៊ី ព្រោះវាអត់ចំណីជាច្រើនថ្ងៃហើយ ជួនពេលនោះ កងទ័ពខ្មែរក្រហមមកទាន់បានសម្លុតគាត់ខ្លាំងៗថា «មិត្តឯងបំផ្លាញអង្គការបានតែយកវ៉ៃចោលទេ» ។ ម្ដាយរបស់ខ្ញុំយំផងអង្វរផងថា «សុំទោស! ខ្ញុំខុសហើយ ខ្ញុំឈប់ធ្វើអ៊ីចឹងទៀតហើយ» ។ ទៅដល់សង្កាត់ស្រះជីក ស្រុកភ្នំស្រុក ខេត្តបាត់ដំបង ខ្មែរក្រហមចាប់ផ្ដើមសួរឈ្មោះនិងមុខរបរដែលគាត់ធ្វើពីមុន ។ ឪពុករបស់ខ្ញុំនឹងត្រូវស្លាប់ប្រសិនបើគាត់ប្រាប់គេត្រង់ថាធ្វើគ្រូបង្រៀន ។ ២ទៅ៣ថ្ងៃក្រោយមកប្រជាជនដែលជម្លៀសទៅនោះត្រូវបានបែងចែកជាក្រុមៗដើម្បីងាយស្រួលធ្វើការ ។ អង្គការបានឲ្យឪពុកម្ដាយរបស់ខ្ញុំទៅប្រូតស្រូវនៅស្រែឆ្ងាយៗ ប្រហែល៤-៥គីឡូពីកន្លែងស្នាក់នៅ ។ ម្ដាយរបស់ខ្ញុំតែងតែបារម្ភពីបងប្រុសរបស់ខ្ញុំដែលនៅតូចគ្មានអ្នកណាមើលថែ ជួនកាលមកពីប្រូតវិញបងប្រុសរបស់ខ្ញុំក្ដៅខ្លួន ។ ដោយខ្វះភាពកក់ក្ដៅនិងហូបចុកមិនបានគ្រប់គ្រាន់បងប្រុសរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺរាកមួលយ៉ាងធ្ងន់ធ្ងរ ។ ម្ដាយខ្ញុំគ្មានសង្ឃឹមថាគាត់អាចមានជីវិត

រស់ទេ ព្រោះក្មេងៗដែលនៅជុំវិញខ្ទមសុទ្ធតែឈឺគ្រប់ៗគ្នា ជួនពេលយប់ខ្លះមួយយប់ស្លាប់ពី៨ទៅ១០នាក់ក៏មានដែរ ។

ចុងឆ្នាំ១៩៧៧ អង្គការខ្មែរក្រហមបានចាប់ផ្តើមសម្លាប់មនុស្សបណ្តើរៗ ដោយប្រើនយោបាយថា "សុំសម្តែងការស្មោះត្រង់ អ្នកណាធ្វើអ្វីឲ្យប្រាប់តាមត្រង់ អង្គការនឹងបញ្ជូនទៅរៀនសូត្រដើម្បីឲ្យធ្វើការតាមមុខងាររៀងខ្លួនៗ" ។ ឪពុកខ្ញុំគាត់បានដឹងថាចៅហ្វាយស្រុកខេត្តកំពង់ចាមឈ្មោះថា ស្រីវ៉ែន ដែលរស់នៅជិតខ្ទមម្តាយខ្ញុំ បានទៅចុះឈ្មោះ ហើយរួមទាំងឪពុកមានិងជីដូនមួយឪពុកធំរបស់ខ្ញុំជាច្រើននាក់ទៀត ដែលអ្នកទាំងនោះជាអតីតទាហានស័ក្តិ២ និងគ្រូបង្រៀន បានបាត់ខ្លួនតាំងពីពេលនោះមករហូតដល់សព្វថ្ងៃ ។ ច្រើនថ្ងៃកន្លងមកម្តាយខ្ញុំបានឃើញរថយន្តមួយបញ្ឈរនៅខាងលិចខ្ទមគាត់ប្រហែលជា៥០ម៉ែត្រ គាត់បានលួចមើលតាមប្រឡោះខ្ទមរបស់គាត់ ដែលមានដើមដំឡូងឈើដុះស៊ុបទ្រុបនៅសល់តែចន្លោះទាបជិតដី ដែលអាចមើលឃើញបានចម្ងាយប្រហែល៧ទៅ៨ម៉ែត្រ ម្តាយខ្ញុំឃើញកងឈ្លបចងដៃមនុស្សប្រុសស្រីចំនួន១៥នាក់បណ្តើរ តាមផ្លូវសំដៅជាក់ឡាន រួចបើកចេញទៅទាំងយប់ ។ ម្តាយខ្ញុំក៏ដូចជាអ្នកភូមិព្រួយបារម្ភថា មិនដឹងថាដល់ពេលណាដល់វេនយើងនោះទេ ព្រោះឃើញតែយកមនុស្សទៅបាត់ៗ ។ មិនបានរយៈពេលប៉ុន្មានថ្ងៃផង ម្តាយខ្ញុំត្រូវនារីឈ្លបបណ្តើរយកទៅសហករណ៍ពីបទលួចលីងស្រូវនិងបុកពោតហូប ។ ម្តាយខ្ញុំគាត់ឃ្លានខ្លាំងពេក ព្រោះរបបដែលសហករណ៍ចែកឲ្យមិនគ្រប់គ្រាន់ទេ ។ ក៏ប៉ុន្តែគាត់ត្រូវបានដោះលែងមកវិញ ដោយគ្រាន់តែយកទៅកសាងប៉ុណ្ណោះ ។

នៅថ្ងៃមួយ ចុងឆ្នាំ១៩៧៨ ពេលពួកខ្មែរក្រហមចេញទៅព្រៃបាត់ ប្រជាជនបាននាំគ្នាទៅកាប់អំពៅ ខ្លះបេះផ្លែល្ពៅ ខ្លះយកស្រូវបុកដើម្បីហូប ។ ប្រហែលជាម៉ោង១រំលងអធ្រាត្រខ្មែរក្រហមបានត្រឡប់មកពីព្រៃវិញ ហើយចាប់ចងអ្នកដែលលួចបេះបោចដំណាំទាំងចាស់ទាំងក្មេងចំនួន២៥យកទៅសម្លាប់ចោល ។ ជាបន្តបន្ទាប់ ម្តាយខ្ញុំបានឃើញកងឈ្លបបណ្តើរ សុវណ្ណ ដែលរស់នៅជិតខ្ទមរបស់គាត់ ដោយយកក្រមាចងដៃគាត់ទៅក្រោយបណ្តើរទៅសម្លាប់ទៀត ។ ពេលដែលឪពុករបស់ខ្ញុំត្រឡប់មកពីធ្វើការគាត់ប្រាប់ម្តាយខ្ញុំថាមានយុវជនម្នាក់ឈ្មោះ ឡោះ ដែលជាអ្នកបរទេះដឹកស្បៀង ធ្លាប់ចេញចូលក្នុងឃ្លាំងអង្ករបានខ្សឹបឲ្យប្រយ័ត្ន កុំមាត់ផ្តេសផ្តាស គេកំពុងចម្រាញ់មនុស្ស ។ ក្នុងមួយយប់ពួកខ្មែរក្រហមសម្លាប់មនុស្ស៨នាក់ យប់ខ្លះ២០នាក់ ។ ម្តាយខ្ញុំកាន់តែតក់ស្លុតក្រោយពីស្តាប់រឿងនេះ ។

មិនយូរប៉ុន្មានកងទ័ពវៀតណាមបានចូលមករំដោះនៅខេត្តសៀមរាប ប្រជាជនប្រហែល៥០នាក់ រួមទាំងឪពុកខ្ញុំផងនឹកស្មានថាសន្តិភាពហើយ ពួកគាត់បាននាំគ្នាដើរបូតស្រូវហូប ។ ក៏ប៉ុន្តែការស្មាននោះខុសទាំងស្រុងព្រោះខ្មែរក្រហមគ្រាន់តែរត់ចូលព្រៃប៉ុណ្ណោះព្រោះខ្លាចវៀតណាមសម្លាប់ ។ ពេលសភាពការណ៍ស្ងប់ស្ងាត់កងទ័ពខ្មែរក្រហមត្រឡប់ចូលភូមិវិញ ខណៈពេលដែលឈ្លបបានមកទាន់ឃើញឪពុករបស់ខ្ញុំ និងប្រជាជនប្រហែល២០នាក់ទៀតកំពុងយួរស្បោងស្រូវ ឈ្លបទាំងនោះក៏បានព័ទ្ធចាប់និងបណ្តើរឪពុករបស់ខ្ញុំទៅសហករណ៍ ។ ឪពុករបស់ខ្ញុំភ័យខ្លាំងណាស់ គាត់គិតថាជីវិតរបស់គាត់ត្រូវបញ្ចប់ហើយនៅពេលនោះ ប៉ុន្តែសំណាងល្អព្រោះថាមិនមែនមានតែគាត់ទេ ដែលត្រូវបានកងទ័ពខ្មែរក្រហមចាប់ខ្លួននោះ ។ ឈ្លបបានដើរចេញពីគាត់ទៅរកអ្នកផ្សេងទៀត ឆ្លៀតឱកាសនោះគាត់បានគេចខ្លួនសំដៅទៅកន្លែងស្នាក់នៅ ។ ចំណែកអ្នកដែលនៅទីនោះត្រូវឈ្លបឃុំទុកនៅក្នុងឃ្លាំងអត់មានខ្យល់ចេញចូលមួយយប់ និងថែមទាំងត្រូវបានវាយទាត់ធាក់ទៀតផង ។

ម្តាយខ្ញុំជាកូនទី៦ក្នុងចំណោមបងប្អូនបង្កើត៨នាក់ ប្រុស២នាក់ ស្រី៦នាក់ ។ ក្រោយពីរបបខ្មែរក្រហមដួលរំលំម្តាយខ្ញុំនៅសល់តែបងប្អូន៣នាក់ទេ ចំណែក៥នាក់ទៀតស្លាប់ក្នុងរបបនោះ ។

បទពិសោធន៍ដែលម្តាយផ្តល់ឲ្យខ្ញុំគឺជាមូលដ្ឋានមួយដែលជំរុញឲ្យខ្ញុំមានចំណាប់អារម្មណ៍ក្នុងអានសៀវភៅឯកសារផ្សេងៗ និងស្វែងយល់បន្ថែមស្តីពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ តាមរយៈការចុះចែកឯកសារ និងជួបសម្ភាសន៍ជាមួយអ្នកភូមិដែលមានវ័យចំណាស់ហើយធ្លាប់ឆ្លងកាត់របបនោះ ធ្វើឲ្យខ្ញុំជឿជាក់ថា របបកម្ពុជាប្រជាធិបតេយ្យពិតជាមានមែន ។ ខ្ញុំសង្ឃឹមថាក្មេងដែលកើតជំនាន់ក្រោយនឹងជឿថាមានរបបនេះដូចជារូបខ្ញុំដែរ ។

**តាត លក្ខិណា**

# លិខិតពីមិត្តអ្នកអាន

**តាកែវ, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៧**

ក្នុងនាមខ្ញុំជាអ្នកចូលចិត្តអានឯកសាររបស់មជ្ឈមណ្ឌលម្នាក់ ខ្ញុំពេញចិត្តនូវការងាររបស់មជ្ឈមណ្ឌលដែលបានខិតខំប្រមូលចងក្រងឯកសារទុកជាប្រវត្តិសាស្ត្រអំពីសម័យខ្មែរក្រហមដែលបានប្រព្រឹត្តនូវអំពើព្រៃផ្សៃ កាប់សម្លាប់មនុស្សសម្រាប់ឲ្យកូនខ្មែរជំនាន់ក្រោយនិងពិភពលោកបានយល់ដឹងនិងធ្វើជាមេរៀនដើម្បីទប់ស្កាត់នូវអំពើរបៀបនេះកុំឲ្យកើតឡើងជាលើកទីពីរក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។

លោកនាយកជាទីគោរព! ខ្ញុំមានការសោកស្តាយចំពោះព្រឹត្តិការណ៍ខាងលើនេះ ថ្វីដ្បិតតែរបបខ្មែរក្រហមបានដួលរលំពីអំណាចដឹកនាំរហូតមកដល់បច្ចុប្បន្ននេះមានរយៈពេលជិត៣០ឆ្នាំមកហើយក្តី ក៏ក្រុមនោះនៅមិនទាន់ត្រូវបានអង្គការសហប្រជា-ជាតិ សហគមន៍អន្តរជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានបំពេញកាតព្វកិច្ចដ៏ចម្បងក្នុងការនាំយកពួកខ្មែរក្រហមមកកាត់ទោសបាននៅឡើយ ធ្វើឲ្យប្រជាពលរដ្ឋខ្មែរទាំងជនរងគ្រោះ អ្នកស្លាប់ព្រមទាំងសាច់ញាតិរបស់ជនរងគ្រោះនៅកំពុងទន្ទឹងរង់ចាំយ៉ាងអន្ទះសាពីមួយថ្ងៃ ទៅមួយខែ ទៅមួយឆ្នាំ រហូតដល់ពេលនេះ ។

ប៉ុន្តែជាការពិត អ្នកណាក៏ដឹងដែរថា ជាលទ្ធផលនៃការចរចាគ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ បានសម្រេចជាផ្លែផ្កា បង្កើតបានតុលាការនេះឡើងដែលហៅថា “អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” ដែលសមាសភាពក្នុងតុលាការមានខ្មែរ និងបរទេសកំពុងតែដំណើរការយ៉ាងសកម្មនាពេលនេះ ។ ប៉ុន្តែគេនៅមើលឃើញនិងមានក្តីព្រួយបារម្ភអំពីបញ្ហាតុលាការនេះដែរ ដោយសារទាំងរូបខ្ញុំ និងអ្នកឯទៀតបានស្តាប់ឮតាមប្រព័ន្ធព័ត៌មានផ្សេងៗផ្សាយអំពីឧបសគ្គដែលចេះតែកើតឡើងជាបន្តបន្ទាប់នៅក្នុងដំណើរការរៀបចំបញ្ហាផ្សេងៗនៅក្នុងតុលាការពិសេសនេះដែលមតិរិះគន់ម្នាងបានចោទថា ឧបសគ្គមួយក្នុងឧបសគ្គជាច្រើនផ្សេងទៀតនោះ ថាកើតមកពីភាគីមេធាវីខ្មែរដែលមានលោក គី តិច ជាប្រធាន បានបង្គាប់ឲ្យមេធាវីបរទេសបង់ប្រាក់ច្រើនឲ្យគណៈមេធាវីខ្មែរសម្រាប់សិទ្ធិការពារក្តីឲ្យជនរងគ្រោះ ឬជនជាប់ចោទណាម្នាក់ ឬក៏ថាមេធាវីខ្មែរទាមទារប្រាក់ខែឲ្យបានស្មើនឹងប្រាក់ខែពួកបរទេសជាដើម ។ បញ្ហាដែលចេះតែកើតមានឥតឈប់ឈរទាំងមុនបង្កើតនិងក្នុងពេលបង្កើតបាននាពេលនេះ មើលទៅធ្វើឲ្យមានមតិផ្សេងៗខ្លះ បានលើកឡើងថា ឧបសគ្គអាចធ្វើឲ្យតុលាការខ្មែរក្រហមបរាជ័យថ្វីបើវាបានបង្កើតមកហើយក៏ដោយ ។ ពិសេសទៅទៀតនោះមតិខ្លះបានលើកឡើងថា ភាពយឺតយ៉ាវនិងឧបសគ្គចំពោះតុលាការខ្មែរក្រហមនេះ ដោយសារគេមិនចង់ឲ្យតុលាការនេះបង្កើតឡើងបានជាប់ទេ ហើយធ្វើពន្យារៗធ្វើឲ្យមានឧបសគ្គនេះ ឧបសគ្គនោះជាហូរហែទុកឲ្យមេខ្មែរក្រហមចាស់ៗស្លាប់អស់ ទើបគេធ្វើឲ្យត្រូវគ្នាបង្កើតតុលាការ ហើយពេលធ្វើសវនាការកាត់ទោសមេខ្មែរក្រហម ពេលនោះអ្នកពាក់ព័ន្ធក្នុងការកាប់សម្លាប់ខ្មែរជាច្រើនទៀតនោះ នាំគ្នាឆ្លើយទម្លាក់កំហុសទៅលើមេដឹកនាំខ្មែរក្រហមដែលបានស្លាប់ថាជាអ្នកប្រព្រឹត្តនិងសម្លាប់ប្រជាជន ហើយអ្នកដែលជាអ្នកពាក់ព័ន្ធបានរួចខ្លួនទាំងអស់គ្នាតែម្តង ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ មតិដែលបានលើកឡើងនេះពុំបានបញ្ជាក់អំពីអត្តសញ្ញាណអ្នកពាក់ព័ន្ធនេះឲ្យសាធារណជនបានដឹងទេ មតិនេះគ្រាន់តែបញ្ជាក់ជាឃ្លាអះអាងថា “ទឹកថ្លាទើបមើលឃើញត្រី” ។ ដូច្នេះបើយើងផ្អែកទៅតាមដំណើររអាក់រអួលនិងឧបសគ្គនានាដែលចេះតែកើតទាំងមុននឹងទាំងក្រោយ ទាក់ទងនឹងការបង្កើតតុលាការខ្មែរក្រហមនេះឡើង វាសមស្របទៅនឹងមតិដែលបានលើកឡើងពីខាងដើមនេះដែរ ព្រោះទម្រាំបង្កើតតុលាការនេះឡើងបានវាចំណាយចំណាយពេលអស់ជាងមួយទសវត្សរ៍ហើយចាប់ពីប្រទេសកម្ពុជាយើងបានបង្កើតរដ្ឋាភិបាលស្របច្បាប់តាំងពីឆ្នាំ១៩៩៣មកម្ល៉េះ ហើយការចរចាបង្កើតតុលាការទើបតែធ្វើឡើងចាប់ពីឆ្នាំ១៩៩៧មក ។ នៅពេលថ្មីៗនេះ ប្រហែលជាគេមើលឃើញអាចជាបរាជ័យនៃតុលាការនេះហើយ ទើបលោកឧបការីរដ្ឋមន្ត្រីការបរទេស សហរដ្ឋអាមេរិក

ដែលមកធ្វើទស្សនកិច្ចប្រទេសកម្ពុជាបានមានប្រសាសន៍ថា «បើតុលាការខ្មែរក្រហមបរាជ័យ គឺជាការអាម៉ាស់របស់ប្រទេសកម្ពុជា» ។ ប៉ុន្តែសម្រាប់ខ្ញុំ ចំពោះប្រសាសន៍របស់លោកឧបការីដែលបានថ្លែងយ៉ាងដូច្នេះនោះ វាជាការត្រឹមត្រូវនិងមិនអាចប្រកែកបានឡើយ ប៉ុន្តែខ្ញុំគិតថា វាមិនមែនតែកម្ពុជាទេ ដែលបានទទួលរងការអាម៉ាស់តែម្នាក់ឯងនោះ គឺទាំងសហរដ្ឋអាមេរិក ទាំងអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិក៏ត្រូវទទួលរងអាម៉ាស់ដូចកម្ពុជាដែរ ព្រោះថាបទឧក្រិដ្ឋដែលពួកខ្មែរក្រហមបានបង្កឡើងជាទង្វើផ្ទុយនឹងច្បាប់អន្តរជាតិហើយត្រូវតែផ្តន្ទាទោសតាមផ្លូវច្បាប់ ។ ផ្ទុយទៅវិញ បើថាអ្នកប្រព្រឹត្តពុំត្រូវបានកាត់ទោស ហើយទុកឲ្យរួចខ្លួនទៅវិញ និងបានត្រឹមតែគេចាប់អារម្មណ៍និងយកចិត្តទុកដាក់ចងក្រងឯកសារទុកសម្រាប់សិក្សាក្នុងសាលា និងផ្សព្វផ្សាយឲ្យពិភពលោកបានដឹងប៉ុណ្ណោះ គឺវាគ្មានខ្លឹមសារអ្វីសោះឡើយ ដោយសារអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មក្នុងប្រទេសមួយធ្វើឲ្យមនុស្សស្លាប់រាប់លាននាក់ពិភពលោកទាំងមូលគ្មានវិធានការនឹងប្រមូលយកមកដោះស្រាយរកយុត្តិធម៌ឲ្យជនរងគ្រោះបានផង ជាប្រការមួយមិនត្រឹមត្រូវទាល់តែសោះ ។ តើអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិជាតួអង្គតំណាងឲ្យឆន្ទៈមនុស្សជាតិ ស្នេហាយុត្តិធម៌ សន្តិភាពតើជាតួអង្គយ៉ាងដូចម្តេចទៅវិញ? តើឲ្យប្រទេសជាតិមួយ ឬជាតិសាសន៍មួយ ដែលត្រូវគេឈ្លានពាន កាប់សម្លាប់ ជិះជាន់សង្កត់សង្កិនធ្វើបាបពីសំណាក់អ្នកដឹកនាំរបស់ខ្លួន ឬពីប្រទេសមួយផ្សេងទៀតនោះ តើឲ្យពួកគាត់ទៅពឹងអ្នកណា ឬមួយរត់ទៅពឹង ឬបួងសួងសុំព្រះសំពះទេវតាឲ្យជួយរកយុត្តិធម៌និងសុខសន្តិភាពពីបុរីអាទិទេព?

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ទាំងរូបខ្ញុំ ក៏ដូចប្រជាពលរដ្ឋខ្មែរ ទូទៅនៅតែមានជំនឿយ៉ាងមុតមាំថា អង្គការសហប្រជាជាតិពិតជានឹងផ្តោតចក្ខុវិស័យធ្វើការត្រិះរិះពិចារណាបានយ៉ាងល្អិតល្អន់សំដៅរិះរកវិធានការជាច្រើនក្នុងការធ្វើឲ្យសម្រេចនូវបេសកកម្មដ៏សែនថ្លៃថ្លាដើម្បីស្វែងរកយុត្តិធម៌ជូនជនកម្ពុជាបានជោគជ័យជាប្រវត្តិសាស្ត្រ តាមរយៈការកាត់ទោសខ្មែរក្រហមនាពេលខាងមុខនេះជាពុំខានឡើយ ទោះបីថាតុលាការនេះមានឧបសគ្គតូចធំដែលកំពុងតែកើតមានជាបន្តៗយ៉ាងណាក្តី ។ ជាពិសេសទៅទៀតនោះ ខ្ញុំមានជំនឿថា អង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិ ពិតជាបានយល់ច្បាស់ជុំវិញព្រឹត្តការណ៍នានាក្នុងសង្គមខ្មែរជាហូរហែកន្លងមករហូតមកដល់បច្ចុប្បន្ននេះយ៉ាងពិតប្រាកដ ពោលគឺចំពោះទស្សនៈថ្មីដែលកើតមាននាពេលនេះតែងតែនិយមនាំគ្នានិយាយថា «អ្នកមានអំណាច មានលុយគេអាចប្រើខ្មោចឡើងរាំនិងច្រៀងឲ្យយើងមើលនិងស្តាប់ក៏បានដែរ ប្រសិនបើគេចង់ប្រើ» ។ ដូច្នេះខ្ញុំយល់ថាការងារអ្វីក៏ដោយគេអាចធ្វើឲ្យសម្រេចបានឲ្យតែបុគ្គល សហគមន៍ជាតិ និងអន្តរ-ជាតិ មានឆន្ទៈពិតប្រាកដក្នុងការធ្វើនិងមានបំណងច្បាស់លាស់ វៀរលែងតែការងារប្រាសចាកពីច្បាប់ធម្មជាតិខ្លះដែលគេមិនអាចធ្វើបានប៉ុណ្ណោះ ។ ជាក់ស្តែងឧបមាថា បុគ្គល សហគមន៍ជាតិ និងអន្តរជាតិ នាំគ្នាយកទឹកសាបរំងាស់យកអំបិល មិនអាចបានអំបិលឡើយ ។ យ៉ាងណាមិញ ចំពោះបទឧក្រិដ្ឋអំពើប្រល័យពូជសាសន៍ ដែលមនុស្សមួយក្រុមធ្វើការប្រឆាំងនឹងច្បាប់អន្តរជាតិរឿងអ្វីដែលថាមិនអាចធ្វើបាននោះ! បើអង្គការសហប្រជាជាតិតំណាងឲ្យប្រជាជាតិក្នុងពិភពលោកទៅហើយ! ប៉ុន្តែផ្ទុយទៅវិញប្រសិនបើអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជាគ្មានឆន្ទៈ និងបំណងធ្វើទេនោះ គឺពិតជាពុំអាចធ្វើបានមែន ហើយកុំថាឡើយរឿងកាត់ទោសខ្មែរក្រហម សូម្បីតែអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាល ដើរទៅចាប់សត្វស្លាបដែលគេដាក់ក្នុងទ្រុងក៏មិនអាចចាប់បានដែរ ។ ដូច្នេះសម្រាប់ខ្ញុំៗគិតថា វាអាស្រ័យតែលើឆន្ទៈនិងបំណងទាំងនេះប៉ុណ្ណោះ ដែលជាកត្តាកំណត់អំពីរឿងតុលាការ ខ្មែរក្រហម ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមានជំនឿនិងសង្ឃឹមថា អង្គការសហប្រជាជាតិ អង្គការជាតិនិងអន្តរជាតិ និងរាជរដ្ឋាភិបាលពិតជាសហការធ្វើឲ្យបានសម្រេចនូវសេចក្តីប្រាថ្នាដ៏ចម្បងរបស់ជនកម្ពុជាគ្រប់រូបដែលកំពុងទន្ទឹងរង់ចាំទទួលនូវយុត្តិធម៌ដែលបានទទួលមកពីសវនាការកាត់ទោសខ្មែរក្រហមនៅពេលខាងមុខឆាប់ៗនេះយ៉ាងពិតប្រាកដ ពោលគឺមិនធ្វើឲ្យជីវិតអ្នកស្លាប់ទៅជាងមួយលាននាក់ក្លាយជាឥតន័យដូចជីវិតសត្វស្រមោចដែលគ្មានតម្លៃបន្តិចសោះឡើយ ។ ខ្ញុំគិតថា ជនកម្ពុជាជាច្រើនក៏គិតដូចខ្ញុំដែរថា

ការចង់ឲ្យមានការកាត់ទោសខ្មែរក្រហមនោះពុំមែនមានគំនុំចង់សងសឹកគ្នានោះទេ តែជាការចង់បានយុត្តិធម៌និងការចង់ដឹងអំពីមូលហេតុ និងកត្តាអ្វីខ្លះដែលបានធ្វើឲ្យមានការសម្លាប់ខ្មែរ តើអ្នកណាខ្លះដែលបានប្រព្រឹត្តដោយចេតនា ឬឲ្យដៃទៅអ្នកសម្លាប់ប៉ុណ្ណោះ ។ ជនកម្ពុជាចង់បានការផ្សះផ្សា ការយោគយល់អធ្យាស្រ័យគ្នារវាងខ្មែរនិងខ្មែរ ឬខ្មែរនិងបរទេស ដោយត្រូវឆ្លងឬមិនអាចរំលងយុត្តិធម៌ជាដាច់ខាត ពោលគឺការផ្សះផ្សារួបរួមសាមគ្គីគ្នា និងមិនអាចប្រាសចាកកាតព្វកិច្ច យុត្តិធម៌ ធ្វើជាគោលបានឡើយ ។

នៅទីបញ្ចប់ ខ្ញុំសូមជូនពរដល់លោកនាយក និងបុគ្គលិកមជ្ឈមណ្ឌលព្រមទាំងជនកម្ពុជាទាំងអស់ ជួបប្រទះនូវសេចក្តីសុខសន្តិភាព រស់នៅក្នុងជីវភាពសម្បូរធូរធារ និងសប្បាយរីករាយជានិច្ចនិរន្តរ៍ ។

**គុជ រ៉ា**

## សេចក្តីប្រកាសរកឪពុកឈ្មោះ យូន វណ្ណធឿង

ខ្ញុំបាទឈ្មោះ ធឿង វណ្ណដារ៉ុង ជាអនុរដ្ឋលេខាធិការ និង នូវ សុវត្ថិរ៉ូ (ធឿង វណ្ណដារ៉ូ) ជារដ្ឋលេខាធិការនៃក្រសួងព័ត៌មាន ត្រូវជាកូនសូមប្រកាសរកដំណឹងឪពុកឈ្មោះ យូន វណ្ណធឿង ដែលបាត់ខ្លួននៅក្នុងសង្គ្រាមឆ្នាំ១៩៧០ នៅតំបន់ស្រុកស្អាងព្រែកតូច (មុំសមរភូមិកោះទាវ-សិត្បូ) ខេត្តកណ្តាល ។ មុនឆ្នាំ១៩៧០ លោកប៉ាជាអតីតទាហានហ្លួង ឬ“នាយទាហានរក្សាព្រះអង្គ” លោកជាទាហានម្នាក់ក្នុងចំណោមទាហានហ្លួងបួននាក់របស់ព្រះអង្គ ។ ក្រោយមកក្រុមរបស់លោកត្រូវបានរំសាយ ហើយទទួលបញ្ជាឲ្យដឹកនាំទ័ព១០០នាក់ឡើងសមរភូមិនៅស្អាងព្រែកតូច នៅពេលនោះលោកប៉ានិងសហសេវិកពីរ-បីនាក់ត្រូវកងទ័ពខ្មែរក្រហមសហការជាមួយកងទ័ពវៀតកុងព័ទ្ធចាប់ខ្លួន លើកលែងតែកូនទាហានប៉ុណ្ណោះត្រូវបានដោះលែងឲ្យមានសេរីភាព ។ លោកប៉ាក៏បានបាត់ខ្លួនចាប់តាំងពីពេលនោះមក ។ អ្វីដែលពួកយើងចង់បានបំផុតនៅពេលនេះគឺចង់ដឹងថាលោកនៅទីណា ចំពោះរឿងថា លោកបានស្លាប់ ឬរស់នោះ ពួកយើងត្រៀមចិត្តរួចជាស្រេចថា លោកប៉ាចែកឋានរួចទៅហើយ ពីព្រោះយើងសង្ឃឹមតិចណាស់ដែលថា លោកអាចគេចផុតពីក្រញាំដៃដ៏អមនុស្សធម៌នៃរបបនេះ ។

ប្រសិនបើបងប្អូនណាបានដឹងដំណឹង និងឃើញគាត់រស់នៅកន្លែងណា សូមមេត្តាជួយផ្តល់ដំណឹងមកខ្ញុំបាទតាមទូរស័ព្ទលេខ ០១២ ៩៣១ ៤២៨ ឬ ០១១ ៧៧៤ ៩៨៨ ។ សូមអរគុណ ។

## សេចក្តីប្រកាសរកឪពុកម្តាយ បងស្រី ប្អូនប្រុស និងប្អូនស្រី

នាងខ្ញុំឈ្មោះ ទូច យឿន អាយុ៥៣ឆ្នាំ និងស្វាមីឈ្មោះ ចែម រឿន អាយុ៥៨ឆ្នាំ រៀបការនៅឆ្នាំ១៩៧៤ រស់នៅខេត្តសៀមរាប សូមប្រកាសសួររកឪពុកម្តាយ បងស្រី ប្អូនប្រុស និងប្អូនស្រី ដូចមានរាយនាមខាងក្រោម ៖

១)ឪពុកឈ្មោះ ទូច យ៉ាន ជាអតីតទាហានលន់នល់នៅខេត្តសៀមរាប បានបាត់ខ្លួននៅឆ្នាំ១៩៧៥ ពេលដែលកងទ័ពរំដោះវាយបានទីក្រុងភ្នំពេញ, ២)ម្តាយឈ្មោះ ផៃ យ៉ុម (អាយុ៦៨ឆ្នាំក្នុងឆ្នាំ១៩៧៥) , ៣)ទូច រឿន ជាបងស្រី, ៤)ទូច ធឿន (បើនៅរស់សព្វថ្ងៃមានអាយុ៣៥ឆ្នាំ) , ៥)ទូច សារ៉ែន ជាប្អូនស្រី និង ៦)ទូច សារុន ជាប្អូនស្រីពៅ ។

ប្រសិនបងប្អូនណាបានឮដំណឹងនេះ សូមទាក់ទងមកកូនប្រុសរបស់នាងខ្ញុំឈ្មោះ វ៉ាន់ ណារុង ទូរស័ព្ទលេខ ០១១ ៦៦៩ ៨០១ និងកូនប្រុស វ៉ាន់ ណាវ៉ា ទូរស័ព្ទ ០៩២ ៨១៤ ៥៩១ ឬតាមរយៈមជ្ឈមណ្ឌលកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ!

# សេចក្តីប្រកាសរកបងប្រុស និងបងស្រី

បន្ទាប់ពីខ្ញុំបានអានព័ត៌មាននិងបានដឹងថាអង្គការរបស់លោកជួយស្វែងរកសមាជិកគ្រួសារដែលបានបាត់ខ្លួន នាងស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយស្វែងរកបងប្រុសនិងបងស្រីរបស់ខ្ញុំដែលបានបែកពីខ្ញុំនៅក្នុងឆ្នាំ១៩៧៥ ។


ណាអូមិ ហាមម័រស្លី

ខ្ញុំនិងបងស្រីភ្លោះរបស់ខ្ញុំ កើតក្នុងខែមករា ឆ្នាំ១៩៧៥ នៅក្នុងទីក្រុងភ្នំពេញ ។ មួយសប្តាហ៍ក្រោយ យើងទាំងពីរត្រូវបានបញ្ជូនទៅកាន់មណ្ឌលកុមារកំព្រានៅទីក្រុងភ្នំពេញដែលមានឈ្មោះថា ផ្ទះកាណាដា ។ នៅក្នុងខែមីនា ឆ្នាំ១៩៧៥ យើងទាំងពីរត្រូវបានគ្រួសារជនជាតិកាណាដាមួយ យកទៅចិញ្ចឹមនៅប្រទេសកាណាដា ។ សព្វថ្ងៃយើងខ្ញុំទាំងពីរនាក់កំពុងតែស្វែងរកព័ត៌មានស្តីពីបងប្រុស និងបងស្រីដែលត្រូវបានទុកចោលនៅទីក្រុងភ្នំពេញ ។

យើងខ្ញុំទាំងពីរពុំដឹងថាឪពុកម្តាយបងប្អូនរបស់ខ្ញុំមានឈ្មោះអ្វីខ្លះ និងក៏ពុំដឹងថាយើងទាំងពីរនាក់កើតនៅទីណានោះទេ ។ យើងខ្ញុំទាំងពីរនាក់គ្រាន់តែដឹងព័ត៌មានបន្តិចបន្តួចពីស្ត្រីជនជាតិកាណាដាដែលបម្រើការនៅមណ្ឌលកុមារកំព្រាតែប៉ុណ្ណោះ ។

ឪពុករបស់យើងខ្ញុំទាំងពីរនាក់ បានស្លាប់នៅមុនពេលដែលយើងទាំងពីរនាក់កើតមកម្ល៉េះ ហើយគាត់ទំនងជាទាហាន លន់ នល់ ។ បន្ទាប់ពីម្តាយរបស់ខ្ញុំបានផ្តល់កំណើតឲ្យយើងទាំងពីរនាក់នៅក្នុងឆ្នាំ១៩៧៥មក សុខភាពរបស់គាត់បានចុះទន់ខ្សោយដោយសារតែកង្វះអាហារបរិភោគ និងធ្វើឲ្យគាត់មិនអាចចិញ្ចឹមបីបាច់យើងទាំងពីរបាន ។ បន្ទាប់ពីបុគ្គលិកមណ្ឌលកុមារកំព្រាទទួលបានព័ត៌មានអំពីខ្ញុំទាំងពីរ ពួកគេបានស្វែងរកយើងរហូតបានប្រទះឃើញយើងនៅដេកលើគំនរសំរាមនៅក្នុងខ្ទមមួយ ។ បន្ទាប់មកក៏បាននាំយើងទាំងពីរទៅកាន់ផ្ទះកាណាដា និងយកម្តាយរបស់ខ្ញុំទៅសាលាសំណាក់ ។ បងស្រីខ្ញុំមានអាយុប្រហែល១៨ឆ្នាំ ធ្វើការនៅមណ្ឌលកុមារកំព្រា ហើយបងប្រុសខ្ញុំមានអាយុប្រហែល៧ឆ្នាំស្នាក់នៅជាមួយម្តាយ ។

នៅក្នុងផ្ទះកាណាដា មានកុមារកំព្រាចំនួន៤០នាក់ និងបុគ្គលិកខ្មែរប្រហែល១០នាក់ឬ១៥នាក់មើលថែរក្សាកុមារទាំងនោះ ។ ក្រោយមក កុមារទាំងនោះត្រូវបានយកទៅចិញ្ចឹមនៅប្រទេសកាណាដា ។ ផ្ទះកាណាដានេះ រៀបចំឡើងដោយស្ត្រីជនជាតិកាណាដាជាច្រើននាក់ ។ លោក ស្រី ណាអូមិ ប្រុណស្តេន បានធ្វើដំណើរចុះឡើងពីកម្ពុជាទៅកាណាដាក្នុងការចាត់ចែងការទទួលយកក្មេងទៅចិញ្ចឹម ចំណែកលោកស្រី ដុល្លី ឆារ៉េត និង អាណា ឆារ៉េត ជាអ្នកមើលថែរក្សាកុមារកំព្រាទាំងនោះ ។

ទោះបីជាយើងខ្ញុំទាំងពីរនាក់ពុំមានព័ត៌មានលម្អិតច្រើនស្តីអំពីក្រុមគ្រួសាររបស់ខ្ញុំយ៉ាងណាក៏ដោយ ខ្ញុំសង្ឃឹមថា សារតាររបស់ខ្ញុំ និងផ្ទះកាណាដានេះ អាចផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់បងប្អូន ដែលបានដឹងដំណឹងអំពីបងប្រុស និងបងស្រីរបស់យើងទាំងពីរនាក់ ។ ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនដល់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការជួយជ្រោមជ្រែងស្វែងរកព័ត៌មានបន្ថែមស្តីអំពីគ្រួសាររបស់យើងខ្ញុំទាំងពីរនាក់ និងអាចជួយធ្វើឲ្យយើងទាំងពីរនាក់ជួបជុំគ្រួសារវិញ ។

**ណាអូមិ ហាមម័រស្លី**


បងស្រីរបស់ ណាអូមិ ហាមម័រស្លី នៅផ្ទះកាណាដា

# ស្រណោះ

**កំណាព្យ ៖ បទពាក្យប្រាំពីរ**

◆ ស្រណោះធម្មជាតិខៀវស្រងាត់
ស្រណោះព្រៃឈើលើផ្ទៃដី
ស្រណោះយប់ស្ងាត់សត្វពេញព្រៃ
ស្រណោះអ្វីៗគេរដូនតា ។

◆ ស្រណោះក្រោមដីមានមិនខ្វះ
ស្រណោះបឹងបួមានមច្ឆា
ស្រណោះរ៉ែមាសច្រើនហិកតា
ស្រណោះបុប្ផាក្រពុំសាយ ។

◆ ស្រណោះអង្គរដ្ឋងព្រលឹង
ស្រណោះខ្មែរក្រោមឃ្លាតទៅឆ្ងាយ
ស្រណោះធ្លាប់ពឹងផុតទុក្ខកាយ
ស្រណោះធ្លាប់វាយលើលោកគ្មាន ។

◆ ស្រណោះប៉ុលពតលែងមួយក្បាច់
ស្រណោះនឹងកឃើញពោះស្រេកឃ្លាន
ស្រណោះសម្រេចស្លាប់រាប់លាន
ស្រណោះធ្លាប់បានស្នានខុសអស់ ។

◆ ស្រណោះគុកពតគ្មានជញ្ជាំង
ស្រណោះអាល័យថ្ងៃរំដោះ
ស្រណោះខែប្រាំងធ្លាប់អាលោះ
ស្រណោះរងគ្រោះទាំងរដ្ឋា ។

◆ ស្រណោះធ្វើការដូចសត្វធាតុ
ស្រណោះភ្នំពេញគ្មានទិវា
ស្រណោះយើងឃ្លាតក្រុមគ្រួសារ
ស្រណោះចិត្តវាខ្មៅដូចក្អែក ។

◆ ស្រណោះក្រចេះខេត្តត្បូងសាន
ស្រណោះពីរធ្នូទុក្ខរំលែក
ស្រណោះស្លួលបានចាត់ចែងចែក
ស្រណោះហ្វូងប្រែតស្លាប់ហាលវាល ។

◆ ស្រណោះជម្លៀសជៀសទៅឆ្ងាយ
ស្រណោះរណ្តៅដើមឈើទាល
ស្រណោះរូបកាយគេរាប់ក្បាល
ស្រណោះពេលកាយឡើងរថយន្ត ។

◆ ស្រណោះបូព៌ាវាចោទក្បត់
រស់នៅពាយ័ព្យទុក្ខសែនធ្ងន់
ស្រណោះកម្សត់លើកបែបន់
ស្រណោះវែកពុនពេលឆ្លងកាត់ ។

◆ ស្រណោះវាចោទខ្មែរថាយួន
ចោទ កា.ហ្សេ.បេ ពាក្យបីមាត់
គំនុំគុំកួនវាទូទាត់
ដើម្បីកម្ចាត់ភាគបូព៌ា ។

◆ ស្រណោះបបរដូចទឹកភ្នែក
មិនបាច់ត្បងចបក៏មរណា
របបចម្លែកចែកប្រហារ
ផ្ទៃកាយឈឺផ្សាចាំតែថ្ងៃ ។

◆ ស្រណោះអង្គការវាប្រកាស
មហាលោតផ្លោះមហាទាល់ទី
មហាខ្លាំងណាស់មហាមានន័យ
មហាគ្មានពីរលើលោកា ។

**ម៉ន ឈុនហេង**

**មេឃុំខ្សាច់អណ្តែត ស្រុកឆ្លូង ខេត្តក្រចេះ**

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 89, May 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.